# គហដ្ឋសីល

វត្តនិគ្រោធវ័ន "គល់ទទឹង"

មុនីកោសល្យ នៅ ហៃឡុន

ប្រមូលរៀបរៀង

ពុទ្ធសករាជ ២៥៥៤

ចែកជាធម្មទាន

៥០០០ឆ្នាំ

WWW.5000-YEARS.ORG



ឯកសារនេះបាន ទាញចេញពី គេហទំព័រ
www.5000-years.org

# គហដ្ឋសីល

## វត្តនិគ្រោធវ័ន "គល់ទទឹង"

មុនីកោសល្យ នៅ-ហៃឡុន

ប្រមូលរៀបរៀង

ពុទ្ធសករាជ ២៥៥៤

| | |
|---|---|
| សៀវភៅឈ្មោះ | គហដ្ឋសីល ( សីលរបស់គ្រហស្ថ ) |
| រៀបរៀងដោយ | មុនីកោសល្យ នៅ-ហៃឡុន |
| វាយអត្ថបទដោយ | នៅ-ពីឡុត, ផុង-ពន្លឺរ័តន៍, ហេង-សុវណ្ណរ័ត្ន |
| ផ្ទៀងផ្ទាត់ដោយ | ក្រុមអ្នកមានឧបការៈក្នុងការងារធម្មទាន |
| កែសម្រួលដោយ | ភិក្ខុ អគ្គជីវោ គង់-សុមិត្ត |
| កាលបរិច្ឆេទ | ១៥ កើត ខែចេត្រ ឆ្នាំឆ្លូវ ព.ស. ២៥៥៣ |
| បោះពុម្ព | លើកទី ១ ចំនួន ២០០០ ក្បាល |
| ធម្មទានដោយ | ព្រះសង្ឃ និងពុទ្ធបរិស័ទទូទៅ ទាំងក្នុង និងក្រៅប្រទេស |
| ស្ថានទីធ្វើ | ពុទ្ធមណ្ឌលមហាសតិប្បដ្ឋាន វត្តនិគ្រោធវ័ន "គល់ទទឹង" ភូមិកោះក្របី ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្ដាល |
| រក្សាសិទ្ធិ | ដោយវត្តនិគ្រោធវ័ន "គល់ទទឹង" |

# អារម្ភកថា

សៀវភៅនេះ កើតឡើងដោយបានប្រមូលអត្ថបទ ធម៌វិន័យ ជាព្រះពុទ្ធដីកាផង ជាព្រះអដ្ឋកថាផង ពីក្នុងគម្ពីរនានាជាច្រើនគឺ : គម្ពីរព្រះត្រៃបិដក អដ្ឋកថា ខុទ្ទកនិកាយ សម្មោហវិនោទនី កង្ខាវិតរណី សមន្តប្បាសាទិកា មង្គលត្ថទីបនី និងសៀវភៅផ្សេងៗ ច្រើនទៀត ស្រង់យកសេចក្ដីដែលជាប់ទាក់ទងនឹងសីល សិក្ខាបទជាដើម ជាវត្ថុចាំបាច់សម្រាប់គ្រហស្ថអ្នកទ្រទ្រង់ ប្រដាប់តាក់តែងលម្អកាយ វាចា ចិត្ត ។ អត្ថបទស្រង់មកនោះ សរសេរបញ្ចូលក្នុងសៀវភៅនេះ ដាក់ឈ្មោះថា "គហដ្ឋសីល" ។

ដើម្បីជាប្រយោជន៍ចំពោះអ្នកត្រូវការសមាទានសីល ដែលមិនទាន់បានដឹង បើបានសិក្សារៀនសូត្រ តាមសេចក្ដីពន្យល់ណែនាំរបស់អ្នកប្រាជ្ញ បណ្ឌិតពីបុរាណសម្ដែងចងក្រងទុកមកនេះ ហើយអាចបានដឹង ។

ដោយការបានឃើញប្រយោជន៍របស់សៀវភៅនេះហើយ ក៏ញុំាំងឆន្ទៈឱ្យកើតឡើង មានព្យាយាមស្រង់ប្រមូលអត្ថបទបានគ្រប់គ្រាន់ហើយ ក៏សម្រេចចិត្តយកទៅឱ្យកូនឈ្មោះ ឆៅ-ពីឡុត

ជួយវាយអត្ថបទដោយកុំព្យូទ័រឱ្យ កូននោះក៏យកចិត្តទុកដាក់ប្រឹងប្រែងជួយវាយអត្ថបទផង ជួយប្រមូលអត្ថបទបន្ថែមទៀតផង ។ ចំណែកលោក ជួន-ពន្លឺរ័តន៍ និងលោក ហេង-សុវណ្ណារ័ត្ន មានសេចក្តីជ្រះថ្លាក្នុងការងារធម្មទាននេះដែរ បានចូលរួមជួយវាយកុំព្យូទ័រ នូវអត្ថបទដែលខ្ញុំត្រូវបន្ថែមក្រោយ បានសម្រេចជាសៀវភៅ ហើយខ្ញុំយកសៀវភៅនេះទៅប្រគេនលោកម្ចាស់ធម្មបាលោ សាន-សប្បាយ ចៅអធិការវត្តវិសុទ្ធិមគ្គ លោកម្ចាស់ សទ្ធម្មជោតិបាលោ អ៊ិន-សំអឿន ព្រះធម្មាចារ្យ វត្តគល់ទទឹង សូមលោកជួយពិនិត្យ ពិគ្រោះកែសម្រួលសេចក្តីសមគួរហើយ បន្ទាប់មកខ្ញុំបានយកសៀវភៅនេះ ទៅប្រគេនលោកម្ចាស់ច្រើនព្រះអង្គ និងញោមខ្លះទៀត សូមឱ្យជួយពិនិត្យកែលម្អបានសមរម្យហើយ ក្រោយមកខ្ញុំបានយកទៅប្រគេនព្រះគ្រូ គម្ភីរត្ថេរោ យឹ-ធិត ជាព្រះវិន័យធរគណ ស្រុកកៀនស្វាយ ខេត្តកណ្តាល និង លោកម្ចាស់គ្រូ មេត្តាបាលោ ធឹម-សឿត ចៅអធិការវត្តនិគ្រោធវ័ន ភូមិកោះក្របី ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្តាល សូមឱ្យលោកជួយផ្ទៀងផ្ទាត់

ថែមទៀត លោកក៏បានពិនិត្យផ្ទៀងផ្ទាត់យល់ថា ត្រឹមត្រូវហើយ ទើបខ្ញុំយកទៅចាត់ចែងបោះពុម្ព សម្រាប់ប្រគេនចែកជូនជាធម្មទាន តាមសមត្ថភាព ។

ដោយអំណាចនៃការប្រឹងប្រែង ក្នុងការងារសៀវភៅនេះ ផលបុណ្យនោះ សូមឱ្យបានសម្រេចបំណងប្រាថ្នាដល់លោកអ្នក ដ៏មានគុណទាំងអស់ មានព្រះមាតាបិតា គ្រូឧបជ្ឈាយាចារ្យ ជាដើម ដល់លោកម្ចាស់គ្រប់ព្រះអង្គ ញាតិញោម ពុទ្ធបរិស័ទ ទាំងអស់ ដែលបានជួយឧបត្ថម្ភគាំទ្រ ដោយកម្លាំងកាយ វាចា ចិត្ត និងទ្រព្យធន ដើម្បីឱ្យបានសម្រេច ជាសៀវភៅធម្មទាននេះ ព្រមទាំងសព្វសត្វនិករទាំងអស់ក្នុងលោក បានប្រកបព្រមដោយ សតិបញ្ញា ស្មារតីជាសម្មាទិដ្ឋិ បានសេចក្ដីសុខក្នុងលោកនេះ និងលោកខាងមុខ រហូតដល់អវសានជាតិ ។

វត្តនិគ្រោធវ័ន "គល់ទទឹង" ថ្ងៃសៅរ៍ ២ កើត
ខែភទ្របទ ឆ្នាំឆ្លូវ ឯកស័ក ព.ស. ២៥៥៣ ។
រៀបរៀងដោយខ្ញុំព្រះករុណា អាត្មាភាព
មុនីកោសល្យ នៅ-ហៃឡុន

# ឯកសារពិគ្រោះ

១- គម្ពីរព្រះត្រៃបិដក

២- អដ្ឋកថា ខុទ្ទកនិកាយ

៣- សម្មោហវិនោទនី "សិក្ខាបទវិភង្គ" រៀបរៀងដោយ **រតនប្បជ្ជោតោ** ភិក្ខុ ក-វ៉ាន ព.ស. ២៥១២

៤- កង្ខាវិតរណី អដ្ឋកថាបាតិមោក្ខ រៀបរៀងដោយ សាមណេរ សេម-សុវណ្ណរ័ត្ន សាមណេរ សាំ-ច័ន្ទធីរ៍ ព.ស. ២៥៤៦

៥- សមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យ

៦- គម្ពីរមង្គលត្ថទីបនី ប្រែរៀបរៀងដោយ ភិក្ខុ **វិនយធរោ** (មហា យិន-នឿន) ព.ស. ២៥៣៤

៧- គិហិបដិបត្តិរបស់ព្រះគ្រូវិមលប្បញ្ញោ អ៊ុំ-ស៊ូ ព្រះគ្រូ**សង្ឃសត្ថា** ជួន-ណាត ព.ស. ២៥៤១

៨- ពុទ្ធបូជា រៀបរៀងដោយលោកម្ចាស់គ្រូ **មេត្តាបាលោ** ឌីម-សឿត

៩- ពិធីសុំសីល រៀបរៀងដោយ ភិក្ខុ សុន្ទរ៍-សាមៀន
១០- ព្រះត្រៃសរណគមន៍ ទសសិក្ខាបទវិភង្គ រៀបរៀង
ដោយ ភិក្ខុ ទក្ខប្បញ្ញោ វ៉ាន់-ចាន់សារ៉ែន
១១- អាគារិយវិន័យ រៀបរៀងដោយលោកគ្រូបណ្ឌិត
ធម្មាចារ្យ គាំ-អ៊ីវ
១២- វចនានុក្រមខ្មែរ សម្ដេចព្រះសង្ឃរាជ គណៈមហានិកាយ
ជ.ណ. ជោតញ្ញាណោ

# អ្នកមានឧបការៈ ក្នុងការខោរធម្មទាន

លោកម្ចាស់គ្រូ មេត្តាធាលោ ទឹម-សឿត
លោកម្ចាស់ ធម្មធាលោ សាន-សប្បាយ
លោកម្ចាស់ សទ្ធម្មជោតិធាលោ អ៊ិន-សំអឿន
លោកម្ចាស់ វជិរប្បញ្ញោ គូ-សុភាព
លោកម្ចាស់ សុវណ្ណជោតោ ភួង-សុវណ្ណ
លោកម្ចាស់ អគ្គវង្សោ ឆាយ-កន
លោកម្ចាស់ អគ្គធីរោ គង់-សុមិត្ត
លោកម្ចាស់ សុចិណ្ណោ ញឹប-យ៉ន្ត
លោកម្ចាស់ ភទ្ទវំសោ សួរ-ស៊ុម
លោកម្ចាស់ ជិនវំសប្បិយោ លន-សុខហេង
លោកម្ចាស់ បញ្ញាសុមាលី សឹម-ស៊ីសាមុត
លោកម្ចាស់ សុមេធបណ្ឌិតោ ស៊ិន-ផល្លា
លោកម្ចាស់ ធម្មសារោ ច្រឹក-ពិសិដ្ឋ
លោកជំទាវ នួច-ស៊ីវដ្ឋា ឧបាសិកា ខៀវ-អៀម
លោក ផួង-ពន្លឺរ័តន៍ លោកគ្រូ ប៊ុត-បឿន
យុវសិស្ស នៅ-ពីឡុត ឧបាសក ធូ-សុខជា
លោក ហេង-សុវណ្ណរ័ត្ន ឧបាសក អ៊ុំ-ប៊ុនជា

# បញ្ជីមាតិកា

អារម្ភកថា … … … … … … … … … … … … … … … … … … … … ក
ឯកសារពិគ្រោះ … … … … … … … … … … … … … … … … … … ឃ
អ្នកមានឧបការៈ ក្នុងការផ្សារធម្មទាន… … … … … … … … … ច
បញ្ជីមាតិកា… … … … … … … … … … … … … … … … … … … … ឆ
រតនត្តយបូជា … … … … … … … … … … … … … … … … … … … ១
ពុទ្ធរតនប្បណាម… … … … … … … … … … … … … … … … … … ១
ធម្មរតនប្បណាម… … … … … … … … … … … … … … … … … … ៦
សង្ឃរតនប្បណាម… … … … … … … … … … … … … … … … … ១១
រតនប្បណាម … … … … … … … … … … … … … … … … … … … ១៧
យោ កប្បកោដី … … … … … … … … … … … … … … … … … … ២០
នមស្ការដោយអធិដ្ឋាន. … … … … … … … … … … … … … … … ២២
នមស្ការបូជនីយវត្ថុជាទីគោរព … … … … … … … … … … … ២៣
សុភមង្គលគាថា … … … … … … … … … … … … … … … … … ២៤
ប្រយោជន៍នៃការសិក្សាព្រះពុទ្ធប្បញ្ញត្តិ … … … … … … … … … ២៦
ពណ៌នាព្រះរតនត្រ័យ… … … … … … … … … … … … … … … … ២៨

ពន្យល់អំពីព្រះពុទ្ធ ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ៣១
ពាក្យថា ពុទ្ធ ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ៣៤
ពន្យល់អំពីសរណគមន៍ និងអ្នកដល់សរណគមន៍ ... ... ... ... ៣៦
សម្តែងសរណគមន៍ដាច់ មិនដាច់ និងផល... ... ... ... ... ... ... ៤០
ពន្យល់អំពីព្រះធម៌ និងព្រះសង្ឃ . ... ... ... ... ... ... ... ... ... ... ... ៤២
អធិប្បាយហេតុក្នុងការកំណត់តាមលំដាប់ ... ... ... ... ... ... ... ៤៤
ពាក្យឧបមាព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ . ... ... ... ... ... ... ... ... ... ៤៥
បុព្វភាគប្បដិបត្តិ . ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ៥១
ឧបាសកនិទ្ទេស ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ៦៦
សីលនៃឧបាសក.. ... ... ... ... ... ... ... ... ... ... ... ... ... ... ៦៧
អាជីវនៃឧបាសក. ... ... ... ... ... ... ... ... ... ... ... ... ... ... ៦៨
វិបត្តិនៃឧបាសក... ... ... ... ... ... ... ... ... ... ... ... ... ... ៧០
សម្បត្តិនៃឧបាសក.. ... ... ... ... ... ... ... ... ... ... ... ... ៧១
គុណនៃឧបាសក.. ... ... ... ... ... ... ... ... ... ... ... ... ... ... ៧៣
និច្ចសីល ( សីល ៥ ) ... ... ... ... ... ... ... ... ... ... ... ... ... ... ..៧៦
ពោលអំពីការដាច់ .. ... ... ... ... ... ... ... ... ... ... ... ... ... ៧៩

វិធីសមាទាននិច្ចសីលបែបបច្ចេកសមាទាន . … … … ៨០
វិធីសមាទាននិច្ចសីលបែបឯកជ្ឈសមាទាន . … … … ៩០
ឧបោសថសីល ( សីល ៨ ) .. … … … … … … … … … … … … …៩៥
បកតិឧបោសថ.. … … … … …… … … … … … … … … … ៩៥
បដិជាគរឧបោសថ . … … … … … … … … … … … … … … ៩៨
បាដិហារិយឧបោសថ . … … … … … … … … … … … … ១០២
វិធីសមាទានឧបោសថសីលបែបបច្ចេកសមាទាន.. … ១០៥
វិធីសមាទានឧបោសថសីលបែបឯកជ្ឈសមាទាន.. … ១១៩
វិធីសមាទានបាដិហារិយឧបោសថសីល. … … … … … ១២៤
ទសសីល ( សីល ១០ )… … … … … … … … … … … … … … .១៣១
វិធីសមាទានសីល ១០ . … … … … … … … … … … … ១៣៤
អានិសង្សសីលសង្ខេប .. … … … … … … … … … … … ១៤០
បែបអ្នករក្សាសីល ១០ . … … … … … … … … … … … ១៤៤
ពណ៌នាសិក្ខាបទ. … … … … … … … …… … … … … … … … … … … ១៤៦
ពន្យល់បទទូទៅ .. … … … … … … … … … … … … … … … … ១៤៨
១. បាណាតិបាតសិក្ខាបទ…. … … … … … … … … … ១៥២

ពោលអំពីទោស... ... ... ... ... ... ... ... ... ... ... ... ១៥៧
ពោលអំពីអានិសង្ស ... ... ... ... ... ... ... ... ... ... ១៦១
២. អទិន្នាទានសិក្ខាបទ. .. ... ... ... ... ... ... ... ... ... ... ... ១៦៣
ពោលអំពីទោស... ... ... ... ... ... ... ... ... ... ... ... ១៧៥
ពោលអំពីអានិសង្ស. ... ... ... ... ... ... ... ... ... ... ១៧៧
៣. កាមេសុ មិច្ឆាចារសិក្ខាបទ . ... ... ... ... ... ... ... ... ១៧៩
ពោលអំពីអានិសង្ស. ... ... ... ... ... ... ... ... ... ... ១៨៨
អព្រហ្មចរិយសិក្ខាបទ .. ... ... ... ... ... ... ... ... ... ... ១៨៩
ពោលអំពីអានិសង្ស ... ... ... ... ... ... ... ... ... ... ១៩៤
៤. មុសាវាទសិក្ខាបទ.. ... ... ... ... ... ... ... ... ... ... ... ... ១៩៦
ពោលអំពីទោស... ... ... ... ... ... ... ... ... ... ... ... ២០១
ពោលអំពីអានិសង្ស ... ... ... ... ... ... ... ... ... ... ២០៤
៥. សុរាមេរយមជ្ជប្បមាទដ្ឋានសិក្ខាបទ. ... ... ... ... ... ២០៦
ពោលអំពីទោស... ... ... ... ... ... ... ... ... ... ... ... ២០៨
ពោលអំពីអានិសង្ស ... ... ... ... ... ... ... ... ... ... ២១១
៦. វិកាលភោជនសិក្ខាបទ... ... ... ... ... ... ... ... ... ... ... ២១៥

៧. នច្ចគីតវាទិតវិសូកទស្សនសិក្ខាបទ . … … … … … … ២៣០

៨. មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានសិក្ខាបទ ២៣៧

៩ ឧច្ចាសយនមហាសយនសិក្ខាបទ.. … … … … … … ២៤១

១០ ជាតរូបរជតប្បដិគ្គហណាសិក្ខាបទ.. … … … … … ២៥៣

វិធីបវារណាបច្ច័យ ៤ … … … … … … … … … … … … … … ២៥៩

សីលវត្តេរគាថា. … … … … … … … … … … … … … … … … … ២៦១

ពណ៌នាអំពីការប្រព្រឹត្តធម៌ . … … … … … … … … … … … … ២៦៥

អរិយមគ្គប្រកបដោយអង្គ ៨ … … … … … … … … … … … ២៨៥

គុណរបស់ព្រះនិព្វានមាន ២៩ យ៉ាង .. … … … … … … … … ៣៤៩

អក្ខរំ ឯកមេកញ្ច
ពុទ្ធរូបសមំ សិយា
តស្មា ហិ បណ្ឌិតោ ពោសោ
លិខេយ្យ បិដកត្តយំ ។

អក្សរមួយតួៗ ស្មើនឹងព្រះពុទ្ធរូបមួយអង្គ
ព្រោះហេតុនោះឯង បុគ្គលដែលជាបណ្ឌិត
យល់ឃើញយ៉ាងនេះហើយ គប្បីរចនា
ព្រះត្រៃបិដក ។

## សេចក្ដីបញ្ជាក់

ការបោះពុម្ពជាលើកទី ២ នេះ ខ្ញុំបានកែសម្រួលនូវអក្ខរាវិរុទ្ធ និងពាក្យកំហុសឆ្គង មួយចំនួនថែមទៀត ។ ប្រសិនបើពុទ្ធបរិស័ទ អ្នកអាន អ្នកសិក្សានូវសៀវភៅនេះ បានឃើញនូវកំហុសឯណានីមួយ ព្រោះសេចក្ដីភ្លាំងភ្លាត់ ដោយអចេតនា សូមមេត្តា ជួយផ្ដល់ជាពត៌មាន តាមដែលអាចធ្វើបាន ។

សូមអរគុណ និងអរព្រះគុណ !!

## រតនត្តយបូជា

## ថ្វាយគ្រឿងសក្ការៈដល់ព្រះរតនត្រ័យ

ឥមេហិ ទីបធូបាទិសក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ អភិបូជយាមិ មាតាបិតាទីនំ គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

ប្រែថា ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាម្ចាស់ ដោយគ្រឿងសក្ការៈទាំងឡាយ មានទៀននិងធូបជាដើមនេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់អ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាផង អស់កាលជាអង្វែងទៅហោង ។

## ពុទ្ធរតនប្បណាម

## ថ្វាយបង្គំព្រះពុទ្ធរតនៈ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ប្រែថា កិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

( សូធ្យបាលី ៣ ចប់ , សម្រាយតែ ១ ចប់ )

យោ សន្និសិន្នោ វរពោធិមូលេ
មារំ សសេនំ មហតី វិជេយ្យា(១)
សម្ពោធិមាគច្ឆិ អនន្តញាណោ
លោកុត្តមោ តំ បនមាមិ ពុទ្ធំ ។

ប្រែថា ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់គង់ចម្រើននូវព្រះអានាបានស្សតិកម្មដ្ឋាន លើរតនបល្ល័ង្កក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរ បានផ្ចាញ់នូវមារាធិរាជ ព្រមទាំងសេនាដ៏ច្រើនហើយ ទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ មានប្រាជ្ញារកទីបំផុតគ្មាន ព្រះអង្គប្រសើរជាងសត្វលោក ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធអង្គនោះ ដោយគោរព ។

( ក្រាបថ្វាយបង្គំម្តង )

នមស្ការព្រះសម្មាសម្ពុទ្ធ ដូចសេចក្តីខាងលើនេះគឺ នមស្ការដោយសង្ខេប មិនបានញែកកាលចេញជា ៣ ឡើយ, បើនមស្ការដោយពិស្តារវិញ ទើបញែកកាលចេញជា ៣ ដូចសេចក្តីខាងក្រោមនេះ ។

---

១ ដែលធ្លាប់សូធ្យមកថា " វិជ្ជយោ " តែបានពិនិត្យផ្ទៀងផ្ទាត់ទៅឃើញថា "វិជេយ្យា " ទើបត្រឹមត្រូវ ត្រូវប្រែដូច " វិជិត្វា " ឬ " វិជេត្វា "

យេ ច ពុទ្ធា អតីតា ច យេ ច ពុទ្ធា អនាគតា
បច្ចុប្បន្នា ច យេ ពុទ្ធា អហំ វន្ទាមិ សព្វទា ។

ប្រែថា ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធនិព្វានកន្លងទៅហើយក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលនឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលខាងមុខក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធ ក្នុងភទ្រកល្បនេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ គ្រប់កាលទាំងពួង ។

( ក្រាបថ្វាយបង្គំម្តង )

រួចហើយគប្បីតាំងចិត្តរឭកដល់ពុទ្ធគុណទាំង ១០ ព្រះនាម ដោយបន្លឺនកាយវាចាថា ៖

ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ
វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ
បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។

ប្រែថា ឥតិបិ សោ ភគវា អរហំ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា **អរហំ** ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវពោលគឺកិលេស ព្រមទាំងវាសនា គឺកាយបយោគនិង

វចីបយោគ, សម្មាសម្ពុទ្ធោ ទ្រង់ព្រះនាមថា **សម្មាសម្ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹង នូវញេយ្យធម៌ទាំងពួង ដោយប្រពៃ ចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ, វិជ្ជាចរណសម្បន្នោ ទ្រង់ព្រះនាមថា **វិជ្ជាចរណសម្បន្នោ** ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា ៣ និងវិជ្ជា ៨ និងចរណៈ ១៥, សុគតោ ទ្រង់ព្រះនាមថា **សុគតោ** ព្រោះព្រះអង្គមាន ដំណើរល្អ យាងទៅកាន់សុន្ទរស្ថាន គឺអមតមហានិព្វាន, លោកវិទូ ទ្រង់ព្រះនាមថា **លោកវិទូ** ព្រោះព្រះអង្គជ្រាប ច្បាស់នូវត្រៃលោក, អនុត្តរោ ទ្រង់ព្រះនាមថា **អនុត្តរោ** ព្រោះព្រះអង្គប្រសើរ ដោយសីលាទិគុណ រកបុគ្គលណាមួយ ស្មើគ្មាន, បុរិសធម្មសារថិ ទ្រង់ព្រះនាមថា **បុរិសទម្មសារថិ** ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យ គួរនឹង ទូន្មានបាន, សត្ថា ទេវមនុស្សានំ ទ្រង់ព្រះនាមថា **សត្ថា ទេវមនុស្សានំ** ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតា និងមនុស្ស ទាំងឡាយ, ពុទ្ធោ ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ ដឹងនូវចតុរារិយសច្ច ហើយញុំាងអ្នកដទៃឱ្យត្រាស់ដឹងផង, ភគវា

ទ្រង់ព្រះនាមថា **ភគវា** ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភព ខ្ជាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។

វត្ថុកដល់ពុទ្ធគុណរួចហើយ គប្បីប្រកាសប្ដេជ្ញាខ្លួនដោយពាក្យសច្ចៈថា ៖

**នត្ថិ មេ សរណំ អញ្ញំ ពុទ្ធោ មេ សរណំ វរំ**

**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ។**

ប្រែថា **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណា មិនមានឡើយ, **ពុទ្ធោ មេ សរណំ វរំ** មានតែព្រះពុទ្ធជាម្ចាស់ជាទីពឹងទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្ដីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណាដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

ប្ដេជ្ញាដូច្នេះហើយ គប្បីសូត្រសូមខមាទោសនឹងព្រះពុទ្ធជាម្ចាស់ថា

**ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ ពុទ្ធេ**

**យោ ខលិតោ ទោសោ ពុទ្ធោ ខមតុ តំ មមំ ។**

ប្រែថា ឧត្តមខ្ពង់ វន្ទេហំ បាទបំសុំ វរុត្តមំ ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវល្អងធូលីព្រះបាទ នៃព្រះសម្មាសម្ពុទ្ធដ៏ប្រសើរខ្ពង់ខ្ពស់ ដោយអវយវៈដ៏ឧត្តមគឺត្បូង, ពុទ្ធេ យោ ខលិតោ ទោសោ ទោសឯណា ដែលខ្ញុំព្រះករុណា ធ្វើឱ្យភ្លាំងភ្លាត់ហើយ ក្នុងព្រះពុទ្ធជាម្ចាស់ ពុទ្ធោ ខមតុ តំ មមំ សូមព្រះពុទ្ធជាម្ចាស់ អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ។

( ក្រាបថ្វាយបង្គំម្តង )

## ធម្មរតនប្បណាម

ក្រាបថ្វាយបង្គំព្រះធម្មរតនៈ

អដ្ឋង្គិការិយបថោ ជនានំ

មោក្ខប្បវេសាយ ឧជូ ច មគ្គោ

ធម្មោ អយំ សន្តិករោ បណីតោ

និយ្យានិកោ តំ បនមាមិ ធម្មំ ។

ប្រែថា ព្រះសទ្ធម្មឯណា ជាធម៌ប្រកបដោយអង្គ ៨ ប្រការ ជាគន្លងដំណើរនៃព្រះអរិយបុគ្គលជាម្ចាស់ ជាផ្លូវដ៏ត្រង់

ក្នុងកិរិយាញ៉ាំងជនដែលប្រាថ្នានូវព្រះនិព្វាន ឱ្យចូលទៅកាន់ព្រះនិព្វានបាន ព្រះធម៌នេះ ជាធម៌ធ្វើឱ្យត្រជាក់ រម្ងាប់បង់នូវភ្លើងទុក្ខ ភ្លើងកិលេស ជាធម៌ដ៏ឧត្តម ជាគុណញ៉ាំងសត្វឱ្យចេញចាកសង្សារទុក្ខ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសទ្ធម្មនោះដោយគោរព ។

( ក្រាបថ្វាយបង្គំម្តង )

នមស្ការដល់ព្រះសទ្ធម្ម ដូចសេចក្តីខាងលើនេះ គឺនមស្ការដោយសង្ខេប មិនបានញែកកាលចេញជា ៣ ឡើយ បើនមស្ការដោយពិស្តារវិញ ទើបញែកកាលចេញជា ៣ ដូចសេចក្តីខាងក្រោមនេះ

**យេ ច ធម្មា អតីតា ច យេ ច ធម្មា អនាគតា**
**បច្ចុប្បន្នា ច យេ ធម្មា អហំ វន្ទាមិ សព្វទា ។**

ប្រែថា ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ដែលនិព្វានកន្លងទៅហើយក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ នឹងមានមកក្នុងកាលខាងមុខក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ទ្រង់

ប្រតិស្ឋានទុកក្នុងកាលសព្វថ្ងៃនេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធម៌ទាំងឡាយនោះ គ្រប់កាលទាំងពួង ។

រួចហើយគប្បីតាំងចិត្តរឭកដល់ធម្មគុណ

ដោយបង្អោនកាយវាចាថា ៖

ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ

អកាលិកោ ឯហិបស្សិកោ ឱបនយិកោ

បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។

ប្រែថា ស្វាក្ខាតោ ភគវតា ធម្មោ ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដកជាធម៌ គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយដោយល្អ (ធម្មោ ព្រះនព្វលោកុត្តរធម៌មាន ៩ ប្រការ គឺមគ្គ ៤ ផល ៤ និព្វាន ១) សន្ទិដ្ឋិកោ ជាធម៌គឺព្រះអរិយបុគ្គលទាំងពួង ដឹងពិតឃើញពិត ដោយបច្ចវេក្ខណញ្ញាណ គឺថានឹងបានដឹងដោយស្តាប់ ដោយជឿបុគ្គលដទៃនោះៗ ក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង អកាលិកោ ជាធម៌ឱ្យនូវផលមិនរង់ចាំកាល គឺថាកាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផលក៏កើតក្នុងលំដាប់គ្នា មិនបានឃឹតយូរឡើយ, ឯហិបស្សិកោ

ជាធម៌គួរដល់ឯហិបស្សវិធី គឺថាបើព្រះអរិយបុគ្គលដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃឱ្យចូលមកមើលបាន, ឱបនយិកោ ជាធម៌គឺព្រះអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួន ដោយអំណាចនៃភាវនា, បច្ចត្តំ វេទិតព្វោ វិញ្ញូហិ ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើមគប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។

វព្ទកដល់ព្រះធម្មគុណដូច្នេះរួចហើយ គប្បីប្រកាសប្តេជ្ញាខ្លួន ដោយពាក្យសច្ចៈថា ៖

**នត្ថិ មេ សរណំ អញ្ញំ ធម្មោ មេ សរណំ វរំ**

**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ។**

ប្រែថា **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរព្ទកនៃខ្ញុំព្រះករុណាមិនមានឡើយ **ធម្មោ មេ សរណំ វរំ** មានតែព្រះធម៌ជាម្ចាស់ ជាទីពឹងទីរព្ទកដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

ប្រគេនខ្ញុំទ្រានទូច្នេះរួចហើយ

គប្បីសូត្រសូមខមាទោសនឹងព្រះធម៌ជាម្ចាស់ថា ៖

**ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ[១] វរំ ធម្មេ**

**យោ ខលិតោ ទោសោ ធម្មោ ខមតុ តំ មមំ**

ប្រែថា **ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ** ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះធម៌ដ៏ប្រសើរ មានពីរប្រការ គឺព្រះបរិយត្តិធម៌ និងព្រះនព្វលោកុត្តរធម៌ ដោយអវយវៈដ៏ឧត្តម គឺត្បូង, **ធម្មេ យោ ខលិតោ ទោសោ** ទោសឯណា ដែលខ្ញុំព្រះករុណា ធ្វើឱ្យភ្លាំងភ្លាត់ហើយក្នុងព្រះធម៌ជាម្ចាស់ **ធម្មោ ខមតុ តំ មមំ** សូមព្រះធម៌ជាម្ចាស់ អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។

( ក្រាបថ្វាយបង្គំម្តង )

---

១. ក្នុងសៀវភៅបោះពុម្ពអក្សរសីហឡៈ ( ប្រទេសស្រីលង្កា) ថា "តិវិធំ" សំដៅសេចក្តីចំពោះព្រះធម៌ ៣ យ៉ាង គឺ ព្រះបរិយត្តិធម៌, បដិបត្តិធម៌ និងបដិវេធធម៌ ។

## សង្ឃរតនប្បណាម

ថ្វាយបង្គំព្រះសង្ឃរតនៈ

សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ

សន្តិន្ទ្រិយោ សព្វមលប្បហីនោ

គុណេហិនេកេហិ សមិទ្ធិបត្តោ

អនាសវោ តំ បនមាមិ សង្ឃំ ។

ព្រះអរិយសង្ឃឯណា ដ៏បរិសុទ្ធវិសេស ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ មានឥន្ទ្រិយរម្ងាប់ហើយ មានមន្ទិលគឺរាគាទិក្កិលេសទាំងពួងបន្សាត់បង់ហើយ ជាព្រះសង្ឃដល់ហើយនូវកិរិយាសម្រេចដោយគុណទាំងឡាយដ៏ច្រើន ជាព្រះសង្ឃមានអាសវធម៌មិនមាន គឺថាជាព្រះខីណាស្រព ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះអរិយសង្ឃនោះ ដោយគោរព ។

( ក្រាបថ្វាយបង្គំម្ដង )

នមស្ការដល់ព្រះអរិយសង្ឃ ដូចសេចក្ដីខាងលើនេះ គឺនមស្ការដោយសង្ខេប មិនបានញែកកាលចេញជា ៣ ឡើយ បើនមស្ការដោយពិស្ដារវិញ ទើបញែកកាលចេញជា ៣ ដូចសេចក្ដីខាងក្រោមនេះ

យេ ច សង្ឃា អតីតា ច យេ ច សង្ឃា អនាគតា
បច្ចុប្បន្នា ច យេ សង្ឃា អហំ វន្ទាមិ សព្វទា ។

*ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គនិងផលកន្លងទៅហើយក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃនឹងបានសម្រេចមគ្គ និងផលក្នុងកាលខាងមុខក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គនិងផលក្នុងកាលជាបច្ចុប្បន្ននេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសង្ឃទាំងឡាយនោះ គ្រប់កាលទាំងពួង ។*

*( ក្រាបថ្វាយបង្គំម្តង )*

*រួចហើយគប្បីតាំងចិត្តរឭកដល់សង្ឃគុណ*
*ដោយបង្អោនកាយវាចាថា ៖*

សុបដិបន្នោ ភគវតោ សាវកសង្ឃោ
ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ
ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ
សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ
យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា

ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ
បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ
អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

ប្រែថា សុបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌, ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមប្បដិបទា, ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វានជាស្ពានក្សេមផុតចាកទុក្ខទាំងពួង, សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់សីល សមាធិបញ្ញា , យទិទំ ចត្តារិ បុរិសយុគានិ ព្រះសង្ឃឯណា បើរាប់ជាគូនៃបុរសទាំងឡាយមាន ៤ គូ គឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គនិងសោតាបត្តិផលជាគូ ១ សកទាគាមិមគ្គនិង

សកទាគាមិផលជាគូ ១ អនាគាមិមគ្គនិងអនាគាមិផលជាគូ ១ អរហត្តមគ្គ និងអរហត្តផលជាគូ ១ , អដ្ឋ បុរិសបុគ្គលា បើរាប់រៀងជាបុរសបុគ្គលមាន ៨ គឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ ១ សោតាបត្តិផល ១ សកទាគាមិមគ្គ ១ សកទាគាមិផល ១ អនាគាមិមគ្គ ១ អនាគាមិផល ១ អរហត្តមគ្គ ១ អរហត្តផល ១, ឯស ភគវតោ សាវកសង្ឃោ ព្រះសង្ឃទាំងនោះ ជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ, អាហុនេយ្យោ លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីលហើយ នាំមកអំពីចម្ងាយបង្អោនចូលមកបូជា, ធាហុនេយ្យោ លោកគួរទទួលនូវអាគន្តុកទានគឺទានដែលបុគ្គលតាក់តែង ដើម្បីញាតិនិងមិត្តដែលមកអំពីទិសផ្សេងៗ ហើយបង្អោនចូលមកបូជា, ទក្ខិណេយ្យោ លោកគួរទទួលនូវទានដែលបុគ្គលជឿនូវកម្មនិងផលនៃកម្មហើយបូជា, អញ្ជលិករណីយោ លោកគួរដល់អញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ, អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។

វព្ទកដល់សង្ឃគុណដូច្នេះរួចហើយ
គប្បីប្រកាសប្ដេជ្ញាខ្លួនដោយពាក្យសច្ចៈថា ៖

នត្ថិ មេ សរណំ អញ្ញំ សង្ឃោ មេ សរណំ វរំ
ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ។

ប្រែថា នត្ថិ មេ សរណំ អញ្ញំ វត្ថុដទៃជាទីពឹង ទីរឭកនៃខ្ញុំព្រះករុណាមិនមានឡើយ, សង្ឃោ មេ សរណំ វរំ មានតែព្រះសង្ឃជាម្ចាស់ជាទីពឹង ទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា, ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ សូមសិរីសួស្ដីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

ប្ដេជ្ញាខ្លួនដូច្នេះរួចហើយ
គប្បីសូធ្យសូមខមាទោសនឹងព្រះសង្ឃជាម្ចាស់ថា ៖

ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ
សង្ឃេ យោ ខលិតោ ទោសោ សង្ឃោ ខមតុ តំ មមំ

ប្រែថា ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះសង្ឃដ៏ប្រសើរ មានពីរប្រការ គឺ

សម្មតិសង្ឃនិងអរិយសង្ឃ ដោយអវយវៈដ៏ឧត្តមគឺត្បូង, **សង្ឃេ យោ ខលិតោ ទោសោ** ទោសឯណាដែលខ្ញុំព្រះករុណា ធ្វើឱ្យភ្លាំងភ្លាត់ហើយ ក្នុងព្រះសង្ឃជាម្ចាស់, **សង្ឃោ ខមតុ តំ មមំ** សូមព្រះសង្ឃជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។

( ក្រាបថ្វាយបង្គំម្តង )

វិធីនមស្ការថ្វាយបង្គំនូវព្រះរតនត្រ័យមិនចំពោះកាល និងថ្វាយបង្គំនូវព្រះរតនត្រ័យក្នុងកាលទាំង ៣ និងសេចក្តីរឭកគុណព្រះរតនត្រ័យ និងពាក្យប្តេជ្ញាខ្លួនចំពោះព្រះរតនត្រ័យ និងថ្វាយបង្គំ សូមខមាទោសចំពោះព្រះរតនត្រ័យទាំង ៥ ន័យ ដែលបានពោលមកហើយខាងដើមនោះ ក៏ចប់តែប៉ុណ្ណេះដោយពិស្តារ ។

អ្នកដែលមានសទ្ធា ប្រាថ្នានឹងនមស្ការដល់ព្រះរតនត្រ័យនោះ បើមានពេលឱកាសល្មមនឹងសូធ្យនមស្ការទាំង ៣ បទឱ្យបានចប់សព្វគ្រប់ ដោយសេចក្តីពិស្តារ ដូចបែបខាងដើមនោះក៏ជាការឧត្តមប្រពៃក្រៃពេក តែបើពេលខ្លី មិនអាចនឹងសូធ្យឱ្យចប់សព្វគ្រប់បាន ក៏គ្រាន់តែសូធ្យសេចក្តីរឭកពុទ្ធគុណ ធម្មគុណ សង្ឃគុណ និងថ្វាយបង្គំ ហើយនឹងសូធ្យថ្វាយសក្ការបូជាដោយសេចក្តីសង្ខេបខ្លីៗ វិញក៏បាន ដូចន័យតទៅនេះ ។

# រតនប្បណាម

*បែបសង្ខេបព្រមទាំងបូជាគ្រឿងសក្ការៈ*

ឥតិបិ សោ ភគវា អរហំ ។ល។ ពុទ្ធោ ភគវាតិ តំ អរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។

*ប្រែថា ឥតិបិ សោ ភគវា អរហំ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា* ***អរហំ*** *ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវពោល គឺកិលេសព្រមទាំងវាសនា គឺកាយបយោគនិងវចីបយោគ ។ល។ ភគវា ទ្រង់ព្រះនាមថា* ***ភគវា*** *ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ជាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។*

តំ អរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ *ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គប្រកបព្រមហើយដោយគុណ មានគុណថា* ***អរហំ*** *ជាដើមនោះ ដោយសិរសា គឺ ត្បូង,* តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ *ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះសម្មាសម្ពុទ្ធ*

ជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយ មានប្រមាណប៉ុណ្ណេះ ។

( ក្រាបថ្វាយបង្គំម្តង )

**ស្វាក្ខាតោ ភគវតា ធម្មោ ។ល។ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ តំ ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ តញ្ច ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។**

ប្រែថា **ស្វាក្ខាតោ ភគវតា ធម្មោ** ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដកជាធម៌ គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយដោយល្អ ។ល។ **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ជាធម៌ គឺអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។

**តំ ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ** ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះធម៌ជាម្ចាស់ ដ៏ប្រកបព្រមហើយដោយគុណ មានគុណថា **ស្វាក្ខាតោ** ជាដើមនោះ ដោយសិរសាគឺត្បូង, **តញ្ច ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ** ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះធម៌ជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយ មានប្រមាណប៉ុណ្ណេះ ។

( ក្រាបថ្វាយបង្គំម្តង )

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ ។ល ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ តំ សុបដិបន្នាទិគុណសំយុត្តំ សង្ឃំ សិរសា នមាមិ តញ្ច សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ**

*ប្រែថា* **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌ ។ល ។* **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** *លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោករកខេត្តដទៃ ក្រៃលែងជាងគ្មាន ។*

**តំ សុបដិបន្នាទិគុណសំយុត្តំ សង្ឃំ សិរសា នមាមិ** *ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះសង្ឃជាម្ចាស់ ដ៏ប្រកបព្រមហើយដោយគុណ មានគុណថា* **សុបដិបន្នោ** *ជាដើមនោះ ដោយសិរសាគឺត្បូង,* **តញ្ច សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ** *ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះសង្ឃជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយ មានប្រមាណប៉ុណ្ណេះ ។*

*( ក្រាបថ្វាយបង្គំម្តង )*

# យោ កប្បកោដី

បាលីប្រែជាពាក្យកាព្យ

យោ កប្បកោដីហិបិ អប្បមេយ្យំ
កាលំ ករោន្តោ អតិទុក្ករានិ
ខេទំ គតោ លោកហិតាយ នាថោ
នមោ មហាការុណិកស្ស តស្ស

ព្រះពុទ្ធជាទីពឹង ជាពំនឹងសព្វសត្វា
ព្រះអង្គកាលប្រាថ្នា ធ្វើកសាងអស់កាលយូរ ។
រាប់ដោយកោដិកប្បា ច្រើនគណនាហួសគិតគូរ
បានត្រាស់ជាសព្វញ្ញូ ត្រាស់ជាគ្រូលើភពឋាន ។
ធ្វើកម្មជាកម្រ សត្តនិករគ្រាប់ពុំបាន
តោកយ៉ាកលំបាកប្រាណ ព្រោះប្រយោជន៍ដល់សព្វសត្វ ។
ខ្ញុំសូមឱនសិរសា ចិត្តប្រាថ្នាបង្គំថ្វាត់
ព្រះពុទ្ធករុណាសត្វ នោះជាទីពឹងសព្វកាល ។

អសម្ពុធំ ពុទ្ធនិសេវិតំ យំ
ភវាភវំ គច្ឆតិ ជីវលោកោ
នមោ អវិជ្ជាទិកិលេសជាលំ
វិទ្ធំសិនោ ធម្មវរស្ស តស្ស

សត្វតែងកើតស្លាប់បង់ ព្រោះចំណងកម្មជាគោល
ឲ្យវិលវល់អន្ទោល ក្នុងភពតូចនិងភពធំ ។
ហេតុតែមិនដឹងធម៌ ជាម្ចាស់ល្អស្អាតសុខុម
គឺព្រះពុទ្ធសេពសម ចិត្តខ្ញុំសូមនមស្ការ ។
នូវធម៌ប្រពៃពិត វិសេសសុទ្ធនោះឯងណា
កាត់បង់នូវអវិជ្ជា គឺបណ្ដាញកិលេសហើយ ។

គុណេហិ យោ សីលសមាធិបញ្ញា
វិមុត្តិញ្ញាណប្បភុតីហិ យុត្តោ
ខេត្តញ្ជនានំ កុសលត្ថិកានំ
តមរិយសង្ឃំ សិរសា នមាមិ

ព្រះសង្ឃអគ្គសាវ័ក មានសំវរៈសទ្ធាទ្រង់
កបដោយគុណសីលត្រង់ និងសមាធិបញ្ញា ។

និងវិមុត្តិញាណ　　កិលេសគ្មានក្នុងអាត្មា
ជាបុញ្ញក្ខេត្តា　　ជនត្រូវការជាកុសល ។
ខ្ញុំសូមឱនសិរសី　　ដល់ព្រះអរិយបុគ្គល
ជាបុត្តព្រះទសពល　　ជាមង្គលដល់សព្វសត្វ ។

## នមស្ការដោយអធិដ្ឋាន

ឥច្ចេវមច្ចន្ត　នមស្សនេយ្យំ
នមស្សមានោ រតនត្តយំ យំ
បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ
តស្សានុភាវេន ហតន្តរាយោ

ខ្ញុំសូមនមស្ការ　　លើកហត្ថាឱនសិរសី
បង្គំគុណទាំងបី　　ខ្ពស់លើសលប់ត្រៃលោកា ។
សូមបុណ្យកងកុសល　　ឱ្យបានដល់យើងខ្ញុំណា
ពេញពោរស្មើធារា　　ដូចជលសាធំទូលាយ ។
សូមឱ្យកម្ចាត់បង់　　អពមង្គលទាំងឡាយ
ឱ្យចៀសចេញចាកឆ្ងាយ　　ក្តីអន្តរាយកុំបីមាន ។
ដោយកម្លាំងអានុភាព　　បុញ្ញលាភជាប្រធាន

កងបុញ្ញរាសីមាន សូមបានក្សាន្តកុំមានមោះ ។
ដោយគុណនមស្ការ ត្រៃរតនាប្រសើរខ្ពស់
សូមអានិសង្សនោះ ដាក់ដល់ឋាននិព្វានហោង ។

## នមស្ការបូជនីយវត្ថុជាទីគោរព

វន្ទាមិ ចេតិយំ សព្វំ សព្វដ្ឋានេសុបតិដ្ឋិតំ
សារីរិកធាតុ មហាពោធិ ពុទ្ធរូបំ សកលំ សទា ។
ខ្ញុំសូមថ្វាយបង្គំ ឆ្ពោះព្រះបរមចេតិយ
ព្រមទាំងព្រះសារី- រិកធាតុនៃព្រះពុទ្ធ ។
និងមហាពោធិព្រឹក្ស ដែលគួរនឹកដោយលំអុត
លំឱនចិត្តបរិសុទ្ធ លើកកម្បង់អញ្ជលី ។
និងព្រះពុទ្ធរូប តំណាងអង្គព្រះមុនី
ដែលឋិតនៅគ្រប់ទី ឋាននានានោះទាំងអស់ ។
( ដោយតេជះនៃគុណ ព្រះមានបុណ្យប្រសើរខ្ពស់
ដែលតែងតែរំលស់ រំដោះទុក្ខភ័យអន្តរាយ ។
សូមឱ្យខ្ញុំបានសុខ ឃ្លាតចាកទុក្ខផងទាំងឡាយ
សត្រូវទោះជិតឆ្ងាយ សូមឱ្យក្លាយមកជាមិត្ត ។

សូមទាន់ព្រះអរិ- យមេត្រេយ្យថ្លៃវិសិដ្ឋ
សូមបានឃើញធម៌ពិត សមដូចចិត្តប្រាថ្នាហោង ) ៕

## សុភមង្គលគាថា

ពាក្យពោលប្រកាសសូមសេចក្ដីល្អ
និងសេចក្ដីចម្រើនគ្រប់យ៉ាង

ហោតុ សព្វំ សុមង្គលំ រក្ខន្តុ សព្វទេវតា
សព្វពុទ្ធានុភាវេន សោត្ថិ ហោតុ និរន្តរំ ៕

ប្រែថា ហោតុ សព្វំ សុមង្គលំ សុមង្គលគឺសេចក្ដីចម្រើនដ៏ល្អគ្រប់យ៉ាងចូរមានដល់ខ្ញុំ, រក្ខន្តុ សព្វទេវតា ទេវតាទាំងពួងទាំងឡាយ ចូររក្សានូវខ្ញុំ, សព្វពុទ្ធានុភាវេន ដោយអានុភាពនៃព្រះពុទ្ធគ្រប់ព្រះអង្គ, សោត្ថិ ហោតុ និរន្តរំ សូមសិរីសួស្ដីចូរមានដល់ខ្ញុំឱ្យបានគ្រប់ពេលកុំបីមានចន្លោះឡើយ ៕

ហោតុ សព្វំ សុមង្គលំ រក្ខន្តុ សព្វទេវតា
សព្វធម្មានុភាវេន សោត្ថិ ហោតុ និរន្តរំ ៕

ប្រែថា ហោតុ សព្វំ សុមង្គលំ សុមង្គលគឺសេចក្ដីចម្រើនដ៏ល្អគ្រប់យ៉ាងចូរមានដល់ខ្ញុំ, រក្ខន្តុ សព្វទេវតា ទេវតាទាំងពួងទាំងឡាយ ចូររក្សានូវខ្ញុំ, សព្វធម្មានុភាវេន ដោយអានុភាពនៃព្រះធម៌ទាំងពួង, សោត្ថិ ហោតុ និរន្តរំ សូមសិរីសួស្ដីចូរមានដល់ខ្ញុំឱ្យបានគ្រប់ពេលកុំបីមានចន្លោះឡើយ ។

ហោតុ សព្វំ សុមង្គលំ រក្ខន្តុ សព្វទេវតា

សព្វសង្ឃានុភាវេន សោត្ថិ ហោតុ និរន្តរំ ។

ប្រែថា ហោតុ សព្វំ សុមង្គលំ សុមង្គលគឺសេចក្ដីចម្រើនដ៏ល្អគ្រប់យ៉ាង ចូរមានដល់ខ្ញុំ, រក្ខន្តុ សព្វទេវតា ទេវតាទាំងពួងទាំងឡាយ ចូររក្សានូវខ្ញុំ, សព្វសង្ឃានុភាវេន ដោយអានុភាពនៃព្រះសង្ឃទាំងពួង, សោត្ថិ ហោតុ និរន្តរំ សូមសិរីសួស្ដីចូរមានដល់ខ្ញុំឱ្យបាន គ្រប់ពេលកុំបីមានចន្លោះឡើយ ។

"ចប់ត្រៃប្រណាមដោយសង្ខេបតែប៉ុណ្ណេះ"

# ប្រយោជន៍នៃការសិក្សាព្រះពុទ្ធប្បញ្ញត្តិ

- (គហដ្ឋសីល) ដើម្បីប្រយោជន៍ចំពោះគ្រហស្ថអ្នកសមាទានសីលណាមួយ ដែលមិនទាន់ច្បាស់លាស់ក្នុងសិក្ខាបទ ព្រោះខ្លួនមិនទាន់បានរៀន
- កាលបានរៀនសូត្រតាមពុទ្ធប្បញ្ញត្តិ ដែលព្រះលោកនាថជាអ្នកប្រាជ្ញបណ្ឌិតពីបុរាណ ទ្រង់ត្រាស់សម្តែងបង្គ្រងទុកមកហើយនេះ ដើម្បីប្រយោជន៍ដល់ការបានដឹង
- ការបានដឹង ដើម្បីប្រយោជន៍ដល់សេចក្តីសង្រួម
- សេចក្តីសង្រួម ដើម្បីប្រយោជន៍ដល់សេចក្តីមិនក្តៅក្រហាយចិត្ត
- សេចក្តីមិនក្តៅក្រហាយចិត្ត ដើម្បីប្រយោជន៍ដល់បាមុជ្ជៈគឺសេចក្តីរីករាយទន់
- បាមុជ្ជៈ ដើម្បីប្រយោជន៍ដល់បីតិ គឺសេចក្តីរីករាយដ៏ក្លា
- បីតិ ដើម្បីប្រយោជន៍ដល់បស្សទ្ធិ គឺសេចក្តីស្ងប់រម្ងាប់

- បស្សទ្ធិ ដើម្បីប្រយោជន៍ដល់សុខៈ គឺសេចក្តីសុខកាយ សប្បាយចិត្ត
- សុខៈ ដើម្បីប្រយោជន៍ដល់សមាធិ គឺការតម្កល់ចិត្តមាំ
- សមាធិ ដើម្បីប្រយោជន៍ដល់យថាភូតញ្ញាណទស្សនៈ គឺតរុណវិបស្សនា (វិបស្សនាទន់ខ្ចី)
- យថាភូតញ្ញាណទស្សនៈ ដើម្បីប្រយោជន៍ដល់និព្វិទា គឺពលវវិបស្សនា (វិបស្សនាមានកម្លាំង)
- និព្វិទា ដើម្បីប្រយោជន៍ដល់វិរាគៈ គឺអរិយមគ្គ
- វិរាគៈ ដើម្បីប្រយោជន៍ដល់វិមុត្តិ គឺអរហត្តផល
- វិមុត្តិ ដើម្បីប្រយោជន៍ដល់វិមុត្តិញ្ញាណទស្សនៈ គឺបច្ចវេក្ខណញ្ញាណ
- វិមុត្តិញ្ញាណទស្សនៈ ដើម្បីប្រយោជន៍ដល់អនុបាទាបរិនិព្វាន គឺរំលត់មិនឱ្យមានបច្ច័យជាគ្រឿងប្រកាន់តទៅ ។

ចងតាមលំនាំក្នុងគម្ពីរវិន័យបិដក ភាគ ១៣ ទំព័រ ១៩៥ ត្រង់ចូឡសង្គាម

## ពណ៌នាព្រះរតនត្រ័យ

ពុទ្ធំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក ។

ធម្មំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរឭក ។

សង្ឃំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក ។

ព្រះរតនត្រ័យនេះ អ្នកណាជាអ្នកពោល ពោលក្នុងទីណា ពោលកាលណា ពោលព្រោះហេតុអ្វី ម្យ៉ាងទៀតកាលដែលមិនបានត្រាស់ទុកមកអំពីដំបូង តើព្រោះហេតុអ្វី បានជាក្នុងទីនេះ ទើបពោលថា ត្រាស់ទុកជាលើកដំបូង ចាំបាច់ត្រូវជម្រះពាក្យផ្ដើមខាងដើម តអំពីនោះទៅ ក៏នឹងពន្យល់អំពីព្រះពុទ្ធអំពីការដល់ព្រះត្រៃសរណៈ អំពីបុគ្គលដែលគួរដល់សរណៈ នឹងសម្ដែងអំពីការដាច់ និងមិនដាច់នៃសរណគមន៍ ទាំងផលទាំងសរណៈដែលគួរដល់ សូម្បីក្នុងសរណៈពីរទៀតមាន **ធម្មំ សរណំ** ជាដើម ក៏គប្បីជ្រាបថា មានន័យយ៉ាងនេះដូចគ្នានឹងសេចក្ដីអធិប្បាយហេតុក្នុងការកំណត់ដោយលំដាប់ និងការប្រកាសព្រះរតនត្រ័យនោះ ដោយពាក្យឧបមាទាំងឡាយ ។

បណ្ដាគាថាទាំងនោះ គាថាដំបូងមាន ៥ បញ្ហាគឺ :

១- ព្រះរតនត្រ័យនេះ អ្នកណាពោល ?

២- ពោលក្នុងទីណា ?

៣- ពោលកាលណា ?

៤- ពោលព្រោះហេតុអ្វី ?

៥- ម្យ៉ាងទៀត កាលដែលព្រះតថាគតមិនបានត្រាស់ទុកមកអំពីដំបូង ព្រោះហេតុអ្វីក្នុងទីនេះ ទើបពោលថាត្រាស់ទុកជាលើកដំបូង ?

ខ្ញុំនឹងឆ្លើយនូវបញ្ហាទាំង ៥ នោះដូចតទៅនេះ ៖

សួរថា អ្នកណាពោល ឆ្លើយថា ព្រះមានព្រះភាគជាអ្នកត្រាស់ទុក មិនមែនសាវក មិនមែនពួកឥសី មិនមែនទេវតាពោលឡើយ ។

សួរថា ពោលក្នុងទីណា ឆ្លើយថា នៅក្នុងព្រៃឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ។

សួរថា ពោលកាលណា ឆ្លើយថា កាលព្រះយសបន្ទុះនូវព្រះអរហន្ត ព្រមទាំងសំឡាញ់ទាំងឡាយ កាលព្រះអរហន្ត ៦១ អង្គ ធ្វើការសម្ដែងធម៌ក្នុងលោក ដើម្បីប្រយោជន៍ជាសុខដល់ជនច្រើន ។

សួរថា ពោលព្រោះហេតុអ្វី ឆ្លើយថា ដើម្បីបព្វជ្ជា ដើម្បីឧបសម្បទា ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ ក៏ឯឧបសម្បទាបេក្ខៈ ដែលភិក្ខុគប្បីឱ្យបព្វជ្ជា ឧបសម្បទ័យ៉ាងនេះ ដំបូងឱ្យកោរសក់និងពុកមាត់ ឱ្យគ្រងសម្ពត់កាសាវៈ ឆៀងស្មាម្ខាង ឱ្យថ្វាយបង្គំភិក្ខុទាំងឡាយ ឱ្យអង្គុយច្រហោងផ្គងអញ្ជលី លើកដៃប្រណម្យឡើង ប្រៀនប្រដៅឱ្យថាតាមយ៉ាងនេះថា **ពុទ្ធំ សរណំ គច្ឆាមិ, ធម្មំ សរណំ គច្ឆាមិ, សង្ឃំ សរណំ គច្ឆាមិ ។**

សួរថា ហេតុអ្វី ក្នុងទីនេះទើបត្រាស់ថាជាលើកដំបូង ឆ្លើយថា ព្រោះហេតុដែលទេវតា និងមនុស្សនាំគ្នាចូលគាល់កាន់ព្រះសាសនា ដោយធ្វើជាឧបាសកខ្លះ ជាបព្វជិតខ្លះ ដោយផ្លូវនេះ ដូច្នេះទើបគួរដឹងថា នវង្គសត្ថុសាសន៍ ( ពាក្យប្រៀនប្រដៅប្រកបដោយអង្គ ៩ )នេះ ព្រះបុព្វាចារ្យទាំងឡាយ រួបរួមទុកដោយបិដកទាំងបី យកឡើងកាន់ផ្លូវការប្រាប់ ការប្រៀនប្រដៅទើបត្រាស់ជាលើកដំបូងក្នុងខុទ្ទកបាឋៈនេះ ព្រោះជាផ្លូវសម្រាប់ចូលទៅកាន់ព្រះសាសនា ។

# ពន្យល់អំពីព្រះពុទ្ធ

ឥឡូវនេះ ពាក្យណាដែលខ្ញុំពោលទុកថា នឹងពន្យល់អំពីព្រះពុទ្ធ អំពីការដល់សរណៈ និងអំពីបុគ្គលអ្នកដល់សរណៈ ។

ក្នុងពាក្យនោះ សត្វវិសេស ឈ្មោះថា ពុទ្ធៈ ព្រោះបញ្ញត្តិអាស្រ័យខន្ធសន្តាន ដែលត្រូវអប់រំដោយការបន្ទុះអនុត្តរវិមោក្ខ ជានិមិត្តនៃព្រះញាណ ដែលមិនមានអ្វីៗ រាំងបានឡើយ ឬព្រោះបញ្ញត្តិអាស្រ័យការត្រាស់ដឹងឯង យ៉ាងក្រៃលែងនូវសច្ចៈ ដែលជាបទដ្ឋាននៃព្រះសព្វញ្ញុតញ្ញាណ ដូចលោកពោលទុកថា ៖

ព្រះមានព្រះភាគអង្គឯណា ជាព្រះសយម្ភូ មិនមានអាចារ្យ ត្រាស់ដឹងក្រៃលែងដោយព្រះអង្គឯង នូវសច្ចៈទាំងឡាយ ក្នុងធម៌ទាំងឡាយ ដែលមិនបានស្ដាប់មកអំពីមុន ទ្រង់បន្ទុះព្រះសព្វញ្ញុតញ្ញាណក្នុងធម៌ពួកនោះ និងភាវៈជាអ្នកជំនាញក្នុងពលៈទាំងឡាយ ព្រះមានព្រះភាគអង្គនោះ ឈ្មោះថា ពុទ្ធៈ ។

ការពន្យល់អំពីព្រះពុទ្ធដោយអត្ថប៉ុណ្ណោះសិនចុះ ។

តែកាលពោលដោយព្យញ្ជនៈ គប្បីជ្រាបដោយន័យជាដើមយ៉ាងនេះថា ៖

+ ឈ្មោះថា ព្រះពុទ្ធ ព្រោះទ្រង់ជាអ្នកត្រាស់ដឹង

+ ឈ្មោះថា ព្រះពុទ្ធ ព្រោះទ្រង់ជាអ្នកដាស់សត្វឱ្យភ្ញាក់ ។ សមដូចពាក្យដែលលោកពោលទុកថា ៖

- ឈ្មោះថា ព្រះពុទ្ធ ដោយអត្ថដូចម្ដេច ?

- ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុទ្រង់ត្រាស់ដឹងនូវសច្ចៈទាំងឡាយ ។

- ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុទ្រង់ញ៉ាំងពពួកសត្វឱ្យត្រាស់ដឹង ។

- ឈ្មោះថា ព្រះពុទ្ធ ព្រោះព្រះអង្គដឹងធម៌ទាំងពួង ។

- ឈ្មោះថា ព្រះពុទ្ធ ព្រោះព្រះអង្គឃើញធម៌ទាំងពួង ។

- ឈ្មោះថា ព្រះពុទ្ធ ព្រោះព្រះអង្គដឹងច្បាស់ ។

- ឈ្មោះថា ព្រះពុទ្ធ ព្រោះព្រះអង្គរីកហើយ ។

- ឈ្មោះថា ព្រះពុទ្ធ ព្រោះគេពោលថា ព្រះអង្គមានអាសវៈអស់ហើយ ។

- ឈ្មោះថា ព្រះពុទ្ធ ព្រោះគេពោលថា ព្រះអង្គមានឧបក្កិលេសចេញហើយ ។

- ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុទ្រង់ប្រាសចាករាគៈដោយចំណែកមួយ ។

- ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុទ្រង់ប្រាសចាកទោសៈ ដោយចំណែកមួយ ។

- ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុទ្រង់ប្រាសចាកមោហៈ ដោយចំណែកមួយ ។

- ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុទ្រង់មានកិលេសចេញហើយ ដោយចំណែកមួយ ។

- ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុទ្រង់ទៅហើយកាន់ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង ។

- ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុទ្រង់ជាបុគ្គលឯក ត្រាស់ដឹងចំពោះសម្មាសម្ពោធិញ្ញាណ មិនមានគុណជាតិដទៃក្រៃលែងជាង ។

- ឈ្មោះថា ព្រះពុទ្ធ ព្រោះទ្រង់កំចាត់បង់សេចក្តីល្ងង់ ព្រោះការបាននូវប្រាជ្ញា ។

- ឈ្មោះថា ព្រះពុទ្ធនោះ មិនមែនព្រះមាតាថ្វាយ មិនមែនព្រះបិតាថ្វាយ មិនមែនបងប្អូនប្រុសថ្វាយ មិនមែនបងប្អូនស្រីថ្វាយ មិនមែនពួកមិត្រនិងអមាត្យថ្វាយ មិនមែនពួកញាតិនិងសាលោហិតថ្វាយ មិនមែនពួកសមណ

ព្រាហ្មណ៍ថ្វាយ មិនមែនពួកទេវតាថ្វាយទេ ព្រះនាមថា ព្រះពុទ្ធនុ៎ះរបស់ព្រះពុទ្ធទាំងឡាយ មានព្រះភាគជាព្រះនាម កើតក្នុងទីបំផុតនៃវិមោក្ខ បញ្ញត្តិថា ព្រះពុទ្ធនេះ កើត ព្រោះការត្រាស់ដឹង ព្រមដោយការបានចំពោះនូវសព្វញ្ញុ-តញ្ញាណ ទៀបគល់ពោធិព្រឹក្ស ហេតុនោះ លោកពោលថា ព្រះពុទ្ធ ។

" ចប់អធិប្បាយពាក្យថា ព្រះពុទ្ធ "

( បិដកលេខ ៦៨ ទំព័រ ១០៦ )

## ពាក្យថា ពុទ្ធ

ក្នុងពាក្យថា **ពុទ្ធ:** នោះ ឈ្មោះថា **ពុទ្ធ** ព្រោះអត្ថថា ត្រាស់ដឹងសច្ចៈទាំងឡាយ ដូចអ្នកដែលចុះមកក្នុងលោក ក៏ហៅថា អ្នកចុះមក ។ ឈ្មោះថា **ពុទ្ធ** ព្រោះអត្ថថា ទ្រង់ដាស់សត្វឱ្យភ្ញាក់ ដូចខ្យល់ធ្វើស្លឹកឈើឱ្យស្ងួត ក៏ហៅថា ស្លឹកឈើស្ងួត ។ បទថា **សព្វញ្ញុតាយ ពុទ្ធោ** លោកអធិប្បាយថា ឈ្មោះថា ព្រះពុទ្ធ ព្រោះទ្រង់អាចដឹងបានគ្រប់យ៉ាង ។ បទថា **សព្វទស្សាវិតាយ ពុទ្ធោ** លោកអធិប្បាយថា ឈ្មោះថា **ពុទ្ធ**

ព្រោះអាចដឹងធម៌បានគ្រប់យ៉ាង ។ បទថា **អនញ្ញាញេយ្យតាយ ពុទ្ធោ** លោកអធិប្បាយថា ឈ្មោះថា **ពុទ្ធ** ព្រោះត្រាស់ដឹងដោយខ្លួនឯង មិនមានអ្នកដទៃឱ្យត្រាស់ដឹង ។ បទថា **វិកសិតាយ ពុទ្ធោ** លោកអធិប្បាយថា ឈ្មោះថា **ពុទ្ធ** ព្រោះទ្រង់លេចចេញ ហេតុលេចចេញដោយព្រះគុណច្រើនប្រការ ដូចផ្កាឈូកលេចចេញ ។ ដោយបទយ៉ាងនេះជាដើមថា **ខីណាសវសង្ខាតេន ពុទ្ធោ** លោកអធិប្បាយថា ឈ្មោះថា **ពុទ្ធ** ព្រោះទ្រង់ភ្ញាក់ហើយ ហេតុអស់កិលេសដុតសេចក្តីងងុយគ្រប់យ៉ាង ដូចបុរសភ្ញាក់ព្រោះអស់សេចក្តីងងុយ ព្រោះទ្រង់លះធម៌ដែលធ្វើសេចក្តីស្ពុតនៃចិត្តបាន ។ លោកពោលថា **ឯកាយតនមគ្គំ គតោតិ ពុទ្ធោ** ដូចនេះ ក៏ដើម្បីសម្តែងថា ព្រះមានព្រះភាគជាម្ចាស់ លោកហៅថា **ពុទ្ធ:** ក៏ព្រោះទ្រង់ចម្រើនឯកាយតនមគ្គ ដូចបុរសសូម្បីដើរផ្លូវ គេក៏ហៅថា អ្នកដើរទៅ ព្រោះបរិយាយ(ផ្លូវ)នៃអត្ថថាទៅកាន់ផ្លូវត្រាស់ដឹង ។ បទថា **ឯកោ អនុត្តរំ សម្មាសម្ពោធិ អភិសម្ពុទ្ធោតិ ពុទ្ធោ** លោកអធិប្បាយថា ឈ្មោះថា **ពុទ្ធ** មិនមែនព្រោះត្រាស់ដឹងដោយអ្នកដទៃ តាមពិតឈ្មោះថា **ពុទ្ធ** ព្រោះ

គ្រាស់ដឹងយ៉ាងក្រៃលែងនូវសម្មាសម្ពោធិ ដែលប្រសើរបំផុត ដោយព្រះអង្គឯងប៉ុណ្ណោះ ។ ពាក្យនេះថា **អពុទ្ធិវិហាតត្តាយ ពុទ្ធិបដិលាភោ ពុទ្ធោ** ជាពាក្យសម្ដែងបរិយាយថា **ពុទ្ធិ ពុទ្ធំ ពុទ្ធោ** ។ ក្នុងពាក្យនោះ គប្បីជ្រាបអត្ថដែលអាចធ្វើ **ពុទ្ធៈ** សព្ទរបស់បទគ្រប់បទឱ្យសម្រេចសេចក្ដី ដោយន័យយ៉ាងនេះថា លោកអធិប្បាយដើម្បីឱ្យដឹងថា សំពត់ខៀវ សំពត់ក្រហម ក៏ព្រោះប្រកបដោយពណ៌ខៀវ ពណ៌ក្រហម តអំពីនោះ ពាក្យជាដើមយ៉ាងនេះថា **ពុទ្ធោតិ នេតំ ឆាមំ** លោកពោលទុក ក៏ដើម្បីឱ្យដឹងថា បញ្ញត្តិនេះប្រព្រឹត្តទៅតាមអត្ថគឺសេចក្ដី ។

ពន្យល់អំពីព្រះពុទ្ធសួម្បីដោយព្យញ្ជនៈ មានន័យដូចពោលមកនេះ ។

## ពន្យល់អំពីសរណគមន៍ និងអ្នកដល់សរណគមន៍

ឥឡូវនេះ នឹងពន្យល់អំពីការដល់សរណគមន៍ជាដើម ដូចតទៅនេះ ៖

ព្រះរតនត្រ័យ ដែលឈ្មោះថា **សរណៈ** ព្រោះកំចាត់ អធិប្បាយថា ប្របាច់ ទម្លាយ នាំចេញ រំលត់ភ័យគឺសេចក្ដីខ្លាច

សេចក្ដីតក់ស្លុត ទុក្ខ ទុគ្គតិ សេចក្ដីសៅហ្មង ដោយការដល់សរណៈនោះនុ៎ះឯង របស់អ្នកទាំងឡាយ ដែលដល់សរណគមន៍ ។

ន័យមួយទៀត ព្រះពុទ្ធជាម្ចាស់ឈ្មោះថា **សរណៈ** ព្រោះកំចាត់ភ័យរបស់សត្វទាំងឡាយ ដោយការឱ្យចូលដល់វត្ថុដែលមានប្រយោជន៍ និងនាំចេញអំពីវត្ថុដែលមិនមានប្រយោជន៍ ។

ព្រះធម៌ឈ្មោះថា **សរណៈ** ព្រោះឱ្យសត្វឆ្លងកន្តារៈគឺភព និងឱ្យសេចក្ដីរីករាយចិត្ត ។

ព្រះសង្ឃ ឈ្មោះថា **សរណៈ** ព្រោះធ្វើសក្ការៈដែលជនបូជាសូម្បីតិចតួច ត្រឡប់ជាបានផលក្រៃលែង ព្រោះដូច្នោះ ព្រះរតនត្រ័យនោះ ទើបឈ្មោះថា **សរណៈ** ដោយបរិយាយដូចពោលមកនេះ ។

ចិត្តុប្បាទគឺសេចក្ដីជ្រះថ្លាក្នុងព្រះរតនត្រ័យនោះ និងសេចក្ដីគោរពក្នុងព្រះរតនត្រ័យនោះ កំចាត់បង់កិលេសបាន ប្រព្រឹត្តទៅដោយអាការគឺភាវៈដែលមានព្រះរតនត្រ័យនោះជាប្រមុខ ឬមិនមានអ្នកដទៃជាបច្ច័យ( ដឹកនាំ )ឈ្មោះថា **សរណគមន៍** ។ សត្វ

អ្នកពោរពេញដោយចិត្តប្បាទនោះ រមែងដល់ព្រះរតនត្រ័យនោះជាសរណៈ អធិប្បាយថា រមែងចូលដល់ព្រះរតនត្រ័យ ដោយចិត្តប្បាទ ដែលមានប្រការដូចពោលហើយយ៉ាងនេះថា នេះជាសរណៈរបស់ខ្ញុំ ។ ក៏បុគ្គលកាលនឹងចូលដល់ រមែងចូលដល់ដោយវិធីសមាទាន ដូចយ៉ាងនាយពាណិជពីរនាក់ ឈ្មោះថា **តបុស្សៈ** និង**ភល្លិកៈ** ជាដើមថា **"បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំង ពីរនាក់នោះ សូមដល់ព្រះមានព្រះភាគ និងព្រះធម៌ជាសរណៈ សូមព្រះមានព្រះភាគ មេត្តាចាំទុកនូវខ្ញុំព្រះករុណាទាំងពីរនាក់ថា ជាឧបាសក"** ដូចនេះក៏បាន ។

ចូលដល់ដោយវិធីសូមយ៉ាងពិសេស ដូចយ៉ាងព្រះមហាកស្សបៈជាដើមថា **"បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគជាសាស្តារបស់ខ្ញុំព្រះអង្គៗ ជាសាវក"** ដូចនេះក៏បាន ។

ចូលដល់ដោយវិធីបង្អោនខ្លួន ចូលទៅក្នុងព្រះរតនត្រ័យនោះ ដូចយ៉ាងព្រហ្មាយុព្រាហ្មណ៍ជាដើម សេចក្តីបាលីថា កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះ ព្រហ្មាយុព្រាហ្មណ៍ក៏ក្រោកចាកអាសនៈ ធ្វើសំពត់ឆៀងស្មាម្ខាង ប្រណម្យដៃទៅកាន់

ទីដែលព្រះមានព្រះភាគគង់នៅ បន្លឺឧទាន ៣ គាថាដូច្នេះថា ៖

"នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស, នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស, នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស, កិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃ ចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ" ដូច្នេះក៏បាន ។

ចូលដល់ដោយវិធីប្រគល់ខ្លួន ដូចយោគីបុគ្គលអ្នកខ្វល់ខ្វាយក្នុងកម្មដ្ឋានក៏បាន ។

ចូលដល់ដោយវិស័យនិងដោយកិច្ចច្រើនវិធី ដូចជាវិធីកំចាត់ឧបក្កិលេសដោយការដល់សរណគមន៍ ដូចព្រះអរិយបុគ្គលទាំងឡាយក៏បាន ។

ពន្យល់អំពីការដល់សរណគមន៍ និងអំពីបុគ្គលអ្នកដល់សរណគមន៍ ដូចពោលមកនេះ ។

## សម្តែងសរណគមន៍ដាច់ មិនដាច់ និងផល

ឥឡូវនេះ នឹងសម្តែងសរណគមន៍ដាច់ជាដើម ដែលខ្ញុំពោលទុកថា នឹងសម្តែងសរណគមន៍ដាច់ និងមិនដាច់ព្រមទាំងផល ដូចតទៅនេះ ៖

សរណគមន៍ដាច់ របស់បុគ្គលអ្នកដល់សរណគមន៍ មាន ២ យ៉ាងគឺ មិនមានទោស ១ មានទោស ១ ។

- សរណគមន៍ដាច់ព្រោះការស្លាប់ ឈ្មោះថា **មិនមានទោស** ។

- សរណគមន៍ដាច់ព្រោះងាកទៅកាន់សាសនាដទៃ និងប្រព្រឹត្តខុសក្នុងព្រះសាស្តានោះ ឈ្មោះថា **មានទោស** ។

ការដាច់សូម្បីទាំងពីរនោះ រមែងមានដល់ពួកបុថុជ្ជនប៉ុណ្ណោះ សរណៈរបស់បុថុជ្ជនពួកនោះ រមែងឈ្មោះថា សៅហ្មងព្រោះប្រព្រឹត្តទៅ ដោយសេចក្តីមិនដឹង សេចក្តីសង្ស័យ និងសេចក្តីដឹងខុស និងព្រោះប្រព្រឹត្តមិនអើពើជាដើម ក្នុងព្រះពុទ្ធគុណទាំងឡាយ ចំណែកព្រះអរិយបុគ្គល មិនមានសរណៈដែលដាច់ទេ និងមិនមានសរណៈដែលសៅហ្មងទេ ដូចដែលត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ

ឧទ្ទិសខ្លួនចំពោះគ្រូដទៃ ដោយហេតុណា ហេតុនោះ មិនមែនជាហេតុ មិនមែនជាបច្ច័យឡើយ គឺហេតុមិនដែលមានឡើយ” ។ ចំណែកពួកបុថុជ្ជន រមែងមិនដល់ការដាច់សរណៈ ដរាបណា ដរាបនោះ ក៏នៅឈ្មោះថា ជាអ្នកមានសរណៈមិនដាច់ ការដាច់សរណៈរបស់បុថុជ្ជនពួកនោះ រមែងមានទោស មានសេចក្តីសៅហ្មងនិងអំណោយផលមិនគួរប្រាថ្នា ការដាច់សរណៈដែលមិនមានទោស ក៏មិនមានផល ព្រោះរកវិបាកមិនបាន ។ ចំណែកការមិនដាច់សរណៈពោលដោយផល ក៏រមែងឱ្យផលដែលគួរប្រាថ្នាតែម្យ៉ាង សមដូចព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងថា ៖

ពួកជនណាមួយ ដល់ព្រះពុទ្ធជាសរណៈ ពួកជននោះ លះបង់កាយមនុស្សទៅហើយ ក៏នឹងមិនចូលដល់អបាយភូមិ នឹងធ្វើពួកទេវតាឱ្យបរិបូណ៌ ដូច្នេះ ។

ក៏ក្នុងពាក្យនោះ គប្បីជ្រាបសេចក្តីអធិប្បាយនៃគាថាយ៉ាងនេះថា ជនពួកណា ដល់សរណៈដោយកាត់ឧបក្កិលេសបានដាច់ដោយសរណគមន៍ ជនពួកនោះ នឹងមិនទៅកាន់អបាយ ។ ចំណែកជនក្រៅនោះ នឹងមិនទៅកាន់អបាយ ក៏ដោយការដល់សរណៈ ។

សម្តែងសរណគមន៍ដាច់ មិនដាច់ និងផលត្រឹមប៉ុណ្ណេះ សិនចុះ ។

## ពន្យល់អំពីព្រះធម៌ និងព្រះសង្ឃ

ឥឡូវនេះ នឹងអធិប្បាយ ពាក្យដែលខ្ញុំពោលទុកថា សូម្បីក្នុងសរណៈទាំងពីរមាន **ធម្មំ សរណំ** ជាដើម ក៏គប្បីជ្រាបន័យយ៉ាងនោះដូចគ្នា ដូចតទៅ :

ន័យនៃការពណ៌នាសេចក្តីនោះ ខ្ញុំពោលទុកក្នុងពាក្យនេះថា **ពុទ្ធំ សរណំ គច្ឆាមិ** ក៏គប្បីជ្រាបន័យនៃការពណ៌នាសេចក្តីក្នុងបទទាំងពីរនេះថា **ធម្មំ សរណំ គច្ឆាមិ, សង្ឃំ សរណំ គច្ឆាមិ** ។ ពិតមែន សូម្បីការពណ៌នានោះ ពោលដោយអត្ថនិងព្យញ្ជនៈ របស់ព្រះធម៌និងព្រះសង្ឃ ខ្ញុំនឹងពន្យល់ត្រង់សេចក្តីដែលមិនដូចគ្នាប៉ុណ្ណោះ ក្នុងព្រះធម៌និងព្រះសង្ឃនេះ អាចារ្យមួយពួកពោលថា មគ្គ ផល និព្វាន ឈ្មោះថា **ព្រះធម៌** ។ ខន្តិ សេចក្តីពេញចិត្តឬមតិរបស់ពួកយើងថា មគ្គនិងវិពាកៈប៉ុណ្ណោះ ឈ្មោះថា ព្រះធម៌ក្នុងទីនេះ ព្រោះទ្រង់ជាអ្នកចម្រើនមគ្គផល និងជាអ្នកធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វានហើយ ដោយមិនឱ្យធ្លាក់ទៅក្នុងអបាយទាំងឡាយ នឹងធ្វើឱ្យរីករាយចិត្តយ៉ាងក្រៃលែង សមដូចពាក្យដែលព្រះមានព្រះភាគ ត្រាស់ទុកក្នុងអគ្គប្បសាទសូត្រនោះជាដើមយ៉ាងនេះថា "ម្នាលអានន្ទ អ្នកសម្គាល់ដូចម្តេច ? ធម៌ពួកណាដែលតថាគតសម្តែង ដើម្បី

ដ៏និយ៉ាងក្រៃលែង សម្រាប់អ្នកទាំងឡាយ គឺសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គៈ ៧ និងអរិយមគ្គប្រកបដោយអង្គ ៨ ម្នាលអានន្ទ អ្នកនឹងមិនឃើញភិក្ខុសូម្បីពីររូប មានវាទៈផ្សេងគ្នា ក្នុងធម៌ពួកនេះឡើយ" ។ មែនពិត ព្រះសង្ឃដោយបរមត្ថនេះ ដែលបុគ្គលគប្បីដល់ថាជាសរណៈ ក្នុងព្រះសូត្រដែលព្រះមានព្រះភាគត្រាស់ទុកថា ព្រះសង្ឃសាវ័ករបស់ព្រះមានព្រះភាគ ជាអ្នកគួរឱនលំទោន គួរទទួលការស្វាគមន៍ គួរធ្វើបុណ្យ គួរធ្វើអញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ល្អក្រៃលែងក្នុងលោក ។ សរណគមន៍របស់អ្នកដល់សរណៈនោះ រមែងមិនដាច់ មិនសៅហ្មង ដោយការធ្វើការថ្វាយបង្គំជាដើម ក្នុងភិក្ខុសង្ឃ ឬភិក្ខុនីសង្ឃ សូម្បីពួកដទៃឬព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ឬសម្មតិសង្ឃផ្សេងដោយសង្ឃចតុវគ្គជាដើម ឬសូម្បីក្នុងបុគ្គលណាម្នាក់ ដែលបួសឧទ្ទិសចំពោះព្រះមានព្រះភាគ សេចក្តីផ្សេងគ្នាក្នុងសង្ឃសរណៈមានត្រឹមប៉ុណ្ណោះ ចំណែកការដាច់ និងមិនដាច់ជាដើមនៃសរណគមន៍នេះ និងទីពីរក្រៅពីពោលហើយ គប្បីជ្រាបតាមន័យ ដែលពោលមកហើយ ការពណ៌នាសេចក្តីនេះថា សូម្បីក្នុងសរណៈទាំងពីរថា **ធម្មំ សរណំ** ជាដើម គប្បីជ្រាបថា ន័យដូចគ្នាទាំងអស់ ។

## អធិប្បាយហេតុក្នុងការកំណត់តាមលំដាប់

ក្នុងពាក្យនេះថា នឹងអធិប្បាយហេតុក្នុងការកំណត់តាមលំដាប់ ឥឡូវនេះ នឹងអធិប្បាយហេតុក្នុងការកំណត់តាមលំដាប់យ៉ាងនេះថា ក្នុងពាក្យដល់សរណៈទាំងបីនោះ លោកប្រកាសព្រះពុទ្ធជាម្ចាស់ជាលំដាប់ដំបូង ព្រោះជាអ្នកប្រសើរលើសជាងសត្វទាំងពួង ប្រកាសព្រះធម៌ លំដាប់បន្ទាប់ ព្រោះជាដែនកើតរបស់ព្រះពុទ្ធជាម្ចាស់នោះ និងព្រោះជាធម៌ ដែលព្រះមានព្រះភាគអង្គនោះ ទ្រង់នាំមកប្រៀនប្រដៅហើយប្រកាស ព្រះសង្ឃលំដាប់ចុងក្រោយ ព្រោះជាអ្នកទ្រទ្រង់ទុកនូវព្រះធម៌នោះ និងព្រោះមានសេចក្តីស្រឡាញ់ចំពោះព្រះធម៌នោះ ន័យមួយទៀតលោកប្រកាសព្រះពុទ្ធលំដាប់ដំបូង ព្រោះទ្រង់ប្រកបសត្វទាំងពួងក្នុងផលប្រយោជន៍ ប្រកាសព្រះធម៌លំដាប់បន្ទាប់ ព្រោះជាដែនកើតនៃព្រះពុទ្ធនោះ និងព្រោះជាធម៌ដែលជាផលប្រយោជន៍ដល់សត្វទាំងពួង ប្រកាសព្រះសង្ឃលំដាប់ចុងក្រោយ ព្រោះព្រះសង្ឃជាអ្នកបដិបត្តិ ដើម្បីបន្ទះនូវផលប្រយោជន៍ និងមានផលប្រយោជន៍ដែលបន្ទះហើយ កំណត់ដោយសេចក្តីជាសរណៈ ។

## ពាក្យឧបមាព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ

ឥឡូវនេះ នឹងអធិប្បាយពាក្យថា នឹងប្រកាសព្រះរតនត្រ័យនោះ ដោយពាក្យឧបមាទាំងឡាយដូច្នេះ ៖

១- ព្រះពុទ្ធជាម្ចាស់ ប្រៀបដូចព្រះចន្ទពេញវង់

- ព្រះធម៌ ប្រៀបដូចរង្វង់ពន្លឺរស្មីរបស់ព្រះចន្ទ

- ព្រះសង្ឃ ប្រៀបដូចពិភពលោកដែលបែងចាំងដោយរស្មីរបស់ព្រះចន្ទពេញបូណ៌មី

២- ព្រះពុទ្ធ ប្រៀបដូចព្រះអាទិត្យដែលបញ្ចេញកំដៅយ៉ាងស្រទន់

- ព្រះធម៌ ប្រៀបដូចកាំរស្មីរបស់ព្រះអាទិត្យនោះ

- ព្រះសង្ឃ ប្រៀបដូចពិភពលោកដែលព្រះអាទិត្យនោះកំចាត់ងងឹតហើយ ។

៣- ព្រះពុទ្ធ ប្រៀបដូចមនុស្សដុតព្រៃ

- ព្រះធម៌ជាគ្រឿងដុតព្រៃគឺកិលេស ប្រៀបដូចជាភ្លើងសម្រាប់ដុតព្រៃ

- ព្រះសង្ឃជាបុញ្ញក្ខេត្ត ព្រោះដុតកិលេសបានហើយ ប្រៀបដូចភូមិភាគដែលជាទីគួរធ្វើស្រែ ព្រោះដុតព្រៃអស់ហើយ ។

៤- ព្រះពុទ្ធ ប្រៀបដូចមេឃភ្លៀងធំ

- ព្រះធម៌ ប្រៀបដូចទឹកភ្លៀង

- ព្រះសង្ឃអ្នករម្ងាប់កង្វល់កិលេស ប្រៀបដូចជនបទដែលមិនមានល្អងធូលីព្រោះភ្លៀងធ្លាក់ ។

៥- ព្រះពុទ្ធ ប្រៀបដូចសារថីដ៏ល្អ

- ព្រះធម៌ ប្រៀបដូចឧបាយហ្វឹកហាត់សេះអាជានេយ្យ

- ព្រះសង្ឃ ប្រៀបដូចហ្វូងសេះអាជានេយ្យដែលហ្វឹកហាត់ល្អហើយ ។

៦- ព្រះពុទ្ធ ប្រៀបដូចសល្យពេទ្យ (ពេទ្យវះកាត់) ព្រោះទ្រង់ដកព្រួញគឺកិលេសបានទាំងអស់

- ព្រះធម៌ ប្រៀបដូចឧបាយសម្រាប់ដកព្រួញចេញ

- ព្រះសង្ឃអ្នកដកកូនសរ គឺទិដ្ឋិចេញហើយប្រៀបដូចជាជនដែលត្រូវដកព្រួញចេញ ។

៧- ន័យមួយទៀត ព្រះពុទ្ធ ប្រៀបដូចចក្ខុពេទ្យ (ពេទ្យភ្នែក) ព្រោះទ្រង់យកធូលីគឺមោហៈចេញបានហើយ

- ព្រះធម៌ ប្រៀបដូចឧបាយជាគ្រឿងយកធូលីចេញ

- ព្រះសង្ឃ ប្រៀបដូចអ្នកមានភ្នែកដែលយកធូលីចេញហើយ អ្នកមានកែវភ្នែក គឺញាណដែលស្រស់ថ្លា ប្រៀបដូចជនដែល

អស់ធូលីពីភ្នែកហើយ មានកែវភ្នែកស្រស់ថ្លា ។

៨- ម្យ៉ាងទៀត ព្រះពុទ្ធ ប្រៀបដូចគ្រូពេទ្យដែលឆ្លាតព្រោះទ្រង់អាចកំចាត់ព្យាធិ គឺកិលេសព្រមទាំងអនុស័យចេញបាន

- ព្រះធម៌ ប្រៀបដូចថ្នាំដែលព្រះអង្គទ្រង់ផ្សំត្រឹមត្រូវហើយ

- ព្រះសង្ឃអ្នកមានព្យាធិ គឺ កិលេស និងអនុស័យដែលរម្ងាប់ហើយ ប្រៀបដូចពួកជន មានព្យាធិរម្ងាប់ហើយ ព្រោះប្រកបថ្នាំ ។

៩- ន័យមួយទៀត ព្រះពុទ្ធជាម្ចាស់ ប្រៀបដូចអ្នកបង្ហាញផ្លូវ

- ព្រះធម៌ ប្រៀបដូចផ្លូវល្អឬទីដែលមិនមានភ័យ

- ព្រះសង្ឃ ប្រៀបដូចអ្នកដើរផ្លូវដល់ទីដែលផុតភ័យ

១០- ព្រះពុទ្ធ ប្រៀបដូចជានាយនាវិក( អ្នកម្ចាស់ទូក )ដ៏ល្អ

- ព្រះធម៌ ប្រៀបដូចទូក

- ព្រះសង្ឃ ប្រៀបដូចអ្នកដំណើរឆ្លងដល់ត្រើយ ។

១១- ព្រះពុទ្ធ ប្រៀបដូចព្រៃហិមពាន្ត

- ព្រះធម៌ ប្រៀបដូចឱសថដែលកើតអំពីព្រៃហិមពាន្តនោះ

- ព្រះសង្ឃ ប្រៀបដូចជាជនមិនមានរោគព្រោះប្រើប្រាស់ថ្នាំ ។

១២- ព្រះពុទ្ធ ប្រៀបដូចជាអ្នកប្រទានទ្រព្យ

- ព្រះធម៌ ប្រៀបដូចជាទ្រព្យសម្បត្តិ

- ព្រះសង្ឃ អ្នកបានអរិយទ្រព្យមកដោយប្រពៃ ប្រៀបដូចជនអ្នកបានទ្រព្យដូចសេចក្តីប្រាថ្នា ។

១៣- ព្រះពុទ្ធ ប្រៀបដូចអ្នកបង្ហាញកំណប់ទ្រព្យ

- ព្រះធម៌ ប្រៀបដូចកំណប់ទ្រព្យ

- ព្រះសង្ឃ ប្រៀបដូចអ្នកបានកំណប់ទ្រព្យ ។

១៤- ន័យម្យ៉ាងទៀត ព្រះពុទ្ធទ្រង់ជាវីរបុរស ប្រៀបដូចជាអ្នកប្រទានអភ័យ

- ព្រះធម៌ ប្រៀបដូចជាពាក្យបំបាត់ភ័យ

- ព្រះសង្ឃ អ្នកកន្លងភ័យគ្រប់យ៉ាង ប្រៀបដូចអ្នកមិនមានភ័យ

១៥- ព្រះពុទ្ធ ប្រៀបដូចអ្នកលួងលោម

- ព្រះធម៌ ប្រៀបដូចជាពាក្យលួងលោម

- ព្រះសង្ឃ ប្រៀបដូចជនដែលគេលួងលោម

១៦- ព្រះពុទ្ធ ប្រៀបដូចមិត្តល្អ

- ព្រះធម៌ ប្រៀបដូចជាពាក្យទូន្មានដែលជាផលប្រយោជន៍

- ព្រះសង្ឃ ប្រៀបដូចអ្នកជួបប្រយោជន៍ខ្លួន ព្រោះជួប

ផលប្រយោជន៍ ។

១៧- ព្រះពុទ្ធ ប្រៀបដូចអណ្តូងកើតទ្រព្យ

- ព្រះធម៌ ប្រៀបដូចទ្រព្យដែលមានប្រយោជន៍

- ព្រះសង្ឃ ប្រៀបដូចជនអ្នកបានទ្រព្យដែលមានប្រយោជន៍

១៨- ព្រះពុទ្ធ ប្រៀបដូចជាអ្នកផ្ងូតទឹកឱ្យព្រះរាជកុមារ

- ព្រះធម៌ ប្រៀបដូចជាទឹក ដែលជោករហូតដល់ក្បាល

- ព្រះសង្ឃ អ្នកស្រង់ទឹកល្អហើយដោយទឹក គឺព្រះសទ្ធម្ម ប្រៀបដូចពួកព្រះរាជកុមារ ដែលងូតទឹកល្អហើយ ។

១៩- ព្រះពុទ្ធ ប្រៀបដូចអ្នកបំពាក់គ្រឿងអលង្ការ

- ព្រះធម៌ ប្រៀបដូចជាគ្រឿងអលង្ការ

- ព្រះសង្ឃ អ្នកប្រដាប់ដោយព្រះសទ្ធម្ម ប្រៀបដូចជាព្រះរាជឱរស ដែលពាក់គ្រឿងអលង្ការហើយ ។

២០- ព្រះពុទ្ធ ប្រៀបដូចដើមចន្ទន៍

- ព្រះធម៌ ប្រៀបដូចក្លិន ដែលកើតអំពីដើមចន្ទន៍នោះ

- ព្រះសង្ឃ អ្នករម្ងាប់សេចក្តីក្តៅក្រហាយបាន ព្រោះបរិភោគប្រើប្រាស់ព្រះសទ្ធម្ម ប្រៀបដូចជនអ្នករម្ងាប់សេចក្តីក្តៅក្រហាយដោយការប្រើខ្លឹមចន្ទន៍ ។

២១- ព្រះពុទ្ធ ប្រៀបដូចបិតាប្រគល់មរតកដោយធម៌
- ព្រះធម៌ ប្រៀបដូចមរតក
- ព្រះសង្ឃ អ្នកទទួលមរតកគឺព្រះសទ្ធម្ម ប្រៀបដូចពួកបុត្ត អ្នកទទួលមរតក ។

២២- ព្រះពុទ្ធ ប្រៀបដូចផ្កាបទុមដែលរីក
- ព្រះធម៌ ប្រៀបដូចទឹកដមដែលកើតអំពីផ្កាបទុមរីកនោះ
- ព្រះសង្ឃ ប្រៀបដូចពួកភមរជាតិដែលក្រេបទឹកដមនោះ ។

គប្បីប្រកាសព្រះរតនត្រ័យនោះ ដោយសេចក្ដីឧបមាទាំងឡាយ ដូចពោលមកដូច្នេះ ។

មាតិការបស់កថាពណ៌នា សេចក្ដីដែលយកមកតាំងទុកក្នុងខាងដើមដោយ ៤ គាថាថា អ្នកណាពោល, ពោលទីណា, ពោលកាលណា, ពោលព្រោះហេតុអ្វីជាដើម, ក៏ជាការដែលប្រកាសហើយដោយអត្ថ ដោយកថា មានប្រមាណត្រឹមប៉ុណ្ណោះឯង ។

"ចប់ការពណ៌នាព្រះរតនត្រ័យ"

( អដ្ឋកថាខុទ្ទកបាឋៈ ឈ្មោះបរមត្ថជោតិកា )

## បុព្វភាគប្បដិបត្តិ

បុរសស្ត្រីដែលមានសទ្ធាជ្រះថ្លា ក្នុងគុណព្រះរតនត្រ័យ គឺគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ហើយមានប្រាថ្នានឹងប្ដេជ្ញាខ្លួនជាឧបាសកឬជាឧបាសិកា ជាបុព្វភាគប្បដិបត្តិ គឺសេចក្ដីប្រតិបត្តិជាចំណែកខាងដើមឱ្យបានពេញស៊ប់ ជាអ្នកកាន់ព្រះពុទ្ធសាសនា ឬជាអ្នកតម្កល់នៅក្នុងព្រះពុទ្ធសាសនានោះ, ដំបូងបង្អស់ត្រូវបញ្ចេញវចីភេទ សូមខមាទោសនឹងព្រះរតនត្រ័យ ក្នុងទីចំពោះព្រះភក្ត្រព្រះពុទ្ធរូបក៏បាន ចំពោះព្រះស្តូបឬព្រះចេតិយ ដែលបញ្ចុះព្រះសារីរិកធាតុ ព្រះសម្មាសម្ពុទ្ធក៏បាន ចំពោះមុខបុគ្គល គឺភិក្ខុ ១ រូបក៏បាន ២ រូបក៏បាន ចំពោះមុខគណៈគឺភិក្ខុ ៣ រូបក៏បាន ចំពោះសង្ឃគឺភិក្ខុទាំងឡាយ តាំងពី ៤ រូបឡើងទៅ ក៏បានលុះសូមខមាទោសរួចហើយ ត្រូវបញ្ចេញវចីភេទពោល ប្រកាសប្ដេជ្ញាខ្លួន ឱ្យជាអ្នកបានដល់ព្រះត្រៃសរណគមន៍ ជាឧបាសកឬជាឧបាសិកា ក្នុងព្រះពុទ្ធសាសនាជាខាងក្រោយ រួចហើយត្រូវសមាទាននិច្ចសីល រក្សាឱ្យខ្ជាប់តទៅ, បើមាន សទ្ធាជ្រះថ្លា ក៏គប្បីរក្សាឧបោសថសីល តាមកាលកំណត់ ដែលត្រូវរក្សាម្ដងៗនោះផង នឹងមានផលានិសង្សច្រើនដោយ លំដាប់ៗ ឡើង ។

ពាក្យសូមខមាទោសនឹងព្រះរតនត្រ័យ ក្នុងទីចំពោះព្រះភក្ត្រព្រះពុទ្ធរូបក៏បាន ចំពោះព្រះស្តូបឬព្រះចេតិយ ដែលបញ្ចុះព្រះសារីរិកធាតុ ព្រះសម្មាសម្ពុទ្ធក៏បាន ចំពោះព្រះសិរីមហាពោធិព្រឹក្សក៏បាន ។

បើបុរសតែម្នាក់ ត្រូវសូត្រថា ៖

អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ យថាមុឡ្ហំ យថាអកុសលំ យោហំ ភន្តេ កាយេន វា វាចាយ វា មនសា វា ភគវតោ វា ធម្មស្ស វា សង្ឃស្ស វា អគារវំ អកាសឹ តស្ស មេ ភន្តេ ភគវា អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយ ។

ប្រែថា បពិត្រព្រះមានព្រះភាគដ៏ចម្រើន ទោសកំហុសដែលប្រព្រឹត្តកន្លង គ្របសង្កត់ហើយនូវខ្ញុំព្រះករុណា តាមដោយខ្ញុំព្រះករុណា ជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស បពិត្រព្រះមានព្រះភាគដ៏ចម្រើន ក្រែងខ្ញុំព្រះករុណាបានធ្វើហើយ នូវសេចក្តីល្មើស មិនគោរពដល់ព្រះដ៏មានព្រះភាគក្តី ដល់ព្រះធម៌ក្តី ដល់ព្រះសង្ឃក្តី ដោយកាយក្តី ដោយវាចាក្តី ដោយចិត្តក្តី បពិត្រព្រះមានព្រះភាគដ៏ចម្រើន សូមព្រះដ៏មាន

ព្រះភាគអត់នូវទោសកំហុសនោះ ដល់ខ្ញុំព្រះករុណា ព្រោះអំពើនៃទោសនោះ ជាសេចក្ដីខុសពិត ដើម្បីនឹងបានសង្រួម គឺថានឹងប្រព្រឹត្តឱ្យល្អតទៅក្នុងខាងមុខនោះហោង ។

បើស្ត្រីតែម្នាក់ ត្រូវសូធ្យថា ៖

អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ យថាមុឡ្ហំ យថាអកុសលំ យាហំ ភន្តេ កាយេន វា វាចាយ វា មនសា វា ភគវតោ វា ធម្មស្ស វា សង្ឃស្ស វា អគារវំ អកាសឹ តស្សា មេ ភន្តេ ភគវា អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយ ។

ប្រែថា បពិត្រព្រះមានព្រះភាគដ៏ចម្រើន ទោសកំហុសដែលប្រព្រឹត្តកន្លង គ្របសង្កត់ហើយនូវខ្ញុំព្រះករុណា តាមដោយខ្ញុំព្រះករុណា ជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស បពិត្រព្រះមានព្រះភាគដ៏ចម្រើន ក្រែងខ្ញុំព្រះករុណាបានធ្វើហើយ នូវសេចក្ដីល្មើស មិនគោរពដល់ព្រះដ៏មានព្រះភាគក្ដី ដល់ព្រះធម៌ក្ដី ដល់ព្រះសង្ឃក្ដី ដោយកាយក្ដី ដោយវាចាក្ដី ដោយចិត្តក្ដី បពិត្រព្រះមានព្រះភាគដ៏ចម្រើន សូមព្រះដ៏មានព្រះភាគអត់នូវទោសកំហុសនោះ ដល់ខ្ញុំព្រះករុណា ព្រោះ

អំពើនៃទោសនោះ ជាសេចក្តីខុសពិត ដើម្បីនឹងបានសង្រួម គឺថា នឹងប្រព្រឹត្តឱ្យល្អតទៅក្នុងខាងមុខនោះហោង ។

បើបុរសច្រើននាក់ ត្រូវសូធ្យបែបនេះ, បើសូធ្យលាយស្ត្រី, បុរសក៏នៅតែសូធ្យបែបនេះដែរថា ៖

អច្ចយោ នោ ភន្តេ អច្ចគមា យថាពាលេ យថាមុឡ្ហេ យថាអកុសលេ យេ មយំ ភន្តេ កាយេន វា វាចាយ វា មនសា វា ភគវតោ វា ធម្មស្ស វា សង្ឃស្ស វា អគារវំ អករិម្ហា តេសំ នោ ភន្តេ ភគវា អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយ ។

ប្រែថា បពិត្រព្រះមានព្រះភាគដ៏ចម្រើន ទោសកំហុសដែលប្រព្រឹត្តកន្លង គ្របសង្កត់ហើយនូវខ្ញុំព្រះករុណាទាំងឡាយ តាមដោយខ្ញុំព្រះករុណាទាំងឡាយ ជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស បពិត្រព្រះមានព្រះភាគដ៏ចម្រើន ក្រែងខ្ញុំព្រះករុណាទាំងឡាយ បានធ្វើហើយនូវសេចក្តីល្មើស មិនគោរពដល់ព្រះដ៏មានព្រះភាគក្តី ដល់ព្រះធម៌ក្តី ដល់ព្រះសង្ឃក្តី ដោយកាយក្តី ដោយវាចាក្តី ដោយចិត្តក្តី បពិត្រព្រះមានព្រះភាគដ៏ចម្រើន សូមព្រះដ៏មានព្រះភាគអត់នូវទោសកំហុសនោះ

ដល់ខ្ញុំព្រះករុណាទាំងឡាយ ព្រោះអំពើនៃទោសនោះ ជាសេចក្ដីខុសពិត ដើម្បីនឹងបានសង្រួម គឺថានឹងប្រព្រឹត្តឱ្យល្អតទៅ ក្នុងខាងមុខនោះហោង ។

បើស្ត្រីច្រើននាក់ ត្រូវសូធ្យបែបនេះ, បើសូធ្យលាយបុរស, ស្ត្រីក៏នៅតែសូធ្យបែបនេះដែរថា ៖

**អច្ចយោ នោ ភន្តេ អច្ចគមា យថាពាលា យថាមុឡ្ហា យថាអកុសលា យា មយំ ភន្តេ កាយេន វា វាចាយ វា មនសា វា ភគវតោ វា ធម្មស្ស វា សង្ឃស្ស វា អគារវំ អករិម្ហា តាសំ នោ ភន្តេ ភគវា អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយ ។**

ប្រែថា បពិត្រព្រះមានព្រះភាគដ៏ចម្រើន ទោសកំហុសដែលប្រព្រឹត្តកន្លង គ្របសង្កត់ហើយនូវខ្ញុំព្រះករុណាទាំងឡាយ តាមដោយខ្ញុំព្រះករុណាទាំងឡាយ ជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស បពិត្រព្រះមានព្រះភាគដ៏ចម្រើន ក្រែងខ្ញុំព្រះករុណាទាំងឡាយ បានធ្វើហើយនូវសេចក្ដីល្មើសមិនគោរពដល់ព្រះដ៏មានព្រះភាគក្ដី ដល់ព្រះធម៌ក្ដី ដល់ព្រះសង្ឃក្ដី ដោយកាយក្ដី ដោយវាចាក្ដី ដោយចិត្តក្ដី បពិត្រព្រះមានព្រះ

ភាគដ៏ចម្រើន សូមព្រះដ៏មានព្រះភាគអត់នូវទោសកំហុសនោះ ដល់ខ្ញុំព្រះករុណាទាំងឡាយ ព្រោះអំពើនៃទោសនោះ ជាសេចក្តីខុសពិត ដើម្បីនឹងបានសង្រួម គឺថានឹងប្រព្រឹត្តឱ្យល្អតទៅក្នុងខាងមុខនោះហោង ។

( បើលំបាកពោលបាលី ពោលតែសម្រាយក៏បាន ) ។

លុះបានសូមខមាទោសនឹងព្រះរតនត្រ័យ ដូច្នេះរួចហើយ គប្បីបញ្ចេញ វចីភេទប្តេជ្ញាខ្លួនជាអ្នកដល់ព្រះត្រៃសរណគមន៍ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរឭកដើម្បីនឹងឱ្យឡើងនាមបញ្ញត្តិជាឧបាសក ឬជាឧបាសិកា ក្នុងព្រះពុទ្ធសាសនាតទៅ, ឯប្តេជ្ញាខ្លួននោះនឹងប្តេជ្ញាក្នុងទីចំពោះព្រះភក្ត្រព្រះពុទ្ធរូបក៏បាន ចំពោះព្រះស្តូបឬព្រះចេតិយ ដែលបញ្ចុះព្រះសារីរិកធាតុព្រះដ៏មានបុណ្យក៏បាន ចំពោះព្រះសិរីមហាពោធិព្រឹក្សក៏បាន ។

បើបុរសតែម្នាក់ ត្រូវសូធ្យប្តេជ្ញាខ្លួនដោយពាក្យថា ៖

ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ
ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភគវា
ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ

ប្រែថា បពិត្រព្រះមានព្រះភាគដ៏ចម្រើន ខ្ញុំព្រះករុណា

សូមដល់នូវព្រះដ៏មានព្រះភាគផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹង ទីរឭក សូមព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបនូវខ្ញុំព្រះករុណាថាជា ឧបាសក បានដល់ហើយនូវព្រះរតនត្រ័យ ជាទីពឹង ទីរឭក ស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមរៀងទៅ ។

បើស្ត្រីតែម្នាក់ ត្រូវសូធ្យប្តេជ្ញាខ្លួនដោយពាក្យថា ៖

**ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ**

**ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសិកំ មំ ភគវា**

**ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ**

ប្រែថា បពិត្រព្រះមានព្រះភាគដ៏ចម្រើន ខ្ញុំព្រះករុណាសូមដល់នូវព្រះដ៏មានព្រះភាគផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹង ទីរឭក សូមព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបនូវខ្ញុំព្រះករុណាថាជា ឧបាសិកាបានដល់ហើយនូវព្រះរតនត្រ័យ ជាទីពឹង ទីរឭកស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមរៀងទៅ ។

បើគ្នាច្រើន ក៏ត្រូវសូធ្យដូចន័យមុន ខុសគ្នាតែត្រង់ពាក្យថា ភគវន្តំ ថា ភគវា ប៉ុណ្ណោះ, បើគ្នាច្រើនហើយ នឹងសូធ្យប្តេជ្ញាខ្លួនព្រមគ្នាដោយពាក្យជាឯកវចនៈក៏បាន ព្រោះសូធ្យព្រមទាំងអស់គ្នា ។

ពាក្យថា ដោយពាក្យជា ឯកវចនៈក៏បាន សំដៅដល់ការសូត្រតាមលំនាំបុរសតែម្នាក់, ស្ត្រីតែម្នាក់ខាងលើតែសូត្រព្រមជាមួយគ្នាបាន ។

( បើលំបាកពោលបាលី ពោលតែសម្រាយក៏បាន ) ។

ឯពាក្យសូមខមាទោសចំពោះព្រះរតនត្រ័យនោះ ក្នុងទីនេះសូមរៀបរៀងតែវិធីខមាទោសចំពោះមុខព្រះសង្ឃប៉ុណ្ណោះ ។

បើបុរសតែម្នាក់ ត្រូវសូត្រថា ៖

អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ យថាមុឡ្ហំ យថាអកុសលំ យោហំ ភន្តេ កាយេន វា វាចាយ វា មនសា វា ពុទ្ធស្ស វា ធម្មស្ស វា សង្ឃស្ស វា អគារវំ អកាសឹ តស្ស មេ ភន្តេ សង្ឃោ អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយ ។

ប្រែថា បពិត្រព្រះសង្ឃដ៏ចម្រើន ទោសកំហុសដែលប្រព្រឹត្តកន្លង គ្របសង្កត់ហើយនូវខ្ញុំព្រះករុណា តាមដោយខ្ញុំព្រះករុណា ជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស បពិត្រព្រះសង្ឃដ៏ចម្រើន ក្រែងខ្ញុំព្រះករុណាបានធ្វើហើយ នូវសេចក្តីល្មើស មិនគោរពដល់ព្រះពុទ្ធជាម្ចាស់ក្តី

ដល់ព្រះធម៌ក្តី ដល់ព្រះសង្ឃក្តី ដោយកាយក្តី ដោយវាចាក្តី ដោយចិត្តក្តី បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃអត់នូវទោសកំហុសនោះ ដល់ខ្ញុំព្រះករុណា ព្រោះអំពើនៃទោសនោះជាសេចក្តីខុសពិត ដើម្បីនឹងបានសង្រួម គឺថានឹងប្រព្រឹត្តឱ្យល្អតទៅក្នុងខាងមុខនោះហោង ។

បើស្ត្រីតែម្នាក់ ត្រូវសូធ្យថា ៖

អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ យថាមុឡ្ហំ យថាអកុសលំ យាហំ ភន្តេ កាយេន វា វាចាយ វា មនសា វា ពុទ្ធស្ស វា ធម្មស្ស វា សង្ឃស្ស វា អគារវំ អកាសឹ តស្សា មេ ភន្តេ សង្ឃោ អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយ ។

ប្រែថា បពិត្រព្រះសង្ឃដ៏ចម្រើន ទោសកំហុសដែលប្រព្រឹត្តកន្លង គ្របសង្កត់ហើយនូវខ្ញុំព្រះករុណា តាមដោយខ្ញុំព្រះករុណា ជាមនុស្សល្ងង់ខ្លៅជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស បពិត្រព្រះសង្ឃដ៏ចម្រើន ក្រែងខ្ញុំព្រះករុណាបានធ្វើហើយ នូវសេចក្តីល្មើស មិនគោរពដល់ព្រះពុទ្ធជាម្ចាស់ក្តី ដល់ព្រះធម៌ក្តី ដល់ព្រះសង្ឃក្តី ដោយកាយក្តី ដោយវាចាក្តី ដោយ

ចិត្តក្តី បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃអត់នូវទោស កំហុសនោះ ដល់ខ្ញុំព្រះករុណា ព្រោះអំពើនៃទោសនោះ ជាសេចក្តីខុសពិត ដើម្បីនឹងបានសង្រួម គឺថានឹងប្រព្រឹត្តឱ្យល្អ តទៅក្នុងខាងមុខនោះហោង ។

បើបុរសច្រើននាក់ ត្រូវសូធ្យបែបនេះ, បើសូធ្យលាយស្ត្រី, បុរសក៏នៅតែសូធ្យបែបនេះដែរថា ៖

អច្ចយោ ណោ ភន្តេ អច្ចគមា យថាពាលេ យថាមុឡ្ហេ យថាអកុសលេ យេ មយំ ភន្តេ កាយេន វា វាចាយ វា មនសា វា ពុទ្ធស្ស វា ធម្មស្ស វា សង្ឃស្ស វា អគារវំ អកម្ហា តេសំ ណោ ភន្តេ សង្ឃោ អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយ ។

ប្រែថា បពិត្រព្រះសង្ឃដ៏ចម្រើន ទោសកំហុសដែលប្រព្រឹត្តកន្លង គ្របសង្កត់ហើយនូវខ្ញុំព្រះករុណាទាំងឡាយ តាមដោយខ្ញុំព្រះករុណាទាំងឡាយ ជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស បពិត្រព្រះសង្ឃដ៏ចម្រើន ក្រែងខ្ញុំព្រះករុណាទាំងឡាយ បានធ្វើហើយនូវសេចក្តីល្មើស មិនគោរពដល់ព្រះពុទ្ធជាម្ចាស់ក្តី ដល់ព្រះធម៌ក្តី ដល់ព្រះសង្ឃក្តី ដោយ

កាយក្តី ដោយវាចាក្តី ដោយចិត្តក្តី បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃអត់នូវទោសកំហុសនោះ ដល់ខ្ញុំព្រះករុណាទាំងឡាយ ព្រោះអំពើនៃទោសនោះ ជាសេចក្តីខុសពិត ដើម្បីនឹងបានសង្រួម គឺថានឹងប្រព្រឹត្តឱ្យល្អតទៅក្នុងខាងមុខនោះហោង ។

បើស្រ្តីច្រើននាក់ ត្រូវសូត្របែបនេះ, បើសូត្រលាយបុរស, ស្រ្តីក៏នៅតែសូត្របែបនេះដែរថា ៖

អច្ចយោ នោ ភន្តេ អច្ចគមា យថាពាលា យថាមុឡ្ហា យថាអកុសលា យា មយំ ភន្តេ កាយេន វា វាចាយ វា មនសា វា ពុទ្ធស្ស វា ធម្មស្ស វា សង្ឃស្ស វា អគារវំ អករិម្ហា តាសំ នោ ភន្តេ សង្ឃោ អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយ ។

ប្រែថា បពិត្រព្រះសង្ឃដ៏ចម្រើន ទោសកំហុសដែលប្រព្រឹត្តកន្លង គ្របសង្កត់ហើយនូវខ្ញុំព្រះករុណាទាំងឡាយ តាមដោយខ្ញុំព្រះករុណាទាំងឡាយ ជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស បពិត្រព្រះសង្ឃដ៏ចម្រើន ក្រែងខ្ញុំព្រះករុណាទាំងឡាយ បានធ្វើហើយនូវសេចក្តីល្មើស មិនគោរពដល់ព្រះពុទ្ធជាម្ចាស់ក្តី ដល់ព្រះធម៌ក្តី ដល់ព្រះសង្ឃក្តី ដោយ

កាយក្តី ដោយវាចាក្តី ដោយចិត្តក្តី បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃអត់នូវទោសកំហុសនោះ ដល់ខ្ញុំព្រះករុណាទាំងឡាយ ព្រោះអំពើនៃទោសនោះ ជាសេចក្តីខុសពិត ដើម្បីនឹងបានសង្រួម គឺថានឹងប្រព្រឹត្តឱ្យល្អតទៅក្នុងខាងមុខនោះហោង ។

(បើលំបាកពោលបាលី ពោលតែសម្រាយក៏បាន) ។

លុះបានសូមខមាទោសនឹងព្រះរតនត្រ័យដូច្នេះ រួចហើយគប្បីបញ្ចេញវចីភេទប្តេជ្ញាខ្លួន ជាអ្នកដល់ព្រះត្រៃសរណគមន៍ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរឭកដើម្បីនឹងឱ្យឡើងនាមបញ្ញត្តិជាឧបាសក ឬជាឧបាសិកាក្នុងព្រះពុទ្ធសាសនាតទៅ, ប្តេជ្ញាខ្លួនចំពោះមុខបុគ្គល ឬគណៈ ឬសង្ឃក៏បាន ។

ឯពាក្យសូធ្យប្តេជ្ញាខ្លួនចំពោះព្រះរតនត្រ័យនោះ ក្នុងទីនេះសូមរៀបរៀងតែវិធីប្តេជ្ញាខ្លួនចំពោះមុខព្រះសង្ឃប៉ុណ្ណោះ ។

បើបុរសតែម្នាក់ ត្រូវប្តេជ្ញាដោយពាក្យថា ៖

ឯសាហំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ សង្ឃោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ ។

ប្រែថា បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណាសូមដល់

នូវព្រះដ៏មានព្រះភាគ ដែលទ្រង់បរិនិព្វានទៅ អស់កាលយូរ អង្វែងហើយនោះផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក សូមព្រះសង្ឃជ្រាបនូវខ្ញុំព្រះករុណាថា ជាឧបាសក បានដល់ហើយនូវព្រះរតនត្រ័យជាទីពឹង ទីរឭកស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមរៀងទៅ ។

បើស្ត្រីតែម្នាក់ ត្រូវប្ដេជ្ញាដោយពាក្យថា ៖

**ឯសាហំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសិកំ មំ សង្ឃោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ ។**

ប្រែថា បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណាសូមដល់ នូវព្រះដ៏មានព្រះភាគ ដែលទ្រង់បរិនិព្វានទៅ អស់កាលយូរ អង្វែងហើយនោះផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក សូមព្រះសង្ឃជ្រាបនូវខ្ញុំព្រះករុណាថា ជាឧបាសិកា បានដល់ហើយនូវព្រះរតនត្រ័យជាទីពឹង ទីរឭកស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមរៀងទៅ ។

បើបុរសច្រើននាក់ ត្រូវប្ដេជ្ញាខ្លួនដោយពាក្យបែបនេះ , បើសូធ្យលាយស្ត្រី , បុរសក៏នៅតែសូធ្យបែបនេះដែរថា ៖

**ឯតេ មយំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកេ នោ សង្ឃោ ធារេតុ អជ្ជតគ្គេ បាណុបេតេ សរណំ គតេ**

*ប្រែថា បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមដល់នូវព្រះដ៏មានព្រះភាគ ដែលទ្រង់បរិនិព្វានទៅអស់កាលយូរអង្វែងហើយនោះផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក សូមព្រះសង្ឃជ្រាបនូវខ្ញុំព្រះករុណាទាំងឡាយថាជាឧបាសក បានដល់ហើយនូវព្រះរតនត្រ័យជាទីពឹង ទីរឭកស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមរៀងទៅ ។*

*បើស្ត្រីច្រើននាក់ ត្រូវប្ដេជ្ញាខ្លួនដោយពាក្យបែបនេះ, បើសូធ្យលាយបុរស , ស្ត្រីក៏នៅតែសូធ្យបែបនេះដែរថា ៖*

**ឯតា មយំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសិកាយោ នោ សង្ឃោ ធារេតុ អជ្ជតគ្គេ បាណុបេតា សរណំ គតា**

*ប្រែថា បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមដល់នូវព្រះដ៏មានព្រះភាគ ដែលទ្រង់បរិនិព្វានទៅអស់កាល*

យូរអង្វែងហើយនោះផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក សូមព្រះសង្ឃជ្រាបនូវខ្ញុំព្រះករុណាទាំងឡាយថា ជាឧបាសិកា បានដល់ហើយនូវព្រះរតនត្រ័យជាទីពឹងទីរឭក ស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមរៀងទៅ ។

រួចព្រះសង្ឃត្រូវទទួលថា **សាធុ** ប្រែថា ប្រពៃហើយ ។ បុរសឬស្ត្រី កាលបើបានពោលពាក្យប្តេជ្ញាខ្លួន ជាអ្នកបានដល់ព្រះត្រៃសរណគមន៍ ជាទីពឹងទីរឭកដូច្នេះ រួចហើយ ក៏បាននាមប្បញ្ញត្តិថា "ឧបាសក" ឬ "ឧបាសិកា" ក្នុងខណៈនោះឯង ។

វិធីសូមខមាទោសក្តី វិធីសូមប្តេជ្ញាខ្លួនជាឧបាសកជាឧបាសិកាក្តី បើអ្នកដែលមិនចេះសូធ្យជាបាលី នឹងសូធ្យជាសេចក្តីសម្រាយ តាមភាសារបស់ខ្លួននោះក៏បាន បើចេះសូធ្យទាំងបាលី ទាំងសេចក្តីប្រែសម្រាយផង ដូចបានពោលមកហើយនោះជាការប្រពៃពិត តែកុំសូធ្យតែបាលីទទេ ដោយមិនដឹងថាជាអ្វីនោះឡើយ ព្រោះកិច្ចដែលសូធ្យខមាទោសនិងប្តេជ្ញាខ្លួននោះ ចំពោះយកសទ្ធា គឺសេចក្តីជឿជាក់និងបញ្ញាជាសម្មាទិដ្ឋិដែលដឹងពិត យល់ត្រូវពិតជាប្រមាណ ។

( ចប់បុព្វភាគប្បដិបត្តិតែប៉ុណ្ណេះ )

## ឧបាសកនិទ្ទេស

សម្ដែងអំពីនាមថា ឧបាសក

និងធម៌របស់ឧបាសកផ្សេងៗ មានសីលជាដើម

ជនដែលមាននាមបញ្ញត្តិថា " ឧបាសក " នោះ ដោយហេតុដែលបានចូលទៅជិតដល់នូវព្រះរតនត្រ័យ ជាទីពឹងទីរឭក ដូចពុទ្ធភាសិតដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សម្ដែងចំពោះមហានាមសក្យរាជថា "ម្នាលមហានាម គ្រហស្ថឯណាមួយ បានដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីពឹងទីរឭក គ្រហស្ថនោះឯង បានឈ្មោះថា ឧបាសក បើស្ត្រីហៅថា ឧបាសិកា" ។

ម្យ៉ាងទៀត មានបាលីថា **រតនត្តយំ ឧបាសតីតិ ឧបាសកោ** ជនឯណា ចូលទៅអង្គុយជិតព្រះរតនត្រ័យ ជននោះឈ្មោះថា ឧបាសក ។

អធិប្បាយថា ជនដែលចូលទៅអង្គុយជិតព្រះរតនត្រ័យនោះគឺ មិនមែនជាអ្នកចូលទៅអង្គុយជិតព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជានិច្ច ដោយរូបកាយនោះទេ គឺលោកសង្គ្រោះយកនាមកាយជាប្រមាណ, សូម្បីជននោះ ស្ថិតនៅក្នុងទីឆ្ងាយប៉ុន្មាន

តែមានសន្តានចិត្តប្រព្រឹត្តជាប់នៅក្នុងគុណព្រះរតនត្រ័យជានិច្ច, ចិត្តនោះឱនទៅតោងយកគុណព្រះរតនត្រ័យ ជាទីពឹងទីរឭកជានិច្ចហើយ ជននោះឈ្មោះថា បានចូលទៅអង្គុយជិតព្រះរតនត្រ័យជានិច្ច, បើគ្រាន់តែចូលទៅអង្គុយជិតព្រះពុទ្ធដោយរូបកាយ តែសន្តានចិត្តនោះ ស្ថិតនៅក្នុងទីឆ្ងាយអំពីគុណព្រះរតនត្រ័យ មិនបង្អោនចិត្តទៅក្នុងគុណព្រះរតនត្រ័យទេ ជននោះឈ្មោះថា ស្ថិតនៅឆ្ងាយអំពីគុណព្រះរតនត្រ័យ មិនមែនជា "ឧបាសក ឬឧបាសិកា " ឡើយ ។

## សីលនៃឧបាសក

បញ្ចវិរតិចេតនា គឺចេតនាដែលវៀរចាកវេរាទាំង ៥ ឈ្មោះថាជា "សីលនៃឧបាសក" ដូចពុទ្ធភាសិត ដែលព្រះបរមគ្រូជាម្ចាស់ទ្រង់ត្រាស់ សម្តែងចំពោះមហានាមសក្យរាជថា "ម្នាលមហានាម ឧបាសកឯណា បានវៀរចាក **បាណាតិបាត** គឺមិនសម្លាប់សត្វ ១ វៀរចាក **អទិន្នាទាន** គឺមិនលួចទ្រព្យអ្នកដទៃ ១ វៀរចាក **កាមេសុមិច្ឆាចារ** គឺមិនប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ វៀរចាក **មុសាវាទ** គឺមិននិយាយកុហក ១ វៀរចាក **សុរាមេរយ** គឺមិនផឹកនូវសុរានិងមេរ័យ ១ ឧបាសកនោះ ឈ្មោះថា **ឧបាសកមានសីល** " ។

## អាជីវនៃឧបាសក

កិរិយាលះបង់នូវជំនួញខុស ៥ ប្រការ ហើយប្រកបកិច្ចការចិញ្ចឹមជីវិតដោយត្រឹមត្រូវតាមធម៌ ឈ្មោះថា **"អាជីវនៃឧបាសក"** ដូចមានពុទ្ធប្បញ្ញត្តិ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ហាមចំពោះភិក្ខុទាំងឡាយថា ៖

**បញ្ចិមា ភិក្ខវេ វណិជ្ជា ឧបាសកេន អករណីយា**

ម្នាលភិក្ខុទាំងឡាយ ជំនួញខុសទាំងឡាយ ៥ ប្រការ ឧបាសកមិនគប្បីធ្វើឡើយ ។

ជំនួញខុស ៥ ប្រការនោះគឺ :

១- **សត្ថវណិជ្ជា** ជួញគ្រឿងសស្ត្រាវុធសម្រាប់ប្រហារគឺធ្វើគ្រឿងសស្ត្រាវុធនោះដោយខ្លួនឯង ឬឱ្យអ្នកដទៃគេធ្វើឱ្យ ឬបានមកដោយហេតុឯណាមួយ ហើយលក់នូវគ្រឿងសស្ត្រាវុធនោះ ។

២- **សត្តវណិជ្ជា** ជួញមនុស្ស ។

៣- **មំសវណិជ្ជា** ជួញសាច់ គឺចិញ្ចឹមសត្វទាំងឡាយ មានជ្រូកជាដើម លុះសត្វទាំងឡាយនោះចម្រើនធំឡើង ក៏លក់ឱ្យអ្នកដទៃ ឬជួញសត្វមានជីវិត( ហេតុនៃការសម្លាប់ ) ។

៤. **មជ្ជវណិជ្ជា** ជួញទឹកស្រវឹង គឺផ្សំគ្រឿងស្រវឹងឯណាមួយឱ្យកើតឡើងជាទឹកស្រវឹងដោយខ្លួនឯង ឬទិញគេយកមកហើយលក់នូវទឹកស្រវឹងនោះ ។

៥. **វិសវណិជ្ជា** ជួញថ្នាំពិស គឺចាត់ចែងផ្សំថ្នាំពិសឱ្យកើតឡើងដោយខ្លួនឯង ឬឱ្យគេផ្សំឱ្យ ឬបានមកដោយហេតុឯណាមួយ ហើយលក់នូវថ្នាំពិសនោះ ។

ឧបាសកកាលបើវៀរចាកជំនួញខុសទាំង ៥ ប្រការនេះហើយ បានប្រតិបត្តិការចិញ្ចឹមជីវិតដោយធម៌ឈ្មោះថា **មានអាជីវដោយប្រពៃតាមធម៌** នោះគឺជាអ្នកវៀរចាកការបោកបញ្ឆោត ឬបន្លំដោយជញ្ជីង បញ្ឆោតដោយមាស បញ្ឆោតដោយរង្វាល់រង្វាស់ បន្ទុសបំភាន់ បញ្ឆោតបោកប្រាស និងបន្លំដោយរបស់ប្លមវៀរចាកកិរិយាកាត់នូវអវយវៈមានដៃជាដើម សម្លាប់ ចងធ្វើមនុស្សឱ្យវង្វេងផ្លូវ ប្លន់ កំហែងយកទ្រព្យ ។

កាលបើសន្សំកសាងកុសលកម្មយ៉ាងនេះ លុះបែកធ្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ ក៏បានទៅកើតក្នុងស្ថានសុគតិសួគ៌ទេវលោក រមែងគ្របសង្កត់នូវទេវតាឯទៀតដោយហេតុ ១០ ប្រការគឺ អាយុទិព្វ ១ សម្បុរទិព្វ ១ យសទិព្វ ១ សុខទិព្វ ១

អធិបតីទិព្វ ១ រូបទិព្វ ១ សំឡេងទិព្វ ១ ក្លិនទិព្វ ១ រសទិព្វ ១ សម្ផស្សទិព្វ ១ ។

លុះច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈទាំងឡាយពីរនេះ គឺជាអ្នកមានធ្មេញជិតស្និទ្ធល្អ ១ មានចង្កូម (ទាំង ៤) សស្អាត ១ ។

## វិបត្តិនៃឧបាសក

ធម្មជាតដែលញ៉ាំងសីល និងអាជីវធម៌នៃឧបាសកឱ្យវិនាស ឈ្មោះថា **វិបត្តិ** ។ វិបត្តិនោះមាន ៥ យ៉ាងគឺ :

១- អស្សទ្ធោ ហោតិ ឧបាសកមិនជឿគុណព្រះរតនត្រ័យ ។

២- ទុស្សីលោ ហោតិ ឧបាសកទ្រុស្តសីល ។

៣- កោតុហលមង្គលិកោ ហោតិ ឧបាសកប្រកបដោយមង្គលភ្ញាក់ផ្អើល ។

៤- មង្គលំ បច្ចេតិ នោ កម្មំ ឧបាសកប្រកាន់ជឿថា មង្គលមាន ឬក្សពារវេលាជាដើមឱ្យផល មិនប្រកាន់ជឿថា កម្មជាកុសលនិងអកុសលឱ្យផលឡើយ ។

៥- ឥតោ ច ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ តត្ថ ច

បុព្វការំ ករោតិ ឧបាសកស្វែងរកតែទក្ខិណេយ្យបុគ្គល គឺបដិគ្គាហកៈ អ្នកទទួលទានខាងក្រៅព្រះពុទ្ធសាសនា ហើយធ្វើនូវទានដល់ទក្ខិណេយ្យបុគ្គល ខាងក្រៅព្រះពុទ្ធសាសនានោះ ។

ឧបាសកឯណាប្រកបដោយវិបត្តិ ៥ យ៉ាងនេះ ត្រង់វិបត្តិណាមួយហើយ, ឧបាសកនោះឈ្មោះថា "ឧបាសកចណ្ឌាល" គឺឧបាសកដូចជាមនុស្សថោកទាប ហើយកាចព្រហើនមិនក្រែងច្បាប់ផង, ឈ្មោះថា "ឧបាសកមលៈ" គឺឧបាសកមានធម៌ជាមន្ទិលសៅហ្មងផង, ឈ្មោះថា "ឧបាសកបដិកិដ្ឋៈ" គឺឧបាសកដែលអ្នកប្រាជ្ញទាំងឡាយ លោកតិះដៀលផង ។

## សម្បត្តិនៃឧបាសក

ធម្មជាតដែលញាំងសីល និងអាជីវធម៌នៃឧបាសកឱ្យបរិបូណ៌ឱ្យបរិសុទ្ធប្រពៃឈ្មោះថា "សម្បត្តិ" ។ សម្បត្តិនោះមាន ៥ យ៉ាងគឺ :

១- សទ្ធោ ហោតិ ឧបាសកមានសេចក្តីជឿជាក់ច្បាស់ក្នុងគុណព្រះរតនត្រ័យ ។

២- សីលវា ហោតិ ឧបាសកមានសីល ។

៣- ន កោតុហលមង្គលិកោ ហោតិ ឧបាសកមិនប្រកប ដោយមង្គលភ្ញាក់ផ្អើល ។

៤- កម្មំ បច្ចេតិ នោ មង្គលំ ឧបាសកប្រកាន់ជឿថា កម្ម ជាកុសលនិងអកុសលឱ្យផល មិនប្រកាន់ជឿថា មង្គលមានឫក្សពារ វេលាជាដើមឱ្យផលឡើយ ។

៥- ន ឥតោ ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ ឥធ ច បុព្វការំ ករោតិ ឧបាសកមិនស្វែងរកទក្ខិណេយ្យ បុគ្គលគឺ បដិគ្គាហកៈ អ្នកទទួលទានខាងក្រៅព្រះពុទ្ធ សាសនាឡើយ ហើយធ្វើទានតែក្នុងទក្ខិណេយ្យបុគ្គល ក្នុងព្រះពុទ្ធសាសនានេះ ។

ឧបាសកឯណា ប្រកបដោយសម្បត្តិ ៥ យ៉ាងនេះហើយ ឧបាសកនោះ ឈ្មោះថា ឧបាសករតនៈ គឺ ឧបាសកដូចជា រតនវត្ថុមានកែវជាដើមផង ។

ឈ្មោះថា ឧបាសកបទុមៈ គឺឧបាសកដូចជាផ្កាឈូកមាន ពណ៌ក្រហមផង ។

ឈ្មោះថា ឧបាសកបុណ្ឌរីកៈ គឺឧបាសកដូចជាផ្កាឈូក មានពណ៌សផង ។

# គុណនៃឧបាសក

ធម៌សម្រាប់ឧបាសក ឧបាសិកាប្រតិបត្តិគ្រប់រូប ដើម្បីនឹងឱ្យកើត ឱ្យចម្រើននូវសម្បត្តិទាំងពួង ឈ្មោះថាគុណ ។ គុណនេះជារបស់ឧបាសក ឧបាសិកា ហៅថា "ឧបាសកគុណ" មាន ១០ យ៉ាងគឺ :

១- **សង្ឃេន សទ្ធឹ សមានសុខទុក្ខោ ហោតិ** ឧបាសកអ្នករួមសេចក្ដីសុខទុក្ខ មួយអន្លើដោយភិក្ខុសង្ឃ គឺថាបើភិក្ខុសង្ឃមានសេចក្ដីសុខ ក៏ត្រេកអរ បើភិក្ខុសង្ឃមានសេចក្ដីទុក្ខព្រួយ ក៏ព្រួយជាមួយផង ។

២- **កាយិកវាចសិកញ្ច សុរក្ខិតំ ហោតិ** ឧបាសកមានកាយកម្ម និងវចីកម្មរក្សាហើយដោយប្រពៃ ។

៣- **ធម្មោ អធិបតេយ្យោ ហោតិ** ឧបាសកមានធម៌ជាអធិបតី គឺថាបើប្រព្រឹត្តធ្វើអ្វីៗ រមែងកាន់យកធម៌ ជាធំជាទីតាំង ជាទីអាងមាំ មិនឱ្យខុស មិនឱ្យឃ្លៀងឃ្លាតអំពីធម៌ឡើយ ។

៤- **យថាថាមេន សំវិភាគរតោ ច ហោតិ** ឧបាសកជាអ្នកត្រេកអរក្នុងការបរិច្ចាគទាន តាមសមគួរដល់កម្លាំងនៃខ្លួនគឺធ្វើទានតាមសមគួរដល់ទ្រព្យតិចនិងច្រើន បើមានតិចក៏ធ្វើតិច បើមានច្រើនក៏ធ្វើច្រើន មិនមានមច្ឆរិយធម៌ គ្របសង្កត់សន្តានចិត្តឡើយ ។

៥- **ជិនសាសនំ ជានិតុញ្ច វាយមតិ** ឧបាសកឧស្សាហ៍ព្យាយាមដើម្បីនឹងឱ្យដឹងច្បាស់នូវសាសនៈ គឺពាក្យប្រៀនប្រដៅ ពាក្យបណ្ដាំនៃព្រះជិនស្រី ។

៦- **សម្មាទិដ្ឋិកោ ច ហោតិ** ឧបាសកជាសម្មាទិដ្ឋិ គឺមានប្រាជ្ញាឃើញត្រូវតាមសេចក្ដីពិត ។

៧- **អបគតោ កោតុហលមង្គលិកោ ច ហោតិ** ឧបាសកប្រាសចាកមង្គលភ្ញាក់ផ្អើល ហើយជាអ្នកមិនប្រកាន់ជឿថា មង្គល មានឫក្សពារវេលាជាដើមឱ្យផលឡើយ ប្រកាន់ជឿតែកម្មជាកុសលនិងអកុសលថាឱ្យផល ។

៨- **ជីវិតហេតុបិ អញ្ញំ សត្ថារំ ន ឧទ្ទិសតិ** ឧបាសកបើទុកជាមានហេតុគួរដល់នូវសេចក្ដីវិនាសជីវិតក្ដី ក៏

មិនលះបង់ព្រះរតនត្រ័យ ហើយត្រឡប់ទៅកាន់យកមនុស្សដទៃជាគ្រូអាចារ្យជាទីពឹងរបស់ខ្លួនថា ប្រសើរជាងព្រះរតនត្រ័យនោះឡើយ ។

៩- សមគ្គារាមោ ច ហោតិ ឧបាសកមានសេចក្ដីត្រេកអរក្នុងសាមគ្គីធម៌ គឺសេចក្ដីព្រមព្រៀងគ្នា ។

១០- សាសនេ ចរតិ ឧបាសកប្រព្រឹត្តល្អក្នុងព្រះពុទ្ធសាសនា គឺប្រព្រឹត្តតាមតែធម៌វិន័យព្រះពុទ្ធសាសនា ។

ឧបាសកគុណទាំង ១០ យ៉ាងនេះ ឧបាសក ឧបាសិកា គប្បីប្រព្រឹត្តតាមកុំឱ្យឃ្លៀងឃ្លាតឡើយ ព្រោះជាធម៌អាចនឹងធ្វើចិត្តឧបាសក ឧបាសិកាអ្នកប្រព្រឹត្តឱ្យសុចរិតផូរផង់ក្នុងព្រះពុទ្ធសាសនា ហើយឱ្យបានជាបច្ច័យនៃនិព្វានសម្បត្តិផង ។

"ចប់ឧបាសកនិទ្ទេសដោយសង្ខេបប៉ុណ្ណោះ"

# និច្ចសីល (សីល ៥)

## ការសមាទានសិក្ខាបទមានពីរយ៉ាង

គប្បីជ្រាបថា ការសមាទានសិក្ខាបទនោះមានពីរគឺ :

១- សមាទានកាន់យកដោយខ្លួនឯង ។

២- សមាទានកាន់យកអំពីសំណាក់អ្នកដទៃ ។

សេចក្ដីថា ការសមាទានកាន់យកនូវសីល ដោយអធិដ្ឋានថា "ខ្ញុំ/អញ អធិដ្ឋាននូវសីលទាំង ៥ " ដោយខ្លួនឯងតែម្ដង កាលបើបានអធិដ្ឋានថា **បញ្ច សីលានិ អធិដ្ឋាមិ** ដូច្នេះហើយ ឈ្មោះថា បានសមាទានដោយខ្លួនឯងស្រេចហើយ ។

ការសមាទានកាន់យកអំពីសំណាក់អ្នកដទៃនោះ បានដល់ចូលខ្លួនទៅអង្គុយក្នុងសំណាក់ទីជិតអ្នកដទៃ ហើយតាំងវាចាសមាទានថា **បញ្ចសីលានិ សមាទិយាមិ** ដូច្នេះក៏បាន ។

សូមទាញយកន័យសមាទានដែលមាននៅក្នុងគម្ពីរបរម្ថ-ជោតិកា ត្រង់**អាទានតោ** មកបន្ថែមទៀតថា ៖

**អាទានតោតិ បាណាតិបាតាតិតោ វេរមណី សិក្ខាបទានិ ចេតានិ សាមណេរេន ភិក្ខុស្ស សន្តិកេ**

សមាទិន្នានេវ ហោន្តិ ។

ត្រង់បទបាលីថា **អាទានតោ** នេះលេចសេចក្តីបន្ទិចថា សិក្ខាបទទាំងឡាយ មានបាណាតិបាតា **វេរមណី** **សិក្ខាបទំ** ជាដើម ចំណែកសាមណេរ ឱ្យសមាទានក្នុងសំណាក់ភិក្ខុនេះជាកម្រិត ( ឃើញប្លែកគ្នាពីគ្រហស្ថពិត ) ។

នៅក្នុងបរមត្ថទីបនី ឃើញមានលេចសេចក្តីបន្តិចដែរថា ៖

សមាទានតោ អញ្ញស្ស គរុដ្ឋានីយស្ស សន្តិកេ តំ អលភន្តេន សយមេវ បញ្ច សីលានិ ឯកជ្ឈំ ធាដិយេក្កំ វា សមាទិយន្តេន សមាទិន្នានិ ហោន្តិ ។

ត្រង់បទបាលីថា **សមាទានតោ** នេះលេចសេចក្តីថា គ្រហស្ថកាលបើរកបុគ្គលជាទីគោរពមិនបាន ឬថាមិនអាចចូលទៅកាន់សំណាក់បុគ្គលដទៃ ដែលគួរជាទីគោរពនោះបានទេ នឹងតាំងសមាទាននូវបញ្ចសីលជាឯកជ្ឈៈ ឬជាបច្ចេកៈដោយខ្លួនឯងបានពិត សិក្ខាបទទាំងឡាយបានឈ្មោះថា **សមាទានហើយ** ។

"បន្ថែមពាក្យថា ការសមាទានរបស់ឧបាសក ឧបាសិកាជាគ្រហស្ថនោះ បើរកបុគ្គលដទៃដែលគួរគោរពមិនបានទេ គប្បី

តាំងសមាទានសីល ដោយខ្លួនឯងទៅចុះ ទោះបីសមាទានជាឯកជ្ឈៈក៏បាន ជាបច្ចេកៈក៏បាន យ៉ាងនេះ បានឈ្មោះថា **សមាទានហើយ**" ។

ក៏សិក្ខាបទពួកនេះមាន **បាណាតិបាតា វេរមណី សិក្ខាបទំ** ជាដើម សាមណេរសមាទានក្នុងសំណាក់ភិក្ខុប៉ុណ្ណោះ ទើបជាការសមាទាន ចំណែកឧបាសកសមាទានខ្លួនឯងក្ដី សមាទានក្នុងសំណាក់របស់អ្នកដទៃក្ដី ក៏ជាការសមាទានហើយ សមាទានរួមគ្នាក្ដី សមាទានផ្សេងគ្នាក្ដី ក៏ជាការសមាទានហើយ តែផ្សេងគ្នាយ៉ាងណាសោត បុគ្គលសមាទានរួមក៏មានវិរតិមួយ មានចេតនាមួយប៉ុណ្ណោះ តែប្រាកដថា ចេតនាពួកនោះ មានដល់ទៅ ៥ ដោយអំណាចកិច្ចគឺនាទី ។ ចំណែកបុគ្គលដែលបានសមាទានផ្សេងគ្នា ក៏គប្បីជ្រាបថា មានវិរតិ ៥ ចេតនាក៏ ៥ ក្នុងខនេះ គប្បីជ្រាបវិនិច្ឆ័យ ដោយការសមាទាន ដោយប្រការដូច្នេះ ។

## ពោលអំពីការដាច់

ក្នុងខនេះ សម្រាប់សាមណេរទាំងឡាយ កាលសិក្ខាបទមួយដាច់គ្រប់សិក្ខាបទក៏ជាការដាច់ ព្រោះសិក្ខាបទទាំងនោះ ជាឋានទីតាំងនៃបារាជិករបស់សាមណេរពួកនោះ ដោយសិក្ខាបទរបស់សាមណេរកន្លងល្មើសនោះឯង ក៏មានកម្មតជាប់គ្នាមក ។

តែសម្រាប់គ្រហស្ថ កាលសីលមួយដាច់ ក៏ដាច់តែមួយប៉ុណ្ណោះ ព្រោះសីលរបស់គ្រហស្ថពួកនោះ មានអង្គ ៥ រមែងសម្បូរម្យ៉ាងដោយការសមាទានសីលនោះប៉ុណ្ណោះ ។ តែអាចារ្យមួយពួកទៀតពោលថា បណ្តាសីលដែលគ្រហស្ថសមាទានមួយៗ ( បច្ចេកសមាទាន )កាលសីលមួយដាច់ ក៏ដាច់តែមួយប៉ុណ្ណោះ តែសីលដែលគ្រហស្ថសមាទានរួមគ្នា បែបឯកជ្ឈសមាទានគឺសមាទានយ៉ាងនេះថា "**ឥមានិ បញ្ច សិក្ខាបទានិ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទទាំងឡាយប្រកបដោយអង្គ ៥ នេះ" កាលសីលមួយដាច់ សីលសូម្បីដ៏សេសក៏ដាច់គ្រប់សិក្ខាបទ ។ ព្រោះហេតុអ្វី ? ព្រោះសីលដែលសមាទានមិនដាច់ ដោយសីលដែលគ្រហស្ថកន្លងល្មើសនោះឯងក៏មានសេចក្តីពាក់ព័ន្ធដោយកម្ម ក្នុងសេចក្តីនេះ គប្បីជ្រាបវិនិច្ឆ័យសូម្បីដោយការដាច់ ដោយប្រការដូច្នេះ ។

## វិធីសមាទាននិច្ចសីល បែបបច្ចេកសមាទាន

ពុទ្ធសាសនិកជន ដែលបានដល់ព្រះត្រៃសរណគមន៍ បានឡើង នាមប្បញ្ញត្តិជាឧបាសកឬជាឧបាសិកាហើយ កាលបើនឹងសមាទាននូវនិច្ចសីល គឺសីល ៥ ជាបច្ចេកសមាទាន អំពីបុគ្គលដទៃគឺភិក្ខុ ឬសាមណេរនោះ គប្បីសូធ្យនមស្ការថ្វាយបង្គំរំឭកដល់គុណព្រះរតនត្រ័យជាមុន រួចហើយត្រូវសូមនូវនិច្ចសីល ព្រមទាំងព្រះត្រៃសរណគមន៍ ចំពោះនឹងភិក្ខុ ឬសាមណេរដែលខ្លួននឹងសមាទាននោះ ។

អ្នកសមាទានម្នាក់ ត្រូវសូធ្យថា ៖

**ឱកាស អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ យាចាមិ ។**

**ទុតិយម្បិ អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ យាចាមិ ។**

**តតិយម្បិ អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ យាចាមិ ។**

ប្រែថា សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា សូមនូវសីលទាំងឡាយ ៥ មួយអន្លើដោយព្រះត្រៃ-

សរណគមន៍ ដើម្បីប្រយោជន៍ទឹងរក្សាផ្សេងៗគ្នា ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា សូមនូវសីលទាំងឡាយ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍ទឹងរក្សាផ្សេងៗ គ្នា, ជាគម្រប់ពីរដងផង ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា សូមនូវសីលទាំងឡាយ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍ទឹងរក្សាផ្សេងៗ គ្នា ជាគម្រប់បីដងផង ។

ឬទឹងសូមថា ៖

ឱកាស អហំ ភន្តេ វិសុំ វិសុំ រក្ខណត្ថាយ តិសរណេន សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ យាចាមិ អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ ។

ទុតិយម្បិ អហំ ភន្តេ វិសុំ វិសុំ រក្ខណត្ថាយ តិសរណេន សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ យាចាមិ អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ ។

តតិយម្បិ អហំ ភន្តេ វិសុំ វិសុំ រក្ខណត្ថាយ តិសរណេន សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ យាចាមិ អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ ។

ប្រែថា សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា សូមនូវនិច្ចសីលប្រកបព្រមដោយអង្គ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នា, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណា,

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា សូមនូវនិច្ចសីលប្រកបព្រមដោយអង្គ ៥ មួយអន្លើដោយព្រះត្រៃ-សរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា, ជាគម្រប់ពីរដងផង, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណា,

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា សូមនូវនិច្ចសីលប្រកបព្រមដោយអង្គ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា ជាគម្រប់បីដងផង, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណា ។

អ្នកសមាទានច្រើននាក់ ត្រូវសូត្រថា ៖

ឱកាស មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ យាចាម ។

ទុតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ យាចាម ។

តតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ យាចាម ។

ប្រែថា សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវសីលទាំងឡាយ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា,

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវសីលទាំងឡាយ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា, ជាគម្រប់ពីរដងផង ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវសីលទាំងឡាយ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា ជាគម្រប់បីដងផង ។

ឬនឹងសូមថា ៖

ឧកាស មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ យាចាម អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ ។

ទុតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ យាចាម អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ ។

តតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ យាចាម អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ ។

*ប្រែថា សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវនិច្ចសីលប្រកបព្រមដោយអង្គ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណាទាំងឡាយ,*

*បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូម*

នូវនិច្ចសីលប្រកបព្រមដោយអង្គ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា ជាគម្រប់ពីរដងផង, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្ដីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណាទាំងឡាយ ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវនិច្ចសីលប្រកបព្រមដោយអង្គ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា ជាគម្រប់បីដងផង, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្ដីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណាទាំងឡាយ ។

( សូមដូច្នេះក៏បាន តាមសេចក្ដីពេញចិត្តរបស់អ្នកសូម )

លោកអ្នកឱ្យសីល ត្រូវសូធ្យ **នមោ** ៣ ចប់ ហើយឱ្យព្រះត្រៃសរណគមន៍ និងនិច្ចសីល, អ្នកសមាទានត្រូវទទួលថាតាមលោកដោយបញ្ចេញវចីភេទ ឱ្យច្បាស់លាស់, កុំទទួលខ្សឹបៗ ។

លោកសូត្រថា ៖

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

( សូត្រ ៣ ដង )

ប្រែថា រីកិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

ពុទ្ធំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក ។

ធម្មំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរឭក ។

សង្ឃំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក ។

ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក ជាគម្រប់ពីរដងផង ។

ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរឭក ជាគម្រប់ពីរដងផង ។

**ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក ជាគម្រប់ពីរដងផង ។

**តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក ជាគម្រប់បីដងផង

**តតិយម្បិ ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរឭក ជាគម្រប់បីដងផង ។

**តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក ជាគម្រប់បីដងផង ។

ហើយលោកថា **តិសរណគ្គហណំ បរិបុណ្ណំ** ( ប្រែថា ) កិរិយាកាន់យកនូវព្រះត្រៃសរណគមន៍បរិបូណ៌តែប៉ុណ្ណេះ ។ អ្នកសមាទានត្រូវទទួលថា **អាម ភន្តេ** ( ប្រែថា ) ករុណាលោកម្ចាស់ ។ ហើយលោកឱ្យនិច្ចសីលជាបច្ចេកសមាទានថា ៖

**បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វ មានជីវិតឱ្យធ្លាក់ចុះកន្លងគឺសម្លាប់សត្វ ។

**អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុ

វៀរចាកកិរិយាកាន់យកនូវវត្ថុ ដែលគេមិនបានឱ្យដោយកាយ ឬដោយវាចា ។

**កាមេសុ មិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

**មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

**សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ។

រួចហើយលោកអ្នកឱ្យសីល លោកពោលដាស់តឿនក្រើនរំឭកថា ៖

**ឥមានិ បញ្ច សិក្ខាបទានិ សាធុកំ កត្វា អប្បមាទេន និច្ចកាលំ សម្មារក្ខិតព្វំ** ប្រែថា អ្នក/អ្នកទាំងឡាយ គប្បីធ្វើនូវសិក្ខាបទទាំងឡាយ ៥ នេះឱ្យប្រពៃ ត្រូវរក្សា

ឱ្យល្អអស់កាលជានិច្ចដោយសេចក្តីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។

បើអ្នកសមាទានតែម្នាក់ត្រូវថា "អ្នក" បើគ្នាច្រើនត្រូវថា "អ្នកទាំងឡាយ" ។

អ្នកសមាទានត្រូវទទួលថា អាម ភន្តេ ( ប្រែថា ) ករុណាលោកម្ចាស់ ។

ហើយលោកសម្តែងអានិសង្សសីលឱ្យស្តាប់ តទៅទៀតថា ៖

**សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា**

**សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ**

( ប្រែថា ) សត្វទាំងឡាយទៅកាន់ស្ថានសួគ៌បាន ក៏ព្រោះសីល, សត្វទាំងឡាយបានបរិបូណ៌ដោយភោគៈ ក៏ព្រោះសីល, សត្វទាំងឡាយបានទៅកាន់ទីរំលត់ទុក្ខពោលគឺព្រះនិព្វាន ក៏ព្រោះសីល, ព្រោះហេតុនោះ បុគ្គលជាសប្បុរស គប្បីជម្រះនូវសីលឱ្យបរិសុទ្ធ កុំឱ្យសៅហ្មងឡើយ ។

អ្នកសមាទានត្រូវទទួលថា សាធុ ប្រែថា ប្រពៃហើយ ។

" ចប់វិធីសមាទាននិច្ចសីលជាបច្ចេកសមាទាន តែប៉ុណ្ណេះ "

## វិធីសមាទាននិច្ចសីល បែបឯកជ្ឈសមាទាន

*អ្នកសមាទានម្នាក់ ត្រូវសូធ្យថា ៖*

ឱកាស អហំ ភន្តេ តិសរណេន សហ ឯកជ្ឈំ កត្វា បញ្ចង្គសមន្នាគតំ និច្ចសីលំ យាចាមិ អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ ។

ទុតិយម្បិ អហំ ភន្តេ តិសរណេន សហ ឯកជ្ឈំ កត្វា បញ្ចង្គសមន្នាគតំ និច្ចសីលំ យាចាមិ អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ ។

តតិយម្បិ អហំ ភន្តេ តិសរណេន សហ ឯកជ្ឈំ កត្វា បញ្ចង្គសមន្នាគតំ និច្ចសីលំ យាចាមិ អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ ។

*ប្រែថា សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា សូមនូវនិច្ចសីល ប្រកបព្រមដោយអង្គ ៥ ធ្វើឱ្យជាឯកជ្ឈៈ គឺសមាទានរួមតែម្ដង មួយអន្លើដោយព្រះត្រៃសរណគមន៍ បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្ដីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណា ។*

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា សូមនូវនិច្ចសីលប្រកបព្រមដោយអង្គ ៥ ធ្វើឱ្យជាឯកជ្ឈៈ គឺសមាទានរួមតែម្ដងមួយអន្លើដោយព្រះត្រៃសរណគមន៍ ជាគម្រប់ពីរដងផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្ដីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណា ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា សូមនូវនិច្ចសីលប្រកបព្រមដោយអង្គ ៥ ធ្វើឱ្យជាឯកជ្ឈៈ គឺសមាទានរួមតែម្ដងមួយអន្លើដោយព្រះត្រៃសរណគមន៍ ជាគម្រប់បីដងផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្ដីអនុគ្រោះឱ្យនូវសីលដល់ខ្ញុំព្រះករុណា ។

អ្នកសមាទានច្រើននាក់ ត្រូវសូមថា ៖

ឱកាស មយំ ភន្តេ តិសរណេន សហ ឯកជ្ឈំ កត្វា បញ្ចង្គសមន្នាគតំ និច្ចសីលំ យាចាម អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ ។

ទុតិយម្បិ មយំ ភន្តេ តិសរណេន សហ ឯកជ្ឈំ កត្វា បញ្ចង្គសមន្នាគតំ និច្ចសីលំ យាចាម អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ ។

**តតិយម្បិ មយំ ភន្តេ តិសរណេន សហ ឯកជ្ឈំ កត្វា បញ្ចង្គសមន្នាគតំ និច្ចសីលំ យាចាម អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ ។**

*ប្រែថា សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវនិច្ចសីល ប្រកបព្រមដោយអង្គ ៥ ធ្វើឱ្យជាឯកជ្ឈៈ គឺសមាទានរួមតែម្តង មួយអន្លើដោយព្រះត្រៃសរណគមន៍ បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណាទាំងឡាយ ។*

*បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវនិច្ចសីល ប្រកបព្រមដោយអង្គ ៥ ធ្វើឱ្យជាឯកជ្ឈៈ គឺសមាទានរួមតែម្តង មួយអន្លើដោយព្រះត្រៃសរណគមន៍ ជាគម្រប់ពីរដងផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណាទាំងឡាយ ។*

*បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវនិច្ចសីល ប្រកបព្រមដោយអង្គ ៥ ធ្វើឱ្យជាឯកជ្ឈៈ គឺសមាទានរួមតែម្តង មួយអន្លើដោយ ព្រះត្រៃសរណគមន៍ ជាគម្រប់បីដងផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវ*

សេចក្ដីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណាទាំងឡាយ ។

រួចលោកអ្នកឱ្យសីល ត្រូវតាំង នមោ ៣ ចប់ រួចហើយឱ្យព្រះត្រៃសរណគមន៍, អ្នកសមាទានត្រូវទទួលថាតាមលោក, រួចលោកប្រាប់អំពីកិច្ចកាន់យកព្រះត្រៃសរណគមន៍ ដូចក្នុងវិធីបច្ចេកសមាទានខាងដើម រួចហើយលោកឱ្យនូវនិច្ចសីលជាឯកជ្ឈសមាទានថា ៖

**បញ្ចង្គសមន្នាគតំ និច្ចសីលំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវនិច្ចសីលដែលប្រកបដោយអង្គ ៥, ឬថា **បញ្ចសីលានិ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសីលទាំងឡាយ ៥ ដូច្នេះ ។ អ្នកសមាទានត្រូវថាតាមលោក ៣ ដង, រួចលោកពោលដាស់តឿនក្រើនរំលឹកថា ៖

**ឥមំ បញ្ចង្គសមន្នាគតំ និច្ចសីលំ សាធុកំ**
**កត្វា អប្បមាទេន និច្ចកាលំ សម្មារក្ខិតព្វំ ។**

ប្រែថា អ្នក/អ្នកទាំងឡាយ គប្បីធ្វើនូវនិច្ចសីល ប្រកបព្រមដោយអង្គ ៥ នេះឱ្យប្រពៃ គឺត្រូវរក្សាឱ្យល្អអស់កាលជានិច្ចដោយសេចក្ដីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។

អ្នកសមាទានត្រូវទទួលថា **អាម ភន្តេ** ករុណាលោក

ម្ចាស់ ។

ហើយលោកសម្តែងអានិសង្សសីលឱ្យស្តាប់តទៅទៀតថា ៖

សីលេន សុគតី យន្តិ សីលេន ភោគសម្បទា

សីលេន និព្វុតី យន្តិ តស្មា សីលំ វិសោធយេ

(ប្រែថា) សត្វទាំងឡាយទៅកាន់ស្ថានសួគ៌បាន ក៏ព្រោះសីល, សត្វទាំងឡាយបានបរិបូណ៌ដោយភោគៈ ក៏ព្រោះសីល, សត្វទាំងឡាយបានទៅកាន់ទីរំលត់ទុក្ខពោលគឺព្រះនិព្វាន ក៏ព្រោះសីល, ព្រោះហេតុនោះ បុគ្គលជាសប្បុរស គប្បីជម្រះនូវសីលឱ្យបរិសុទ្ធ កុំឱ្យសៅហ្មងឡើយ ។

អ្នកសមាទានត្រូវទទួលថា **សាធុ** ប្រែថា ប្រពៃហើយ ។

សមាទានប៉ុណ្ណេះ ក៏ជាការស្រេច មិនបាច់សូធ្យញែកឈ្មោះសិក្ខាបទទាំង ៥ រាយមួយម្តងៗ ដូចបច្ចេកសមាទាននោះឡើយ សមាទានប៉ុណ្ណេះហើយ ត្រូវរក្សាដោយតាំងវិរតិចេតនាវៀរចាកឱ្យគ្រប់សិក្ខាបទ ក្នុងនិច្ចសីលដែលខ្លួនបានសមាទានហើយនោះ ។

"ចប់ វិធីសមាទាននិច្ចសីលជាឯកជ្ឈសមាទានតែប៉ុណ្ណេះ"

## ឧបោសថសីល (សីល ៨)

ឧបោសថ មានអង្គ ៣ គឺ :

- កាល បានដល់ កាល គឺថ្ងៃដែលត្រូវរក្សា
- ចេតនា បានដល់ ការវៀរចាកគ្រប់សិក្ខាបទទាំង ៨
- វចីភេទ បានដល់ ការបញ្ចេញវាចាឱ្យច្បាស់ៗ ។

នៅក្នុងគម្ពីរបរមត្ថទីបនីភាគ ៣ ចែងថា ៖

តត្ថ បកតិប្បដិជាគរវសេន ទុវិធំ ហោតិ ឧបោសថ-កម្មំ បណ្ដាកម្មទាំងឡាយនោះ ឧបោសថកម្មមានពីរយ៉ាងគឺ :

- ដោយអំណាចបកតិឧបោសថ ១
- ដោយអំណាចបដិជាគរឧបោសថ ១ ។

## បកតិឧបោសថ

ចំណែកកាលដែលនឹងរក្សាបកតិឧបោសថនោះ ឧបាសក ឧបាសិកា អ្នករក្សាត្រូវដឹងថា តើថ្ងៃណាជាថ្ងៃរក្សាឧបោសថ ? លុះដឹងកាលដែលត្រូវរក្សាហើយ គប្បីរក្សាតាមកាលនោះចុះ ។

នៅក្នុងគម្ពីរបរមត្ថទីបនី និងគម្ពីរបរមត្ថជោតិកា អដ្ឋកថា

ខុទ្ទកនិកាយ សុត្តនិបាត ត្រង់ធម្មិកសូត្រថែងថា ៖

ឥធនេ្ត្ត សន្និដ្ឋានំ បញ្ចមី អដ្ឋមី ចាតុទ្ទសី
បណ្ណរសីតិ ជុណ្ហបក្ខេ ចត្តារោ តថា កាឡបក្ខេតិ
មាសស្ស អដ្ឋទិវសា បកតិឧបោសថស្ស កាលោ

ក្នុងកាលនៃបកតិឧបោសថនេះ មានកំណត់ដូច្នេះ កាល នៃបកតិឧបោសថក្នុងមួយខែមាន ៨ ថ្ងៃគឺ ៤ ថ្ងៃ ក្នុងជុណ្ហបក្ខ (ខាងខ្នើត) ពោលគឺថ្ងៃ ៥ កើត, ៨ កើត, ១៤ កើត, និង ១៥ កើត, ក្នុងកាឡបក្ខ (ខាងរនោច) ក៏មាន ៤ ថ្ងៃដូចគ្នា (គឺថ្ងៃ ៥ រោច, ៨ រោច, ១៤ រោច, និងថ្ងៃ ១៥ រោច ) (បើខែខ្វះត្រង់ថ្ងៃ ១៤ រោច ថយមកថ្ងៃ ១៣ រោច, ១៥ រោច ថយមកថ្ងៃ ១៤ រោចវិញ) តែនៅក្នុងព្រះពុទ្ធដីកា របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ (សុត្តនិបាត) ទ្រង់សម្តែងថា ៖

តតោ ច បក្ខស្សុបោសថំ
ចាតុទ្ទសី បញ្ចទសិញ្ច អដ្ឋមី
បាដិហារិកបក្ខញ្ច បសន្នមានសោ
អដ្ឋង្គុបេតំ សុសមត្តរូបំ ។

ព្រោះហេតុនោះ អ្នកចូរមានចិត្តជ្រះថ្លា រក្សាឧបោសថដែលប្រកបដោយអង្គ ៨ ឱ្យមានសភាពពេញលេញល្អអស់ថ្ងៃទី ១៤ ទី ១៥ និងថ្ងៃទី ៨ នៃបក្ខផង អស់បាដិហារិកបក្ខផង ។

តាមព្រះពុទ្ធដីកានេះឃើញថា កាលនៃបកតិឧបោសថខាងខ្នើតគឺ ថ្ងៃ ១៤ កើត, ១៥ កើត, និងថ្ងៃ ៨ កើត, ខាងរនោចគឺថ្ងៃ ១៤ រោច, ១៥ រោច, និងថ្ងៃ ៨ រោចប៉ុណ្ណោះ ។

តែសេចក្ដីនេះ លោកពោលទុកក្នុងអដ្ឋកថាទាំងឡាយឬក្នុងគម្ពីរមង្គលត្ថទីបនីថា ៖

**កាមញ្ច បញ្ចមី ធាលិយំ ឆាគតា សា បន ជម្មសក្កាហាកេហិ ឋបិតត្តា គហេតញ្ញា វ**

ថ្ងៃទី ៥ មិនមានមកក្នុងព្រះបាលី ( ព្រះពុទ្ធដីកា ) ក៏ពិតមែនហើយ តែជាគប្បីកាន់យកនូវថ្ងៃទី ៥ នោះកុំខាន ព្រោះជាថ្ងៃដែលព្រះធម្មសង្គាហកាចារ្យទាំងឡាយ បានតាំង( កំណត់ ) ទុកហើយ ។

កាលនៃបកតិឧបោសថ ដូចបានពណ៌នាមកនេះ ឧបាសកឧបាសិកា អ្នកប្រាថ្នាបុណ្យកុសល គប្បីថែរក្សាឧបោសថសីលតាមកាលនេះចុះ ។

## បដិជាគរឧបោសថ

*ចំណែកកាលនៃបដិជាគរឧបោសថ លោកសម្តែងទុកក្នុងគម្ពីរមង្គលត្ថទីបនីថា ៖*

ចតុត្ថី ឆដ្ឋី សត្តមី នវមី តេរសីតិ ជុណ្ហេ បញ្ចធាដិបតោ ចតុត្ថី ឆដ្ឋិ សត្តមី នវមី ទ្វាទសី វា តេរសីវាតិ កាឡេ ឆ ចាតិ មាសស្ស ឯកាទស ទិវសា បដិជាគរឧបោសថស្ស កាលោ

*កាលនៃបដិជាគរឧបោសថក្នុងមួយខែមាន ១១ ថ្ងៃ គឺខាងខ្នើតមាន ៥ ថ្ងៃ គឺថ្ងៃ ៤ កើត, ៦ កើត, ៧ កើត, ៩ កើត, និងថ្ងៃ ១៣ កើត, ខាងរនោចមាន ៦ ថ្ងៃ គឺថ្ងៃ ១ រោច, ៤ រោច, ៦ រោច, ៧ រោច, ៩ រោច, និងថ្ងៃ ១២ រោច ឬ ១៣ រោច ។*

តទញ្ញោ អបរិបុណ្ណមាសេ ទស បរិបុណ្ណមាសេ ឯកាទស ទិវសា ឧបោសថស្ស កាលោ ន ហោតិ

*កាលនៃឧបោសថ ( បដិជាគរឧបោសថ )ក្នុងខែមិនពេញ*

មាន ១០ ថ្ងៃ ក្នុងខែពេញមាន ១១ ថ្ងៃ ដទៃអំពីថ្ងៃនោះ មិនមែនជាកាលនៃឧបោសថទេ ។

នៅក្នុងគម្ពីរមនោរថបូរណី អដ្ឋកថា អង្គុត្តរនិកាយ តិកនិបាត ត្រង់ទេវទូតវគ្គ ចតុមហារាជសូត្រពន្យល់ថា ៖

ឧបោសថំ ឧបវសន្តីតិ មាសស្ស អដ្ឋវារេ ឧបោសថង្គានិ អធិដ្ឋហន្តិ ។ បដិជាគរោន្តីតិ បដិជាគរឧបោសថកម្មំ នាម ករោន្តិ ។ តំ ករោន្តោ ឯកស្មឹ អឌ្ឍមាសេ ចតុន្នំ ឧបោសថទិវសានំ បច្ចុគ្គមនានុគ្គមនវសេន ករោន្តិ ។ បញ្ចមី ឧបោសថំ បច្ចុគ្គច្ឆន្តា ចតុត្ថិយំ ឧបោសថិកា ហោន្តិ អនុគ្គច្ឆន្តា ឆដ្ឋិយំ ។ អដ្ឋមី ឧបោសថំ បច្ចុគ្គច្ឆន្តា សត្តមិយំ, អនុគ្គច្ឆន្តា នវមិយំ ចាតុទ្ទសី ឧបោសថំ បច្ចុគ្គច្ឆន្តា តេរសិយំ បណ្ណរសី ឧបោសថំ អនុគ្គច្ឆន្តា បាដិបទេ ឧបោសថិកា ហោន្តិ ។

ពាក្យថា រក្សានូវឧបោសថ បានសេចក្ដីថា ជនទាំងឡាយរមែងអធិដ្ឋាននូវអង្គឧបោសថមួយខែ ៨ ដង ។ ពាក្យថា បដិជាគរោន្តិ សេចក្ដីថា រមែងធ្វើនូវឧបោសថកម្មឱ្យមាន

ឈ្មោះថាបដិជាគរៈ ។ ឧបាសក ឧបាសិកា កាលរក្សានូវបដិជាគរឧបោសថនោះ រមែងធ្វើដោយអំណាចការទទួលនិងការជូនដំណើរនៃថ្ងៃឧបោសថទាំងឡាយ ៤ ក្នុងកន្លះខែមួយ ។ កាលទទួលនូវឧបោសថក្នុងថ្ងៃទី ៥ រមែងជាអ្នករក្សាឧបោសថក្នុងថ្ងៃទី ៤ ការជូនដំណើរ រមែងជាអ្នករក្សាឧបោសថក្នុងថ្ងៃទី ៦ ។ កាលទទួលនូវឧបោសថសីលក្នុងថ្ងៃទី ៨ រមែងជាអ្នករក្សានូវឧបោសថក្នុងថ្ងៃទី ៧ ការជូនដំណើររមែងជាអ្នករក្សាឧបោសថក្នុងថ្ងៃទី ៩ ។ កាលទទួលនូវឧបោសថក្នុងថ្ងៃទី ១៤ រមែងជាអ្នករក្សានូវឧបោសថក្នុងថ្ងៃទី ១៣ ការជូនដំណើររមែងជាអ្នករក្សាឧបោសថក្នុងថ្ងៃ ១ រោច ។

នៅក្នុងគម្ពីរសារត្ថមញ្ជូសា ជាដីកានៃអង្គុត្តរនិកាយ ទុតិយភាគ បញ្ជាក់ថា ៖

អដ្ឋ វារេតិ ឯកស្មឹ អឌ្ឍមាសេ ចតុក្ខត្តុំ តថា ឥតរស្មិន្តិ ឯវំ អដ្ឋ វារេ ។ អធិដ្ឋហន្តីតិ អធិតិដ្ឋន្តិ ។ បដិជាគរោន្តីតិ បដិ បដិ ជាគរោន្តិ ។ បុញ្ញំ ករោន្តា ហិ សត្តា ជាគរោន្តិ នាម កាតព្វកិច្ចប្បសុតត្តា ឥតរេ បន

**សុបន្តិ ឆាម សហិតបរហិតវិមុត្តត្តា ។ ចាតុទ្ទសិ-ឧបោសថស្ស អនុគមនំ វិយ បណ្ណរសិឧបោសថស្ស បច្ចុគ្គមនំ ន លព្ភតិ ឆិវសាភាវតោ ។**

*ពាក្យថា អស់វារៈ ៨ ដង សេចក្តីថា រមែងអធិដ្ឋានអស់វារៈ ៨ ដង យ៉ាងនេះ គឺក្នុងកន្លះខែមួយ ៤ ដង, ក្នុងកន្លះខែមួយទៀតក៏ ៤ ដង ដូចគ្នា ។ ពាក្យថា រមែងអធិដ្ឋាន មានន័យថា រមែងតាំងចិត្តមាំ ។ ពាក្យថា* **បដិជាគរោន្តិ** *ប្រែថា រមែងភ្ញាក់រឭកដោយលំដាប់ៗ ។ ពិតមែនហើយ សត្វទាំងឡាយ កាលធ្វើបុណ្យ ឈ្មោះថា រមែងភ្ញាក់រឭក ព្រោះភាពជាអ្នកក្រវល់ក្រវាយក្នុងកិច្ចដែលខ្លួនឯងគប្បីធ្វើ, តែថា សត្វដទៃទៀត ឈ្មោះថា រមែងដេកលក់ ព្រោះភាពជាអ្នករួចផុតចាកប្រយោជន៍របស់ខ្លួននិងប្រយោជន៍អ្នកដទៃ ។ ការរក្សាឧបោសថក្នុងថ្ងៃទី ១៥ រោច ( រមែងមិនបានដើម្បីទទួល និងការជូនដំណើរ ) ដូចមិនបានការជូនដំណើរឧបោសថក្នុងថ្ងៃទី ១៤ រោច ព្រោះគ្មានថ្ងៃ ។*

## បាដិហារិយឧបោសថ

*នៅក្នុងគម្ពីរអភិធានប្បទីបិកាសូចិសម្តែងថា ៖*

*(ធម្មជាត)នាំទៅនូវធម៌ជាសត្រូវ ឈ្មោះថា* **បាដិហារ្យ** *វិគ្គហៈថា* **បដិបក្ខេ ហរតីតិ = បាដិហារិយំ (ធម្មជាតំ)** ។ *នៅក្នុងគម្ពីរសារត្ថមញ្ជូសា ជាដីកានៃអង្គុត្តរនិកាយ ទុតិយភាគ សម្តែងថា ៖*

និច្ចំ និពន្ធំ ឧបោសថំ សំវច្ឆរេ សំវច្ឆរេ បដិបដិ
ហារិតព្វតោ បវត្តេតព្វោ បាដិហារិយបក្ខោ នាម

*ឧបោសថជានិច្ច គឺអស់កាលមិនដាច់ ឈ្មោះថា បាដិហារិយបក្ខ ព្រោះត្រូវនាំទៅតាមលំដាប់ៗ គឺគប្បីប្រព្រឹត្តទៅរាល់ៗ ឆ្នាំ ។*

*នៅក្នុងគម្ពីរអដ្ឋកថា មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ តិកនិបាត ត្រង់រាជសូត្រសម្តែងថា ៖*

បាដិហារិយបក្ខោ នាម អន្តោវស្សេ តេមាសំ និពន្ធុបោសថោ តម្បិ អសក្កោន្តស្ស ទ្វិន្នំ បវារណានំ អន្តរេ ឯកមាសំ និពន្ធុបោសថោ តម្បិ អសក្កោន្តស្ស បឋមប្បវារណតោ បដ្ឋាយ ឯកោ អឌ្ឍមាសោ បាដិហារិយ

**បក្ខោយេវ ឆាម ។**

ឧបោសថដែលបុគ្គលរក្សាអស់កាលជាប់មិនដាច់ គឺរក្សាជានិច្ចរហូតអស់ប្រជុំនៃខែ ៣ ( ៣ ខែ )ខាងក្នុងវស្សា ឈ្មោះថា បាដិហារិយបក្ខ, កាលមិនអាច( នឹងរក្សា )ឧបោសថ សូម្បីខាងក្នុងវស្សា ៣ ខែនោះបាន ឧបោសថដែលរក្សាអស់កាលមិនដាច់( ជានិច្ច ) ( នឹងរក្សា )អស់ប្រជុំនៃខែមួយ ( មួយខែ )ក្នុងរវាងថ្ងៃបវារណាទាំងពីរគឺថ្ងៃ ១៥ កើត ខែកត្តិក ( ឬ )កាលមិនអាច( នឹងរក្សា )ឧបោសថជានិច្ចអស់មួយខែនោះបាន នឹងរក្សាកន្លះខែ ចាប់តាំងពីថ្ងៃបវារណាដំបូង ក៏ឈ្មោះថា **បាដិហារិយបក្ខ** ដូចគ្នា ។

តែនៅក្នុងគម្ពីរបរមត្ថជោតិកា អដ្ឋកថាខុទ្ទកនិកាយ សុត្តនិបាត ត្រង់ធម្មិកសូត្រទុតិយភាគសម្តែងថា ៖

**បាដិហារិយបក្ខញ្ចាតិ ឯត្ថ បន វស្សូបនាយិកាយ បុរិមភាគេ អាសាឡ្ហមាសោ អន្តោវស្សេ តយោ មាសេ កត្តិកមាសោតិ ឥមេ បញ្ច មាសា បាដិហារិយបក្ខោតិ វុច្ចន្តិ ។**

ក៏ក្នុងបទថា **បាដិហារិយបក្ខញ្ច** នេះ ខែទាំងឡាយ ៥ នេះ គឺខែអាសាឍក្នុងចំណែកខាងដើម ជិតនឹងថ្ងៃចូលវស្សា, ៣ ខែ

ខាងក្នុងវស្សានិងខែកត្តិក លោកហៅថា **បាដិហារិយបក្ខ** ។

អាចារ្យពួកដទៃពោលថា **បាដិហារិយបក្ខ** មាន ៣ ខែប៉ុណ្ណោះ គឺខែអាសាឍ ខែកត្តិក និងខែផល្គុន ។ អាចារ្យមួយពួកទៀតពោលថា ថ្ងៃ ៤ ៗ នៃថ្ងៃបក្ខុបោសថ ដោយអំណាចថ្ងៃខាងដើម និងខាងចុង ពោលគឺថ្ងៃ ១៣ កេច, ១ កេច, ៧ កេច, និងថ្ងៃ ៩ កេច, រាល់ៗ បក្ខ ។ ប្រពៃយ៉ាងណា គប្បីកាន់យកយ៉ាងនោះចុះ ។

**សត្តំ វា បន បុញ្ញកាមេន ភាវិតព្វំ។ ឯវមេតំ បាដិហារិយបក្ខញ្ច បសន្នមានសោ អដ្ឋង្គុបេតំ សុសមត្តរូបំ សុបរិបុណ្ណរូបំ ឯកម្បិ ទិវសំ អបរិច្ចជន្តោ អដ្ឋង្គុបេតំ ឧបោសថំ ឧបវស្សាតិ សម្ពន្ធិតព្វំ ។**

ចំណែកបុគ្គលអ្នកប្រាថ្នាបុណ្យ គប្បីចម្រើន (គប្បីធ្វើ) បានគ្រប់យ៉ាង ។ សេចក្តីថា បណ្ឌិតគប្បីចងចាំទុកយ៉ាងនេះថា បុគ្គលមានចិត្តជ្រះថ្លា កាលមិនលះបង់នូវបាដិហារិយបក្ខ ដែលប្រកបដោយអង្គ ៨ សូម្បីមួយថ្ងៃ គឺថារក្សារៀងរាល់ថ្ងៃធ្វើឱ្យសម្បូរល្អ ឱ្យបរិបូណ៌ល្អ ឈ្មោះថា ចូលទៅរក្សានូវឧបោសថដែលប្រកបដោយអង្គប្រាំបី ។

## វិធីសមាទានឧបោសថសីល បែបបច្ចេកសមាទាន

ឧបាសក ឧបាសិកា ជាអ្នករក្សានូវឧបោសថសីល កាលបើដល់ថ្ងៃជិតនឹងរក្សានូវឧបោសថសីល គឺមុនមួយថ្ងៃ ត្រូវកំណត់ថា ព្រឹកឡើងនឹងរក្សានូវឧបោសថសីលនោះ គប្បីចាត់ចែងការងារដែលគួរចាត់ចែង មានវិធីចាត់ចែងនូវអាហារជាដើម ដែលជាការងារគឺខ្លួនត្រូវធ្វើ ឬត្រូវប្រើឱ្យគេធ្វើក្នុងថ្ងៃស្អែក គឺក្នុងថ្ងៃឧបោសថកាល ឱ្យហើយក្នុងថ្ងៃនោះជាមុន តែកុំចាត់ចែងការងារដែលមិនប្រកបដោយធម៌ ដែលជាការងារគឺខ្លួនជាឧបាសក ឧបាសិកា មិនគួរចាត់ចែងនោះឡើយ, លុះដល់ព្រឹកឡើងជាថ្ងៃឧបោសថកាល ត្រូវរក្សានូវឧបោសថសីល គប្បីភ្ញាក់ឡើងអំពីព្រលឹម ហើយខ្ពុរមាត់ ជម្រះធ្មេញឱ្យស្អាតរួចហើយ បើបានសមាទាននូវឧបោសថសីល ក្នុងវេលានោះក៏ជាការប្រពៃ បើឃើញថាសមាទានពីព្រលឹមនោះមិនទាន់ទេ ក៏គប្បីកំណត់នូវឧបោសថកាល គឺកាលជាទីរក្សានូវឧបោសថសីលក្នុង ១ ថ្ងៃ ១ យប់នោះ ដោយបញ្ចេញវាចាអធិដ្ឋានថា ៖

**អជ្ជ ឧបោសថោ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ ឧបោសថិកោ / ឧបោសថិកា / ភវិស្សាមិ**

ប្រែថា ថ្ងៃនេះជាថ្ងៃត្រូវរក្សានូវឧបោសថសីល, ខ្ញុំអញនឹងជាអ្នករក្សានូវឧបោសថសីលអស់ថ្ងៃនេះនិងយប់នេះ ។

បើឧបាសក ត្រូវថា **ឧបោសថិកោ**, បើឧបាសិកា ត្រូវថា **ឧបោសថិកា** ។ បើមិនចេះបាលី នឹងអធិដ្ឋានតាមភាសារបស់ខ្លួនៗ ក៏គួរដោយពិត, លុះអធិដ្ឋានកំណត់កាលដូច្នេះរួចហើយ ត្រូវតាំងវិរតិចេតនា វៀរចាកសីលភេទ គឺហេតុដែលជាទីទម្លាយនូវសីលនោះៗ ឱ្យគ្រប់សិក្ខាបទទាំង ៨, កាលបើបានអធិដ្ឋានដូច្នេះរួចហើយ តអំពីពេលនោះមក ក៏គប្បីសមាទាននូវឧបោសថសីលអំពីបុគ្គលដទៃ មានភិក្ខុជាដើមតាមកាលដ៏គួរចុះ បើទុកជាដល់ពេលព្រះអាទិត្យរះខ្ពស់ឡើង ប្រមាណពេញពន្លឺខ្លាំង ទើបបានសមាទានក្តី ក៏ឈ្មោះថា បានសមាទានដោយប្រពៃ ឈ្មោះថា បានរក្សានូវឧបោសថសីលពេញកាលកំណត់ ១ ថ្ងៃ ១ យប់ ដោយបរិបូណ៌ ព្រោះអ្នកសមាទាន បានធ្វើនូវឧបោសថកាលមិនឱ្យខ្វះខាត ទាំងវិរតិចេតនាសោត ក៏កើតខ្លាំងក្លាបរិបូណ៌ក្នុងសន្តាន នឹងបានផលានិសង្សច្រើន ។

ក្នុងមង្គលត្ថទីបនី អដ្ឋកថាឧបោសថសូត្រថា ក្នុងថ្ងៃឧបោសថ គប្បីបញ្ចេញវាចា សមាទានអង្គនៃឧបោសថទាំង

ឡាយ ក្នុងសំណាក់ភិក្ខុឬសាមណេរ នៃឧបាសកឬឧបាសិកា អ្នកដឹងលក្ខណៈនៃសីល ១០ តាំងអំពីព្រលឹមស្រាងៗ ។ ប៉ុន្តែ កាលបើមិនចេះបាលី គប្បីអធិដ្ឋានថា "អាត្មាអញអធិដ្ឋាននូវ ឧបោសថ ដែលព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តិទុកហើយ" ដូច្នេះ ។ កាលបើមិនមានអ្នកដទៃ គប្បីអធិដ្ឋានខ្លួនឯងក៏បានដែរ តែគប្បី បញ្ចេញវាចាដោយពិត ។

ដីកានៃឧបោសថសូត្រនោះថា ក្នុងពីរបទថា **វាចំ ភិន្ទិត្វា** គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ អ្នករក្សាឧបោសថគប្បីធ្វើការ កំណត់កាលថា អាត្មាអញនឹងរក្សានូវឧបោសថ អស់កាលថ្ងៃនេះ និងយប់នេះ ដូច្នេះហើយ ធ្វើដោយការរួមជាមួយគ្នា ដោយ អំណាចអង្គឧបោសថថា អាត្មាអញសមាទាននូវសិក្ខាបទទាំង ៨ ដូច្នេះហើយ គប្បីបញ្ចេញវាចា សមាទានអង្គឧបោសថ ជា បច្ចេកសមាទាន ( ចំពោះអង្គ ) តាមបាលីយ៉ាងនេះថា **"បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ ។ល ។ ឧច្ចាសយនមហាសយនា វេរមណី សិក្ខាបទំ សមាទិយាមិ** ដូច្នេះ ។ ( ហេតុនេះ អ្នករក្សាសីលត្រូវសិក្សាឱ្យចេះសិក្ខាបទ ដែលខ្លួនរក្សា ទាំងបាលីទាំងសេចក្តីប្រែ ព្រោះវិរតិនិងចេតនា

អាស្រ័យការដឹងសេចក្តីនៃសិក្ខាបទ ដែលខ្លួនសមាទាន ) ។ បើមិនបានអ្នកដទៃគប្បីអធិដ្ឋានដោយខ្លួនឯងក៏បាន ។ ពិតមែន សីលរបស់ឧបាសក គឺបុគ្គលអ្នករក្សានូវឧបោសថ សមាទានដោយខ្លួនឯងក្តី ឈ្មោះថា បានសមាទានហើយ សមាទានក្នុងសំណាក់បុគ្គលដទៃក្តី ឈ្មោះថា បានសមាទានហើយ សមាទានរួមគ្នា ( ជាឯកជ្ឈសមាទាន )ក្តី សមាទានជាបច្ចេកសមាទាន ( ចំពោះអង្គមួយៗ ) ក្តី ក៏ឈ្មោះថា បានសមាទានហើយ ដូចគ្នាដែរ ។

សួរថា សេចក្តីខុសប្លែកអំពីគ្នា នឹងមានយ៉ាងដូចម្តេច ឆ្លើយថា បើបុគ្គលសមាទាន( ជាឯកជ្ឈសមាទាន ) រួមគ្នាវិរតិក៏ដូចគ្នាតែមួយប៉ុណ្ណោះ ចេតនាក៏មានមួយដួងដូចគ្នាដែរ ។

ប៉ុន្តែវិរតិចេតនាទាំងពីរនោះ ធ្វើកិច្ចនៃវិរតិនិងចេតនាគ្រប់បែបយ៉ាង ព្រោះហេតុនោះ សិក្ខាបទទាំងអស់ចាត់ទុកថាគឺបុគ្គលអ្នករក្សាឧបោសថ បានសមាទានហើយដោយពិត ដោយការសមាទានរួមនោះឯង ។ មួយទៀត បើបុគ្គលសមាទានជាបច្ចេកសមាទាន វិរតិនិងចេតនាផ្សេងៗ គ្នា រមែងកើតឡើងតាមនាទីរបស់ខ្លួន ដោយអំណាចនៃកិច្ច ។ ក៏ក្នុងការសមាទានសីល

គ្រប់យ៉ាង គប្បីបញ្ចេញវាចាដោយពិត ។

កាលបើឧបាសក ឧបាសិកា នឹងសមាទាននូវឧបោសថសីលប្រកបព្រមដោយអង្គ ៨ ជាបច្ចេកសមាទានអំពីបុគ្គលដទៃ គឺភិក្ខុឬសាមណេរនោះ គប្បីសូធ្យនមស្ការថ្វាយបង្គំរំឭកដល់គុណព្រះរតនត្រ័យ ជាមុនរួចហើយ ត្រូវសូមនូវឧបោសថសីលព្រមទាំងព្រះត្រៃសរណគមន៍ ចំពោះភិក្ខុឬសាមណេរ ដែលខ្លួននឹងសមាទាននោះ ។

អ្នកសមាទានម្នាក់ ត្រូវសូធ្យថា ៖

ឱកាស អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋ សីលានិ យាចាមិ ។

ទុតិយម្បិ អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋ សីលានិ យាចាមិ ។

តតិយម្បិ អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋ សីលានិ យាចាមិ ។

ប្រែថា សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា សូមនូវសីលទាំងឡាយ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា,

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា សូមនូវសីលទាំងឡាយ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា ជាគម្រប់ពីរដងផង ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាសូមនូវសីលទាំងឡាយ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា ជាគម្រប់បីដងផង ។

ឬនឹងសូមថា ៖

ឱកាស អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាមិ អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ ។

ទុតិយម្បិ អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាមិ អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ ។

តតិយម្បិ អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាមិ អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ ។

ប្រែថា សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា សូមនូវឧបោសថសីល ប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណា,

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា សូមនូវឧបោសថសីលប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា ជាគម្រប់ពីរដងផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណា,

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា សូមនូវឧបោសថសីល ប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា ជាគម្រប់បីដងផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណា ។

*អ្នកសមាទានច្រើននាក់ ត្រូវសូធ្យថា ៖*

ឱកាស មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋ សីលានិ យាចាម ។

ទុតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋ សីលានិ យាចាម ។

តតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋ សីលានិ យាចាម ។

*ប្រែថា សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវសីលទាំងឡាយ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា,*

*បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវសីលទាំងឡាយ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា, ជាគម្រប់ពីរដងផង ។*

*បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវសីលទាំងឡាយ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា, ជាគម្រប់បីដងផង ។*

ឬនឹងសូមថា ៖

ឧកាស មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាម អនុគ្គហំ កត្វា សីលំ ទេថ ណោ ភន្តេ ។

ទុតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាម អនុគ្គហំ កត្វា សីលំ ទេថ ណោ ភន្តេ ។

តតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាម អនុគ្គហំ កត្វា សីលំ ទេថ ណោ ភន្តេ ។

ប្រែថា សូមគោរព, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវឧបោសថសីល ប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណាទាំងឡាយ,

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវឧបោសថសីល ប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះ

ត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា, ជាគម្រប់ពីរដងផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្ដីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណាទាំងឡាយ,

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវឧបោសថសីល ប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា, ជាគម្រប់បីដងផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្ដីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណាទាំងឡាយ ។

សូមដូច្នេះក៏បាន តាមសេចក្ដីពេញចិត្តរបស់អ្នកសូម ។

រួចលោកអ្នកឱ្យសីល ត្រូវតាំង **នមោ** ៣ ចប់ រួចហើយឱ្យព្រះត្រៃសរណគមន៍, អ្នកសមាទាន ត្រូវទទួលថាតាមលោក, រួចលោកប្រាប់អំពីកិច្ចកាន់យកព្រះត្រៃសរណគមន៍ដូចក្នុងវិធីបច្ចេកសមាទានខាងដើម

រួចហើយលោកឱ្យនូវឧបោសថសីលជាបច្ចេកសមាទានថា ៖

**បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ**

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុ ដែលគេមិនបានឱ្យដោយកាយ ឬដោយវាចា ។

អព្រហ្មចរិយា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តនូវធម៌មិនប្រសើរគឺសេពនូវមេថុនធម្ម ។

មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ។

វិកាលភោជនា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាបរិភោគនូវភោជនាហារក្នុងកាលខុស ។

នច្ចគីតវាទិតវិសូកទស្សនមាលាគន្ធវិលេបនធារណ-មណ្ឌនវិភូសនដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយារាំ និងច្រៀង និងប្រគំនិងមើលនូវល្បែងដែលជាសត្រូវដល់កុសលធម៌និងកិរិយាទ្រទ្រង់ និងប្រដាប់ និងតាក់តែងស្អិតស្អាងរាងកាយ ដោយផ្កាកម្រង និងគ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ ។

ឧច្ចាសយនមហាសយនា វេរមណី សិក្ខាបទំ សមាទិយាមិ

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក ទីសេនាសនៈដ៏ខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ ។

រួចហើយអ្នកសមាទាន សូមឲ្យកំណត់ឧបោសថកាលថា ៖

ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញត្តំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សម្មទេវ អភិរក្ខិតុំ សមាទិយាមិ ។

ប្រែថា ខ្ញុំព្រះករុណា សូមសមាទាននូវឧបោសថសីល ដ៏ប្រកបព្រមដោយអង្គ ៨ ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់

ត្រាស់បញ្ញត្តទុកហើយនេះ ដើម្បីនឹងរក្សាឱ្យបរិបូណ៌ប្រពៃ អស់កាលកំណត់ថ្ងៃនេះនិងយប់នេះ សូមកុសលចូរជាឧបនិស្ស័យធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ក្នុងអនាគតទៅឯមុខនោះហោង ។

បាលីនេះ គ្រាន់តែជាពាក្យសម្រាប់ពោលកំណត់កាលឱ្យដឹងថា ឧបោសថសីលទាំង ៨ សិក្ខាបទនេះ អ្នកសមាទានត្រូវរក្សាតែត្រឹម ១ ថ្ងៃ ១ យប់នោះប៉ុណ្ណោះ, ហេតុនោះ បើអ្នកសមាទាន បានចេះដឹងច្បាស់ប្រាកដក្នុងឧបោសថកាលហើយ មិនបាច់សូធ្យក៏បាន, តែបើទុកជាចេះដឹងច្បាស់ប្រាកដហើយ នឹងសូធ្យបាលីនេះ ព្រមទាំងសេចក្ដីប្រែផងនោះ ក៏ជាការប្រពៃណាស់ ជាហេតុនាំឱ្យរឹតតែចេះស្ទាត់ប្រាកដទាំងអស់គ្នាឡើង ។

រួចហើយលោកអ្នកឱ្យសីល លោកពោលដាស់តឿនក្រើនរំឭកថា ៖

ឥមានិ អដ្ឋ សិក្ខាបទានិ ឧបោសថសីលវសេន
ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សាធុកំ កត្វា
អប្បមាទេន សម្មារក្ខិតព្វំ ។

ប្រែថា អ្នក/អ្នកទាំងឡាយគប្បីធ្វើនូវសិក្ខាបទទាំងឡាយ ៨ នេះឱ្យប្រពៃ ត្រូវរក្សាឱ្យល្អដោយអំណាចនៃឧបោសថសីល អស់កាលកំណត់ត្រឹម ១ ថ្ងៃ ១ យប់នេះ ដោយសេចក្ដីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។

អ្នកសមាទានត្រូវទទួលថា **អាម ភន្តេ** (ប្រែថា) ករុណាលោកម្ចាស់ ។

ហើយលោកសម្ដែងអានិសង្សសីលឱ្យស្ដាប់តទៅទៀតថា ៖

**សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា**

**សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ**

(ប្រែថា) សត្វទាំងឡាយទៅកាន់ស្ថានសួគ៌បាន ក៏ព្រោះសីល, សត្វទាំងឡាយ បានបរិបូណ៌ដោយភោគៈ ក៏ព្រោះសីល, សត្វទាំងឡាយបាន ទៅកាន់ទីរំលត់ទុក្ខពោល គឺព្រះនិព្វាន ក៏ព្រោះសីល, ព្រោះហេតុនោះ បុគ្គលជាសប្បុរស គប្បីជម្រះនូវសីលឱ្យបរិសុទ្ធ កុំឱ្យសៅហ្មងឡើយ ។

អ្នកសមាទានត្រូវទទួលថា **សាធុ** ប្រែថា ប្រពៃហើយ ។

“ចប់ វិធីសមាទានឧបោសថសីលជាបច្ចេកសមាទានតែប៉ុណ្ណេះ”

## វិធីសមាទានឧបោសថសីល បែបឯកជ្ឈសមាទាន

*អ្នកសមាទានម្នាក់ ត្រូវសូធ្យថា ៖*

ឱកាស អហំ ភន្តេ តិសរណេន សហ ឯកជ្ឈំ កត្វា អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាមិ អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ ។

ទុតិយម្បិ អហំ ភន្តេ តិសរណេន សហ ឯកជ្ឈំ កត្វា អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាមិ អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ ។

តតិយម្បិ អហំ ភន្តេ តិសរណេន សហ ឯកជ្ឈំ កត្វា អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាមិ អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ ។

*ប្រែថា សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា សូមនូវឧបោសថសីល ប្រកបព្រមដោយអង្គ ៨ ធ្វើឱ្យជាឯកជ្ឈៈ គឺសមាទានរួមតែម្ដង មួយអន្លើដោយព្រះត្រៃសរណគមន៍ បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្ដីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណា ។*

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា សូមនូវឧបោសថសីល ប្រកបព្រមដោយអង្គ ៨ ធ្វើឱ្យជាឯកជ្ឈៈ គឺសមាទានរួមតែម្តង មួយអន្លើដោយ ព្រះត្រៃសរណគមន៍ ជាគម្រប់ពីរដងផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណា ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា សូមនូវឧបោសថសីលប្រកបព្រមដោយអង្គ ៨ ធ្វើឱ្យជាឯកជ្ឈៈ គឺសមាទានរួមតែម្តង មួយអន្លើដោយព្រះត្រៃសរណគមន៍ ជាគម្រប់បីដងផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណា ។

បើអ្នកសមាទានច្រើននាក់ ត្រូវសូមថា ៖

ឱកាស មយំ ភន្តេ តិសរណេន សហ ឯកជ្ឈំ កត្វា អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាម អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ ។

ទុតិយម្បិ មយំ ភន្តេ តិសរណេន សហ ឯកជ្ឈំ កត្វា អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាម អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ ។

តតិយម្បិ មយំ ភន្តេ តិសរណេន សហ ឯកជ្ឈំ កត្វា អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាម អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ ។

ប្រែថា សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវឧបោសថសីល ប្រកបព្រមដោយអង្គ ៨ ធ្វើឱ្យជាឯកជ្ឈៈ គឺសមាទានរួមតែម្តង មួយអន្លើដោយព្រះត្រៃសរណគមន៍ បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណាទាំងឡាយ ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវឧបោសថសីល ប្រកបព្រមដោយអង្គ ៨ ធ្វើឱ្យជាឯកជ្ឈៈគឺសមាទានរួមតែម្តង មួយអន្លើដោយព្រះត្រៃសរណគមន៍ ជាគម្រប់ពីរដងផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណាទាំងឡាយ ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវឧបោសថសីល ប្រកបព្រមដោយអង្គ ៨ ធ្វើឱ្យជាឯកជ្ឈៈគឺសមាទានរួមតែម្តង មួយអន្លើដោយព្រះត្រៃសរណគមន៍ ជាគម្រប់បីដងផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើ

នូវសេចក្ដីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណាទាំងឡាយ ។

រួចលោកអ្នកឱ្យសីល ត្រូវតាំង នមោ ៣ ចប់ រួចហើយឱ្យព្រះត្រៃសរណគមន៍, អ្នកសមាទានត្រូវទទួលថាតាមលោក, រួចលោកប្រាប់អំពីកិច្ចកាន់យកព្រះត្រៃសរណគមន៍ ដូចក្នុងវិធីបច្ចេកសមាទានខាងដើម រួចហើយលោកឱ្យឧបោសថសីលជាឯកជ្ឈសមាទានថា **អដ្ឋង្គសមន្នាគតំ ឧបោសថំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវឧបោសថសីលដែលប្រកបព្រមដោយអង្គ ៨, ឬថា **អដ្ឋ សីលានិ សមាទិ-យាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសីលទាំងឡាយ ៨,

អ្នកសមាទានត្រូវថាតាមលោក ៣ ដង, រួចត្រូវសូធ្យកំណត់កាលឧបោសថថា ៖

**ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញត្តំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សម្មទេវ អភិរក្ខិតុំ សមាទិយាមិ ។**

ខ្ញុំព្រះករុណា សូមសមាទាននូវឧបោសថសីល ដ៏ប្រកបព្រមដោយអង្គ ៨ ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់បញ្ញត្តទុកហើយនេះ ដើម្បីនឹងរក្សាឱ្យបរិបូណ៌ប្រពៃ អស់កាល

កំណត់ថ្ងៃនេះ និងយប់នេះ សូមកុសលចូរជាឧបនិស្ស័យ ធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ក្នុងអនាគតទៅឯមុខនោះហោង ។

ទើបលោកជាស់តឿនក្រើនរំលឹកថា ៖

ឥមំ អដ្ឋង្គសមន្នាគតំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សាធុកំ កត្វា អប្បមាទេន សម្មារក្ខិតព្វំ ។

( ប្រែថា ) អ្នក/អ្នកទាំងឡាយ គប្បីរក្សានូវឧបោសថ ដ៏ប្រកបព្រមដោយអង្គ ៨ នេះ ឱ្យប្រពៃគឺត្រូវរក្សាឱ្យល្អ អស់កាលកំណត់ត្រឹមថ្ងៃនេះ និងយប់នេះ ដោយសេចក្តីមិនប្រមាទ គឺថាកុំគប្បីធ្វេសប្រហែសឡើយ ។

អ្នកសមាទានត្រូវទទួលថា អាម ភន្តេ ករុណាលោកម្ចាស់ ។

ហើយលោកសម្តែងអានិសង្សសីលឱ្យស្តាប់តទៅទៀតថា ៖

សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា
សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ

( ប្រែថា ) សត្វទាំងឡាយទៅកាន់ស្ថានសួគ៌បាន ក៏ព្រោះសីល, សត្វទាំងឡាយបានបរិបូណ៌ដោយភោគៈ ក៏ព្រោះសីល, សត្វទាំងឡាយបានទៅកាន់ទីរំលត់ទុក្ខពោលគឺព្រះនិព្វាន ក៏ព្រោះ

សីល, ព្រោះហេតុនោះ បុគ្គលជាសប្បុរស គប្បីជម្រះនូវសីល ឱ្យបរិសុទ្ធ កុំឱ្យសៅហ្មងឡើយ ។

អ្នកសមាទានត្រូវទទួលថា សាធុ ប្រែថា ប្រពៃហើយ ។

សមាទានប៉ុណ្ណេះ ក៏ជាការស្រេច មិនបាច់សូធ្យញែកឈ្មោះសិក្ខាបទទាំង ៨ រាយមួយម្តងៗ ដូចបច្ចេកសមាទាននោះឡើយ សមាទានប៉ុណ្ណេះហើយ ត្រូវរក្សាដោយតាំងវិរតិចេតនា វៀរចាកឱ្យគ្រប់សិក្ខាបទក្នុងឧបោសថសីល ដែលខ្លួនបានសមាទានហើយនោះ អស់ ១ ថ្ងៃ ១ យប់ ។

"ចប់ វិធីសមាទានឧបោសថសីលជាឯកជ្ឈសមាទានតែប៉ុណ្ណេះ"

## វិធីសមាទានបាដិហារិយឧបោសថសីល

អ្នកសមាទានម្នាក់ ត្រូវសូធ្យថា ៖

ឱកាស អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ បាដិហារិយបក្ខុបោសថំ យាចាមិ, អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ ។

ទុតិយម្បិ អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ បាដិហារិយបក្ខុបោសថំ

**យាចាមិ, អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ ។**

**តតិយម្បិ អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ចាដិហារិយបក្ខុបោសថំ យាចាមិ, អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ ។**

*( ប្រែថា ) សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា សូមសមាទាននូវបាដិហារិយឧបោសថសីល ប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះឱ្យនូវសីលដល់ខ្ញុំព្រះករុណា ។*

*បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា សូមសមាទាននូវបាដិហារិយឧបោសថសីល ប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា, ជាគម្រប់ពីរដងផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណា ។*

*បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា សូមសមាទាន*

នូវបាដិហារិយឧបោសថសីល ប្រកបព្រមដោយអង្គ ៨ មួយ អន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នា, ជាគម្រប់បីដងផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណា ។

អ្នកសមាទានច្រើននាក់ត្រូវសូធ្យថា ៖

ឱកាស មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ បាដិហារិយបក្ខុបោសថំ យាចាម, អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ ។

ទុតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ បាដិហារិយបក្ខុបោសថំ យាចាម, អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ ។

តតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ បាដិហារិយបក្ខុបោសថំ យាចាម, អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ ។

( ប្រែថា )សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមសមាទាននូវបាដិហារិយឧបោសថសីល

ប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណាទាំងឡាយ ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមសមាទាននូវបាដិហារិយឧបោសថសីល ប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា, ជាគម្រប់ពីរដងផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណាទាំងឡាយ ។

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមសមាទាននូវបាដិហារិយឧបោសថសីល ប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា, ជាគម្រប់បីដងផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណាទាំងឡាយ ។

( លោកអ្នកឱ្យសីល ត្រូវឱ្យដូចវិធីសូមឧបោសថសីលបែបបច្ចេកសមាទានខាងដើម )

អ្នកសមាទានគប្បីសូធ្យកំណត់ឧបោសថកាលថា ៖

**ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញត្តំ បាដិហារិយ-បក្ខុបោសថំ ឥមំ (អឌ្ឍមាសំ) សម្មទេវ អភិរក្ខិតុំ សមាទិយាមិ ។**

( ប្រែថា ) ខ្ញុំព្រះករុណា សូមសមាទាននូវបាដិហារិយឧបោសថសីល ដ៏ប្រកបព្រមដោយអង្គ ៨ ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់បញ្ញត្តទុកហើយនេះ ដើម្បីនឹងរក្សាឱ្យបរិបូណ៌ប្រពៃ អស់កាលកំណត់ ( កន្លះខែ ) នេះ សូមកុសលចូរជាឧបនិស្ស័យ ធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វានពួដ៏អនាគត ទៅខាងមុខនោះហោង ។

បើលោកអ្នកត្រូវការសមាទាន កំណត់កាលប៉ុន្មាន គប្បីផ្លាស់បាលីនៅក្នុងចន្លោះវង្វង់ក្រចក ដូចមានបាលីនេះគឺ **ឯកមាសំ** មួយខែ, **តិមាសំ** បីខែ, **ចតុមាសំ** បួនខែ, ។

ចំណែកព្រះសង្ឃ កាលនឹងសូធ្យ ក៏ត្រូវផ្លាស់បាលីក្នុង

ចន្លោះវេទ្ធង់ក្រចក តាមការសូមកំណត់ឧបោសថកាលដែរ ។

ព្រះសង្ឃសូធ្យថា ៖

ឥមានិ អដ្ឋសិក្ខាបទានិ ចាដិហារិយបក្ខុបោសថសីល-វសេន ឥមំ (អឌ្ឍមាសំ) សាធុកំ កត្វា អប្បមាទេន សម្មារក្ខិតព្វំ ។

( ប្រែថា ) អ្នក/អ្នកទាំងឡាយ គប្បីធ្វើនូវសិក្ខាបទទាំងឡាយ ៨ នេះឱ្យប្រពៃ ត្រូវរក្សាឱ្យល្អដោយអំណាចនៃបដិហារិយបក្ខុបោសថសីលអស់កាលកំណត់ ( កន្លះខែ ) នេះដោយសេចក្តីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។

អ្នកសមាទានត្រូវទទួលថា អាម ភន្តេ ករុណាលោកម្ចាស់ ។

ហើយលោកសម្តែងអានិសង្សសីលឱ្យស្តាប់តទៅទៀតថា ៖

សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា
សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ

( ប្រែថា ) សត្វទាំងឡាយទៅកាន់ស្ថានសួគ៌បាន ក៏ព្រោះសីល, សត្វទាំងឡាយបានបរិបូណ៌ដោយភោគៈ ក៏ព្រោះសីល, សត្វទាំងឡាយបានទៅកាន់ទីរំលត់ទុក្ខពោលគឺព្រះនិព្វាន ក៏ព្រោះ

សីល, ព្រោះហេតុនោះ បុគ្គលជាសប្បុរស គប្បីជម្រះនូវសីលឱ្យបរិសុទ្ធ កុំឱ្យសៅហ្មងឡើយ ។

អ្នកសមាទានត្រូវទទួលថា **សាធុ** ប្រែថា ប្រពៃហើយ ។

ក្រៅពីនិច្ចសីល និងឧបោសថសីលជាដើមនេះ ក៏មានសីលដទៃទៀត ដែលឧបាសក ឧបាសិកាអាចរក្សាបានគឺ **អាជីវមដ្ឋកសីល** និង**ទសសីល** ឬ **អតិរេកសីល** ។

ការវៀរចាកទុច្ចរិត ៧ យ៉ាងគឺ ការសម្លាប់សត្វ ១ ការលួចទ្រព្យអ្នកដទៃ ១ ការប្រព្រឹត្តខុសក្នុងកាម ១ ការនិយាយកុហក ១ ការនិយាយញុះញង់ ១ ការជេរប្រទេច ១ ការនិយាយឥតប្រយោជន៍ ១ និងការចិញ្ចឹមជីវិតតាមផ្លូវខុសដែលព្រះពុទ្ធទ្រង់ហាម ១ (ថែមទៀត) ។ សិក្ខាបទ ៨ នេះហៅថា **អាជីវមដ្ឋកសីល** ។

អ្នករក្សាសីល ៨ នេះ អាចបរិភោគអាហារក្នុងវេលាវិកាលបាន គ្រាន់តែសីលនោះវិសេសជាងសីល ៥ បន្តិច ។

## ទសសីល (សីល ១០)

គប្បីដឹងថា សិក្ខាបទទាំងឡាយ ១០ នេះ ជាសាធារណៈ ទូទៅដល់បព្វជិតនិងគ្រហស្ថ ពិតមែន ប៉ុន្តែគ្រហស្ថជាអនិពទ្ធសីល បព្វជិតជានិពទ្ធសីល ។

សូមទាញយកបាលីជាគ្រឿងអាងមកថា ៖

**ខណ្ឌតោតិ គហដ្ឋា យំ យំ វីតិក្កមន្តិ ។ តំ តទេវ ខណ្ឌំ ហោតិ ភិជ្ជតិ ។ អវសេសំ ន ភិជ្ជតិ ។**

ត្រង់ពាក្យថា ដាច់ សេចក្តីថា គ្រហស្ថទាំងឡាយ កាលប្រព្រឹត្តកន្លងនូវសិក្ខាបទណាៗ រមែងដាច់ បែកធ្លាយនូវសិក្ខាបទនោះៗ ប៉ុណ្ណោះ ឯសិក្ខាបទដ៏សេសសល់ពីនោះ មិនដាច់ មិនបែកធ្លាយទេ ។

ព្រោះហេតុអ្វី ? ព្រោះថា គ្រហស្ថទាំងឡាយជាអនិពទ្ធសីល គឺថាជាសីលមិនជាប់ដោយភេទនៃខ្លួនជាគ្រហស្ថ ឬជាកម្មពទ្ធៈ ជាប់ដោយកម្មណាមួយឡើយ ។ បើខ្លួនគ្រហស្ថអាចរក្សាគ្រប់គ្រងនូវសិក្ខាបទណាៗ ប៉ុន្មាន ក៏ថែរក្សានូវសិក្ខាបទនោះៗ ប៉ុណ្ណោះទៅ ។

**សាមណេរានំ បន ឯកស្មិម្បិ វីតិក្កមន្តេ សព្វានិបិ ភិជ្ជន្តិយេវ ។ នកេវលញ្ច ឯតានិ ។ សេសសីលានិបិ ភិជ្ជន្តិយេវ ។**

*ចំណែកខាងសាមណេរទាំងឡាយវិញ កាលបើប្រព្រឹត្តកន្លងនូវសិក្ខាបទសូម្បីតែមួយ សិក្ខាបទទាំងឡាយឯទៀត ក៏រមែងបែកធ្លាយទាំងអស់ ។ មិនត្រឹមតែសិក្ខាបទទាំងឡាយប៉ុណ្ណឹងទេ សូម្បីតែសីលទាំងឡាយដ៏សេសសល់ពីនេះទៀត ក៏គង់តែបែកធ្លាយដូចគ្នាទាំងអស់ ។*

*ព្រោះហេតុអ្វី ? ព្រោះថា សាមណេរទាំងឡាយជានិពន្ធសីល គឺថាមានសីលជាប់មិនដាច់ ជាចាំបាច់ចំពោះភេទនៃខ្លួនជាសាមណេរ ឬជាកម្មពន្ធៈនៅជាប់ដោយកម្មប្រចាំភេទ ។*

*បើសាមណេរដឹងខ្លួនថា កិរិយាប្រព្រឹត្តកន្លងនូវសិក្ខាបទនោះជាវត្ថុទណ្ឌកម្មហើយ ដូច្នេះក៏សូមទណ្ឌកម្ម ធ្វើតបនូវទោសនោះៗ ក្នុងសិក្ខាបទនោះៗ* ***សីលំ បរិបុណ្ណំ ហោតិ*** *សីលក៏កើតឡើង ពេញបរិបូណ៌វិញដូចដើម ។*

*សិក្ខាបទទាំង ១០ នេះ បុគ្គលសមាទានដោយឆន្ទៈ*

វីរិយៈ ចិត្តៈ វិមំសា យ៉ាងខ្សោយ ក៏ឈ្មោះថា **ហីនៈ** ( អន់ថយ ) ។ ដោយឆន្ទៈ វីរិយៈ ចិត្តៈ វិមំសា យ៉ាងកណ្ដាល ក៏ឈ្មោះថា **មជ្ឈិម** ( យ៉ាងកណ្ដាល ) ។ ដោយឆន្ទៈ វីរិយៈ ចិត្តៈ វិមំសា យ៉ាងប្រណីត ក៏ឈ្មោះថា **ឧត្តម** ( ប្រណីត យ៉ាងល្អ ) ។ ន័យម្យ៉ាងទៀត សិក្ខាបទ ១០ នេះ សៅហ្មង ដោយតណ្ហា ទិដ្ឋិ និង មានះ ឈ្មោះថា **យ៉ាងខ្សោយ** ។ មិន សៅហ្មងឈ្មោះថា **យ៉ាងកណ្ដាល** ។ ដែលបញ្ញាត្រួតត្រាក្នុង សិក្ខាបទនោះៗ ឈ្មោះថា **យ៉ាងល្អប្រណីត** ។ ន័យមួយទៀត សិក្ខាបទពួកនោះ ដែលសមាទានដោយកុសលចិត្តជាញាណ វិប្បយុត្តប្រាសចាកសេចក្ដីដឹង ឈ្មោះថា **យ៉ាងខ្សោយ** ។ ដែលសមាទាន ដោយកុសលចិត្តជាញាណសម្បយុត្ត ប្រកប ដោយសេចក្ដីដឹង ជាសសង្ខារិក មានគ្រឿងដឹកនាំ ឈ្មោះថា **យ៉ាងកណ្ដាល** ។ ដែលសមាទានដោយកុសលចិត្តជាញាណ សម្បយុត្ត ជាអសង្ខារិកមិនមានគ្រឿងដឹកនាំ ឈ្មោះថា **យ៉ាង ល្អប្រណីត** ។ គប្បីជ្រាបថា សិក្ខាបទមានយ៉ាងខ្សោយជាដើម ដូចពោលមកដូច្នេះ ។

## វិធីសមាទានសីល ១០

អ្នកសមាទានសីល ១០ មុននឹងសូមសីលត្រូវនមស្ការរំឭកគុណ ព្រះរតនត្រ័យជាមុនសិន តាមអធ្យាស្រ័យ ។

អ្នកសមាទានម្នាក់ ត្រូវសូធ្យថា ៖

ឱកាស អហំ ភន្តេ, តិសរណេន សហ ទស សីលានិ យាចាមិ, អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ

សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាសូមនូវសីលទាំងឡាយ ១០ ព្រមទាំងព្រះត្រៃសរណគមន៍ផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្ដីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណា ។

ទុតិយម្បិ អហំ ភន្តេ, តិសរណេន សហ ទស សីលានិ យាចាមិ, អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ

"បពិត្រព្រះករុណាដ៏ចម្រើន" ខ្ញុំព្រះករុណា សូមនូវសីលទាំងឡាយ ១០ ព្រមទាំងព្រះត្រៃសរណគមន៍ផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្ដីអនុគ្រោះឱ្យនូវសីលដល់ខ្ញុំព្រះករុណា អស់វារៈជាគម្រប់ពីរដងផង ។

តតិយម្បិ អហំ ភន្តេ, តិសរណេន សហ ទស

**សីលានិ យាចាមិ, អនុគ្គហំ កត្វា សីលំ ទេថ មេ ភន្តេ**

*"បពិត្រព្រះករុណាដ៏ចម្រើន" ខ្ញុំព្រះករុណា សូមនូវសីលទាំងឡាយ ១០ ព្រមទាំងព្រះត្រៃសរណគមន៍ផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះឱ្យនូវសីលដល់ខ្ញុំព្រះករុណា អស់វារៈជាគម្រប់បីដងផង ។*

*បើអ្នកសមាទានច្រើននាក់ត្រូវសូធ្យថា ៖*

**ឱកាស មយំ ភន្តេ, តិសរណេន សហ ទស សីលានិ យាចាម, អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ**

*សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវសីលទាំងឡាយ ១០ ព្រមទាំងព្រះត្រៃសរណគមន៍ផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះឱ្យនូវសីល ដល់ខ្ញុំព្រះករុណាទាំងឡាយ ។*

**ទុតិយម្បិ មយំ ភន្តេ, តិសរណេន សហ ទស សីលានិ យាចាម, អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ**

*"បពិត្រព្រះករុណាដ៏ចម្រើន" ខ្ញុំព្រះករុណាទាំងឡាយ សូមនូវសីលទាំងឡាយ ១០ ព្រមទាំងព្រះត្រៃសរណគមន៍ផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តី*

*អនុគ្រោះឱ្យនូវសីល ដល់ខ្ញុំព្រះករុណាទាំងឡាយ ។ អស់វារៈជាគម្រប់ពីរដងផង ។*

តតិយម្បិ មយំ ភន្តេ, តិសរណេន សហ ទស សីលានិ យាចាម, អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ

*"បពិត្រព្រះករុណាដ៏ចម្រើន" ខ្ញុំព្រះករុណាទាំងឡាយ សូមនូវសីលទាំងឡាយ ១០ ព្រមទាំងព្រះត្រៃសរណគមន៍ផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះឱ្យនូវសីល ដល់ខ្ញុំព្រះករុណាទាំងឡាយ ។ អស់វារៈជាគម្រប់បីដងផង ។*

*រួចលោកអ្នកឱ្យសីលពោលពាក្យថា ៖*

យមហំ វទាមិ តំ វទេហិ *"អាត្មាពោលនូវពាក្យណា ចូរអ្នកពោលនូវពាក្យនោះ" ។ បើឧបាសក ឧបាសិកាច្រើនគ្នាតាំងពីពីរនាក់ ឡើងទៅលោកអ្នកឱ្យសីលត្រូវថា ៖*

យមហំ វទាមិ តំ វទេថ *"អាត្មាពោលនូវពាក្យណា ចូរអ្នកទាំងឡាយពោលនូវពាក្យនោះ" ។*

*អ្នកទទួលសីលត្រូវតបថា* អាម ភន្តេ *"ករុណាលោកម្ចាស់" ។*

រូបលោកអ្នកឱ្យសីលត្រូវតាំង នមោ ៣ ចប់ រូបហើយឱ្យព្រះត្រៃសរណគមន៍, អ្នកសមាទានត្រូវទទួលថាតាមលោក, រូបលោកប្រាប់អំពីកិច្ចកាន់យកព្រះត្រៃសរណគមន៍ ដូចក្នុងវិធីបច្ចេកសមាទានខាងដើម រូបលោកឱ្យសីល ១០ តទៅទៀត ។

១- **បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

២- **អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឱ្យដោយកាយឬដោយវាចា ។

៣- **អព្រហ្មចរិយា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តនូវធម៌មិនប្រសើរគឺសេពនូវមេថុនធម្ម ។

៤- **មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

៥- **សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ**

សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទគឺចេតនាជាហេតុ វៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ។

៦- **វិកាលភោជនា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុ វៀរចាកកិរិយាបរិភោគនូវភោជនាហារក្នុងកាលខុស ។

៧- **នច្ចគីតវាទិតវិសូកទស្សនា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុ វៀរចាកកិរិយារាំ និងច្រៀង និងប្រគំ និងមើលនូវល្បែង ដែលជាសត្រូវដល់កុសលធម៌ ។

៨- **មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាទ្រទ្រង់ និងប្រដាប់ និងតាក់តែង ស្អិតស្អាងរាងកាយដោយផ្កាកម្រង និងគ្រឿងក្រអូបនិងគ្រឿងលាបផ្សេងៗ ។

៩- **ឧច្ចាសយនមហាសយនា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ

គឺចេតនាជាហេតុវៀរចាក ទីសេនាសនៈដ៏ខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ ។

**១០- ជាតរូបរជតប្បដិគ្គហណា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាទទួលកាន់យកនូវមាសនិងប្រាក់ដោយខ្លួនឯង, ឬប្រើអ្នកដទៃឱ្យទទួលកាន់យក, ឬត្រេកអរចំពោះមាសនិងប្រាក់នោះ ។

លុះទទួលសីល ១០ ចប់ហើយ លោកអ្នកឱ្យសីលគួរប្រាប់បញ្ជាក់ថា ៖

**ឥមានិ ទស សិក្ខាបទានិ អប្បមាទេន សម្មារក្ខិតព្វំ**

អ្នក/អ្នកទាំងឡាយ ត្រូវរក្សាដោយប្រពៃនូវសិក្ខាបទទាំងឡាយ ១០ នេះ កុំបីធ្វេសប្រហែសឡើយ ។

អ្នកសមាទានត្រូវទទួលថា **អាម ភន្តេ** "ករុណាលោកម្ចាស់" លំដាប់មកទៀត លោកអ្នកឱ្យសីលសម្តែងអានិសង្សសីល ដោយសង្ខេប ឬដោយពិស្តារ ឱ្យអ្នកសមាទានស្តាប់តាមកាលដ៏គួរ តាមតែសម្តែងអានិសង្សសីលត្រង់ណាក៏បាន តាមសមត្ថភាពរបស់លោកអ្នកឱ្យសីល ។

## អានិសង្សសីលសង្ខេប

សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា
សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ

*សត្វទាំងឡាយទៅកាន់សុគតិភព ក៏ព្រោះសីល, សត្វទាំងឡាយ បានបរិបូណ៌ដោយភោគៈ ក៏ព្រោះសីល, សត្វទាំងឡាយបានទៅកាន់ទីរំលត់ទុក្ខពោលគឺព្រះនិព្វាន ក៏ព្រោះសីល, ព្រោះហេតុនោះ បុគ្គលជាសប្បុរស គប្បីជម្រះនូវសីលឱ្យបរិសុទ្ធ កុំឱ្យសៅហ្មងឡើយ ។*

កិកីវ អណ្ឌំ ចមរីវ វាលធឹ បិយំវ បុត្តំ
នយនំវ ឯកកំ តថេវ សីលំ អនុរក្ខមានកា
សុបេសលា ហោថ សទា សគារវា ។

*សត្វត្រដេវវិច រក្សានូវស៊ុតវា យ៉ាងណា, សត្វចាមរី រក្សានូវកន្ទុយរបស់វា យ៉ាងណា, មាតារក្សានូវកូនប្រុសជាទីស្រឡាញ់តែមួយ យ៉ាងណា, ជនមានភ្នែកតែម្ខាងរក្សានូវភ្នែក យ៉ាងណាមិញ, អ្នកទាំងឡាយ កំពុងរក្សាសីល ជាអ្នកមានសីលជាទីស្រឡាញ់ក្រៃលែង ចូរជាអ្នកប្រកបដោយសេចក្តីគោរពសីលឱ្យបានសព្វៗ កាល ក៏យ៉ាងនោះដែរ ។*

សីលំ យោគិស្ស លង្ការោ
សីលំ យោគិស្ស មណ្ឌនំ
សីលេហិ លង្កតោ យោគី
មណ្ឌនេ អគ្គតំ គតោ ។

សីលជាគ្រឿងអលង្ការរបស់យោគី ( អ្នករក្សាសីល ), សីលជាគ្រឿងប្រដាប់របស់យោគី, យោគីប្រដាប់តាក់តែង ដោយសីលទាំងឡាយ បានដល់នូវភាវៈខ្ពង់ខ្ពស់ក្នុងការប្រដាប់ ( រាងកាយ ) ។

សីលនេះលោករាប់ថា ជាអរិយទ្រព្យ ជាទ្រព្យប្រសើរ វិសេសថ្លៃថ្លាជាងទ្រព្យមានវិញ្ញាណ ឥតវិញ្ញាណរបស់បុរស ស្ត្រីក្នុងលោកនេះ ។ ពុទ្ធសាសនិកជន អ្នកមានវិចារណញ្ញាណ គង់នឹងអាចរិះរកឃើញ យល់បានដោយងាយៗ ។

ន បុប្ផគន្ធោ បដិវាតមេតិ
ចន្ទនំ តគរមល្លិកា វា សតញ្ច
គន្ធោ បដិវាតមេតិ សព្វា ទិសា
សប្បុរិសោ បវាយតិ ។

ក្លិនផ្កាបក់ផ្សាយប្រាសខ្យល់ពុំបានទេ ក្លិនខ្លឹមចន្ទន៍ក្តី ក្លិន

ក្រស្នាក្តី ក្លិនផ្កាម្លិះវត្តក្តី បក់ផ្សាយប្រាសខ្យល់ពុំបានទេ មានតែក្លិននៃពួកសប្បុរស (អ្នកមានសីល) ទើបបក់ផ្សាយប្រាសខ្យល់បាន សប្បុរស (អ្នកមានសីល) បក់ផ្សាយក្លិនសព្វទិសានុទិស ទាំងបណ្តោយខ្យល់ ទាំងប្រាសខ្យល់ ។

ចន្ទនំ តគរំ វាបិ ឧប្បលំ អថ វស្សិកី
ឯតេសំ គន្ធជាតានំ សីលគន្ធោ អនុត្តរោ ។

ខ្លឹមចន្ទន៍ក្តី ក្រស្នាក្តី ផ្កាឧប្បលក្តី ផ្កាម្លិះលាក្តី (សុទ្ធតែមានក្លិនក្រអូប) ប៉ុន្តែក្លិនសីលក្រអូបក្រៃលែងជាងគន្ធជាតទាំងនុ៎ះ (ឥតមានគន្ធជាតអ្វី ក្រអូបដូចក្លិនសីលឡើយ ) ។

សព្វេសំ គន្ធជាតានំ សម្បត្តិ អភិកុយ្យតិ
អរិយាតី ឧសនិសា សីលគន្ធោ បវាយតិ ។

(លោកថា សូម្បីក្លិនកាយរបស់អ្នកមានសីល មានពួកភិក្ខុអ្នកមានសីលជាដើម ក៏រមែងធ្វើឱ្យកើតបាមោជ្ជៈ ដល់ទេវតាទាំងឡាយទៅហើយ ចាំបាច់ឡើយនិយាយដល់ក្លិនសីលដែលធ្វើបាមោជ្ជៈដល់ទេវតានោះអី) បានជាមានបាលីគាថាដែលប្រែថា ក្លិនសីលរមែង(ក្រអូប) គ្របសង្កត់នូវគន្ធជាតក្នុងពួកផ្កាទាំងអស់ ក្លិនសីលរមែងសាយភាយបក់ទៅកាន់ទិសទាំង ១០

ឥតមានទើសទាក់ឡើយ ។ ប្រជុំគាថានេះមកថា សីលមានក្លិនក្រអូបសាយសព្វគ្រប់ទិសទាំង ១០ ក្រអូបត្រឡប់ច្រាសខ្យល់ក៏បាន ឥតមានទើសទាល់សល់ចន្លោះឡើយ ។

យា មនុស្សេសុ សម្បត្តិ យា ច ទេវេសុ សម្បទា
ន សា សម្បន្នសីលស្ស ឥច្ឆិតា ហោតិ ទុល្លភា ។

សម្បត្តិណា ក្នុងមនុស្សទាំងឡាយក្តី សម្បទាឯណាក្នុងទេវតាទាំងឡាយក្តី សម្បត្តិនិងសម្បទានោះៗ ជនអ្នកមានសីល មិនបាច់ប្រាថ្នាឡើយ ជារបស់បានងាយៗ ដោយមិនលំបាកឡើយ ។ ( ដូច្នេះជនអ្នកមានសីលរមែង បានសម្រេចដូចបំណងគ្រប់យ៉ាង ) ។

ន សន្តិ បុត្តា តាណាយ ន បិតា នបិ ពន្ធវា
អន្តកេនាធិបន្នស្ស នត្ថិ ញាតីសុ តាណតា
ឯតមត្ថវសំ ញត្វា បណ្ឌិតោ សីលសំវុតោ
និព្វានគមនំ មគ្គំ ខិប្បមេវ វិសោធយេ ។

បុគ្គលដែលមរណសង្គ្រាម គឺសេចក្តីស្លាប់គ្របសង្កត់ហើយ កូនទាំងឡាយ នឹងមកជួយខាទាំងរាំងរាពុំបាន មាតានិងបិតាទាំងឡាយ នឹងមកជួយខាទាំងរាំងរាពុំបាន ផៅពង្សទាំងឡាយ

នឹងមកជួយខាខាំងរាំងរាពុំបាន គ្រឿងខាខាំងរាំងរាក្នុងញាតិទាំងឡាយ មិនមានសោះឡើយ (ព្រោះហេតុនោះ)បណ្ឌិតដែលមានប្រាជ្ញា កាលបើបានដឹងនូវអំណាចនៃប្រយោជន៍ គឺសីលនុ៎ះហើយ ក៏គួរតែសង្រួមប្រយ័ត្នក្នុងសីល ខំជម្រះនូវផ្លូវសម្រាប់ដើរទៅកាន់ព្រះនិព្វានឱ្យឆាប់រួសរាន់កុំបង្អែបង្អង់ឡើយ ។

## បែបអ្នករក្សាសីល ១០

ឧបាសក ឧបាសិកា អ្នករក្សាសីល ១០ ត្រូវកោរសក់ បើមានពុកមាត់ពុកចង្កា ក៏ត្រូវកោរផងដែរ ត្រូវកាត់ក្រចកដៃ-ជើង ឱ្យស្មើនឹងសាច់ ត្រូវស្លៀកពាក់សឬពានាសំពត់សផងក៏បាន តាមគួរដល់ការលៃលកឱ្យសមរម្យតាមសភាពបុរសនិងស្ត្រី ។ សីលកើតមានឡើង ដោយសារវិរតិចេតនា ពុំមែនដោយសារកោរសក់ ស្លៀកពាក់សទេ ក៏ពិតមែនហើយ ប៉ុន្តែ ការកោរសក់ស្លៀកពាក់សនេះ ជាបវេណីមួយសម្រាប់គ្រហស្ថ អ្នកកាន់សីល ១០ ជាគ្រឿងសម្គាល់ឱ្យឃើញប្លែកពីគ្រហស្ថទាំងឡាយទាំងពួនទាំងជាភស្តុតាងដល់ផ្លូវចិត្តរបស់គ្រហស្ថអ្នកកាន់សីល ១០ នោះទៀតផង ប៉ុន្តែកុំយល់ថា ដូចគ្នានឹងអ្នកដែលស្លៀកពាក់សតាមធម្មតា ឬអ្នកដែលកោរសក់ កោរពុកមាត់ ពុកចង្កា តាមធម្មតា

ឥតមានសមាទានកាន់សីលសោះឡើយ ។ អ្នកកាន់សីលនិងអ្នកមិនកាន់សីល មានគុណធម៌ មានសភាពផ្សេងគ្នា ផ្ទុយគ្នាដោយផ្លូវចិត្ត ដោយចរិយានិងគុណសម្បត្តិ សូម្បីអ្នកកាន់សីលផងគ្នា ក៏គង់តែផ្សេងពីគ្នាដោយសីលធម៌ដែរ គឺភិក្ខុមានសីលខ្ពស់ជាងសាមណេរ, សាមណេរមានសីលខ្ពស់ជាងគ្រហស្ថអ្នកកាន់សីល ១០, គ្រហស្ថអ្នកកាន់សីល ១០ មានថ្នាក់ខ្ពស់ជាងអ្នកកាន់សីល ៨, អ្នកកាន់សីល ៨ មានថ្នាក់ខ្ពស់ជាងអ្នកកាន់សីល ៥ ។

អ្នកកាន់សីលទាំងនេះ សុទ្ធតែគួរគោរពគ្នាតាមលំដាប់ថ្នាក់សីល ទាំងតាមលំដាប់អាយុវស្សាចាស់ ក្មេង ហើយនិងគុណសម្បត្តិផងទៀត ទើបសមគួរតាមលំអានគន្លងគារវធម៌ក្នុងព្រះពុទ្ធសាសនា និងបោរាណកធម៌ ក្នុងកាលព្រេងនាយ សូម្បីសត្វតិរច្ឆានធំតូច ដូចសត្វទទា ស្វា ដំរី ដែលចេះគោរពគ្នាតាមលំដាប់ថ្នាក់អាយុចាស់ក្មេង អាចបានសុគតិភពជាទិដ្ឋានុគតិឱ្យមនុស្សយកតម្រាប់បានដែរ ។

( ចប់វិធីសមាទានសីល )

## ពណ៌នាសិក្ខាបទ

កាលសម្តែងវិធីចូលកាន់ព្រះសាសនា ដោយការដល់សរណគមន៍យ៉ាងនេះហើយ ដើម្បីនឹងពណ៌នាបាលីសិក្ខាបទដែលតាំងជាបទសង្ខេបទុក ដើម្បីសម្តែងសិក្ខាបទទាំងឡាយដែលឧបាសក ឬបព្វជិត អ្នកចូលមកកាន់ព្រះសាសនាគប្បីសិក្សាឥឡូវនេះ ខ្ញុំម្ចាស់នឹងពោលមាតិកាដូចតទៅ :

- សិក្ខាបទពួកនេះ អ្នកណាជាអ្នកពោល ?
- ពោលក្នុងទីណា ?
- ពោលក្នុងកាលណា ?
- ពោលព្រោះហេតុអ្វី ?

ក្នុងមាតិកានោះ ១០ សិក្ខាបទ មាន **បាណាតិបាតាវេរមណី** ជាដើមនោះ ព្រះមានព្រះភាគតែមួយព្រះអង្គប៉ុណ្ណោះត្រាស់ទុក មិនមែនពួកសាវកពោលទេ ។ មែនពិត ព្រះមានព្រះភាគ ស្តេចយាងពីក្រុងកបិលភស្តុដល់ក្រុងសាវត្ថី ទ្រង់ឱ្យព្រះរាហុលបព្វជ្ជាហើយ ក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ត្រាស់សិក្ខាបទ ១០ នោះ ដើម្បីទ្រង់កំណត់សិក្ខាបទសម្រាប់សាមណេរទាំងឡាយ សម

ដូចដែលលោកពោលពាក្យនេះទុកថា គ្រានោះ ព្រះមានព្រះភាគ ប្រថាប់តាមព្រះពុទ្ធអធ្យាស្រ័យ ក្នុងក្រុងកបិលព័ស្តុហើយ ស្តេចយាងទៅកាន់ក្រុងសាវត្ថី កាលស្តេចយាងមកតាមលំដាប់ក៏ដល់ក្រុងសាវត្ថី ។ គ្រានោះ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី សម័យនោះ ។ល ។ សាមណេរទាំងឡាយកើតសេចក្តីត្រិះរិះថា សិក្ខាបទទាំងឡាយរបស់ពួកយើងមានប៉ុន្មានហ្ន៎ ពួកយើងនឹងគប្បីសិក្សានូវសិក្ខាបទចំនួនប៉ុន្មាន ភិក្ខុទាំងឡាយទើបនាំសេចក្តីនោះក្រាបទូលដល់ព្រះមានព្រះភាគៗ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត សិក្ខាបទ ១០ សម្រាប់សាមណេរទាំងឡាយ ដើម្បីសាមណេរទាំងឡាយ សិក្សាក្នុងសិក្ខាបទ ១០ នោះគឺ **បាណាតិបាតា វេរមណី** ។ល ។ **ជាតរូបរជតប្បដិគ្គហណា វេរមណី** ដូច្នេះ ។

សិក្ខាបទ ១០ នេះ គប្បីជ្រាបថា លោកលើកឡើងដើម្បីប្រៀនប្រដៅ ដោយទាក់ទងព្រះសូត្រថា **សមាទាយ សិក្ខតិ សិក្ខាបទេសុ** : សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ និងដោយបាលីដែលលោកសម្តែងទុកក្នុងសរណគមន៍ យ៉ាងនេះថា

**បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ** : ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទគឺ ចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វជាដើម គប្បីជ្រាបន័យថា "សិក្ខាបទពួកនេះ អ្នកណាពោល ពោលក្នុងទីណា ពោលក្នុងកាលណា ពោលព្រោះហេតុអ្វី និងពោលន័យនោះ" ប៉ុណ្ណេះសិន ។

## ពន្យល់បទទូទៅ

ក៏ព្រោះបទពួកនេះថា **វេរមណី សិក្ខាបទំ សមាទិយាមិ** ក្នុងបទទាំងនោះជាបទទូទៅគ្រប់សិក្ខាបទដូច្នេះ គប្បីជ្រាបសេចក្តីពន្យល់បទពួកនោះទូទៅ ទាំងព្យញ្ជនៈ ទាំងអត្ថដូចតទៅនេះ ៖

ក្នុងបទទាំងនោះ គប្បីជ្រាបដោយព្យញ្ជនៈជាមុន ឈ្មោះថា **វេរមណី** ព្រោះវៀរចាក អធិប្បាយថា លះបង់ គឺធ្វើឱ្យអស់មិនមានសល់ ។ ន័យមួយទៀត បុគ្គលរមែងវៀរចាកដោយចេតនាខ្លួនធ្វើយ៉ាងនោះ ព្រោះហេតុនោះ ចេតនានោះ ឈ្មោះថា **វេរមណី** ព្រោះផ្លាស់ វិ ជា វេ ។ ដោយហេតុនោះឯងក្នុងពាក្យនេះ ពុទ្ធបរិស័ទគប្បីសូធ្យបានពីរយ៉ាងថា **វេរមណី**

**សិក្ខាបទំ** ឬ **វិរមណី សិក្ខាបទំ** ។ ឈ្មោះថា សិក្ខា ព្រោះជាចំណែកដែលបុគ្គលគប្បីសិក្សា ។ ឈ្មោះថា បទ ព្រោះជាគ្រឿងដល់, បទនៃសិក្ខា, បទនៃសិក្ខាឈ្មោះថា **សិក្ខាបទ** អធិប្បាយថា ឧបាយជាគ្រឿងដល់សិក្ខាបទ ។ ន័យម្យ៉ាងទៀត លោកអធិប្បាយថា ជាមូល ជាទីអាស្រ័យ ជាទីតាំង ។ សិក្ខាបទ គឺចេតនាជាគ្រឿងវៀរចាក ឈ្មោះថា **វេរមណី សិក្ខាបទ** ឬ **វិរមណី សិក្ខាបទ** តាមន័យទាំងពីរ ។ ខ្ញុំម្ចាស់សូមកាន់យកដោយប្រពៃ ឈ្មោះថា **សមាទិយាមិ** លោកអធិប្បាយថា ខ្ញុំម្ចាស់សូមសមាទាន ដោយប្រាថ្នាដើម្បីនឹងមិនប្រព្រឹត្តល្មើស ព្រោះជាអ្នកធ្វើសិក្ខាបទមិនឱ្យអន់ មិនឱ្យដាច់ មិនឱ្យសៅហ្មង ។

តែបើពោលដោយអត្ថ បទថា **វេរមណី** បានដល់ វិរតិចេតនាវៀរចាក ប្រកបដោយចិត្តដែលជាកាមាវចរកុសល, វិរតិនោះ របស់បុគ្គលអ្នកវៀរចាកបាណាតិបាត លោកពោលទុកក្នុងវិភង្គ ដោយន័យជាដើមយ៉ាងនេះថា ចេតនាវៀរ ចេតនាវៀរចាក វៀរចាកជាដាច់ខាត លះបង់ មិនធ្វើ មិនកន្លង មិនល្មើស ការដកស្ពានចេញដោយអរិយមគ្គ ឈ្មោះថា សេតុ ចាក

បាណាតិបាត ក្នុងសម័យនោះ យ៉ាងណា ។ ធម្មតាថា វេរមណីនោះ សូម្បីលោកុត្តរមានក៏ដោយ ប៉ុន្តែក្នុងទីនេះ ក៏គួរជាវេរមណីដែលប្រព្រឹត្តទៅដោយការសមាទាន ព្រោះអ្នកសមាទានពោលថា **សមាទិយាមិ** ព្រោះដូច្នោះ វេរមណីជាលោកុត្តរៈនោះ ទើបមិនមាន, ខ្ញុំម្ចាស់ពោលថា វិរតិ ចេតនាវៀរចាកប្រកបដោយចិត្តដែលជាកាមាវចរកុសល ។

បទថា សិក្ខា បានដល់ សិក្ខា ៣ គឺ **អធិសីលសិក្ខា អធិចិត្តសិក្ខា អធិបញ្ញាសិក្ខា** ។ តែក្នុងទីនេះ សីលគឺសម្បត្តវិរតិ វិបស្សនាផ្នែកលោកិយ រូបជ្ឈាន អរូបជ្ឈាន និងអរិយមគ្គលោកប្រាថ្នាថា **សិក្ខាបទ** ក្នុងបទថា **សិក្ខា** ក្នុងបទថា សិក្ខាបទនេះ, ដូចដែលទ្រង់ត្រាស់ទុកថា ៖

ធម៌ពួកណា ឈ្មោះថា **សិក្ខា** សម័យណា ចិត្តជាកុសលផ្នែកកាមាវចរៈកើតឡើង មួយអន្លើដោយសោមនស្ស ប្រកបដោយញាណ ។ល ។ សម័យនោះ ផស្សៈក៏មាន ។ល ។ សេចក្ដីមិនរួលរាយក៏មាន ធម៌ពួកនេះ ឈ្មោះថា **សិក្ខា** ។

ធម៌ពួកណា ឈ្មោះថា **សិក្ខា** សម័យណា ព្រះយោគាវចរចម្រើនមគ្គ ដោយការចូលដល់រូបជ្ឈាន ស្ងាត់ចាក

កាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលដល់បឋមជ្ឈាន ។ល។ សេចក្តីមិនរវល់រវាយក៏មាន ធម៌ពួកនេះឈ្មោះថា សិក្ខា ។

ធម៌ពួកណា ឈ្មោះថា សិក្ខា សម័យណា ព្រះយោគាវចរចម្រើនមគ្គ ដោយការចូលដល់រូបជ្ឈាន ។ល។ មួយអន្លើដោយនេវសញ្ញានាសញ្ញាយតនជ្ឈាន ។ល។ សេចក្តីមិនរវល់រវាយក៏មាន ធម៌ពួកនេះឈ្មោះថា សិក្ខា ។

ធម៌ពួកណា ឈ្មោះថា សិក្ខា សម័យណា ព្រះយោគាវចរចម្រើន លោកុត្តរជ្ឈាន ជាធម៌ធ្វើសត្វចេញចាកទុក្ខ ។ល។ សេចក្តីមិនរវល់រវាយក៏មាន ធម៌ពួកនេះឈ្មោះថា សិក្ខា ។

បទគឺឧបាយជាគ្រឿងដល់ ន័យម៉្យាងទៀត ជាមូល ជាទីអាស្រ័យ ជាទីតាំងនៃសិក្ខាបទណាមួយ បណ្តាសិក្ខាបទពួកនោះ ព្រោះហេតុនោះ ទើបឈ្មោះថា សិក្ខាបទ សមដូចដែលលោកពោលទុកដូច្នេះថា “ព្រះយោគាវចរអាស្រ័យសីល តាំងនៅក្នុងសីល កាលចម្រើនធ្វើឱ្យច្រើននូវពោជ្ឈង្គៈ ៧” យ៉ាងនេះជាដើម ។ គប្បីយល់ដោយព្យញ្ជនៈ ដោយអត្ថគ្រប់សិក្ខាបទក្នុងបទនោះៗ ដោយប្រការដូច្នេះចុះ ។

## ១. បាណាតិបាតសិក្ខាបទ

*បាណាតិបាត* វធកចេតនាដែលក្លែងសម្លាប់សត្វមានជីវិតឱ្យស្លាប់នោះ គឺសរីរៈរបស់សត្វកំពុងរស់នៅ ចាប់តាំងពីបឋមវិញ្ញាណឡើងទៅ ។

វិនយត្ថមញ្ជូសាដីកាថា ចាប់តាំងពីកលលរូបកើត មួយអន្លើដោយបដិសន្ធិវិញ្ញាណ ។ សម្លាប់មនុស្ស និងអមនុស្ស មានព្រះឥន្ទជាដើម សុទ្ធតែបែកធ្លាយនូវបាណាតិបាតសិក្ខាបទទាំងអស់ ។

(ស្ត្រីសម្លាប់គភ៌ដែលតាំងនៅក្នុងផ្ទៃរបស់ខ្លួន ក៏ជាបាណាតិបាតដោយពិត) ។

វធកចេតនា គឺចេតនាដែលសម្លាប់របស់បុគ្គលដែលសម្គាល់ថា សត្វមានជីវិត ក្នុងសត្វដែលមានជីវិតមែន ប្រព្រឹត្តទៅក្នុងកាយទ្វារ ឬវចីទ្វារណាមួយ អាចញ៉ាំងសេចក្តីព្យាយាមឱ្យកើតឡើងដើម្បីផ្តាច់បង់នូវជីវិតិន្ទ្រិយរបស់សត្វនោះ ហៅថា បាណាតិបាត ។

បើសម្លាប់មាតា បិតា ព្រះអរហន្ត ដែលហៅថា **មាតុឃាត បិតុឃាត អរហន្តឃាត** នោះ មានទោស ២ ជាន់គឺ :

ទី ១ ដាច់សិក្ខាបទ

ទី ២ ត្រូវទោសអនន្តរិយកម្ម ។

បាណាតិបាតនេះ បើពោលទៅតាមប្រយោគនៃការព្យាយាមសម្លាប់នោះមាន ៦ យ៉ាងគឺ :

ក ) **សាហត្ថិកោ** ព្យាយាមសម្លាប់សត្វដោយខ្លួនឯង ដោយកាយរបស់ខ្លួនក្តី ដោយវត្ថុដែលជាប់នឹងកាយក្តី ។

ខ ) **និស្សគ្គិយោ** បំណងសម្លាប់សត្វដែលនៅក្នុងទីឆ្ងាយ ហើយ បាញ់ ពួយ គ្រវែង ចោលទៅនូវគ្រឿងប្រហារទាំងឡាយ មានធ្នូ ស្នា លំពែង យន្ត និងដុំថ្មជាដើម ដោយកាយក្តី ដោយវត្ថុដែលជាប់នឹងកាយក្តី ។

ក្នុងសាហត្ថិកៈ និងនិស្សគ្គិយៈ ទាំងពីរនោះ ប្រយោគនីមួយៗ មាន ២ យ៉ាង ដោយប្រភេទចំពោះនិងមិនចំពោះ ។

ប្រយោគដែលចំពោះគឺ អ្នកសម្លាប់សំដៅចំពោះបុគ្គលណា ហើយប្រហារត្រូវបុគ្គលនោះឯងស្លាប់ ត្រូវទោសបាណាតិបាត ។

ក្នុងប្រយោគដែលមិនចំពោះគឺ គិតថា "បុគ្គលណាមួយក៏ដោយ ចូរស្លាប់ចុះ" បើបុគ្គលណាមួយស្លាប់ដោយការប្រហារនោះជាបច្ច័យ ក៏ជាច់បាណាតិបាតសិក្ខាបទ ទោះបីបុគ្គលនោះស្លាប់ក្នុងខណៈត្រឹមតែប្រហារហើយ ឬស្លាប់ពេលក្រោយដោយរោគនោះឯងក៏ដោយ ក៏ត្រូវទោសក្នុងខណៈប្រហារហើយពិត ។

គ ) **អាណត្តិកោ** មានវាចាប្រើអ្នកដទៃឱ្យគេសម្លាប់សត្វដោយគ្រឿងកំណត់ ៦ យ៉ាងគឺ :

- **វត្ថុ** សត្វដែលត្រូវសម្លាប់ ១
- **កាល** ពេលមានពេលព្រឹកនិងពេលរសៀលជាដើម ១
- **ឱកាស** ទីកន្លែងដែលសត្វស្ថិតនៅ មានក្នុងស្រុក ព្រៃ ទ្វារនៃផ្ទះ និងចន្លោះស្រុកជាដើម ១
- **អាវុធ** គ្រឿងអាវុធមានដាវ ព្រួញ និងលំពែងជាដើម ១
- **ឥរិយាបថ** ឥរិយាបថទាំងឡាយ មានកិរិយាដើរអង្គុយជាដើម របស់សត្វដែលខ្លួនប្រើឱ្យគេសម្លាប់នោះ ១
- **កិរិយាវិសេស** ការសម្លាប់ដោយហេតុទាំងឡាយ មានកិរិយាចាក់ កាត់ កាប់ បាញ់ជាដើម ១

បើអ្នកទទួលបង្គាប់ ទៅសម្លាប់សត្វតាមគ្រឿងកំណត់នោះ ទើបជាប់បាណាតិបាតសិក្ខាបទ ។ បើអ្នកទទួលបង្គាប់ ទៅសម្លាប់សត្វខុសពីគ្រឿងកំណត់នោះ មានទោសតែអ្នកសម្លាប់ប៉ុណ្ណោះ ។

ឃ ) ថាវរោ មានបំណងនឹងសម្លាប់ ដោយប្រើនូវគ្រឿងឧបករណ៍ប្រហារដែលជាអសង្ហារិម មានកិរិយាជីកអណ្ដូង និងកិរិយាបង្កប់នូវគ្រឿងសស្ត្រាវុធមានដាវជាដើម និងលាយថ្នាំពិសដាក់ក្នុងបឹង ឬស្រះជាដើម ដើម្បីឱ្យអ្នកដទៃ ដើរមកធ្លាក់មុត ឬពុលស្លាប់ក្ដី ពុំនោះសោតយកនូវអារម្មណ៍ទាំង ៦ ណាមួយដែលគួរស្រឡាញ់ គួរខ្លាច ដើម្បីឱ្យអ្នកដទៃឃើញហើយសង្រេងសង្រែ ខ្លាច ភិតភ័យស្លាប់ក្ដី មួយទៀត ដាក់ខ្នារអន្ទាក់ ទុកឱ្យសម្លាប់អ្នកដទៃក្ដី ឬមួយសរសេរអក្សរពណិ៌នាសេចក្ដីស្លាប់ក្ដី បើអ្នកដទៃស្លាប់ដោយប្រយោគនោះៗ ជាប់សិក្ខាបទបាណាតិបាត ។

វត្ថុដែលជាថាវរប្បយោគដូចជាអន្ទាក់ ខ្នារជាដើមនេះ បើធ្វើដោយខ្លួនឯង ដោយបំណងនឹងសម្លាប់សត្វ ហើយបើកើតសេចក្ដីក្ដៅក្រហាយក្នុងកាលជាខាងក្រោយវិញ គប្បីញ៉ាំងវត្ថុនោះឱ្យវិនាសសិន ទើបរួចទោស, បើយកវត្ថុនោះទៅលក់ឱ្យគេ

ហើយ គប្បីយកថ្លៃទៅទិញវត្ថុនោះៗ យកមកវិញ (ហើយគប្បីញ៉ាំងវត្ថុនោះឱ្យវិនាសសិនទើបរួចទោស) វត្ថុទាំងឡាយដែលត្រូវទម្លាយបោល មានអណ្តូង ចម្រូង អន្ទាក់ និងពាក្យសរសេរអក្សរពណ៌នាសេចក្តីស្លាប់ជាដើមនោះ ត្រូវធ្វើមិនឱ្យនៅសល់ដែលអ្នកដទៃមិនអាចប្រើប្រាស់ ឬផ្សំផ្គុំអានអក្សរសរសេរពណ៌នាពីសេចក្តីស្លាប់ជាដើមនោះបាន បើមិនធ្វើដូច្នេះទេ មិនរួចអំពីដាច់បាណាតិបាតសិក្ខាបទនេះឡើយ ។

ឆ) **វិជ្ជាមយោ** ព្យាយាមនឹងសម្លាប់សត្វដទៃ ឬអ្នកដទៃដោយកិរិយារាយមន្តអាគមផ្សេងៗ គឺមន្តវិសេសទាំងឡាយមានអាប ធ្មប់ជាដើម ដើម្បីឱ្យអ្នកដទៃស្លាប់, បើគេស្លាប់ដោយប្រយោគនោះៗ ដាច់បាណាតិបាតសិក្ខាបទ ។

ច) **ឥទ្ធិមយោ** បើខ្លួនមានឥទ្ធិឫទ្ធិ ដូចជាឫទ្ធិនាគ ឫទ្ធិគ្រុឌ ឬឫទ្ធិយក្ស-ទេវតា ឬឫទ្ធិមហាក្សត្រជាដើម បើចង់ឱ្យអ្នកណាស្លាប់ អ្នកនោះក៏ស្លាប់ដោយឫទ្ធិនោះៗ ដូចចំណង់មែន ទើបដាច់បាណាតិបាតសិក្ខាបទ ។

## ពោលអំពីទោស

បាណាតិបាតនោះ បើបុគ្គលប្រព្រឹត្តទៅក្នុងសត្វតិរច្ឆានជាដើម ដែលប្រាសចាកគុណសម្បត្តិ គឺជាសម្លាប់សត្វដែលមិនមានសីលគុណជាដើម បើសត្វដែលមានសរីរៈតូចមានទោសក៏តូចដែរ, សត្វដែលមានសរីរៈធំ មានទោសក៏ធំដែរ ព្រោះប្រយោគព្យាយាមធំ, បើប្រយោគព្យាយាមស្មើគ្នា ក៏គង់វត្ថុដែលត្រូវសម្លាប់នោះធំ, បើបុគ្គលឱ្យប្រព្រឹត្តទៅក្នុងមនុស្សជាដើម ដែលមានគុណសម្បត្តិ, មនុស្សដែលមានគុណសម្បត្តិតិចមានទោសតិច, មនុស្សដែលមានគុណសម្បត្តិច្រើន មានទោសច្រើន, ពុំនោះ បើទំហំសរីរៈនិងគុណសម្បត្តិស្មើគ្នា លោកសំដៅយកកិលេស និងសេចក្តីព្យាយាមរបស់អ្នកសម្លាប់, បើអ្នកសម្លាប់ មានកិលេសទន់ខ្សោយ ឬសេចក្តីព្យាយាមទន់ខ្សោយមានទោសតិច, បើមានកិលេសក្លៀវក្លា ឬសេចក្តីព្យាយាមក្លៀវក្លា មានទោសច្រើន ។

បាណាតិបាតនេះ មានអង្គ ៥ គឺ :

១- **បាណោ** សត្វមានជីវិត

២- **បាណសញ្ញិតា** សេចក្តីដឹងថាសត្វមានជីវិត

៣- **វធកចិត្តំ** ចិត្តគិតនឹងសម្លាប់

៤- **ឧបក្កមោ** ព្យាយាមនឹងសម្លាប់ដោយប្រយោគណាមួយ

៥- **តេន មរណំ** សត្វស្លាប់ដោយព្យាយាមនោះ ។

**អនាបត្តិ:** ហេតុដែលមិនត្រូវទោសមាន ៦ យ៉ាងគឺ :

១- មិនក្លែង ២- មិនដឹង ៣- មិនប្រាថ្នានឹងសម្លាប់

៤- ជាមនុស្សឆ្កួត ៥- ជាមនុស្សមានចិត្តរវើរវាយ

៦- ជាមនុស្សមានទុក្ខវេទនាគ្របសង្កត់ ។

ត្រង់ពាក្យថា **មិនក្លែង** សំដៅយក មិនបានគិតថា "យើងនឹងសម្លាប់អ្នកនេះ ដោយសេចក្តីព្យាយាមនេះ"

ត្រង់ពាក្យថា **មិនដឹង** សំដៅយក មិនដឹងថា "អ្នកនេះនឹងស្លាប់ដោយសេចក្តីព្យាយាមនេះ" កាលអ្នកដទៃ សូម្បីស្លាប់ទៅដោយសេចក្តីព្យាយាមនោះ ក៏មិនដាច់សិក្ខាបទ ។

ត្រង់ពាក្យថា **មិនប្រាថ្នានឹងសម្លាប់** សំដៅយក មិនប៉ុនប៉ងនឹងឱ្យស្លាប់ ។ មែនពិត អ្នកជទៃនឹងស្លាប់ដោយសេចក្ដីព្យាយាមណា កាលអ្នកនោះសូម្បីត្រូវសម្លាប់ស្លាប់ដោយសេចក្ដីព្យាយាមនោះ ក៏មិនជាទោសដល់អ្នកមិនប្រាថ្នានឹងឱ្យស្លាប់ ។

ត្រង់ពាក្យថា **ជាមនុស្សឆ្កួត** សំដៅយក ឆ្កួត ព្រោះត្រូវយក្ខចូលស្ដិត ឬឆ្កួតព្រោះប្រម៉ាត់កម្រើក គឺ ដែលមានសញ្ញាវិបរិត ។ ឆ្កួតព្រោះប្រម៉ាត់ (កម្រើក) ឈ្មោះថាឆ្កួត ។ ប្រម៉ាត់មាន ២ គឺ ប្រម៉ាត់មានស្រោម ១ ប្រម៉ាត់មិនមានស្រោម ១ ។ ប្រម៉ាត់មិនមានស្រោមជ្រាបពេញរាងកាយ ដូចលោហិត ។ កាលប្រម៉ាត់នោះកម្រើករមែងមាន កម រមាស់ ដំនួចពិស និងសរីរៈញ័ររន្ធត់ជាដើម ។ ចំណែកប្រម៉ាត់មានស្រោម កាលកម្រើក រមែងឆ្កួត ។ ឆ្កួតព្រោះប្រម៉ាត់ ចាត់ថា ឆ្កួតរហូតជានិច្ច មិនបានសញ្ញា ។ ឆ្កួតព្រោះយក្ខចូលស្ដិត នៅត្រឡប់បានសញ្ញាក្នុងពេលខ្លះៗ ។

អ្នកដែលមានសញ្ញាវិបល្លាស លះបង់ចោលនូវហិរិ និងឱត្តប្បៈ ប្រព្រឹត្តកម្ម មិនសមគួរ ។ សូម្បីញាំញីសិក្ខាបទទាំង

ស្រាលទិនផូន់ ក៏មិនដឹងខ្លួន ។ ឈ្មោះថា ជាអ្នកកែខៃមិនបាន សូម្បីព្រោះការផ្សំថ្នាំព្យាបាល ។ ឆ្កួតព្រោះប្រម៉ាត់ក្តី ព្រោះយក្ខ ចូលស្កិតក្តី ចូរលើកទុក, អ្នកណា វង្វេងភ្លេចសតិដោយ ប្រការទាំងពួង វត្ថុអ្វីៗ ទោះជាភ្លើង មាស លាមក ខ្លឹមចន្ទន៍ ក៏មិនស្គាល់ រមែងដើរជាន់ដូចគ្នាទាំងអស់, ឆ្កួតបែបនោះ មិនមានទោស តែកាលត្រឡប់បានសញ្ញាឡើងក្នុងពេលខ្លះៗ ហើយធ្វើទាំងដឹង មានទោស ។

ត្រង់ពាក្យថា **ជាមនុស្សមានចិត្តរវើរវាយ** សំដៅយក អ្នកបញ្ជូនចិត្ត(ទៅតាមអារម្មណ៍) លោកហៅថា ឆ្កួត ព្រោះ យក្ខចូលស្កិត ។ ពួកយក្ខសម្តែងអារម្មណ៍ទាំងឡាយដែលគួរ ខ្លាច ឬស៊ិកដៃចូលតាមមាត់ ហើយច្របាច់ហទយរូប ធ្វើពួក សត្វឱ្យមានសញ្ញាវិបល្លាស ។

ត្រង់ពាក្យថា **ជាមនុស្សមានទុក្ខវេទនាគ្របសង្កត់** សំដៅ យក អ្នកដែលរសាប់រសល់ ព្រោះទុក្ខវេទនា ហួសប្រមាណ គឺ អ្នកត្រូវសេចក្តីសន្ទប់បាត់ស្មារតីគ្របសង្កត់ហើយ រមែងមិន ដឹងអ្វីៗ មានសភាពដូច្នោះ មិនជាប់សិក្ខាបទ ។

# ពោលអំពីអានិសង្ស

ការវៀរចាកបាណាតិបាតសិក្ខាបទនេះ ជាសិក្ខាបទទី ១ មានផល ២៣ យ៉ាងគឺ :

១- អង្គប្បច្ចង្គ សមន្នាគតា បរិបូណ៌ដោយអវយវៈតូច ធំ (មានរាងកាយល្អសមទ្រង់ មិនវិកលវិការ) ។

២- អារោហនបរិនាហសម្បត្តិ ប្រកបដោយរាងកាយខ្ពស់ ហើយសមទ្រង់ផង

៣- ជវនសម្បត្តិ ជាមនុស្សសម្បូរដោយការរាងវៃល្អ

៤- សុបតិដ្ឋិតបាទតា ភាពជាមនុស្សមានជើងជាន់ស៊ប់ល្អ

៥- ចារុតា ភាពជាមនុស្សមានសេចក្តីជ្រះថ្លារុងរឿងផង

៦- សូចិតា ភាពជាមនុស្សស្អាតល្អផង

៧- មុទុតា ភាពជាមនុស្សទន់ភ្លន់គួរសមផង

៨- សុខិតា ភាពជាមនុស្សជួបប្រទះនឹងសុខចម្រើនផង

៩- សូរតា ភាពជាមនុស្សក្លៀវក្លាក្នុងបរិស័ទផង

១០- មហព្វលតា ភាពជាមនុស្សមានកម្លាំងច្រើនផង

១១- វិសិដ្ឋវចនតា ភាពជាមនុស្សមានវាចាពីរោះក្បោះក្បាយផង

១២- អភេជបរិសតា ភាពជាមនុស្សមានបរិស័ទ មិនបែកបាក់ពីខ្លួនផង
១៣- អឆម្ភិតា ភាពជាមនុស្សមិនតក់ស្លុតភ័យខ្លាចផង
១៤- អប្បជំសិកតា ពួកសឹកសត្រូវប្រទូស្តមិនបានផង
១៥- អបក្កមេន អមរណតា ជាមនុស្សមិនស្លាប់ដោយសេចក្តីព្យាយាមនៃអ្នកដទៃឡើយ
១៦- អនន្តបរិវារតា ជាមនុស្សមានបរិវារច្រើនគ្មានទីបំផុត
១៧- សុរូបតា ភាពជាមនុស្សមានរូបល្អស្រស់ផង
១៨- សុសណ្ឋានតា ភាពជាមនុស្សមានទ្រង់ទ្រាយល្អផង
១៩- អប្បាពាធតា ភាពជាមនុស្សមានជម្ងឺតិចផង
២០- អសោកិតា ភាពជាមនុស្សមិនខូចចិត្តដោយសោកឡើយ
២១- លោកបិយតា ជាទីស្រឡាញ់របស់លោកគឺពួកសត្វផង
២២- បិយេហិ មនាបេហិ សទ្ធិអវិប្បយោគតា មិនបានព្រាត់ប្រាសនិរាសចាកសត្វ និងសង្ខារដែលជាទីស្រឡាញ់និងជាទីពេញចិត្តផង
២៣- ទីឃាយុកតា ភាពជាមនុស្សមានអាយុវែងទៅតាមកាល ។

"ចប់ បាណាតិបាតសិក្ខាបទទី ១ "

## ២. អទិន្នាទានសិក្ខាបទ

*អទិន្នាទាន* ចេតនាដែលក្លែងលួចទ្រព្យគេ ដោយយ៉ាងតូច មានម្ជុលមួយឬចេសមួយសរសៃ ថ្នាំមួយបារីឬស្លឹកសង្កែមួយសន្លឹក ដោយហោចទៅ សូម្បីតែស្មៅមួយទង, ដោយយ៉ាងធំ ច្រើនត្រឹមនគរមួយឡើងទៅ យ៉ាងនេះហៅថា *អទិន្នាទាន* ទាំងអស់ ។

**អទិន្នំ ឆាម យំ អទិន្នំ អនិស្សដ្ឋំ អបរិចត្តំ រក្ខិតំ គោបិតំ មមាយិតំ បរបរិគ្គហិតំ ឯតំ អទិន្នំ ឆាម** ដែលហៅថា ***អទិន្នៈ*** គឺរបស់ឯណាដែលគេមិនទាន់ឱ្យ មិនទាន់លះបង់ឱ្យ មិនទាន់ដាច់ចិត្តឱ្យ គេនៅរក្សា នៅគ្រប់គ្រងនៅប្រកាន់ជារបស់គេ នៅហួងហែង នេះហៅថា របស់គេមិនទាន់ឱ្យ ។

**អទិន្នស្ស អាទានំ អទិន្នាទានំ បរស្ស ហរណំ ថេយ្យំ ចោរិកា** ការកាន់យកនូវរបស់ដែលគេមិនបានឱ្យ គឺនាំយកទៅនូវរបស់អ្នកដទៃ សំដៅយកភាពជាអ្នកលួច ភាពជាចោរ ហៅថា ***អទិន្នាទាន*** ។

នៅក្នុងអដ្ឋកថា សទ្ធម្មប្បកាសិនី អដ្ឋកថាខុទ្ទកនិកាយ បដិសម្ភិទាមគ្គ ពន្យល់ពាក្យអទិន្នាទានថា ពាក្យថា **អទិន្នំ** បានដល់ របស់ដែលគេមិនបានឱ្យ គឺរបស់ដែលអ្នកដទៃហួងហែងរក្សា ។ មនុស្សដទៃបាន ទទួលរបស់ដែលខ្លួនធ្វើតាមសេចក្ដីប្រាថ្នា ជាអ្នកមិនគួរបានទទួលអាជ្ញា និងមិនគួរតិះដៀលក្នុងវត្ថុណា កាលវត្ថុនោះ មនុស្សដទៃហួងហែង ខ្លួនក៏ដឹងថា មនុស្សដទៃហួងហែង ថេយ្យចេតនាដែលក្លែងនឹងលួច ប្រព្រឹត្តទៅក្នុងកាយទ្វារ វចីទ្វារណាមួយ ដែលតាំងឡើងដោយសេចក្ដីព្យាយាមដែលនឹងកាន់យករបស់នោះឈ្មោះថា **អទិន្នាទាន** ។

( ពាក្យថា មនុស្សដទៃហួងហែងរក្សា បានដល់ មនុស្សណាមួយក្រៅពីខ្លួន សូម្បីក្មេងតូចដែលត្រូវជាកូន ឬចៅក្ដី ហួងហែងរក្សាវត្ថុអ្វីមួយ ដើម្បីលេង មានផ្លែឈើ ឬស្មៅជាដើម បើមានថេយ្យចិត្តកាន់យកវត្ថុនោះៗ ឱ្យឃ្លាតចាកទីប៉ុនចម្រៀកសក់ ក៏ដាច់អទិន្នាទានសិក្ខាបទ ) ។

ឯប្រភេទនៃការលួចនោះមាន ២៥ ចាត់ជាពួកមាន ៥ ពួកគឺ :

**១- នានាភណ្ឌបញ្ចកៈ** លួចភណ្ឌនៅផ្សេងៗ មាន ៥

២- ឯកភណ្ឌបញ្ចកៈ លួចភណ្ឌតែមួយមាន ៥

៣- សាហត្ថិកបញ្ចកៈ លួចដោយដៃខ្លួនឯងមាន ៥

៤- បុព្វប្បយោគបញ្ចកៈ អាការត្រូវទោសមុន ប្រយោគលួចមាន ៥

៥- ថេយ្យាវហារបញ្ចកៈ អាការលួចដោយលបលាក់បិទបាំងដោយថេយ្យចិត្តមាន ៥ ។

នានាភណ្ឌបញ្ចកៈ ពួកទីមួយនោះមាន ៥ គឺ :

ក) **អាទិយនៈ** អ្នកលួចបានចោទប្រកាន់ រំលោភយកទ្រព្យគេ មានស្រែចម្ការជាដើម, ពេលម្ចាស់ទ្រព្យគេដាច់អាល័យខ្លួនអ្នកលួចក៏ដាក់ធុរៈថា "អញមិនឱ្យវិញទេ" ទើបដាច់អទិន្នាទានសិក្ខាបទ ។

ខ) **ហរណៈ** អ្នកលួចបាននាំទៅនូវភណ្ឌរបស់អ្នកដទៃដោយថេយ្យចិត្តញ៉ាំងវត្ថុដែលនៅលើក្បាល, លើ-ក, លើស្មា លើចង្កេះឱ្យឃ្លាតផុតចាកទីត្រឹមតែប៉ុនចម្រៀកសក់ក៏ដោយ ក៏ដាច់អទិន្នាទានសិក្ខាបទ ។

គ) **អវហរណៈ** អ្នកលួចបានយកទ្រព្យគេ ផ្ញើទុកនឹងខ្លួន ពេលម្ចាស់គេមកទារមិនឱ្យទៅគេ តែម្ចាស់គេដាច់អាល័យ ក៏

ជាច់អទិន្នាទានសិក្ខាបទ ។

ឃ) **ឥរិយាបថវិកោបនៈ** អ្នកលួចបានយកទ្រព្យគេ យកទាំងម្ចាស់ទ្រព្យទៅផង គ្រាន់តែនាំទៅឱ្យផុតជំហានជាគម្រប់ពីរ ក៏ដាច់អទិន្នាទានសិក្ខាបទ ។

ង) **ឋានាចាវនៈ** អ្នកលួចបានយកទ្រព្យគេនៅលើគោក នាំយកទៅឱ្យឃ្លាតចាកទីត្រឹមតែប៉ុនចម្រៀកសក់ក៏ដោយ ក៏ដាច់អទិន្នាទានសិក្ខាបទ ។

**ឯកភណ្ឌបញ្ចកៈ** ពួកទីពីរមាន ៥ គឺ :

ក) **អាទិយនៈ** អ្នកលួចបានចោទប្រកាន់ដណ្តើមយកខ្ញុំកំដរ និងសត្វចិញ្ចឹមរបស់គេ (បើម្ចាស់គេដាក់ធុរៈ) ដាច់អទិន្នាទានសិក្ខាបទ ។

ខ) **ហរណៈ** អ្នកលួចបានជួយនាំទៅនូវខ្ញុំកំដរនិងសត្វចិញ្ចឹមរបស់គេ ហើយមានថេយ្យចិត្ត ក៏លួចយកទៅតែម្តង ដាច់អទិន្នាទានសិក្ខាបទ ។

គ) **អវហរណៈ** អ្នកលួចបានប្រវញ្ចយកខ្ញុំកំដរនិងសត្វចិញ្ចឹមរបស់គេ ដែលគេផ្ញើទុកនឹងខ្លួន ដាច់អទិន្នាទានសិក្ខាបទ ។

ឃ) **ឥរិយាបថវិកោបនៈ** អ្នកលួចមានថេយ្យចិត្តធ្វើឥរិយាបថនៃខ្ញុំកំដរ និងសត្វចិញ្ចឹមរបស់គេឱ្យកម្រើក ដាច់អទិន្នាទានសិក្ខាបទ ។

ង) **ឋានាចាវនៈ** អ្នកលួចមានថេយ្យចិត្តធ្វើខ្ញុំកំដរនិងសត្វចិញ្ចឹមរបស់គេឱ្យឃ្លាតចាកទី ដាច់អទិន្នាទានសិក្ខាបទ ។

**នានាភណ្ឌបញ្ចកៈ** ពួកទី ១ នោះ លោកសំដៅយកវត្ថុដែលមានវិញ្ញាណនិងវត្ថុដែលឥតមានវិញ្ញាណ, ចំណែកឯកភណ្ឌបញ្ចកៈពួកទី ២ សំដៅយកវត្ថុដែលមានវិញ្ញាណម្យ៉ាងប៉ុណ្ណោះ ។

**សាហត្ថិកបញ្ចកៈ** ពួកទីបីនោះមាន ៥ គឺ :

ក) **សាហត្ថិកៈ** អ្នកលួចបានលួចទ្រព្យគេដោយខ្លួនឯងដាច់អទិន្នាទានសិក្ខាបទ ។

ខ) **អាណត្តិកៈ** អ្នកលួចបានប្រើអ្នកដទៃឱ្យលួចទ្រព្យគេ បើអ្នកដទៃលួចបានមកតាមបង្គាប់ ដាច់អទិន្នាទានសិក្ខាបទ ។

គ) **និស្សគ្គិយៈ** អ្នកលួចបានលួចទ្រព្យគេដោយបោះរំលងទីមានរបងនិងទ្វារជាដើម ឬរត់រំលងគយព្រះរាជធានី ដាច់ខូចអទិន្នាទានសិក្ខាបទ ។

ឃ ) អត្ថសាធកៈ អ្នកលួចញុំាងប្រយោជន៍ឱ្យសម្រេច ជាមុន អំពីកិរិយាលួច គឺបង្គាប់អ្នកដទៃថា អ្នកអាចលួចរបស់នៃជនឯណោះ ក្នុងកាលណា ចូរលួចក្នុងកាលនោះចុះ, ប្រសិនបើអ្នកដទៃលួចបានមែន អ្នកបង្គាប់ជាប់អទិន្នាទានសិក្ខាបទ នៅក្នុងខណៈ ដែលបង្គាប់ហើយភ្លាមហ្នឹងឯង ។

ម្យ៉ាងទៀត អ្នកលួចបានលួចយកវត្ថុ មានស្បែកជើងជាដើម ដែលអាចស្រូប បឺត ជក់ ឬជប់យកប្រេងអំពីឆ្នាំងប៉ោតប្រេងរបស់អ្នកដទៃ ដោយគ្រាន់តែដាក់ស្បែកជើងទៅក្នុងឆ្នាំង ផុតពីដៃភ្លាម ក៏ជាប់អទិន្នាទានសិក្ខាបទភ្លាមដែរ ។

ង ) ធុរនិក្ខេបៈ អ្នកលួច បានលួចទ្រព្យគេ សម្រេចដោយការដាក់ធុរៈ ដូចជាចោទប្រកាន់យកដីជាដើម ឬរបស់ដែលគេផ្ញើទុកនឹងខ្លួន ពុំនោះសោត របស់ដែលខ្លួនបានខ្ចីគេមក បើខ្លួនដាក់ធុរៈថា អញនឹងមិនឱ្យ ឯម្ចាស់ទ្រព្យគេក៏ជាប់អាល័យ ជាប់អទិន្នាទានសិក្ខាបទ ។

បុព្វប្បយោគបញ្ចកៈ ពួកទីប្រាំមាន ៥ គឺ :

ក ) បុព្វបយោគៈ អ្នកលួចមានថេយ្យចិត្តហើយប្រើអ្នកដទៃឱ្យទៅលួច, បាននឹងអាណត្តិកៈអ្នកបង្គាប់ឱ្យអ្នកដទៃលួចទ្រព្យ

គេ ដូចពោលមកហើយក្នុងអាណត្តិកៈ ឈ្មោះថា **បុព្វបយោគ** ។

ខ) **សហប្បយោគៈ** អ្នកលួចបានលួចទ្រព្យគេ ដោយព្យាយាមខ្លួនឯង មានបង្ខិតបង្គោលព្រំឱ្យចូលទៅក្នុងទីស្រែចម្ការគេជាដើម ចំនួនទីប្រមាណចុងសក់ ដាច់អទិន្នាទានសិក្ខាបទ ។

គ) **សំវិធាវហារៈ** អ្នកលួចបបួលគ្នាទៅលួចទ្រព្យគេ បើអ្នកណាមួយលួចបានមក ក៏ដាច់អទិន្នាទានសិក្ខាបទទាំងអស់គ្នា ។

ឃ) **សង្កេតកម្មៈ** អ្នកលួចបបួលគ្នាទៅលួចទ្រព្យគេ ដោយកំណត់កាល មានពេលព្រឹកជាដើម បើអ្នកដទៃលួចបានត្រូវតាមកំណត់ កាលដែលប្រើបង្គាប់នោះមែន ដាច់អទិន្នាទានសិក្ខាបទ ។

ង) **និមិត្តកម្មៈ** អ្នកលួចគិតនឹងលួចទ្រព្យគេ ដោយធ្វើនិមិត្តកម្ម មានកិរិយាមិចភ្នែកនិងកិរិយាញាក់មុខជាដើម ដើម្បីឱ្យសញ្ញាដល់អ្នកដទៃដែលខ្លួនប្រើឱ្យទៅលួច បើអ្នកនោះលួចបានមកតាមសញ្ញានោះមែន ដាច់អទិន្នាទានសិក្ខាបទ ក្នុងពេលដែលឱ្យសញ្ញានោះឯង ។

**ថេយ្យាវហារបញ្ចកៈ** ពួកទីប្រាំមាន ៥ គឺ ៖

ក) **ថេយ្យាវហារៈ** អ្នកលួចបានលបកាត់ទីតមានជញ្ជាំងជាដើម ហើយលបចូលលួចរបស់គេក្តី បោកប្រាស់យករបស់គេក្តី ដោយរង្វាស់រង្វាល់ខ្លះ ដោយថ្លឹងខ្លះ ដោយរាប់បន្ទំខ្លះ ឬក្រឡៃដោយកហាបណៈ ក្លែងក្លាយ សំណជាប្រាក់ ស្ពាន់ជាមាសជាដើម កាលបុគ្គលនោះ កាន់យកយ៉ាងនេះ គប្បីដឹងថា លួចដូចជាចោរ ត្រូវជាប់អទិន្នាទានសិក្ខាបទ ។

ខ) **បសយ្ហាវហារៈ** អ្នកលួច កំហែង សង្កត់ សង្កិនប្លន់ ឬឆក់ដណ្តើម យកទ្រព្យរបស់អ្នកដទៃ ជាប់អទិន្នាទានសិក្ខាបទ ។

គ) **បរិកប្បាវហារៈ** អ្នកលួចទ្រព្យគេដោយកិរិយាកំណត់ៗ ក្នុងទីនេះមាន ២ យ៉ាងគឺ ៖

- **ភណ្ឌបរិកប្បៈ** កំណត់ដោយទ្រព្យ ១
- **ឱកាសបរិកប្បៈ** កំណត់ដោយឱកាស ១ ។

ឯកំណត់ដោយទ្រព្យនោះ ដូចជាខ្លួនអ្នកលួច គិតនឹងលួចសំពត់សាដក ហើយលបចូលទៅក្នុងល្វែង ក្នុងវេលាយប់រួចកំណត់ថា "បើជាសំពត់សាដកទើបអញយក បើជាអំបោះ អញ

មិនយក” ស្រាប់តែលើកការុងឡើង បើក្នុងការុងនោះ ជាសំពត់សាដកមែន ដាច់អទិន្នាទានសិក្ខាបទក្នុងខណៈលើកឡើង, បើជាអំបោះទៅវិញនោះ មិនទាន់ដាច់ អទិន្នាទានសិក្ខាបទទេ ។ លុះលើកការុងចេញមកខាងក្រៅ ហើយស្រាយមើលទើបដឹងថាជាអំបោះ ក៏គិតទៀតថា “អញយកបានរបស់ណាមក ត្រូវយករបស់នោះ” ហើយនាំយកទៅផុតជំហានជាគម្រប់ពីរ ដាច់អទិន្នាទានសិក្ខាបទ ។ ប្រសិនណាបើម្ចាស់គេ ដេញតាមស្រែកថា ចោរៗ, ខ្លួនអ្នកលួចក៏ទំលាក់ចោលរត់ទៅ ឥតទាន់ត្រូវទោសអ្វីនៅឡើយ ។ បើអ្នកដទៃណាមួយកាន់យកទៅខ្លួនត្រូវសងគេ ។ ឬបើម្ចាស់គេត្រឡប់ទៅវិញ ខ្លួនឃើញខ្លួនឯង ហើយធ្វើជាកាន់យកដោយសម្គាល់ថា ជារបស់រើស ក៏ដាច់អទិន្នាទានដែរ បើរើសយកទៅសងគេវិញឥតដាច់អទិន្នាទានសិក្ខាបទឡើយ ។

កំណត់ឱកាស ដូចជាអ្នកលួច ចូលទៅកាន់ទីទាំងឡាយមានបរិវេណរបស់បុគ្គលជាដើម ឃើញនូវរបស់បុគ្គលណាមួយដែលខ្លួនចង់បាន ហើយកំណត់ទីឱកាស មានទ្វារល្វែងនិងមុខផ្ទះជាដើម ហើយគិតថា បើពួកម្ចាស់ទ្រព្យគេ ឃើញអញត្រង់ឱកាសនេះ, អញនឹងធ្វើហាក់ដូចជាចាប់កាន់មើល, បើគេមិនឃើញទេ

អញទើងលួចយក, បើកាន់យករបស់នោះ កន្លងផុតត្រឹមទីឱកាស ដែលបានកំណត់ទុកនោះឯង ជាប់អទិន្នាទានសិក្ខាបទ ។

ឃ) **បដិច្ឆន្នាវហារៈ** អ្នកលួចយកទ្រព្យគេ ដោយកិរិយាបិទបាំង ដូចជាឃើញទ្រព្យគេមានចិញ្ចៀនជាដើម ដែលគេដោះទុកក្នុងទីទាំងឡាយមានទីឱទ្យានជាដើម ហើយបិទបាំងគ្របទុកដោយអាចម៍ដី ឬស្លឹកឈើ ដោយគិតទុកថា "អញទើងកាន់យកជាខាងក្រោយ" ។ បើមិនទាន់លើកឡើងឱ្យឃ្លាតផុតចាកទី មិនទាន់ត្រូវទោសទេ, កាលណាម្ចាស់គេមករកមិនឃើញហើយគេគិតថា ចាំស្អែកសឹមដឹងចុះ, គេនៅអាល័យរបស់គេនៅឡើយ ហើយចៀសចេញទៅ ស្រាប់តែខ្លួនឯងទៅលើកយករបស់នោះមក ជាប់អទិន្នាទានសិក្ខាបទ ក្នុងពេលដែលលើកយកនោះឯង ។ បើខ្លួនកាន់យករបស់នោះ ក្នុងកាលដែលខ្លួនបិទបាំងទុកដោយសម្គាល់ថា របស់អញដូច្នេះក្តី ដោយសម្គាល់ថា ជារបស់រើសបាន ឥឡូវនេះ ម្ចាស់គេទៅបាត់ហើយតើ, របស់នេះគឺគេចោលហើយ ដូច្នេះក្តី ខ្លួនក៏ត្រូវសងគេដែរ ពុំនោះសោតពីរបីថ្ងៃក្រោយមក ពួកម្ចាស់គេមករកទៀតមិនឃើញ, គេ

ក៏ដាក់ធុរៈថាលែងរវល់ ហើយចៀសចេញទៅ, បើខ្លួនបានកាន់យករបស់នោះមក ក៏ត្រូវតែសងគេដែរ ។ មួយទៀត បើពេលក្រោយ មកពួកម្ចាស់គេដឹង ហើយទាមទារយកវិញ, បើខ្លួនឯងបិទបាំងរបស់នោះមិនឱ្យ អទិន្នាទានសិក្ខាបទដាច់ក្នុងខណៈដែលម្ចាស់គេដាក់ធុរៈមិនខាន ។ ព្រោះហេតុអ្វី ? ព្រោះថារបស់នោះ គេមិនឃើញដោយប្រយោគដែលខ្លួន លាក់បិទបាំងទុក ។ ម្យ៉ាងទៀត អ្នកណាមួយ មិនបានបិទបាំងគ្របទុកនូវរបស់មានសភាពដូច្នេះ ដែលស្ថិតនៅក្នុងទីដូចបានពោលមកនោះទេ, ប៉ុន្តែមានថេយ្យចិត្ត ហើយជាន់ពន្លិចបង្កប់របស់នោះទៅក្នុងភក់ឬក្នុងដី, អ្នកនោះ ក៏ដាច់អទិន្នាទានសិក្ខាបទហ្នឹងក្នុងខណៈដែលពន្លិចបង្កប់ចូលទៅនោះឯង ។

ង) កុសាវហារៈ អ្នកលួចទ្រព្យគេដោយការប្តូរស្លាកឆ្នោត ដូចជាឃើញស្លាកគេធ្វើពីបន្ទះឫស្សី ឬស្លឹកឆ្នោត គេសរសេរឈ្មោះអ្នកនេះ អ្នកនោះទុក ហើយគេដាក់សំពត់នៅពីក្រោម ស្លាកនៅពីលើឱ្យជាចំណែកៗ ចែកគ្នា, ខ្លួនមានប្រាថ្នានឹងលើកយកចំណែករបស់អ្នកដទៃ ដែលមានតម្លៃតិចនិងច្រើន

ឬមានតម្លៃស្មើគ្នា ដែលទុកនៅជិតចំណែករបស់ខ្លួន ចំណែកខ្លួនចង់ទំលាក់ស្លាក ដែលគេដាក់លើចំណែករបស់ខ្លួនទៅលើចំណែករបស់អ្នកដទៃ ហើយរើហូតលើកឡើង ប៉ុណ្ណោះមិនទាន់ទៅជាអ្វីនៅឡើយទេ, ដល់ទម្លាក់ទៅលើចំណែកអ្នកដទៃ ក៏មិនទាន់ជាអ្វីដែរ ។ លុះត្រាតែស្លាករបស់ខ្លួនធ្លាក់ទៅលើគេ ហើយខ្លួនរើហូតយកស្លាកគេ អំពីចំណែករបស់គេឱ្យខិត ឬឃ្លាតចាកទីតែបន្តិចប៉ុណ្ណោះជាច់អទិន្នាទានសិក្ខាបទ ក្នុងខណៈដែលរើហូតលើកឡើង ។ ន័យមួយទៀត បើខ្លួនចង់ទាញយកស្លាកគេទម្លាក់មកក្នុងស្លាកខ្លួន ហើយរើហូតយកស្លាកអំពីចំណែកគេមុនដំបូង, ក្នុងខណៈដែលរើឡើង មិនទាន់ជាអ្វីទេ, ក្នុងពេលទម្លាក់ក៏មិនទាន់ជាអ្វី ដល់រើយកស្លាកខ្លួនអំពីចំណែកខ្លួនទៅវិញ ក៏នៅមិនទាន់ជាអ្វីដែរ លុះត្រាតែដាក់ស្លាកខ្លួននោះ ទៅក្នុងចំណែកអ្នកដទៃ គ្រាន់តែដាក់ផុតអំពីដៃភ្លាម ដាច់អទិន្នាទានសិក្ខាបទភ្លាម ក្នុងខណៈនោះឯង ។

(រួមប្រភេទនៃការលួចទាំងអស់ត្រូវជា ២៥) បើលួចដោយប្រភេទណាមួយ សុទ្ធតែជាអទិន្នាទានទាំងអស់ ។

## ពោលអំពីទោស

អទិន្នាទាននោះ បើបុគ្គលប្រព្រឹត្តទៅក្នុងទ្រព្យដ៏ថយថោក គឺលួចយកនូវរបស់ ដ៏ថយថោករបស់បុគ្គលដទៃ មានទោសតិច, លួចយកនូវរបស់ដែលថ្លៃមានទោសច្រើន ព្រោះវត្ថុដែលលួចដ៏ថ្លៃថ្លា, បើវត្ថុស្មើគ្នា លួចយកនូវទ្រព្យរបស់បុគ្គលមានគុណសម្បត្តិតិច មានទោសតិច, លួចយកនូវទ្រព្យរបស់បុគ្គលដែលមានគុណសម្បត្តិច្រើន មានទោសច្រើន, ពុំនោះបើលួចយកទ្រព្យតូច មានទោសតិច, លួចយកនូវទ្រព្យធំ មានទោសធំ ព្រោះប្រយោគព្យាយាមធំ, បើវត្ថុដែលលួច និងគុណសម្បត្តិរបស់ម្ចាស់ទ្រព្យស្មើគ្នា លោកកាត់ទោស សម្រេចដោយកិលេស និងសេចក្តីព្យាយាមរបស់អ្នកលួច បើអ្នកលួចមានកិលេសទន់ ឬសេចក្តីព្យាយាមទន់ មានទោសតិច, បើអ្នកលួចមានកិលេសក្លៀវក្លា មានទោសច្រើន ។

អទិន្នាទាននេះ មានអង្គ ៥ គឺ :

១- បរបរិគ្គហិតំ ទ្រព្យដែលមានម្ចាស់គេហួងហែងរក្សា

២- បរបរិគ្គហិតសញ្ញិតា សេចក្ដីដឹងថា ទ្រព្យដែលមានម្ចាស់គេហួងហែងរក្សា

៣- ថេយ្យចិត្តំ ចិត្តគិតនឹងលួច

៤- ឧបក្កមោ ព្យាយាមនឹងលួច ដោយអាការណាមួយ

៥- តេន ហរណំ លួចបានមកដោយសេចក្ដីព្យាយាមនោះ ។

អនាបជ្ជនៈ ហេតុដែលមិនត្រូវទោសមាន ៧ យ៉ាងគឺ :

១- កាន់យកដោយប្រទ្បំថាជារបស់ខ្លួន

២- កាន់យកដោយសេចក្ដីស្និទ្ធស្នាលនឹងគ្នា

៣- កាន់យកជារបស់ខ្ចីគ្នា

៤- កាន់យករបស់ពួកប្រេតហួងហែងរក្សា

៥- កាន់យករបស់សត្វតិរច្ឆានហួងហែងរក្សា

៦- កាន់យកដោយសម្គាល់ថាជារបស់បង្សុកូល

៧- ជាមនុស្សឆ្កួត ។

# ពោលអំពីអានិសង្ស

អធិដ្ឋានសិក្ខាបទនេះ ជាសិក្ខាបទទី ២ មានអានិសង្ស ១១ យ៉ាងគឺ :

១- មហទ្ធនតា ភាពជាមនុស្សមានទ្រព្យច្រើនផង

២- បហូតធនធញ្ញតា ជាមនុស្សមានរបស់របរ និងធញ្ញាហារដ៏សម្បូរកុះកុម

៣- អនន្តភោគតា ជាមនុស្សរកទ្រព្យបានដោយមិនទើសទាល់ជាទីបំផុត

៤- អនុប្បន្នភោគុប្បត្តិតា ភោគទ្រព្យដែលមិនទាន់កើត ក៏កើតឡើងបាន

៥- ឧប្បន្នភោគថាវរតា ភោគទ្រព្យដែលបានកើតឡើងហើយក៏តាំងនៅខ្ជាប់ខ្ជួនមិនខូចខាត

៦- ឥច្ឆិតានំ លាភានំ ខិប្បដិលាភិតា រកទ្រព្យរបស់ដែលប្រាថ្នាបានដោយឆាប់រហ័សមិនលំបាក

៧-អសាធារណភោគតា មានទ្រព្យសម្បត្តិមិនខ្ចាត់ខ្ចាយ អន្តរាយ ទៅដោយរាជភ័យ ចោរភ័យ ឧទកភ័យ អគ្គិភ័យ ឬញាតិឆបោកឡើយ

៨-អសាធារណធនបដិលាភតា រកទ្រព្យបានមកហើយ មិនបានខ្ជះខ្ជាយសាយភាយទៅផ្តេសផ្តាសឡើយ

៩-លោកុត្តរបដិលាភតា សមរម្យជាអ្នកបាននូវលោកុត្តរទ្រព្យទៀតផង

១០-នត្ថិ ភាវស្ស អជាននតា អសវនតា ភាពជាអ្នកមិនធ្លាប់ដឹង មិនធ្លាប់ឮ ដោយគ្រាន់តែពាក្យថាគ្មាននោះឡើយ

១១-សុខវិហារិតា ទៅនៅទីកន្លែងណា ក៏ជួបប្រទះតែនឹងសុខ ។

"ចប់ អទិន្នាទានសិក្ខាបទទី ២ "

## ៣. កាមេសុ មិច្ឆាចារសិក្ខាបទ

ត្រង់សិក្ខាបទទី ៣ នេះ

សីលសង្កាត់ទី ១ សិក្ខាបទទី ៣ ថា **កាមេសុ មិច្ឆាចារៈ**

សីលសង្កាត់ទី ២ សិក្ខាបទទី ៣ ថា **អព្រហ្មចរិយៈ**

មុននឹងសរសេររៀបរៀង **អព្រហ្មចរិយសិក្ខាបទ** ខ្ញុំសូមបង្ក្រងនូវ**កាមេសុ មិច្ឆាចារសិក្ខាបទ** ជាមុនសិនដូចតទៅនេះ ។

**កាមេសុ មិច្ឆាចារៈ** កិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

នៅក្នុងសទ្ធម្មប្បកាសិនី អដ្ឋកថាខុទ្ទកនិកាយ បដិសម្ភិទាមគ្គ, បរមត្ថទីបនី, និងអដ្ឋកថាខុទ្ទកនិកាយ ឥតិវុត្តកៈបានពន្យល់ពាក្យ កាមេសុមិច្ឆាចារៈថា ៖

បទថា **កាមេសុ** បានដល់ ការប្រព្រឹត្តក្នុងមេថុន ។

បទថា **មិច្ឆាចារោ** បានដល់ ប្រព្រឹត្តលាមកដែលគួរដល់ការតិះដៀល ។

តែដោយលក្ខណៈ ចេតនាដែលប្រព្រឹត្តកន្លងឋានៈ ស្ត្រីដែលមិនគួរប្រព្រឹត្តដោយកាយទ្វារ ជាអ្នកប្រាថ្នាប្រព្រឹត្តអាក្រក់

( អសទ្ធម្ម ) ឈ្មោះថា **កាមេសុ មិច្ឆាចារៈ** ។

មេថុនសមាចារៈមាន ២ យ៉ាងគឺ :

- **សទារសន្តោសៈ** សេចក្តីសន្តោសត្រេកអរនឹងភរិយារបស់ខ្លួនដែលមានច្បាប់អនុញ្ញាតតាមប្រពៃណីឱ្យ ១

- **បរទារគមនៈ** កិរិយាគប់រកនូវភរិយានៃបុគ្គលដទៃដែលច្បាប់ហាមឃាត់ ទាំងពីរនេះហៅថា "**កាម**" ព្រោះសត្វតែងប្រាថ្នា ។ កិរិយាប្រព្រឹត្តខុសក្នុងកាមនោះ ឬក្នុងសត្វជាវត្ថុនៃមេថុន ជាមារយាទដ៏លាមក ដែលលោកអ្នកប្រាជ្ញទាំងឡាយមានព្រះសម្មាសម្ពុទ្ធជាដើម តែងតិះដៀលដោយចំណែកមួយហៅថា **កាមេសុ មិច្ឆាចារៈ** ។

ក្នុងអភិធម្មត្ថវិភាវិនីថា **កាម** មានពីរយ៉ាងគឺ **មេថុនកាម ១ រសកាម ១** មេថុនកាម សំដៅយកមេថុនសមាចារ ២ យ៉ាង ដូចពោលមកនេះ, ឯរសកាមសំដៅយករសរបស់អាហារ សទារសន្តោសៈ និងរសរបស់អាហារឯទៀត, តែក្នុងទីនេះដែលហៅថា ប្រព្រឹត្តខុសក្នុងកាមនោះ សំដៅយកបរទារគមនៈ និងសុរាបានៈផង ។

បានសេចក្តីថា កាមខុសទំនងខុសច្បាប់ប្រពៃណីគេ បានជាហៅថា ប្រព្រឹត្តខុសក្នុងកាម បាលីថា **កាមេសុ មិច្ឆាចារៈ** ។ "កាមេសុមិច្ឆាចារហ្នឹងឯង" ។ បានដល់ កិរិយាគប់រកភរិយានៃបុគ្គលដទៃដូចពោលមកហើយ តែបើតាមលក្ខណៈ លោកសំដៅយក អគមនីយដ្ឋានវីតិក្កមចេតនា គឺចេតនាជាហេតុនាំឱ្យប្រព្រឹត្តកន្លងក្នុងស្ថានដែលមិនគួរគប់រក គឺស្ត្រីដែលមានគេហួងហែងរក្សា ឬបុរសដែលមិនមែនជាស្វាមីរបស់ខ្លួន ប្រព្រឹត្តទៅក្នុងកាយទ្វារតែម្យ៉ាង ដោយប្រាថ្នាដើម្បីនឹងសេពអសទ្ធម្ម ហៅថា **កាមេសុ មិច្ឆាចារៈ** ។

ស្ត្រីដែលជាអគមនីយដ្ឋានរបស់បុរស គឺស្ត្រីដែលបុរសមិនគួរគប់រកដោយអសទ្ធម្មនោះមាន ២០ គឺ :

១- **មាតុរក្ខិតា** ស្ត្រីដែលមានមាតាគ្រប់គ្រងរក្សា

២- **បិតុរក្ខិតា** ស្ត្រីដែលមានបិតាគ្រប់គ្រងរក្សា

៣- **មាតាបិតុរក្ខិតា** ស្ត្រីដែលមានមាតាបិតាគ្រប់គ្រងរក្សា

៤- **ភាតុរក្ខិតា** ស្ត្រីដែលមានបងប្រុសឬប្អូនប្រុសគ្រប់គ្រងរក្សា

៥- ភគិនីរក្ខិតា ស្ត្រីដែលមានបងស្រីឬប្អូនស្រីគ្រប់គ្រងរក្សា

៦- ញាតិរក្ខិតា ស្ត្រីដែលមានញាតិគ្រប់គ្រងរក្សា

៧- គោត្តរក្ខិតា ស្ត្រីដែលមានបុគ្គលមានគោត្តជាមួយគ្នា ឬមានជាតិវង្សជាមួយគ្នាគ្រប់គ្រងរក្សា

៨- ធម្មរក្ខិតា ស្ត្រីដែលមានបព្វជិតពួកណាមួយ អ្នកប្រព្រឹត្តធម៌ត្រូវគ្នាគ្រប់គ្រងរក្សា

៩- សារក្ខា ស្ត្រីដែលប្រកបដោយកិរិយារក្សាគឺស្ត្រីដែលមានស្វាមីហើយឬមានគេប្រកាន់ទុករួចហើយ

១០- សបរិទណ្ឌា ស្ត្រីដែលប្រកបដោយអាជ្ញា គឺស្ត្រីដែលព្រះរាជា ដាក់រាជអាជ្ញា មិនឱ្យអ្នកណាប្រព្រឹត្តកន្លងតាមអំពើចិត្ត ឬមិនឱ្យបុរសណាមួយទៅប្រព្រឹត្តកន្លង

១១- ធនក្កីតា ស្ត្រីដែលគេទិញឬលោះដោយទ្រព្យ ទោះតិចក្តីច្រើនក្តី យកមកធ្វើជាភរិយា ឬត្រឹមតែលោះមកប៉ុណ្ណោះ គេមិនបានដល់ទៅធ្វើជាភរិយាក៏ដោយ

១២- ឆន្ទវាសិនី ស្ត្រីដែលរត់តាមទៅនៅធ្វើជាភរិយារបស់បុរស ដោយសេចក្តីពេញចិត្តរបស់ខ្លួន ហើយបុរស

គេទទួលព្រមផង

១៣- ភោគវាសិនី ស្ត្រីដែលទៅនៅធ្វើជាភរិយារបស់បុរស ព្រោះតែភោគៈ គឺស្ត្រីដែលបានភោគៈ ដោយហោច ទៅត្រឹមតែអង្រែ និងត្បាល់ជាដើម អំពីបុរសណា ក៏ទៅនៅធ្វើជាភរិយារបស់បុរសនោះ

១៤- បដវាសិនី ស្ត្រីដែលទៅធ្វើជាភរិយារបស់បុរស ព្រោះតែសំពត់ គឺស្ត្រីដែលទ័លខ្សត់ ដែលគ្រាន់តែសំពត់ស្លៀកឬសំពត់ដណ្តប់ក៏ក្រដែរ ទើបសុខចិត្តចូលទៅធ្វើជាភរិយាគេ

១៥- ឱទបត្តកិនី ស្ត្រីដែលគេផ្តោបដៃជាមួយបុរស ជ្រលក់ទៅក្នុងផ្តិលទឹកមួយ ហើយគេពោលថា "អ្នកទាំងឡាយចូរប្រេឡុំគ្នា ចូរកុំបែកបាក់គ្នា ឱ្យដូចជាទឹកនេះ"
គឺស្ត្រីដែលគេផ្សំផ្គុំឱ្យទៅជាភរិយារបស់បុរសដោយវិធីបែបនេះ

១៦- ឱភតចុម្ពដា ស្ត្រីដែលគេដាក់ទ្រនូលចុះអំពីក្បាល គឺស្ត្រីរកឧសជាដើម ដែលបុរសណាមួយគេជួយដាក់ទ្រនូលអំពីក្បាល ហើយនាំយកទៅធ្វើជាភរិយាគេ ។

១៧- ទាសី ច ភរិយា ច ស្ត្រីដែលជាទាសីគេផង ជាភរិយាគេផង គឺស្ត្រីដែលជាទាសីរបស់បុរសណាមួយ ហើយបុរសនោះយកធ្វើជាភរិយា

១៨- កម្មការី ច ភរិយា ច ស្ត្រីដែលជាកូនឈ្នួលគេផង ជាភរិយាគេផង គឺស្ត្រីដែលចូលទៅនៅធ្វើការស៊ីឈ្នួលគេហើយ មានបុរសណាមួយ ឬជន្មើរបស់ខ្លួននោះ ទៅសម្រេចរួមសង្វាសជាមួយ លែងត្រូវការដោយភរិយារបស់ខ្លួន

១៩- ធជាហដា ស្ត្រីដែលសេនានាំមកដោយទង់ជ័យ គឺស្ត្រីដែលសេនាជំឡើងទង់ជ័យ លើកទ័ពទៅច្បាំងដណ្តើមដែនរបស់ស្តេច ដទៃកៀរយកបានមក ហើយបុរសណាមួយយកធ្វើជាភរិយា

២០- មុហុត្តិកា ស្ត្រីដែលមានបុរសភប់ប្រសព្វតែមួយស្របក់ៗ គឺស្ត្រីដែលជាសហាយស្មន់របស់បុរសណាមួយ ។

មណ្ឌលត្ថទីបនីពន្យល់ក្នុងជំពូកទី ៩ មានស្ត្រីឈ្មោះសារក្ខាថា ចំណែកត្រកូលទាំងឡាយ សូម្បីកាលបើ ពួកសត្វដែលបដិសន្ធិក្នុងគភ៌ ឋិតនៅក្នុងផ្ទៃពោះ ក៏ធ្វើកតិកាគ្នាថា បើខ្ញុំមានកូនប្រុស អ្នកមានកូនស្រី ធីតារបស់អ្នកនឹងមិនបានដើម្បី

នឹងទៅត្រកូលដទៃ ចូរបានដល់កូនប្រុសរបស់ខ្ញុំ ដូច្នេះស្រី ដែលមានមាតានិងបិតា បានដណ្តឹងទុកហើយ សូម្បីក្នុងផ្ទៃពោះ យ៉ាងនេះ ឈ្មោះថា **ស្រីមានស្វាមី** ។

ស្ត្រីទាំង ២០ ជំពូកដូចពោលមកហើយនេះ គប្បីដឹងថា សុទ្ធតែជាអគមនីយដ្ឋានរបស់បុរស គឺថាសុទ្ធតែបុរសមិនគួរ គប់រកដោយអសទ្ធម្មទាំងអស់ បើបុរសទៅគប់រកដោយអសទ្ធម្ម ចាត់ជាកាមេសុ មិច្ឆាចារៈមែនពិត ។

ចំណែកស្ត្រីគប្បីដឹងថា បុរសដទៃមិនមែនជាស្វាមី ឬ មិនមែនជាគូកំណាន់របស់ខ្លួន ជាអគមនីយដ្ឋានរបស់ស្ត្រី ១២ ជំពូកខាងចុង មានស្ត្រីឈ្មោះសារក្ខាជាដើម គឺថាមិនត្រូវឱ្យស្ត្រី ទាំង ១២ ជំពូកនោះ គប់រកដោយអសទ្ធម្មឡើយ, បើគប់រក ដាច់ កាមេសុ មិច្ឆាចារសិក្ខាបទដែរ ។

មែនពិត បុរសទាំងឡាយ មិនត្រូវទៅគប់រកស្ត្រីដែល មានបុគ្គលណាមួយគេគ្រប់គ្រងរក្សានោះឡើយ, បើទៅគប់រក នឹងស្ត្រី ៨ ជំពូកខាងដើម មានស្ត្រីឈ្មោះ **មាតុរក្ខិតា** ជាដើម ចាត់ជាមិច្ឆាចារៈ ដាច់សិក្ខាបទហ្នឹងដែរ ព្រោះស្ត្រីទាំងនោះ មានមាតាជាដើមគ្រប់គ្រងរក្សា មិនឱ្យនៅរួមសង្វាសជាមួយនឹង

បុរសតាមទំនើងចិត្តខ្លួនឡើយ, បើទៅគប់រកស្ត្រី ១២ ជំពូកខាងចុង មានឈ្មោះ **សារក្ខា** ជាដើម ចាត់ជាមិច្ឆាចារៈ ដាច់សិក្ខាបទហ្នឹងដែរ ព្រោះជាអាការរំលោភចូលទៅក្នុងស្ថានដែលមានបុរសដទៃគេខាំង ។

ចំណែកខាងស្ត្រីវិញ បើខ្លួនមានស្វាមីហើយ ឬមានបុរសណាមួយ គេកំណត់ប្រកាន់ជាភរិយាគេហើយ ខ្លួនមិនគួរគប់រកបុរសដទៃដោយអសទ្ធម្មឡើយ ហេតុនោះស្ត្រី ១២ ជំពូកខាងចុងមានស្ត្រីឈ្មោះ **សារក្ខា** ជាដើម បើទៅគប់រកនឹងបុរសដទៃចាត់ជាមិច្ឆាចារៈ ដាច់សិក្ខាបទហ្នឹងដែរ ព្រោះស្ត្រីទាំងនោះបានឈ្មោះថា មានស្វាមីហើយ, ឯស្ត្រី ៨ ចំពូកខាងដើមមានស្ត្រីឈ្មោះថា **មាតុរក្ខិតា** ជាដើម បើទៅគប់រកបុរសណាមួយ មិនបានឈ្មោះថា មិច្ឆាចារៈ ដាច់សិក្ខាបទនេះឡើយ ព្រោះស្ត្រីទាំងនោះ មិនទាន់មានប្តីហួងហែងនៅឡើយ, បើទុកជាមាតាបិតាជាដើមបីបាច់រក្សា ក៏មិនមែនប្រាថ្នាដោយខ្លួនឯងឡើយ គឺគ្រាន់តែឃាត់នូវអំពើអនាចារ មិនឱ្យទៅគប់រកបុរសដទៃប៉ុណ្ណោះ ព្រោះហេតុនោះ មាតាបិតាជាដើម មិនមែនជាឥស្សរៈ លើសម្ផស្សរបស់ស្ត្រីទាំងនោះឡើយ ។

សូម្បីស្ត្រី ៨ ជំពូកមាន **មាតុរក្ខិតា** ជាដើម បើបុរសណាប្រព្រឹត្តអសទ្ធម្មជាមួយ ដាច់កាមេសុ មិច្ឆាចារៈតែបុរសនោះប៉ុណ្ណោះ, ចំណែកស្ត្រី ៨ ជំពូកនោះ មិនដាច់សិក្ខាបទនេះទេ ។ តែស្ត្រីមានឈ្មោះថា **សារក្ខា** ជាដើម បើប្រព្រឹត្តអសទ្ធម្មជាមួយអ្នកដទៃ ខ្លួនក៏ដាច់កាមេសុ មិច្ឆាចារៈដែរ ។

កាមេសុ មិច្ឆាចារៈនុ៎ះ បើបុគ្គលឱ្យប្រព្រឹត្តទៅក្នុងអគមនីយដ្ឋានដែលប្រាសចាកសីលគុណជាដើម មានទោសតិច, ដែលបរិបូណ៌ដោយសីលគុណជាដើម មានទោសច្រើន, ពុំនោះសោត បើទុកជាប្រាសចាកសីលគុណជាដើម តែបុគ្គលឱ្យប្រព្រឹត្តទៅទាំងបំពាន ក៏មានទោសច្រើនដែរ បើសេចក្តីប្រាថ្នារបស់អ្នកទាំងពីរស្មើគ្នា លោកឱ្យសម្រេចដោយកិលេសទន់ខ្សោយ ឬសេចក្តីព្យាយាមទន់ខ្សោយ មានទោសតិច, បើមានកិលេសក្លៀវក្លា ឬមានសេចក្តីព្យាយាមក្លៀវក្លា មានទោសច្រើន ។

កាមេសុ មិច្ឆាចារសិក្ខាបទនេះ មានអង្គ ៤ គឺ :

១- **អគមនីយវត្ថុ** វត្ថុដែលមិនគួរគប់រក គឺស្ត្រីដែលមានគេគ្រប់គ្រងរក្សា ឬបុរសមិនមែនជាស្វាមីរបស់ខ្លួន

២- តស្មិំ សេវនចិត្តំ ចិត្តចង់សេពក្នុងវត្ថុដែលមិនគួរគប់រកនោះ

៣- សេវនប្បយោគោ ព្យាយាមនឹងសេព

៤- មគ្គេន មគ្គប្បដិបត្តិអធិវាសនំ បានប្រជល់ឬទទួលនូវមគ្គដោយមគ្គ ។

អនាបជ្ជនៈ ហេតុដែលមិនត្រូវទោសមាន ៤ យ៉ាងគឺ :

១- មិនដឹងខ្លួន

២- ឆ្កួត

៣- មានចិត្តរវើរវាយ

៤- មានទុក្ខវេទនាគ្របសង្កត់

រាប់ការមិនត្រេកអរ ១ ផង ជាគម្រប់ ៥ ។

## ពោលអំពីអានិសង្ស

កាមេសុ មិច្ឆាចារសិក្ខាបទនេះជាសិក្ខាបទទី ៣ នៃនិច្ចសីល អានិសង្សនៃការវៀរចាកសិក្ខាបទនេះ ដូចអានិសង្សនៃអព្រហ្មចរិយសិក្ខាបទខាងមុខទាំងអស់ ។

"ចប់ កាមេសុ មិច្ឆាចារសិក្ខាបទ "

## អព្រហ្មចរិយសិក្ខាបទ

*អព្រហ្មចរិយៈ* *កិរិយាប្រព្រឹត្តនូវធម៌មិនប្រសើរ គឺសេព នូវមេថុនធម្ម ។*

*នៅក្នុងព្រះវិន័យបិដក មហាវិភង្គ ត្រង់បារាជិកកណ្ឌ សិក្ខាបទទី ១ បានពន្យល់ពាក្យមេថុនធម្មថា ៖*

មេថុនធម្មោ នាម យោ សោ អសទ្ធម្មោ គាមធម្មោ វសលធម្មោ ទុដ្ឋុល្លំ ឱទកន្តិកំ រហស្សំ ទ្វយំទ្វយសមាបត្តិ ឯសោ មេថុនធម្មោ នាម ។

*ធម៌ដែលហៅថា* **មេថុន** *នោះ គឺធម៌ដែលជារបស់ អសប្បុរស ធម៌របស់អ្នកស្រុក ធម៌របស់មនុស្សថោកទាប ឬអំពើអាក្រក់មានកិច្ចដោយទឹកជាទីបំផុត ជាអំពើដែលជនពីរ នាក់តែងរួបរួមគ្នាធ្វើក្នុងទីកំបាំង នេះឯង ហៅថា* **មេថុនធម្ម** *។*

បដិសេវតិ នាម យោ និមិត្តេន និមិត្តំ អង្គជាតេន អង្គជាតំ អន្តមសោ តិលផលមត្តំបិ បវេសេតិ ឯសោ បដិសេវតិ នាម ។

បុគ្គលឱ្យនិមិត្តរបស់ខ្លួនចូលទៅដោយនិមិត្តគេ ឱ្យអង្គកំណើតខ្លួន ចូលទៅដោយអង្គកំណើតគេ ដោយហោចទៅសូម្បីអស់ទីត្រឹមតែមួយគ្រាប់ល្ង បុគ្គលនោះ ហៅថា **សេព** ។

ពាក្យថា **មេថុនធម្ម** លោកសំដៅយកសេពក្នុងទ្វារមគ្គទាំង ៣០, ទ្វារមគ្គណាមួយក្តី ទុកជាឱនបៀមអង្គជាតរបស់ខ្លួនក្តី បញ្ចូលអង្គជាតរបស់ខ្លួន ចូលទៅក្នុងទ្វារវច្ចៈមគ្គរបស់ខ្លួនក្តី បៀមអង្គជាតរបស់បុគ្គលដទៃក្តី ព្រមឱ្យអ្នកដទៃសេពមេថុននឹងទ្វារមគ្គរបស់ខ្លួន ដោយគេជួលដោយរបស់អ្វី ឬដោយគេបៃចង់ដោយពាក្យប្រកបដោយកាមផ្សេងៗ ឬក៏ដោយអផ្សុកហើយត្រេកអរ ចង់ឱ្យគេសេពក្តី ក៏ដាច់អព្រហ្មចរិយសិក្ខាបទ ។

បណ្តាទ្វារមគ្គទាំង ៣០ នោះ បើខ្លួនមានចិត្តចង់សេព បញ្ចូលអង្គជាតរបស់ខ្លួន មានស្រោមទ្រនាប់ក្តី គ្មានស្រោមទ្រនាប់ក្តី សូម្បីត្រឹមតែមួយគ្រាប់ល្ង ទៅក្នុងឱកាសសើម ដែលខ្យល់ប្រក្រតីមិនពាល់ត្រូវនៃទ្វារមគ្គណាមួយ របស់ខ្លួនក្តី របស់បុគ្គលដទៃក្តី មានស្រោមទ្រនាប់ក្តី គ្មានស្រោមទ្រនាប់ក្តី ម្យ៉ាងទៀត មគ្គណាមួយរបស់បុគ្គលដទៃ សូម្បីស្លាប់ហើយ

សត្វមិនទាន់ស៊ីក្តី សត្វមិនទាន់ស៊ីដោយច្រើនក្តី ម្យ៉ាងទៀត ក្បាលខ្មោចដាច់ក៏បញ្ច្រកអង្គជាតខ្លួន ឱ្យចូលទៅក្នុងមាត់ដែល បើកហាឱ្យប៉ះ ទន្តិចក្នុងមាត់នោះក្តី ក៏ឈ្មោះថា ដាច់អព្រហ្ម ចរិយសិក្ខាបទ ។

បើខ្លួនមិនត្រេកអរទេ តែគេមកកំហែងបង្ខំ រហូតដល់ មានការទះតប់ ជន្លដោយកាំបិតជាដើម ហើយក៏បណ្តោយឱ្យគេ សេពទៅដោយសេចក្តីខ្លាច ដោយគ្មានត្រេកអរ មិនដាច់ សិក្ខាបទនេះឡើយ ។

បើខ្លួនមានចិត្តត្រេកអរ បុគ្គលដទៃញ៉ាំងអង្គជាតខ្លួនចូល ទៅ បណ្តាអង្គជាតកំពុងចូល អង្គជាតចូលស៊ប់ហើយ អង្គជាត កំពុងស្ថិតនៅ អង្គជាតដែលបន្ថយចេញយ៉ាងណាមួយ ដោយ សេចក្តីត្រេកអរ ដាច់សិក្ខាបទនេះហើយ ។

ក៏ការប្រព្រឹត្តខុសក្នុងអព្រហ្មចរិយៈនេះ ដោយការប្រព្រឹត្ត ក្នុងទ្វារមគ្គ ៣០ ទ្វារមគ្គណាមួយនោះ រមែងដាច់អព្រហ្មចរិយ សិក្ខាបទនេះឯង ។

ឯទ្វារមគ្គទាំង ៣០ នោះ ចែកជាទ្វារមគ្គរបស់មនុស្ស ១០, ទ្វារមគ្គអមនុស្ស ១០, ទ្វារមគ្គសត្វតិរច្ឆាន ១០, រួមជា ៣០ ។

ទ្វារមគ្គមនុស្ស ១០ នោះ គឺមនុស្សស្រីមានទ្វារមគ្គ ៣ គឺ**វច្ចមគ្គ**= ទ្វារធំ ១, **បស្សាវមគ្គ**= ទ្វារតូច ១, **មុខមគ្គ**= ទ្វារមាត់ ១, មនុស្សប្រុសមានទ្វារមគ្គ ២ គឺ**វច្ចមគ្គ** ១, **មុខមគ្គ** ១, មនុស្សឧភតោព្យញ្ជនកៈ(មនុស្សមានភេទ ២) មានទ្វារមគ្គ ៣ គឺ**វច្ចមគ្គ** ១, **បស្សាវមគ្គ** ១, **មុខមគ្គ** ១, មនុស្សបណ្ឌកៈ (ខ្ទើយ) មានទ្វារមគ្គ ២ គឺ**វច្ចមគ្គ** ១, **មុខមគ្គ** ១, ផ្សំគ្នាមកត្រូវជាទ្វារមគ្គមនុស្សមាន ១០ ។

ទ្វារមគ្គអមនុស្ស ១០ នោះ ក៏ចាត់ជាស្រីមានទ្វារមគ្គ ៣, ប្រុសមានទ្វារមគ្គ ២, ឧភតោព្យញ្ជនកៈមានទ្វារមគ្គ ៣, បណ្ឌកៈមានទ្វារមគ្គ ២ ផ្សំគ្នាមកត្រូវជាទ្វារមគ្គអមនុស្សមាន ១០ ។

ទ្វារមគ្គសត្វតិរច្ឆាន ១០ នោះ ក៏ចាត់ជាញីមានទ្វារមគ្គ ៣, ឈ្មោលមានទ្វារមគ្គ ២, ឧភតោព្យញ្ជនកៈមានទ្វារមគ្គ ៣, បណ្ឌកៈមានទ្វារមគ្គ ២, ផ្សំគ្នាមកត្រូវជាទ្វារមគ្គសត្វតិរច្ឆានមាន ១០ ។

អព្រហ្មចរិយសិក្ខាបទនេះ មានអង្គ ៤ គឺ :

១- ភេទនវត្ថុ វត្ថុជាទីទម្លាយនូវសីល គឺទ្វារមគ្គទាំង ៣០ ចំពោះត្រង់ទ្វារណាមួយ

២- សេវនចិត្តំ គិតនឹងសេព

៣- តជ្ជោវាយាមោ ព្យាយាមនឹងសេពនូវមេថុនធម្មនោះ

៤- មគ្គេន មគ្គប្បដិបាទនំ ញ៉ាំងមគ្គនិងមគ្គឱ្យដល់គ្នា ។

អនាបត្តិ: ហេតុដែលមិនត្រូវទោសមាន ៤ យ៉ាងគឺ :

១- មិនដឹងខ្លួន

២- ឆ្កួត

៣- មានចិត្តរវើរវាយ

៤- ទុក្ខវេទនាគ្របសង្កត់

រាប់ទាំងមិនត្រេកអរ ១ ផងជាគម្រប់ ៥ ។

## ពោលអំពីអានិសង្ស

ការវៀរចាកអព្រហ្មចរិយសិក្ខាបទនេះជាសិក្ខាបទទី ៣ នៃឧបោសថសីល មានអានិសង្ស ២០ យ៉ាងគឺ :

១- វិកាតបច្ចត្ថិកតា មិនមានសឹកសត្រូវបៀតបៀន

២- សព្វជនស្សបិយតា ជាទីស្រឡាញ់ទុកចិត្តនៃជនទាំងពួង

៣- អន្នបានវត្ថសយនាទីនំ បដិលាភតា រកបាយ ទឹកគ្រឿងស្លៀកដណ្តប់ និងទីកន្លែងដេកនៅបានដោយងាយ

៤- សុខសយនតា ដល់ដេកទៅក៏លក់ជាសុខស្រួល

៥- សុខបដិពុជ្ឈនតា ភ្ញាក់ឡើងវិញក៏ជាសុខស្រួល

៦- អបាយភយវិនិមុត្តតា ផុតភ័យក្នុងអបាយ

៧- អភព្វតា មិនត្រឡប់កើតជាស្រីឬខ្ទើយឡើយ

៨- អកោធនតា ជាមនុស្សមិនងាយនឹងខឹងភ្លាមៗ

៩- សក្កច្ចការិតា ធ្វើអ្វីៗ សុទ្ធតែមានរបៀបរៀបរយល្អ

១០- បច្ចក្ខការិតា ធ្វើអ្វីធ្វើប្រាកដមិនដាក់ធុរៈចោល

១១- អបតិតក្ខន្ធតា មិនឱនកសំយុងចុះ ក្នុងទីប្រជុំជនឡើយ

១២- អនណោមុខតា មិនមានមុខឱនជ្រប់ គឺមានអំណាច

១៣- អញ្ញមញ្ញបិយតា មានមិត្តកឿនសុទ្ធតែស្រឡាញ់គ្នា ដោយស្រួលផង

១៤- បរិបុណ្ណិន្ទ្រិយតា មានឥន្ទ្រិយពេញលេញល្អ

១៥- បរិបុណ្ណលក្ខណតា មានលក្ខណៈគ្រប់គ្រាន់ល្អ

១៦- និវាសច្ឆតា មិនធ្វើឱ្យអ្នកណាមួយរង្កៀសបាន

១៧- អប្បោស្សុក្កតា មានសេចក្តីខ្វល់ខ្វាយតិចក្នុងអំពើឥតប្រយោជន៍

១៨- សុខវិហារិតា ទៅនៅទីកន្លែងណា ក៏ជួបប្រទះតែនឹងសុខ

១៩- អកុតោ ភយា មិនមានភ័យមកពីណាឡើយ

២០- បិយវិប្បយោគភាវតា មិនសូវមានព្រាត់ប្រាសចាករបស់ជាទីស្រឡាញ់ឡើយ ។

"ចប់ អព្រហ្មចរិយសិក្ខាបទទី ៣ "

## ៤. មុសាវាទសិក្ខាបទ

មុសាវាទ កិរិយាពោលនូវពាក្យកុហក ។ នៅក្នុងបរមត្ថជោតិកា បានពន្យល់ពីមុសាវាទថា ក្នុងពាក្យថា មុសាវាទោ នេះ បទថា មុសា បានដល់ វចីប្រយោគ ឬកាយប្រយោគដែលបំបាត់នូវប្រយោជន៍របស់បុគ្គលដទៃ ប្រាថ្នានឹងឱ្យឃ្លៀងឃ្លាតចាកសេចក្តីពិតជាប្រធាន មិច្ឆាចេតនា ចេតនាដែលនឹងនិយាយខុស ធ្វើខុសរបស់បុគ្គលនោះដោយប្រាថ្នានឹងឱ្យអ្នកដទៃ យល់ខុសជាសមុដ្ឋាននៃកាយប្រយោគ និងវចីប្រយោគដែលនឹងធ្វើឱ្យអ្នកដទៃយល់ខុសប្រព្រឹត្តទៅតាមកាយទ្វារ និងវចីទ្វារណាមួយ ឈ្មោះថា មុសាវាទ ។

( ពាក្យថា កាយប្រយោគ សំដៅយកកាយវិការ ដោយអវយវៈណាមួយ ឱ្យអ្នកដទៃយល់សេចក្តីបាន មានការរាដៃ ងក់ក្បាល ឬក៏ខ្លួនមិនបានដេកលក់ទេ តែធ្វើអាការដូចជាដេកលក់ ដើម្បីឱ្យអ្នកដទៃភាន់ច្រឡំបានជាដើម ) ។

( ពាក្យថា អ្នកដទៃ សំដៅយកអ្នកដែលក្រៅពីខ្លួន សូម្បីកូនចៅតូចៗ ក្តី និងសត្វតិរច្ឆានជាទីបំផុតដែលអាចយល់សេចក្តី

បាន ) ។

ចេតនាដែលញុំាងកាយប្រយោគ ឬវចីប្រយោគ ដើម្បីនឹងពោលនូវពាក្យឃ្លៀងឃ្លាតនោះឱ្យកើតឡើង ដោយសេចក្តីប្រាថ្នាចង់ពោលឱ្យឃ្លាត បេញសំដីចំពោះអ្នកដទៃ ហៅថា **មុសាវាទ** បានដល់ ចេតនាជាហេតុពោលនូវពាក្យមិនពិត ឬចេតនាជាហេតុញុំាងពាក្យមិនពិតឱ្យកើតឡើង ។

វិន័យបិដកមហាវិភង្គ ភាគ ៣ ទំ. ២២៤ មានពន្យល់ថា សម្បជានមុសាវាទោ នាម វិសំវាទនបុរេក្ខារស្ស វាចា គិរា ព្យប្បថោ វចីភេទោ វាចសិកា វិញ្ញត្តិ អដ្ឋ អនរិយវោហារា ដែលហៅថា និយាយកុហកដោយដឹងខ្លួននោះ បានដល់វាចា សំដីគន្លងពាក្យ វចីភេទ វិញ្ញត្តិ ប្រព្រឹត្តទៅក្នុងវាចារបស់បុគ្គលដែលធ្វើគំនិត គិតនឹងពោលឱ្យខុសជាប្រធាន និងវោហារមិនមែនជារបស់ព្រះអរិយៈ ៨ យ៉ាងគឺ :

១- អទិដ្ឋំ ទិដ្ឋំ មេតិ ត្រង់ដែលមិនឃើញ និយាយថាអញឃើញ

២- អសុតំ សុតំ មេតិ មិនឮ និយាយថា អញឮ

៣- អមុតំ មុតំ មេតិ មិនបានពាល់ត្រូវ និយាយថា អញបានពាល់ត្រូវ

៤- អវិញ្ញាតំ វិញ្ញាតំ មេតិ មិនដឹងច្បាស់ និយាយថា អញដឹងច្បាស់

៥- ទិដ្ឋំ អទិដ្ឋំ មេតិ ត្រង់ដែលឃើញ និយាយថា អញមិនឃើញ

៦- សុតំ អសុតំ មេតិ ឮ និយាយថា អញមិនឮ

៧- មុតំ អមុតំ មេតិ បានពាល់ត្រូវ និយាយថា អញមិនបានពាល់ត្រូវ

៨- វិញ្ញាតំ អវិញ្ញាតំ មេតិ ដឹងច្បាស់ និយាយថា អញមិនដឹងច្បាស់ ។

អទិដ្ឋំ ឯាម ន ចក្ខុនា ទិដ្ឋំ ដែលហៅថា មិនឃើញ គឺមិនឃើញដោយភ្នែក ។

អសុតំ ឯាម ន សោតេន សុតំ ដែលហៅថា មិនឮ គឺមិនឮដោយត្រចៀក ។

អមុតំ នាម ន ឃានេន ឃាយិតំ, ន ជិវ្ហាយ សាយិតំ, ន កាយេន ផុដ្ឋំ ដែលហៅថា មិនពាល់ត្រូវ គឺមិនហិតដោយច្រមុះ, មិនលិទ្ធដោយអណ្ដាត, មិនប៉ះពាល់ដោយកាយ ។

អវិញ្ញាតំ ន មនសា វិញ្ញាតំ ដែលហៅថា មិនដឹង គឺមិនដឹងដោយចិត្ត ។

ទិដ្ឋំ នាម ចក្ខុនា ទិដ្ឋំ ដែលហៅថាឃើញ គឺឃើញដោយភ្នែក ។

សុតំ នាម សោតេន សុតំ ដែលហៅថាឮ គឺឮដោយត្រចៀក ។

មុតំ នាម ឃានេន ឃាយិតំ, ជិវ្ហាយ សាយិតំ, កាយេន ផុដ្ឋំ ដែលពាល់ត្រូវ គឺហិតដោយច្រមុះ, លិទ្ធដោយអណ្ដាត, ប៉ះពាល់ដោយកាយ ។

វិញ្ញាតំ នាម មនសា វិញ្ញាតំ ដែលហៅថា ដឹងច្បាស់ គឺដឹងច្បាស់ដោយចិត្ត ។

“អាការដែលកុហកនេះ ព្រះសម្ពុទ្ធទ្រង់សម្ដែងតាំងពីអាការ ៣ យ៉ាង, រហូតដល់អាការ ៧ យ៉ាង ។ ដូច្នេះសូមទាញព្រះពុទ្ធដីកាដ៏ខ្លីមកសម្ដែងនៅត្រង់កាល ៣ ហ្នឹងឯង ។

គប្បីដឹងថា ៖

១- បុព្វេវស្ស ហោតិ មុសា ភវិស្សន្តិ មុននឹងពោល គិតថា អញនឹងពោលកុហក

២- ភណន្តស្ស ហោតិ មុសា ភណាមីតិ កំពុងពោល ដឹងថា អញកំពង់ពោលកុហក

៣- ភណិតស្ស ហោតិ មុសា មយា ភណិតំ ពោលរួចហើយ ដឹងថា អញពោលកុហករួចហើយ

ទាំង ៣ កាលនេះ សម្រេចសេចក្ដីថា ដាច់មុសាវាទសិក្ខាបទពិត ។

លោកសម្ដែងក្នុងមង្គលត្ថទីបនីថា : មែនពិត ព្រះឧបាលីពោលពាក្យនេះថា “មុន( ពេលនិយាយ ) ភិក្ខុមានសេចក្ដីដឹងខ្លួនថា អាត្មាអញនឹងពោលមុសា កាលកំពុងនិយាយ រមែងមានសេចក្ដីដឹងខ្លួនថា អាត្មាអញកំពុងពោលមុសា” ដូច្នេះ ។

សេចក្ដីជីងខ្លួនទាំង ២ យ៉ាងនុ៎ះឯង ជាអង្គ, ចំណែកអង្គក្រៅអំពីនេះ នឹងមានក្ដី មិនមានក្ដី, រឿងនុ៎ះ មិនមែនជាហេតុ ។

## ពោលអំពីទោស

មុសាវាទនោះ បើទម្លាយនូវប្រយោជន៍របស់បុគ្គលដទៃតិច មានទោសតិច, ទម្លាយនូវប្រយោជន៍របស់បុគ្គលដទៃច្រើន មានទោសច្រើន, ទម្លាយនូវប្រយោជន៍របស់បុគ្គល ដែលមានសីលគុណជាដើមតិច មានទោសតិច, ដែលមានសីលគុណជាដើមច្រើន មានទោសច្រើន, អ្នកពោលដោយកិលេសទន់ មានទោសតិច, ដោយកិលេសក្លៀវក្លា មានទោសច្រើន ។

ន័យមួយទៀត មុសាវាទនុ៎ះ ប៉ែកខាងគ្រហស្ថបើមានគេមករករបស់ដែលខ្លួនមាន ហើយកុហកដោះសាថា "មិនមាន"ទៅវិញ ដោយមិនចង់ឱ្យ ឬពោលកុហកដោះសាណាមួយចំពោះខ្លួន មានទោសតិច, បើធ្វើជាបន្ទាល់សាក្សីឱ្យគេ ហើយពោលកុហកដើម្បីទម្លាយនូវប្រយោជន៍របស់បុគ្គលដទៃ មានទោសច្រើន, ចំណែកខាងបព្វជិតវិញ បើបានប្រេងឬសប្បិបន្តិចបន្តួចសោះ ហើយពោលបំផ្លើសឱ្យច្រើនឡើងថា "ថ្ងៃនេះប្រេងក្នុងស្រុកហូរ

ដូចជាទឹកស៊ីង” ដោយប្រាថ្នានឹងសើចលេង មានទោសតិច, បើមិនឃើញសោះ មិនឮសោះ ថាឮជាដើម មានទោសច្រើន ។

ន័យខាងចុងនេះ បើពោលឱ្យជាសេចក្ដីរួបរួមខ្លីចុះមកក៏ឃើញថា មុសាវាទនោះ បើបុគ្គលណាមួយ ទោះបីគ្រហស្ថក្ដី បព្វជិតក្ដី ពោលបំណងនឹងមិនឱ្យខូចប្រយោជន៍ខ្លួន ឬមិនឱ្យកើតអន្តរាយដល់ខ្លួន មានទោសតិច, បំណងនឹងឱ្យបានប្រយោជន៍ដល់បុគ្គលដទៃដែលមិនគួរឱ្យបាន, ឱ្យខាតប្រយោជន៍ដល់បុគ្គលដទៃដែលមិនគួរឱ្យខាត ដូចជាធ្វើសាក្សីកោងវៀចជាដើម មានទោសច្រើន, ពោលបំផ្លើសរបស់តិចឱ្យទៅជាច្រើន របស់តូចឱ្យទៅជាធំ, របស់ល្មមឱ្យទៅជាណាស់ ដោយបំណងនឹងសើចលេង មានទោសតិច, បើរបស់មិនឃើញសោះ ថាឃើញ, មិនឮសោះ ថាឮ, មិនដឹងសោះ ថាដឹង មានទោសច្រើន ។ “គប្បីដឹងថាជាមុសាវាទនេះដដែល ប៉ុន្តែគ្រាន់តែឱ្យដឹងថា មានទោសតិចច្រើនប៉ុណ្ណោះ” ។

ឃើញ ឮទេ ? លោកថា ដោយហោចទៅ សូម្បីតែមានបំណងនឹងសើចលេង ហើយពោលកុហកលេង ក៏ជាទោស

ត្រូវដាច់មុសាវាទសិក្ខាបទហ្នឹងដែរ ។

បើឈ្លោះគ្នា ហើយជេរគ្នា ដោយរឿងមិនពិត ដូចគេមិនលួចក្របីគេទេ ខ្លួនជេរគេថា ជាចោរលួចក្របីគេដូច្នេះ មិនត្រូវទោសមុសាវាទសិក្ខាបទនេះទេ, គប្បីដឹងថា ពាក្យនេះជាផរុសវាទទេ, ព្រោះចេតនា របស់អ្នកនិយាយកុហក និងចេតនារបស់អ្នកជេរគេ ដោយរឿងមិនពិតនោះខុសគ្នាយ៉ាងនេះ, អ្នកដែលនិយាយកុហកនោះ ចិត្តឈោងចាប់យករបស់ដែលមិនពិត, មិនមែន, មកនិយាយប្រាប់គេថា ពិត, មែន, ទាញយករបស់ដែលថា ពិត, មែន, មកនិយាយប្រាប់គេថា ជារបស់មិនពិត, មិនមែនទៅវិញ, និយាយយ៉ាងនេះ ឈ្មោះថា ចេតនាកុហក ។ ចំណែកចេតនា ជេរគេនោះ មិនបានឈោងចាប់យករបស់ដែលមិនពិត និងពិតនោះ មកនិយាយទេ គឺជេរៗ ទៅដោយអំណាចកំហឹងខឹងខ្លាំង ឬដោយគ្មានស្មារតី រឭកសព្វគ្រប់ ដោយមិនបានប្រុងស្មារតី ដោយមិនបានគិតវែងឆ្ងាយ ហើយក៏ជេរៗទៅយ៉ាងនេះ ឈ្មោះថា ជាចេតនាជេរ ។

មុសាវាទសិក្ខាបទនេះ មានអង្គ ៤ គឺ :

១- អតថំ វត្ថុ វត្ថុមិនពិត ឬហេតុមិនពិត

២- វិសំវាទនចិត្តំ គិតនឹងពោលឱ្យខុស

៣- តជ្ជោវាយាមោ ព្យាយាមនឹងពោលឱ្យខុសនោះ

៤- បរស្ស តទត្ថវិជាននំ ញ៉ាំងអ្នកដទៃឱ្យដឹងច្បាស់នូវសេចក្តីនោះ ។

អនាបត្តិ: ហេតុដែលមិនត្រូវទោសមាន ៣ យ៉ាងគឺ :

១- ពោលដោយញាប់មាត់ គឺពោលដោយរហ័ស

២- ពោលដោយភ្លាត់មាត់ គឺក្នុងចិត្តគិតថា អញនឹងពោលពាក្យដទៃ ហើយត្រឡប់ជាពោលពាក្យដទៃក្រៅពីគិតទៅវិញ

៣- ឆ្កួត ។

## ពោលអំពីអានិសង្ស

មុសាវាទសិក្ខាបទនេះជាសិក្ខាបទទី ៤ អានិសង្សនៃការវៀរចាកមាន ១៤ យ៉ាងគឺ :

១- វិប្បសន្និន្ទ្រិយតា មានឥន្ទ្រិយទាំង ៥ ដ៏ជ្រះថ្លាស្អាតបាត

២- វិស្សដ្ឋមធុរភាណិតា មានវាចាពីរោះក្បោះក្បាយផង

៣- សមសិតសុទ្ធទន្តា មានធ្មេញត្រឹមស្មើជិតបរិសុទ្ធល្អផង

៤- ឆាតិថូលតោ មានរាងជាមនុស្សសមទ្រង់មិនធាត់ពេក

៥- ឆាតិកីសតោ ជាមនុស្សល្មមមិនស្គមពេក

៦- ឆាតិរស្សតោ ជាមនុស្សល្មមមិនទាបពេក

៧- ឆាតិទីឃតោ ជាមនុស្សល្មមមិនខ្ពស់ពេក

៨- សុខតោ បាននូវសម្ផស្សដ៏សុខស្រួល

៩- ឧប្បលគន្ធមុខតា មានមាត់ជុំក្លិនដូចឧប្បលជាតិផង

១០- សុស្សូសកបរិជនតា មានបរិស័ទជាបរិវារសុទ្ធតែមានសេចក្តីឧស្សាហ៍ល្អផង

១១- អាវេយ្យវចនតា មានសម្តីគួរជឿ ស្តាប់បានផង

១២- មុទុលោហិតតនុជិវ្ហតា រមែងមានអណ្តាតស្តើងក្រហមដូចត្របកផ្កាឈូកផង

១៣- អនុទ្ធតា មានចិត្តមិនរសាត់អណ្តែតផ្តេសផ្តាសផង

១៤- អបគតមម្មនតា មិនមែនជាមនុស្សល្ងង់ខ្លៅផង ។

" ចប់ មុសាវាទសិក្ខាបទទី ៤"

## ៥. សុរាមេរយមជ្ជប្បមាទដ្ឋានសិក្ខាបទ

*សុរាមេរយៈ កិរិយាផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ។*

*អជ្ឈោហរណចេតនា ដែលក្លែងផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ដោយហោចទៅ ចាប់ដើមតាំងអំពីពូជ សូម្បីតែផឹក ប៉ុនចុងស្បូវ ក៏ដាច់សិក្ខាបទសុរាមេរយៈហ្នឹងដែរ ។*

ពីជតោ បដ្ឋាយាតិ សម្ភារេ បដិយាទេត្វា ចាដិយំ បក្ខិត្តកាលតោ តាលនាឡិកេរាទីនំ បុប្ផរសស្ស គហិត-អភិនវកាលតោយេវ ច បដ្ឋាយ ។

*ពាក្យថា ចាប់ដើមតាំងអំពីពូជ សេចក្តីថា មិនគួរចាប់ផ្តើមអំពីកាលដែលគេចាត់ចែងជាគ្រឿងផ្សំដាក់ចុះក្នុងពាង និងចាប់ផ្តើមតាំងតែពីកាលរសនៃផ្កាត្នោត និងដូងជាដើម ដែលគេកាន់ទុក( គឺគេលាយផ្សំ )ថ្មី មែនពិត ។*

*បើមិនដឹងខ្លួន ដូចជាដេកលក់ហើយមានអ្នកដទៃ លបយកសុរា ឬមេរ័យទៅចាក់បង្អកឱ្យចូលទៅក្នុងមាត់ បានជញ្ជក់លេបចូលផុតបំពង់កទៅ មិនដាច់សិក្ខាបទហ្នឹងទេ ព្រោះសិក្ខាបទនេះ ជាសចិត្តកៈ លុះតែមានចិត្តក្លែងទើបត្រូវទោស*

បើឥតមានចិត្តក្លែងទេ មិនត្រូវទោសដាច់សិក្ខាបទហ្នឹងឡើយ ។ ចំណែកភិក្ខុវិញ បើទុកជាមិនដឹងខ្លួន ក៏ត្រូវអាបត្តិបាចិត្តិយៈដែរ ព្រោះសិក្ខាបទនេះជាអចិត្តកៈ ទោះមានចិត្តក្លែងក្តី មិនក្លែងក្តី ឱ្យតែលេបចូលផុតបំពង់កទៅហើយ ត្រូវទោសទាំងអស់ ។

សុរានេះមាន ៥ យ៉ាងគឺ :

១- បិដ្ឋសុរា សុរាធ្វើអំពីម្សៅ

២- បូវសុរា សុរាធ្វើអំពីនំ

៣- ឱទនសុរា សុរាធ្វើអំពីបាយ

៤- កិណ្ណបក្ខិត្តា សុរាដែលគេដាក់ពូជសុរា

៥- សម្ភារសំយុត្តា សុរាដែលគេប្រកបអំពីគ្រឿងផ្សំផ្សេងៗ មានគ្រាប់ម្រេចនិងគ្រាប់ស្ពៃជាដើម ។

មេរ័យមាន ៥ យ៉ាងគឺ :

១- បុប្ផាសវោ ទឹកត្រាំដែលគេធ្វើអំពីផ្កាឈើ

២- ផលាសវោ ទឹកត្រាំដែលគេធ្វើអំពីផ្លែឈើ

៣- មធ្វាសវោ ទឹកត្រាំដែលគេធ្វើអំពីទឹកឃ្មុំ

៤- គុឡាសវោ ទឹកត្រាំដែលគេធ្វើអំពីទឹកអំពៅ

៥- សម្ភារសំយុត្តោ ទឹកត្រាំដែលគេប្រកបអំពីគ្រឿងផ្សំផ្សេងៗ មានផ្លែស្រម៉ និងផ្លែកន្ទួតព្រៃជាដើម ។

**ទោសអំពីទោស**

វត្ថុទាំង ១០ មុខគឺ សុរា ៥ មុខ មេរ័យ ៥ មុខនេះ ជាមេខាងឯបមាទៈ គឺសេចក្ដីប្រហែសធ្វេស ខ្វះគំនិត វង្វេងស្មារតី បានជាមានបាលីថា ឧម្មត្តកការី សំវត្តេតិ អ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើមត្រាស់ថា អ្នកផឹកសុរារមែងញ៉ាំងខ្លួនឯង ឱ្យដល់នូវភាពជាអ្នកខូចខ្លួន គឺជាមនុស្សឆ្កួត, ព្រោះហេតុដូច្នោះបានជាអានិសង្សប្រាប់ថា **ឧម្មាទី វា ខិត្តចិត្តោ វា ឯឡមុគ្គោ វា** ហោតិ មនុស្សអ្នកផឹកសុរា ជា **ឧម្មាទី** ឆ្កួតក៏មាន, **ខិត្តចិត្តោ** ក្រឡុកចិត្តខូចលីលាក៏មាន, **ឯឡមុគ្គោ** ជាជំឡាន់ គ ល្ងីល្ងើក៏មាន,"នេះចំជាប្រមាទពេញទី" នៅក្នុងសិង្គាលកសូត្រ ព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់ត្រាស់ថា ទោសស្ដែងៗ ដល់ ៦ បែបគឺ :

១- សន្ទិដ្ឋិកា ធនជានី ឱ្យទោសស្ដែងៗ ឃើញហិនវិនាសសាបសូន្យទ្រព្យធន

២- កលហប្បវឌ្ឍនី ជាមេនាំឱ្យចម្រើនខាងឈ្លោះប្រកែក

៣- រោគានំ អាយតនំ ជាខេត្តនៃរោគទាំងឡាយ មានរោគកើតក្នុងភ្នែកជាដើម

៤- អកិត្តិសញ្ជននី តែងមានកេរ្តិ៍ឈ្មោះអាក្រក់ផ្សាយទៅសព្វទិសទី

៥- កោបិននិទ្ទំសនី ជាមនុស្សអស់ហិរិ ហ៊ានបង្ហាញកេរ្តិ៍ខ្មាសឱ្យគេមើល

៦- បញ្ញាយ ទុព្វលីករណី ធ្វើឲ្យបញ្ញាឱ្យមានកម្លាំងថយចុះ ។

"ន គោវលំ មិនអស់ត្រឹមប៉ុណ្ណឹងទេ អ្នកផឹកសុរាបើផឹកបន្តិចបន្តួចត្រឹមតែមួយទូកដៃ មានទោសតិច ផឹកច្រើនជាងនេះចំនួន ១ កំបង់ដៃ មានទោសច្រើនបន្តិច (តាមលំដាប់)

កាយចាលនសមត្ថំ បើផឹកច្រើនរហូតដល់អាចញ៉ាំងកាយឱ្យ កក្រើកព្រហើន ហ៊ានធ្វើឃាតកម្មដល់អ្នកស្រុក អ្នកនិគមចាត់ជាទោសធំក្រៃលែងទៅទៀត"

សុរាមេរយសិក្ខាបទនេះ មានអង្គ ៤ គឺ :

១- មជ្ជនីយវត្ថុ វត្ថុជាទីតាំងនៃសេចក្តីស្រវឹងគឺសុរានិងមេរ័យ

២- បាតុកម្យតាចិត្តំ គិតបម្រុងនឹងផឹក

៣- តជ្ជោវាយាមោ ព្យាយាមនឹងផឹកនូវទឹកស្រវឹងនោះ

៤- តស្ស បានំ បានផឹកនូវទឹកស្រវឹងនោះ ឱ្យកន្លងបំពង់ក ចូលទៅ ។

**អនាបជ្ជនៈ** ហេតុដែលមិនត្រូវទោសមាន ៧ យ៉ាងគឺ :

១- ផឹកទឹកមិនស្រវឹង តែទឹកនោះ មានពណ៌ដូចជាទឹកស្រវឹង មានក្លិន ដូចទឹកស្រវឹង មានរសដូចទឹកស្រវឹង

២- ទឹកស្រវឹងដែលគេចម្អិនលាយជាមួយសម្ល មិនមានក្លិន និងរសប្រាកដ

៣- ទឹកស្រវឹងដែលគេចម្អិនលាយនឹងសាច់ មិនមានក្លិននិង រសប្រាកដ

៤- ទឹកស្រវឹងដែលគេចម្អិនលាយនឹងប្រេង មិនមានក្លិននិង រសប្រាកដ

៥- ទឹកអំពៅដែលគេត្រាំនឹងផ្លែកន្ទួតព្រៃ

៦- ផឹកទឹកអរិដ្ឋៈ មិនស្រវឹង ( ថ្នាំដែលគេធ្វើដោយរសនៃ ផ្លែឈើមានផ្លែកន្ទួតព្រៃជាដើម )

៧- ឆ្កួត ។

## ពោលអំពីអានិសង្ស

សុរាបានសិក្ខាបទនេះជាសិក្ខាបទទី ៥ អានិសង្សនៃសិក្ខាបទនេះ មាន ៣៥ យ៉ាងគឺ :

១- កិច្ចករណីយេសុ ខិប្បំ បដិជាននតា ជាមនុស្សដឹងស្គាល់កិច្ចដែលគួរធ្វើក្នុងអតីតៈ អនាគត បច្ចុប្បន្ន យ៉ាងឆាប់រហ័សផង

២- សទាឧបដ្ឋិតសតិតា ជាអ្នកមានសតិតម្កល់នៅខ្ជាប់ខ្ជួនល្អ សព្វកាល

៣- អនុម្មត្តកតា ជាមនុស្សល្អមិនមែនជាមនុស្សឆ្កួតផង

៤- ញាណវន្តតា មានញាណជាគ្រឿងដឹងច្រើនប្រការផង

៥- អនេឡតា ជាមនុស្សមិនញាប់ញ័រផង

៦- អជឡតា ជាមនុស្សមិនសស្លក់សស្លើតស្ពុះស្ពាផង

៧- អមូគតា ជាមនុស្សមិនគប្រដិតផង

៨- អមឌតា ជាមនុស្សមិនស្រវឹងជ្រប់ក្នុងអារម្មណ៍ផង

៩- អប្បមត្តតា ជាមនុស្សមិនប្រមាទក្នុងកុសលធម៌ផង

១០- អសម្មោហតា ជាមនុស្សមិនវង្វេងវង្វាន់ផ្តេសផ្តាសដោយ-សារអារម្មណ៍ផង

១១- អជម្ភិតា ជាមនុស្សមិនងាយនឹងតក់ស្លុតខ្លាចផ្អើលផង

១២- អសារម្ភិតា ជាមនុស្សមិនមានសេចក្តីរំខានដល់ចិត្តផង

១៣- អនិស្សុកិតា ជាមនុស្សមិនប្រណែនឬស្យាអ្នកណាផង

១៤- អប្បោស្សុក្កតា មានសេចក្តីខ្វល់ខ្វាយតិចក្នុងការឥតប្រយោជន៍

១៥- សុខិតតា ជាមនុស្សសុខស្រួលផង

១៦- អភិសម្មតតា មានមនុស្សឯទៀតតែងរាប់អានកោតក្រែងផង

១៧- សច្ចវាទិតា ពោលពាក្យកាលណាសុទ្ធតែសច្ចៈ

១៨- អបិសុណតា មិនដែលពោលពាក្យស៊កសៀតអ្នកណាផង អ្នកផងក៏គ្មាននិយាយស៊កសៀតមករក

១៩- អជរុសតា មិននិយាយពាក្យគ្រោតគ្រាតទ្រគោះដល់

អ្នកណាផង គ្មានអ្នកណាគេនិយាយពាក្យគ្រោតគ្រាតទ្រគោះមករកផង

២០- អសម្ផប្បលាបវាធិតា មិននិយាយនូវពាក្យរោយរាយឥតប្រយោជន៍ ឥតបានការផង

២១- រត្តិន្ទិវមតន្ទិតតា ជាមនុស្សមិនខ្ជិលច្រអូស ទាំងយប់ទាំងថ្ងៃផង

២២- កតញ្ញុតា ជាមនុស្សមានសេចក្ដីដឹងនូវឧបការគុណនៃអ្នកមានគុណផង

២៣- កតវេទិតា ជាមនុស្សដឹងនូវគុណគេហើយ ធ្វើតបនូវឧបការគុណវិញ

២៤- អមច្ឆរិតា ជាមនុស្សមិនកំណាញ់ស្វិតស្វាញខុសទំនង

២៥- ចាគវន្តតា ជាមនុស្សស្គាល់បរិច្ចាគឱ្យតាមកាល

២៦- សីលវន្តតា ជាមនុស្សមានសីលត្រឹមត្រូវល្អ

២៧- ឧជុកតា ជាមនុស្សមានចិត្តពិតត្រង់

២៨- អក្កោធនតា ជាមនុស្សមិនងាយនឹងក្រោធដល់អ្នកណាផង

២៩- ហិរិមនតា ជាមនុស្សមានចិត្តខ្មាសបាប

៣០- ឱត្តប្បិតា ជាមនុស្សមានចិត្តតក់ស្លុតនឹងបាប

៣១- ឧជុទិដ្ឋិតា ជាមនុស្សមានគំនិតឃើញត្រូវ

៣២- មហាបញ្ញតា ជាមនុស្សមានបញ្ញាធំទូលាយ

៣៣- មេធាវិតា ជាមនុស្សមានប្រាជ្ញាយល់ត្រូវ

៣៤- បណ្ឌិតា ភាពជាអ្នកមានញាណគតិសព្វកាល

៣៥- អត្ថានត្ថកុសលតា ឈ្លាសវៃដឹងយល់ក្នុងការមានប្រយោជន៍ និងការដែលគ្មានប្រយោជន៍គ្រប់យ៉ាង ។

"ចប់ សុរាមេរយមជ្ជប្បមាទដ្ឋានសិក្ខាបទទី ៥

( គហដ្ឋសីលសង្កាត់ទី ១ មាន ៥ សិក្ខាបទចប់ប៉ុណ្ណឹង )

## ៦. វិកាលភោជនសិក្ខាបទ

*វិកាលភោជនៈ* កិរិយាបរិភោគនូវភោជនាហារក្នុងកាលខុស ពេលខុស វេលាហួសកំណត់ ។

ក្នុងវិន័យបិដកភាគ ៤ ទំព័រ ១៣២ មានពោលថា ៖

**វិកាលោ នាម មជ្ឈន្តិកេ វីតិវត្តេ យាវ អរុណុគ្គមនា** វេលាដែលព្រះអាទិត្យជ្រេពីត្រង់ទៅ (សូម្បីប៉ុនចម្រៀកសក់) ទល់នឹងអរុណរះឡើង ហៅថា **ពេលវិកាល** ។

កាល បានដល់ វេលាដែលព្រះអាទិត្យរះឡើងហើយ រហូតដល់ថ្ងៃត្រង់ ។

ភោជនាហារ សំដៅយកខាទនីយៈ និងភោជនីយៈ ។

ដែលហៅថា ខាទនីយៈ(នោះ) បានដល់ របស់ទាំងអស់ វៀរលែងតែភោជន ៥ យ៉ាង និងវត្ថុជាយាមកាលិក សត្តាហកាលិក យាវជីវិកចេញ ។

បទថា អវសេសំ **ខាទនីយំ នាម** ហៅថា ខាទនីយៈនេះ មានវិនិច្ឆ័យដូចតទៅនេះ ៖

ក្នុងអាហារវត្ថុ មានទំជាដើម ដែលសម្រេចមកពីបុព្វណ្ណ-ជាតិ និងអបរណ្ណជាតិ មានពាក្យដែលគួរនឹងពោលមុនយ៉ាងនេះ ៖

សូម្បីវត្ថុណាមួយ មានប្រភេទដូចជាស្លឹកនិងឫសគល់ជាដើម ជារបស់ដែលមានគតិដូចអាមិស នេះគឺយ៉ាងណា ? គឺ សូម្បីវត្ថុនេះជាដើមថា ឫសគួរទំពា មើមគួរទំពា ក្រអៅគួរទំពា ចុងឫត្រយគួរទំពា ដើមគួរទំពា សំបកគួរទំពា ស្លឹកគួរទំពា ផ្កាគួរទំពា ផ្លែគួរទំពា គ្រាប់គួរទំពា មៀវគួរទំពា ជ័រគួរទំពា រមែងដល់នូវការសង្គ្រោះចូលក្នុងខាទនីយៈ (របស់គួរទំពា) ទាំងអស់ ។

ដែលហៅថា ភោជនីយៈ បានដល់ ភោជន ៥ យ៉ាងគឺ :

១- ឱទនៈ បាយ

២- កុម្មាសៈ នំស្រស់

៣- សត្តុ នំក្រៀម

៤- មច្ឆៈ ត្រី

៥- មំសៈ សាច់ ។

អ្នកសមាទាននូវសិក្ខាបទវិកាលនេះ មិនអាចបរិភោគនូវខាទនីយៈ និងភោជនីយៈដែលជាយាវកាលិក មានកាលកន្លងថ្ងៃត្រង់បានទេ កាលថ្ងៃជ្រេទៅហើយ បរិភោគរមែងដាច់សិក្ខាបទហ្នឹងឯង ។

សំដៅត្រង់អជ្ឈោហរណចេតនា ដែលលេបភោជនាហារឱ្យកន្លងបំពង់កចូលទៅ ចំពោះត្រង់វត្ថុជាយាវកាលិកដែលត្រូវបរិភោគពីព្រឹកដល់ថ្ងៃត្រង់ លុះជ្រេពីត្រង់ទៅដរាបទល់នឹងអរុណរះ ហៅថា **វិកាល** ក្នុងសិក្ខាបទនេះ អ្នកសមាទានសិក្ខាបទនេះ គប្បីវៀរចាកនូវវិកាលភោជនៈ បើបរិភោគនូវក្នុងពេលវិកាល ដាច់សិក្ខាបទនេះជាកំណត់ ។

គប្បីដឹងថា វិកាលភោជននេះ ទោះដេកលក់ឥតដឹងខ្លួនអ្វីក៏ដោយ បើអ្នកដទៃណាមួយយកភោជនាហារទៅបញ្ចុកក្នុងមាត់ក្នុងវេលាវិកាល, ហើយលេបចូលផុតបំពង់កទៅ ក៏ឈ្មោះថាដាច់នូវវិកាលភោជនសិក្ខាបទដែរ ។ ព្រោះហេតុអ្វី ? ព្រោះសិក្ខាបទនេះ ជាអចិត្តកៈ ទោះក្លែងក្តី មិនក្លែងក្តី មានស្មារតីក្តី មិនមានស្មារតីក្តី ដឹងក្តី មិនដឹងក្តី ក៏មិនជាប្រមាណក្នុងសិក្ខាបទនេះទេ ឱ្យតែលេបរបស់ដែលជាយាវកាលិក ចូលផុតបំពង់កទៅជាប្រមាណ ។

សមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យបិដក បាចិត្តិយកណ្ឌពោលថា ភិក្ខុណាទំពាក៏ដោយ មិនទំពាក៏ដោយ លេបចូលសូម្បីតែបាយមួយគ្រាប់ឱ្យកន្លងបំពង់កទៅ ភិក្ខុនោះដល់ការរាប់

ថា បានឆាន់ ។

រសរបស់អាមិស ដែលជាប់នៅក្នុងប្រហោងធ្មេញ ដែលរអិលឃ្លាតចេញ ហើយលេបកន្លងបំពង់កទៅ ជាប់វិកាលភោជនសិក្ខាបទ ។ បើអាមិសល្អិត រសមិនប្រាកដ ចាត់ជា **អព្វោហារិក** ( មិនគួរគប្បីពោល ) ។

កាលថ្ងៃជិតត្រង់ ភិក្ខុឆាន់អាហារក្នុងទីមិនមានទឹក ខាកខ្ពុរទឹកមាត់ចោលទៅ ពីរបីដុំ ហើយគប្បីទៅកាន់ទីមានទឹកខ្ពុរមាត់ចុះ ។

អាហារដែលឆាន់ហើយកើចេញ មកប៉ះខ្មប់ទឹងពិតានត្រឡប់ចូលទៅក្នុងខាងក្នុងវិញ គួរពិត ព្រោះជាហេតុផុតវិស័យ ។ ដែលកើចេញមកដល់មាត់ហើយ ( ត្រូវខ្ជាក់ចេញ ហើយខ្ពុរមាត់ចោល ) បើលេបចូលទៅ ជាប់វិកាលភោជនសិក្ខាបទ ។

គប្បីកំណត់កាលវេលាគួរបោះសសរបង្គោល គ្រឿងកំណត់កាលទុក ។

មួយទៀត គួរធ្វើភត្តកិច្ចខាងក្នុងកាល ។

(យោបល់របស់អ្នកសរសេរសៀវភៅ បច្ចុប្បន្ន មនុស្ស ច្រើននិយមការកំណត់ ចំណាំពេលវេលា ដោយការប្រើនាឡិកា ជាគ្រឿងឧបករណ៍សម្រាប់សម្គាល់ បានស្រួលមើលទាំងថ្ងៃ ទាំងយប់ សូម្បីព្រះអាទិត្យ ព្រះចន្ទ ផងឹតអាប់រស្មីដោយប្រការ ណាមួយ ក៏អាចដឹងពេលបាន ។ ក្នុងព្រះពុទ្ធសាសនានេះ ព្រះ មានព្រះភាគទ្រង់បញ្ញត្តព្រះវិន័យ ដោយការកំណត់ពេលវេលាជា មួយនឹងព្រះអាទិត្យ គឺព្រះអាទិត្យរះឡើង ត្រង់ និងលិចចុះ ។

សប្បុរសអ្នកទ្រទ្រង់វិកាលភោជនសិក្ខាបទ គួរប្រៀបផ្ទឹម (ម៉ោង) នឹងការប្រែប្រួលនៃព្រះអាទិត្យ ទៅតាមរដូវ និងតាម តំបន់ ។ តាមរដូវ ជួនកាលព្រះអាទិត្យដើរផ្អៀងទៅខាងត្បូង ជួន កាលដើរផ្អៀងទៅខាងជើង ជួនកាលដើរត្រង់ចំពីលើ មួយទៀត ថា ក្នុងគិម្ហន្តរដូវព្រះអាទិត្យដើរក្នុងវិថីទាប ក្នុងវស្សានរដូវព្រះ អាទិត្យដើរក្នុងវិថីកណ្តាល ក្នុងហេមន្តរដូវព្រះអាទិត្យដើរក្នុង វិថីខ្ពស់ ជួនកាលយប់យូរថ្ងៃឆាប់ ជួនកាលថ្ងៃយូរយប់ឆាប់ ។ តាមតំបន់ គឺតំបន់នីមួយៗ ព្រះអាទិត្យរះឡើង ត្រង់ និងលិចចុះ

ខុសម៉ោងគ្នាជាលំដាប់តិច ឬច្រើន ដោយឆ្ងាយឬជិត បើជិតក៏ខុសតិច បើឆ្ងាយក៏ខុសច្រើន ។

ហេតុនេះសប្បុរសអ្នកទ្រទ្រង់វិកាលភោជនសិក្ខាបទ គួរឧស្សាហ៍ប្រៀបផ្ទឹមម៉ោង ជាមួយនឹងព្រះអាទិត្យ ដោយស្រមោលសសរបង្គោលចំណាំពេលវេលា សមដូចក្នុងសមន្តប្បាសាទិកាអដ្ឋកថាព្រះវិន័យ លោកពោលទុកថា គួរបោះសសរបង្គោលគ្រឿងកំណត់កាលទុកមើល ) ។

ឯកាលិកវត្ថុដែលបរិភោគក្នុងកាលនេះ ចែកដោយកាលមាន ៤ យ៉ាងគឺ :

**១ - យាវកាលិក** របស់ដែលត្រូវបរិភោគកំណត់កាលពីអរុណរះឡើង ដរាបដល់ថ្ងៃត្រង់ (គឺអស់កំណត់កាលត្រឹមប៉ុណ្ណឹង) បានដល់វត្ថុទាំងនេះគឺ ខាទនីយភោជនីយាហារ បាយ ផ្លែឈើ នំបង្អែម ចម្អាប ត្រី សាច់ និងអង្ករជាដើម ហៅថា **យាវកាលិក** ។

**២ - យាមកាលិក** ទឹកដែលគួរបរិភោគផឹកបានត្រឹមតែមួយថ្ងៃ មួយយប់ បានដល់ ទឹកបានទាំង ៨ ប្រការគឺ :

១ - អម្ពបានំ ទឹកផ្លែស្វាយ

២- ជម្ពុបានំ ទឹកផ្លែព្រីង

៣- ចោចបានំ ទឹកផ្លែចេកមានគ្រាប់

៤- មោចបានំ ទឹកផ្លែចេកឥតគ្រាប់

៥- មធុបានំ ទឹកផ្លែស្រគំ

៦- មុទ្ទិកបានំ ទឹកផ្លែចាន់

៧- សាលុកបានំ ទឹកក្រអៅឈូក

៨- ផារុសកបានំ ទឹកផ្លែម៉ាក់ប្រាង

ទឹកជាតិផ្លែឈើទាំង ៨ ប្រការនេះ ជាយាមកាលិក ។

ក្នុងសមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យ មហាវគ្គវណ្ណនាថា ព្រះធម្មសង្គាហកត្ថេរទាំងឡាយ កាលកាន់យកសូត្រផ្ទៀងផ្ទាត់មើលក្នុងមហាបទេសនោះ បានឃើញសេចក្ដីនេះថា ទឹកគ្រាប់ធញ្ញជាតិ មិនគួរក្នុងបច្ឆាភត្ត ព្រោះមានព្រះបាលីថា ឋបេត្វា ធញ្ញផលរសំ លើកលែងតែរសនៃគ្រាប់ធញ្ញជាតិ ៧ យ៉ាង ។

ធញ្ញជាតិ ៧ យ៉ាងគឺ :

១- សាលី ស្រូវសាលី

២_ វិហី ស្រូវខ្សាយ

៣_ យវោ ស្រូវដំណើប

៤_ គោធុមោ ស្រងែ

៥_ កង្គុ ថ្លៅ

៦_ វរកោ ពោត ស្កួយ ឬស្មៅកន្ទុយដំរី

៧_ កុទ្រូសកោ ស្មៅគែលលក ។

មហាផល ៩ យ៉ាង អបរណ្ណជាតិគ្រប់ប្រភេទ ក៏មិនគួរ យកមកធ្វើជាទឹកបានឡើយ ។

ឯមហាផល ៩ យ៉ាងនោះគឺ :

១_ តាលផលំ ផ្លែត្នោត

២_ នាឡិកេរផលំ ផ្លែដូង

៣_ បនសផលំ ផ្លែខ្នុរ

៤_ លពុជផលំ ផ្លែខ្នុរសម្ល

៥_ អាលាពុផលំ ផ្លែឃ្លោក

៦_ ឯឡាលុកផលំ ផ្លែត្រឡាច

៧- បុស្សផលំ ផ្លែត្រសក់

៨- តិបុសផលំ ផ្លែឪឡឹក

៩- កុម្ភណ្ឌផលំ ផ្លែល្ពៅ ។

អបរណ្ណជាតិ មានសណ្ដែកល្ងជាដើម ។

មហាផល និងអបរណ្ណជាតិគ្រប់ប្រភេទនោះ មានគតិដូចធញ្ញជាតិដែរ សូម្បីព្រះអង្គមិនបានទ្រង់ហាមទុក ក៏ពិតមែន តែថា រមែងអនុលោមចូលក្នុងអកប្បិយវត្ថុ, ព្រោះហេតុនោះ ទើបមិនគួរក្នុងបច្ឆាភត្ត ( ក្រោយភត្ត ) ។

ទឹកបាន ៨ យ៉ាង ទ្រង់អនុញ្ញាតទុក ទឹកផ្លែឈើតូច មានផ្ដៅ អំពិល ក្រូច ខ្វិត ពទ្រ និងផ្លែសង្ឃ័រជាដើម មានគតិដូចអដ្ឋបានពិត ទឹកបាននៃផ្លែឈើទាំងនេះ ទ្រង់មិនបានអនុញ្ញាតទុកក៏ពិតមែនហើយ តែថារមែងអនុលោមចូលក្នុងវត្ថុជាកប្បិយៈ ព្រោះដូច្នោះ ទើបសមគួរ ។

ក្នុងកុរុន្ទីពោលថា ពិតមែន វៀររសនៃគ្រាប់ស្រូវព្រមទាំងវត្ថុដែលអនុលោមចេញហើយ ដែលឈ្មោះថា ទឹកផ្លែឈើជនៃដែលមិនគួរមិនមាន ទឹកផ្លែឈើគ្រប់ប្រភេទជាយាមកាលិកពិត ។

( ពន្យល់ថែមទៀតថា សូម្បីរសនៃបន្លែ ដែលជាយាវកាលិក ដែលប្រហាប់ក្នុងទឹកត្រជាក់ធ្វើក្តី ឆ្អិនដោយកំដៅព្រះអាទិត្យក្តី រមែងគួរ ) ។

បណ្តាទឹកបានទាំងនោះ អម្ពបាននោះ បានដល់ ទឹកបានដែលធ្វើដោយផ្លែស្វាយខ្ចីឬទុំ ។ បណ្តាស្វាយខ្ចីនិងទុំ ២ យ៉ាងនេះ កាលនឹងធ្វើដោយស្វាយខ្ចី គប្បីបុកស្វាយខ្ចីដាក់ក្នុងទឹកហាលឱ្យឆ្អិនដោយកំដៅព្រះអាទិត្យ ហើយត្រងផ្សំដោយទឹកឃ្មុំ ស្ករ និងកាបូជាដើម ក្នុងទឹកបានគ្រប់ប្រភេទក៏ន័យនេះ ។ អដ្ឋបានទាំងនេះ ត្រជាក់ក្តី ឆ្អិនដោយកំដៅព្រះអាទិត្យក្តី រមែងគួរ ។ ឆ្អិនដោយភ្លើង មិនគួរ ។ ( ពាក្យថា ឆ្អិនដោយភ្លើងមិនគួរនោះ សេចក្តីថា ចាំបាច់ពោលទៅថ្វីដល់ការដាំ ឬស្ងោរនោះ សូម្បីយកទឹកទាំងក្តៅ ដែលដាំដោយភ្លើង មកចាក់ដាក់លាយវត្ថុដែលបុក ឬប្រហាប់សម្រាប់ធ្វើនោះ ទឹកបាននោះ រមែងមិនគួរ ) ។

**៣. សត្តាហកាលិក** ជារបស់ដែលភិក្ខុទុកឆាន់បាន ត្រឹម ៧ ថ្ងៃ បានដល់ ថ្នាំ ៥ ប្រការគឺ :

១- សប្បិ ទឹកដោះថ្លា

២- នវនីត ទឹកដោះខាប់

៣- តេល ប្រេង

៤- មធុ ទឹកឃ្មុំ

៥- ផាណិត ស្ករអំពៅ ។

វិន័យបិដកភាគ ៧ ទំព័រ ៣៥៩ ព្រះមានព្រះភាគទ្រង់ត្រាស់អនុញ្ញាតថា អនុជានាមិ ភិក្ខវេ បញ្ច គោរសេ **ខីរំ ទធឹ តក្កំ នវនីតំ សប្បិ** ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគោរស ៥ យ៉ាងគឺ ទឹកដោះស្រស់ ១ ទឹកដោះជូរ ១ ខ្លាញ់ ១ ទឹកដោះខាប់ ១ ទឹកដោះថ្លា ១ ។

បណ្តាទឹកដោះទាំងនោះ **ខីរំ** ទឹកដោះស្រស់ ១ **ទធឹ** ទឹកដោះជូរ ១ **តក្កំ** ខ្លាញ់ ១ បីប្រភេទនេះ គួរក្នុងកាល ។ **នវនីតំ** ទឹកដោះខាប់ ១ **សប្បិ** ទឹកដោះថ្លា ១ ពីរប្រភេទនេះ គួរគ្រប់កាលទាំងអស់ ។

ពាក្យថា **តេលៈ** ប្រេង បានដល់ប្រេងល្ង ប្រេងស្ពៃ ប្រេងស្រគំ ប្រេងល្ហុងខ្វែរ និងខ្លាញ់ពាវ (របស់សត្វគ្រប់ប្រភេទ

ដែលចម្រាញ់ហើយ ត្រងស្អាតហើយ ) ហៅថា ប្រេង ។ ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតខ្លាញ់នៃសត្វ ដែលមានមំសៈជាអកប្បិយៈទាំងអស់ វៀរតែខ្លាញ់មនុស្សចេញ ។

**មធុ** ទឹកឃ្មុំ បានដល់ ទឹកឃ្មុំដែលពួកមេឃ្មុំធំ ឃ្មុំតូច និងពួកពង្រូតធ្វើ ។

**ផាណិតះ** ស្ករអំពៅ ទឹកអំពៅដែលមិនមានកាក( ត្រងហើយ ) និងស្ករអំពៅគួរក្នុងវិកាល( គួរគ្រប់កាល ) ។ អំពៅដែលគួរដល់ការទំពាក្តី ទឹកអំពៅដែលមានកាកក្តី គួរបានតែក្នុងកាល ។

**៤. យាវជីវិក** របស់ជាភេសជ្ជៈដែលភិក្ខុទុកឆាន់បានទាល់តែអស់ជាកំណត់, បានដល់ ថ្នាំជាភេសជ្ជៈ ដែលព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតទុកមកដូច្នេះគឺ :
មើមរមៀត មើមខ្ញី មើមលំពាន់ មើមប្រស់ មើមអាចម៍ឆ្អឹស មើមរំដេង មើមស្បូវក្លាំង មើមស្មៅក្រវាញជ្រូក ។

បណ្តាមើមទាំងនោះ ដែលចាស់ឬខ្ចីរបស់មើម ក្រមរ និងពួកឫសតូចៗ នៃមើមគ្រប់យ៉ាងចាត់ជា**យាវជីវិក** ។

ពួកទឹកចត់ដែលកើតអំពីដើមស្ដៅ ទឹកចត់ដែលកើតអំពីដើមខ្ទឹងគន់ ទឹកចត់កើតអំពីដើមអំបែងថ្ងៃ ឬពុលឯក ទឹកចត់កើតអំពីវល្លិបណ្ដូលពេជ្រ ទឹកចត់កើតអំពីទន្លា ឬថ្វាន់ ។

ម្យ៉ាងទៀត ទឹកចត់ដទៃណាជាភេសជ្ជៈ មិនផ្សាយទៅដើម្បីខាទនីយៈក្នុងខាទនីយៈ មិនផ្សាយទៅដើម្បីភោជនីយៈ ក្នុងភោជនីយៈ ការសង្គ្រោះត្រួយ ដើម និងសំបកទាំងនោះ ចូលក្នុងព្រះពុទ្ធានុញ្ញាតនេះ រមែងសម្រេច (រមែងប្រើបាន) និងទឹកចត់ដែលពោលហើយ បណ្ឌិតគប្បីជ្រាបថា ជារបស់សមគួរដោយប្រការគ្រប់យ៉ាង ។

ក្នុង**បត្តខាទនីយៈ** មានវិនិច្ឆ័យដូច្នេះ ៖

ពួកស្លឹកស្ដៅ ស្លឹកខ្ទឹងគន់ ស្លឹកអំបែងថ្ងៃ ឬពុលឯក ស្លឹកម្រះព្រៅ ឬស្លឹកជីលីងលាក់ ស្លឹកកប្បាស ។

ម្យ៉ាងទៀតស្លឹកដទៃណា ជាភេសជ្ជៈមិនផ្សាយទៅដើម្បីខាទនីយៈក្នុងខាទនីយៈ មិនផ្សាយទៅដើម្បីភោជនីយៈក្នុងភោជនីយៈ ដូច្នេះស្លឹកទាំងនោះ ជា**យាវជីវិក** ។

ពួកផ្លែពិលង្គ ផ្លែដីប្លី ផ្លែម្រេច ផ្លែស្រម៉ ផ្លែស្រម៉ពីភេក

ផ្លែកន្ទួតព្រៃ ផ្លែក្រវាញ ។

ម្យ៉ាងទៀត ផ្លែនិងផ្កាទាំងឡាយណា ជាភេសជ្ជៈ មិនផ្សាយទៅ ដើម្បីខាទនីយៈក្នុងខាទនីយៈ មិនផ្សាយទៅដើម្បីភោជនីយៈក្នុងភោជនីយៈ ដូច្នេះផ្លែនិងផ្កាទាំងនោះ ជា**យាវជីវិក**ដូចគ្នា ។

ពួកជ័រដែលហូរចេញអំពីដើមហិង្គុ ១ ជ័រដែលគេយកស្លឹកហិង្គុនិងមែកហិង្គុមករំងាស់ ១ ជ័រដែលគេយកតែស្លឹកហិង្គុតែម្យ៉ាងមករំងាស់ ១ ជ័រដែលហូរចេញអំពីត្រួយឈើ ១ ជ័រដែលហូរចេញអំពីស្លឹកឈើ ១ ជ័រដែលគេបេះស្លឹកឈើយកមកធ្វើ ១ កំញាន ១ ។

ម្យ៉ាងទៀត ជ័រឈើដទៃណាជាភេសជ្ជៈ មិនផ្សាយទៅដើម្បីខាទនីយៈក្នុងខាទនីយៈ មិនផ្សាយទៅដើម្បីភោជនីយៈក្នុងភោជនីយៈដូច្នេះ ជ័រទាំងនោះ ចាត់ជា**យាវជីវិក** ។

អំបិលដែលកើតក្បែរឆ្នេរសមុទ្រ មានបែបដូចដីខ្សាច់ អំបិលមានពណ៌ខ្មៅគឺអំបិលប្រក្រតី អំបិលមានពណ៌សកើតលើភ្នំ អំបិលមានពន្លកដុះអំពីផែនដី គឺអំបិលដែលកើតអំពីអាចម៍

ដីមានរសប្រៃ អំបិលមានពណ៌ក្រហមដែលគេចម្អិនជាមួយនឹងសម្ភារៈទាំងពួង ។

កាលបើមានហេតុគឺជម្ងឺ ទើបឆាន់ ឬផឹកបាន បើគ្មានហេតុទេ កុំឆាន់ កុំផឹក ។

វិកាលភោជនសិក្ខាបទនេះ មានអង្គ ៣ គឺ :

១- **វិកាលោ** កាលខុសគឺព្រះអាទិត្យជ្រេទៅហើយ ដរាបទល់នឹងអរុណរះ

២- **យាវកាលិកំ** របស់ដែលបរិភោគបានក្នុងកាល គឺចាប់តាំងពីអរុណរះឡើងដរាបដល់ថ្ងៃត្រង់

៣- **អជ្ឈោហរណំ** លេបចូលកន្លងបំពង់ក ។

**អនាបត្តិ:** ហេតុដែលមិនត្រូវទោសមាន ២ យ៉ាងគឺ :

១- បរិភោគរបស់ដែលជាយាមកាលិក សត្តាហកាលិក និងយាវជីវិកដែលមានហេតុគួរបរិភោគបាន

២- ជាមនុស្សឆ្កួត ។

" ចប់ វិកាលភោជនសិក្ខាបទទី ៦ "

## ៧. នច្ចគីតវាទិតវិសូកទស្សនសិក្ខាបទ

**នច្ចគីត...** កិរិយារាំ និងច្រៀង និងប្រគំដូរ្យតន្ត្រីផ្សេងៗ ដោយខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យគេរាំក្តី ឱ្យគេច្រៀងក្តី ឱ្យគេប្រគំជាដូរ្យតន្ត្រីផ្សេងៗក្តី ទៅមើល ទៅស្តាប់នូវពួកល្បែងដែលជាសឹកសត្រូវដល់កុសលធម៌ក្តី ប្រកបរឿយៗ នូវពួកល្បែងបាស្កា ដែលជាហេតុជាទីតាំងនៃសេចក្តីប្រមាទក្តី ទាំងនេះសុទ្ធតែជាច់ខ្លួចនច្ចគីត...សិក្ខាបទទាំងអស់ ។

ឯល្បែងដែលជាសឹកសត្រូវដល់កុសលធម៌នោះដូច្នេះគឺ :

**នច្ចំ** ល្បែងរាំ **គីតំ** ច្រៀង **វាទិតំ** ប្រគំ **បេក្ខំ** មហោស្រពល្ខោនជាដើម **អក្ខានំ** រឿងចម្បាំងមហាភារតៈ និងរាមកេរ្តិ៍ជាដើម **បាណិស្សរំ** គង **វេតាឡំ** រគាំង **កុម្ភថូនំ** ស្គរមានជ្រុង ៤ **សោភនគរកំ** គូរគំនូររូបរបាំ **ចណ្ឌាលំ** ល្បែងដំដែក **វីសំ** ល្បែងរ៉ាវ **ធោវនំ** ល្បែងលាងឆ្អឹង **ហត្ថិយុទ្ធំ** ដំរីជល់គ្នា **អស្សយុទ្ធំ** សេះប្រខាំគ្នា **មហិសយុទ្ធំ** ក្របីជល់គ្នា **ឧសភយុទ្ធំ** គោជល់គ្នា **អជយុទ្ធំ** ពពែជល់គ្នា **មេណ្ឌយុទ្ធំ** កែះជល់គ្នា **កុក្កុដយុទ្ធំ** មាន់ជល់គ្នា

វង្គកយុទ្ធំ ចាបជល់គ្នា ទណ្ឌយុទ្ធំ លេងគុណដំបង មុដ្ឋិយុទ្ធំ ប្រដាល់ និព្វុទ្ធំ ចម្បាប់ ឧយ្យោធិកំ ចម្បាំង ពលគ្គំ ទីគេរាប់ពល សេនាព្យូហំ ទីលំនៅកងទ័ព អនីកទស្សនំ ទីមើលសេនាដែលប្រកបដោយអង្គ ៤ ។

ចំណែកល្បែងបាស្កា ដែលជាហេតុជាទីតាំង នៃសេចក្ដីប្រមាទនោះដូច្នេះគឺ :

១- អដ្ឋបទំ បាស្កាមានក្រឡា ៨ ( ចត្រង្គមានក្រឡា ៨ )

២- ទសបទំ បាស្កាមានក្រឡា ១០ ( ចត្រង្គមានក្រឡា ១០ ឬបាយខ្ញុំ )

៣- អាកាសំ បាស្កាដែលលេងព្ធដ៏អាកាស ( ចត្រង្គឥតមានក្ដារ លេងតែមាត់ទទេ )

៤- បរិហារបថំ លេងវាងផ្លូវដែលគួរវាង ( លេងបិទមុខបិទពួន )

៥- សន្តិកំ លេងផ្ទាត់គ្រាប់ មានគ្រាប់ក្រួសជាដើម

៦- ខលិកំ លេងបាស្កាក្នុងទីលានសម្រាប់លេង

៧- ឃដិកំ លេងហ៊ឹងឬកូនគោល

៨- សលាកហត្ថំ លេងលោសទឹកលក្ខឱ្យទាយរូប

៩- អក្ខំ លេងអង្គញ់

១០- បង្គចីរំ លេងផ្លុំប៉ីស្លឹក

១១- វង្កកំ លេងនង្គ័លតូច

១២- មោក្ខចិកំ លេងដាំដូង

១៣- ចិង្គុលិកំ លេងកង្ហារ

១៤- បត្តាឡ្ហកំ លេងវាល់ដីខ្សាច់ (បាយឡុកបាយឡ)

១៥- រថកំ លេងរថតូច

១៦- ធនុកំ លេងធ្នូតូច

១៧- អក្ខរិកំ លេងសរសេរអក្សរខ្យល់ឱ្យទាយ

១៨- មានេសិកំ លេងទាយចិត្ត (ស្ដេចចង់)

១៩- យថាវជ្ជំ លេងកំប្លែងត្រាប់គេ ។

ទោសរបស់ចម្រៀងមាន ៥ យ៉ាងគឺ :

១- អត្តនោបិ តស្មឹ សរេ សារជ្ជតិ អ្នកច្រៀងរមែង ត្រេកអរ ក្នុងសម្លេងរបស់ខ្លួននោះ

២- បរេបិ តស្មិំ សរេ សារជ្ជន្តិ ជនទាំងឡាយដទៃរមែង ត្រេកអរក្នុងសម្លេងនោះ

៣- គហបតិកាបិ ឧជ្ឈាយន្តិ ពួកគហបតីទាំងឡាយ តែង ពោលទោស

៤- សរគុត្តីបិ និកាមយមានស្ស សមាធិស្ស ភង្គោ ហោតិ មនុស្សអ្នកពេញចិត្តនឹងការសូត្ររលាក់រលែកជា សម្លេងបែបបទ រមែងបែកខូចសមាធិ

៥- បច្ឆិមា ជនតា ទិដ្ឋានុគតិមាបជ្ជតិ ពួកជនជាន់ក្រោយ នឹងដល់នូវទិដ្ឋានុគតិ គឺយកតម្រាប់តាម ។

ល្បែងប៉ុណ្ណេះជាដើម ជាហេតុជាទីតាំងនៃសេចក្តីប្រមាទ បើលេងខ្លួនឯង ឬទៅមើលគេលេង ជាច់នច្ចគីត...សិក្ខាបទ ហ្នឹងឯង ។

ពាក្យថា នច្ចំ រាំនេះ លោកថា យំកិញ្ចិ នច្ចំ យំកិញ្ចិ គឺតំ យំកិញ្ចិ វាទិតំ ។ បីពាក្យជាដើមនេះ រាំណាមួយ ច្រៀងណាមួយ ប្រគំណាមួយ ឃើញថា ឆាយស្តាប់ណាស់ទៅ

ហើយ ពីព្រោះចប់ត្រង់ពាក្យថាណាមួយ ។

សមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យបិដក ភិក្ខុនីវិភង្គវណ្ណនា បានពន្យល់ពីរបទថា **យច្ចិញ្ចិ វាទិតំ** ប្រគំឯណានីមួយ មានសេចក្តីថា គ្រឿងភ្លេងមានការបន្តឹងខ្សែជាដើម ឬការប្រគំស្គរក៏ដោយ ដោយហោចទៅ សូម្បីវាយ**ឧទកភេរី** (ស្គរទឹក) ទាំងអស់នេះចាត់ជាការប្រគំទាំងអស់ ។ (ក្នុងបទថា វាយ **ឧទកភេរី** = បានសេចក្តីថា អ្នកប្រគំ សន្ទូតផ្ទៃទឹកក្នុងទីណាមួយ ជាស្បែកស្គរ ហើយប្រគំដោយដៃតាមលំនាំ វាយស្គរជាចង្វាក់ភ្លេងដែលខ្លួនចូលចិត្ត) ។

សរុបសេចក្តីឱ្យខ្លីមកថា រាំបែបណាក៏ដោយ ឱ្យតែរាំ ច្រៀងបែបណាក៏ដោយ ឱ្យតែច្រៀង ប្រគំបែបណាក៏ដោយ ឱ្យតែប្រគំ ឈ្មោះថា ជាការរាំ និងប្រគំទាំងអស់ ។

ដូចក្នុងអដ្ឋកថាលោកបានប្រាប់ទៀតថា រាំឯណានីមួយ ដោយហោចទៅ សូម្បីតែសត្វក្ងោក សេក ស្វារាំជាដើម បានឈ្មោះថា **នច្ចះ** ទាំងអស់ចម្រៀងនៃពួករបាំក្តី ចម្រៀងប្រកបដោយព្រះរតនត្រ័យក្នុងកាលអរិយបរិនិព្វានក្តី ចម្រៀង

នៃភិក្ខុអ្នកសូត្រធម៌មិនសង្រួមក្តី ដោយហោចទៅ សូម្បីច្រៀង ដោយធ្មេញក្តី ក៏ឈ្មោះថា **គីតះ** ច្រៀងទាំងអស់ ។

**សាធុគីតំ, សាធុគីតន្តិ អនិច្ចតាទិបដិសំយុត្តំ គីតំ ។** ប្រែមកថា ចម្រៀងថា សាធុ, ដីកាឆ្លើយថា ចម្រៀងប្រកបព្រម ដោយលក្ខណៈ មានអនិច្ចលក្ខណៈជាដើមហ្នឹងហើយ ឈ្មោះថា **សាធុគីតំ** ។

ហេតុនេះត្រូវតាំងវិរតិចេតនាដូច្នេះថា "កុំគប្បីរាំ ច្រៀង ប្រគំ ទៅមើល ទៅស្តាប់ឱ្យសោះ" គួរដឹងតាមបាលីនេះតទៅថា

**វិសូកទស្សនន្តិ កិលេសុប្បត្តិបច្ចយតោ កុសលបក្ខ-ភិន្ទនេន វិសូកានំ វិសូកភូតំ វា ទស្សនំ វិសូកទស្សនំ ។**

ការមើលពួកល្បែងជាសឹកសត្រូវ ឬថាកិរិយាមើលនូវ ពួកល្បែង ដែលជាមេនាំឱ្យកើតសឹកសត្រូវ (ដល់ផ្លូវចិត្តជា កុសល) បានដល់ សឹកសត្រូវទាំងឡាយ ដែលជាមេបក្ស បំបែកពួកកុសល ហើយបានទៅជាបច្ច័យរហូតដល់កើតកិលេស យ៉ាងនេះបានឈ្មោះថា **វិសូកទស្សនំ** ក្នុងសិក្ខាបទនេះ ។

នច្ចគីត...សិក្ខាបទនេះ មានអង្គ ៣ គឺ :

១- នច្ចគីតាទិ ការមើលល្បែងមានរាំច្រៀងជាដើម

២- ទស្សនកម្យតាចិត្តំ ចិត្តគិតបម្រុងនឹងធ្វើ

៣- សុតទស្សនត្ថាយ គមនំ ទៅដើម្បីនឹងស្ដាប់ឬមើល ហើយបានស្ដាប់ឬមើល ។

អនាបត្តិ: ហេតុដែលមិនត្រូវទោសមាន ៦ យ៉ាងគឺ :

១- ឈរមើល ឬស្ដាប់ក្នុងទីលំនៅ (ដែលខ្លួនមិនបញ្ជា)

២- ជនទាំងឡាយ មកកាន់ទីដែលខ្លួនឈរនៅ ឬអង្គុយ ឬក៏ដេក ហើយ(គេ)រាំក្ដី ច្រៀងក្ដី ប្រគំក្ដី

៣- កំពុងដើរទៅជួបតាមផ្លូវ ហើយឃើញក្ដី ឮក្ដី

៤- កាលបើខ្លួនមានកិច្ចដើរទៅហើយ ឃើញក្ដី ឮក្ដី

៥- មានសេចក្ដីអន្តរាយ

៦- ឆ្កួត ។

"ចប់ នច្ចគីតវាទិតវិសូកទស្សនសិក្ខាបទទី ៧ "

## ៨. មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានសិក្ខាបទ

មាលា...កិរិយាទ្រទ្រង់និងប្រដាប់តាក់តែង ស្អិតស្អាងរាងកាយ ដោយផ្កាកម្រងនិងគ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ មានទឹកអប់និងម្សៅលាបមុខជាដើមក្តី ផាត់មុខ ដុសខាត់មុខ ប្រស់មុខ ចុចមុខ ឬចឹមមុខដោយថ្មនោសិលា ឬម្សៅលាបមុខលាបខ្លួនជាដើម ជាចំមាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានសិក្ខាបទទាំងអស់ ។

វត្ថុជាទីតាំងនៃការប្រដាប់ស្អិតស្អាងរាងកាយនោះដូច្នេះគឺ :

ឧច្ឆាទនំ កិរិយាដុសខាត់បំបាត់ក្លិនអាក្រក់ (គ្រឿងអប់) **បរិមទ្ទនំ** ការប្រេបាច់រឹត **ន្ហាបនំ** ការផ្ងូតទឹក **សម្ពាហនំ** ការគក់ប្របាច់ **អាទាសំ** កញ្ចក់ **អញ្ជនំ** វត្ថុសម្រាប់លាប (គ្រឿងប្រដាប់) **មាលាគន្ធវិលេបនំ** ផ្កាកម្រងនិងគ្រឿងក្រអូប និងគ្រឿងលាប **មុខចុណ្ណំ** គ្រឿងលម្អិតសម្រាប់ប្រស់មុខ **មុខវិលេបនំ** វត្ថុសម្រាប់លាបមុខ **ហត្ថពន្ធំ** គ្រឿងប្រដាប់ចងដៃ **សិខាពន្ធំ** ចំណងផ្នួងសក់ **ទណ្ឌំ** ដំបង **នាលិកាំ** បំពង់

ថ្នាំ អសី ដាវ ខគ្គំ ព្រះខ័ន ឆត្តំ ឆត្រ ចិត្រុបាហនំ ស្បែកជើងវិចិត្រ ឧណ្ហីសំ មកុដឬក្បាំងមុខ(ស្ទៀតសក់) មណី កែវមណី វាលវិជនី ផ្លិតធ្វើដោយរោមកន្ទុយសត្វ ឱទាតានិ វត្ថានិ សំពត់ស ទីឃទសានិ សំពត់មានជាយវែង ។

វត្ថុជាទីតាំងនៃការប្រដាប់ស្អិតស្អាងរាងកាយ មានសភាព យ៉ាងនេះ បើអ្នកសមាទាននូវសិក្ខាបទនេះ ហើយស្អិតស្អាងរាង កាយដោយវត្ថុណាមួយ ដាច់សិក្ខាបទ ។

(ពាក្យថា "ឱទាតានិ វត្ថានិ សំពត់ស" ឧបាសក ឧបាសិកាដែលស្លៀកសពាក់ស ល្អប្រពៃហើយ គឺត្រឹមត្រូវ ហើយ សូមកុំសង្ស័យឡើយ កុំប្រឡូំឡើយថាមិនគួរ ឯពាក្យថា សំពត់សនៅក្នុងទីនេះ សំដៅយកការស្លៀកពាក់ដោយបំណង ដើម្បីស្អិតស្អាង តាក់តែង លេងខ្លួន តែប៉ុណ្ណោះ) ។

នៅក្នុងគម្ពីរសុមង្គលវិលាសិនី បានពន្យល់ថា មាលាទីសុ មាលាតិ យំ កិញ្ចិ បុប្ផំ ។ បណ្ដាគ្រឿងប្រដាប់ទាំងឡាយ មានផ្កាឈើជាដើមឈ្មោះថា "មាលា" បានដល់ផ្កាឈើឯណា

ទីមួយ ។

គន្ធន្តិ យំកិញ្ចិ គន្ធជាតំ ។ គន្ធជាតកំណើតក្លិនណាមួយ ក៏ឈ្មោះថា "គន្ធៈ" ដែរ ។

វិលេបនន្តិ ឆវិរាគករណំ ។ កិរិយាធ្វើឱ្យស្បែកសម្បុរថ្លៃបានជាទីតម្រេក ឈ្មោះថា "វិលេបនៈ" ។

តត្ថ បិឡន្ធន្តោ ធារេតិ នាម ។ កាលពាក់ លាបប្រដាប់ទាំងនោះ ឈ្មោះថា "ធារណៈ" ។

ឩនដ្ឋានំ បូរេន្តោ មណ្ឌេតិ នាម កាលបំពេញចំណែកនៃកាយដែលខ្វះ ឈ្មោះថា ប្រដាប់កាយ ។

គន្ធវសេន ឆវិរាគវសេន ច សាទិយន្តោ វិភូសេតិ នាម ។ កាលត្រេកអរដោយអំណាចគ្រឿងក្រអូបផង ដោយអំណាចឆវិរាគៈផង ឈ្មោះថា "វិភូសនៈ" ។ ប្រមូលបាលីមកជាសិក្ខាបទវិញថា មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនៈ ដូច្នេះ ។

មាលា...សិក្ខាបទនេះ មានអង្គ ៣ គឺ :

១- មាលាទិ វត្ថុសម្រាប់ប្រដាប់កាយមានផ្កាកម្រងជាដើម

២- ធារណច្ឆន្ទតា ប្រាថ្នានឹងប្រដាប់តាក់តែង

៣- តស្ស ធារណំ បានប្រដាប់តាក់តែង នូវវត្ថុសម្រាប់ប្រដាប់កាយមានផ្កាកម្រងជាដើមនោះ ។

អនាបត្តិ: ហេតុដែលមិនត្រូវទោសមាន ២ យ៉ាងគឺ :

១- មានជម្ងឺរោគាពាធ

២- ឆ្កួត ។

"ចប់ មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋាន សិក្ខាបទទី ៨"

## ៩. ឧច្ចាសយនមហាសយនសិក្ខាបទ

ឧច្ចាសយនមហាសយនា ទីដេកឬទីអង្គុយដ៏ខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ ។

បរិភោគចេតនា របស់បុគ្គលអ្នកសមាទាននូវសិក្ខាបទនេះ រមែងដាច់នូវសិក្ខាបទ ។

ឯទីសេនាសនៈដ៏ខ្ពស់ហួសប្រមាណនោះគឺ :

-គ្រែឬតាំងដែលមានជើងខ្ពស់ជាង ៨ ធ្នាប់ព្រះសុគត ។

-គ្រែដែល គេកល់កំណាល់ខ្ពស់ជាង ៨ ធ្នាប់មនុស្សប្រក្រតី ។

ឯទីសេនាសនៈដ៏ប្រសើរនោះ គឺកន្លែងដេក ឬទីអង្គុយណាមួយ ដែលគេក្រាលដោយកម្រាលដ៏វិចិត្រផ្សេងៗ ហៅថាទីសេនាសនៈដ៏ប្រសើរ ។

អាសនៈខ្ពស់ហួសប្រមាណ និងអាសនៈដ៏ប្រសើរនោះគឺ :

១- អាសន្ទិ អាសនៈដែលខ្ពស់ហួសប្រមាណ

២- បល្លង្កៈ គ្រែដែលមានជើងវិចិត្រដោយរូបសត្វសាហាវ

៣- គោណកៈ ព្រំដែលមានរោមវែងជាង ៤ ធ្នាប់

៤- ចិត្តកៈ កម្រាលដែលគេធ្វើពីរោមសត្វ វិចិត្រដោយរូបសត្វសាហាវ
៥- បដិកៈ កម្រាលមានពណ៌សដែលគេធ្វើដោយរោមសត្វ
៦- បដលិកៈ កម្រាលដែលធ្វើដោយរោមសត្វជាផ្កាចង្កោម
៧- តូលិកៈ កម្រាលដែលញាត់ដោយសំឡីគ
៨- វិកតិកៈ កម្រាលដែលធ្វើដោយរោមសត្វ វិចិត្រដោយរូបសត្វ មានសត្វសីហៈនិងខ្លាធំជាដើម
៩- ឧទ្ធលោមិ កម្រាលដែលធ្វើដោយរោមសត្វ មានរោមប្រាងឡើងតែម្ខាង
១០- ឯកន្តលោមិ កម្រាលដែលធ្វើដោយរោមសត្វមានរោមប្រាងឡើងទាំងពីរខាង
១១- កដិស្ស កម្រាលដែលធ្វើដោយឌិនមាស និងសូត្រហើយចាក់ស្រែះដោយរតនវត្ថុ
១២- កោសេយ្យៈ កម្រាលដែលធ្វើដោយសរសៃសូត្រហើយចាក់ស្រែះដោយរតនវត្ថុ
១៣- កុត្តកៈ កម្រាលដែលធ្វើដោយរោមសត្វ ល្មមពួកស្រី

របាំ ១៦ នាក់ឈររាំបាន

១៤- ហត្ថត្ថរៈ កម្រាលសម្រាប់ក្រាលលើខ្នងដំរី

១៥- អស្សត្ថរៈ កម្រាលសម្រាប់ក្រាលលើខ្នងសេះ

១៦- រថត្ថរៈ កម្រាលសម្រាប់ក្រាលលើរថ

១៧- អជិនប្បវេណិ កម្រាលដែលធ្វើដោយស្បែកខ្លាឃ្មុំ

១៨- កាទលិមិគបវរបច្ចត្ថរណៈ កម្រាលដ៏ឧត្តមដែលគេធ្វើដោយស្បែកសត្វឈ្មុស

១៩- សឧត្តរច្ឆទៈ ទីដេកដែលមានពណ៌ក្រហមលើ គឺពិតានពណ៌ក្រហមនៅពីខាងលើ

២០- ឧភតោលោហិតកុបធានៈ កម្រាលដែលមានខ្នើយមានពណ៌ ក្រហមទាំងពីរខាង គឺខ្នើយកើយក្បាលក៏ក្រហម ខ្នើយកល់ជើងក៏ក្រហម បានដល់ទីដេកមានខ្នើយក្បាលក្រហម ខ្នើយជើងក្រហមហ្នឹងឯង ។

បណ្តាអាសនៈទាំង ២០ នុ៎ះ អាសនៈ ៣ យ៉ាងគឺ :

**អាសន្ទិ ១ បល្លង្កៈ ១ តូលិកៈ ១** បីនេះ ព្រះពុទ្ធជីកាទ្រង់ហាមផ្តាច់ អង្គុយក៏មិនឱ្យអង្គុយ ដេកក៏មិនឱ្យដេក ជាដាច់

ខាត ។ បើអាសនៈក្រៅពីបីនេះ (គឺអាសនៈ ១៧)ចំពោះបព្វជិត បើជារបស់គ្រហស្ថៗ គេតាក់តែងខ្លួនឯង ក្នុងទីទាំងឡាយ គឺជម្នាសនៈក្តី ទីដែលទាយកអង្គាសក្នុងវត្តក្តី ភោជនសាលាក្តី ផ្ទះគេក្នុងស្រុកក្តី នោះព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតឱ្យអង្គុយបាន តែត្រង់ដេកមិនបានជាដាច់ខាត ។

(គប្បីដឹងថា អាសនៈទាំង ១៧ នុ៎ះ ដែលទ្រង់អនុញ្ញាតឱ្យអង្គុយបានចំពោះតែរបស់គ្រហស្ថ បើជារបស់ខ្លួនវិញក៏ទ្រង់ហាមដែរថា កុំដេក កុំអង្គុយ) ។

ចំពោះគ្រហស្ថខ្លួនឯងវិញ ក្នុងមង្គលត្ថទីបនីត្រង់ឧបោសថកម្មមានសម្តែងថា : ក៏គ្រឿងកម្រាលដែលមិនសមគួរ (គឺអាសនៈ ១៧) ដែលបុគ្គលក្រាលលើគ្រែនិងតាំងរមែងមិនសមគួរ, គ្រឿងកម្រាលផ្សេងទៀតរមែងសមគួរ ។ ដោយហេតុនោះក្នុងអដ្ឋកថាធម្មិកសូត្រ ទើបលោកពោលថា "ក៏ការដេកលើដីសូម្បីក្រាលដោយកម្រាលរោមសត្វជាដើម ក៏សមគួរដែរ" ។

អដ្ឋកថាខុទ្ទកបាឋៈថា "ទីដេកដែលមិនសមគួរ និងកម្រាលដែលមិនសមគួរ ឈ្មោះថា **មហាសយនៈ** " ។

ពូកដែលព្រះសម្មាសម្ពុទ្ធ ទ្រង់អនុញ្ញាតឱ្យប្រើប្រាស់មាន ៥ យ៉ាងគឺ :

១- ឧណ្ណាភិសិ ពូកញាត់ដោយរោមសត្វ

២- ចោឡភិសិ ពូកញាត់ដោយកំណាត់សំពត់

៣- វាកភិសិ ពូកញាត់ដោយសំបកឈើ

៤- តិណភិសិ ពូកញាត់ដោយស្មៅ មានស្មៅជំណោកទន្សាយជាដើម

៥- បត្តភិសិ ពូកញាត់ដោយស្លឹកឈើ ។

គ្រែដែលព្រះសម្ពុទ្ធ ទ្រង់អនុញ្ញាតឱ្យប្រើប្រាស់ដេក-អង្គុយបាននោះមាន ៤ យ៉ាងគឺ :

១- មសារកោ គ្រែដែលគេបញ្ចូលមេទៅក្នុងជំណាប់ជើង

២- ពុន្ទិកាពទ្ធោ គ្រែដែលគេភ្ជាប់មេនឹងជើង

៣- កុឡិរបាទកោ គ្រែដែលមានជើងដូចជាជើងក្តាម

៤- អាហច្ចបាទកោ គ្រែដែលមានជើងចុច ឬគ្រែដែលគេបញ្ចូលជើងទៅក្នុងជំណាប់មេ ។

តាំងដែលព្រះសម្ពុទ្ធ ទ្រង់អនុញ្ញាតឱ្យប្រើប្រាស់ដេកអង្គុយបាននោះមាន ៤ យ៉ាងគឺ :

១- មសារកំ តាំងដែលគេបញ្ចូលមេទៅក្នុងជំណាប់ជើង

២- ពុន្ទិកាពទ្ធំ តាំងដែលមានមេគេបង្ខាំភ្ជាប់នឹងជើង

៣- កុឡិរបាទកំ តាំងដែលមានជើងដូចជាជើងក្តាម

៤- អាហច្ចបាទកំ តាំងដែលមានជើងចុច ឬតាំងដែលគេបញ្ចូលជើងទៅក្នុងជំណាប់មេ ។

សរុបសេចក្តីឱ្យខ្លីមកថា គ្រែ តាំង កៅអីដែលមានពុទ្ធានុញ្ញាតឱ្យប្រើប្រាស់បានទាំងប៉ុន្មាននោះគួរដឹងថា គ្រែ តាំង កៅអីទាំងអម្បាលនោះ សុទ្ធតែមានជើងមានកំពស់ ត្រូវប្រមាណទាំងអស់ទើបប្រើប្រាស់អង្គុយដេកបាន បើគ្រែជាដើមនោះ មានជើងខ្ពស់ហួសប្រមាណ ត្រូវដឹងថាសុទ្ធតែទ្រង់ហាមទាំងអស់ ។

ឯប្រមាណនៃកំពស់ជើងគ្រែ តាំង កៅអីដែលត្រូវប្រមាណខ្នាតនោះ មាននៅក្នុងគម្ពីរមនោរថបូរណី ត្រង់ តិឧបោសថាប្រាប់មកថា "មុដ្ឋិហត្ថបាទកោ កប្បិយមញ្ចោ" ដូច្នេះជាដើមប្រមាណគ្រែជាកប្បិយៈ មានខ្នាតជើងកំពស់ ១ ហត្ថក្តាប់ ។

បើគិតតាមប្រមាណព្រះសុគតខាងដើម លោកតែងប្រមាណក្នុងវិន័យសុទ្ធតែ ៨ ធ្នាប់ព្រះសុគតត្រូវជា ៥ តឹក ឬជា ៥០ សង់ទីម៉ែត្រ ។

ក្នុងមណ្ឌលត្ថទីបនីពោលថា ពិតមែន ជើងគ្រែនិងជើងតាំងមានប្រមាណ ៨ ធ្នាប់ ដោយធ្នាប់នៃព្រះសុគតប៉ុណ្ណោះទើបសមគួរ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ថា "មួយទៀត ភិក្ខុកាលនឹងឱ្យគេធ្វើគ្រែថ្មី ឬតាំងថ្មី គប្បីឱ្យគេធ្វើឱ្យមានជើងបានប្រមាណ ៨ ធ្នាប់ ដោយធ្នាប់នៃព្រះសុគត វៀរលែងតែមេគ្រែខាងក្រោមចេញ កាលបើភិក្ខុធ្វើឱ្យខ្ពស់លើសហួសប្រមាណនោះ ត្រូវអាបត្តិឆេទនកបាចិត្តិយៈមានការកាត់ចេញជាវិន័យកម្ម" ។

ព្រះអដ្ឋកថាពោលទុកហើយក្នុងកង្ខាវិតរណី ត្រង់កុដិការសិក្ខាបទថា "៣ ចំអាមរបស់មជ្ឈិមបុរស ក្នុងពេលឥឡូវនេះឈ្មោះថា ១ ចំអាមរបស់ព្រះសុគត ត្រូវជា ១ ហត្ថ ១ ចំអាមដោយហត្ថនៃជាងឈើ"ដូច្នេះ ព្រោះហេតុនោះ ៣ ធ្នាប់របស់មជ្ឈិមបុរសត្រូវជា ១ ធ្នាប់របស់ព្រះសាស្តា ព្រោះហេតុនោះ ៨ ធ្នាប់នៃព្រះសាស្តា ទើបត្រូវជា ២៤ ធ្នាប់នៃ

មជ្ឈិមបុរស ។ ២៤ ធ្នាប់របស់មជ្ឈិមបុរសត្រូវជា ១ គក់ ។

ព្រោះហេតុនោះ ក្នុងដីកានៃឧបោសថសូត្រ ទើបលោកពោលថា "បទថា **មុដ្ឋិហត្ថបាទកេ** គឺមានជើងប្រមាណមួយគក់ រាប់តាំងអំពីផ្ទៃនៃបាតជើងឡើងទៅ រហូតដល់ទីបំផុតខាងក្រោមនៃមេគ្រែ ។ ក៏មួយគក់ដែលមានឈ្មោះថា ហត្ថរបស់ជាងឈើក្នុងពេលឥឡូវនេះ ស្មើគ្នានឹងហត្ថរបស់មជ្ឈិមបុរស ។ ក៏ព្រោះមួយធ្នាប់កន្លះរបស់បុរសធម្មតា ត្រូវជាមួយធ្នាប់របស់មជ្ឈិមបុរស ។ ចំអាម ហត្ថ លូក និងព្យាម ក៏យ៉ាងដូច្នោះដែរ ព្រោះហេតុនោះ បណ្ឌិតគប្បីយល់ច្បាស់ក្នុងអធិការនេះថា មួយគក់របស់មជ្ឈិមបុរស ត្រូវជាមួយគក់មួយចំអាមរបស់បុរសធម្មតា " ។

ក្នុងមង្គលត្ថទីបនី ត្រង់ឧបោសថកម្ម មានពន្យល់ពីកំណល់ឬទ្រនាប់ជើងគ្រែថា ចំណែកទ្រនាប់គ្រែ ៨ ធ្នាប់ ដោយធ្នាប់នៃមនុស្ស (ធម្មតា) ប៉ុណ្ណោះទើបសមគួរ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ក្នុងសេនាសនក្ខន្ធកៈថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើទ្រនាប់គ្រែខ្ពស់ទេ ភិក្ខុ

ណាប្រើប្រាស់ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតគ្រែទនាប់គ្រែយ៉ាងខ្ពស់ត្រឹម ៨ ធ្នាប់" ។ ចំណែកក្នុង អដ្ឋកថា សេនាសនក្ខន្ធកៈនោះ លោកពោលថា "៨ ធ្នាប់ គឺធ្នាប់ដែលជាប្រមាណរបស់ពួកមនុស្សនោះឯង" ។

អនុជានាមិ ភិក្ខវេ ឧច្ចកម្បិ អាសន្ទិកំ ។ ម្នាលភិក្ខុ ទាំងឡាយ តថាគតអនុញ្ញាតតាំង ៤ ជ្រុងសូម្បីមានជើងខ្ពស់ ។ អដ្ឋកថាថា តាំង ៤ ជ្រុងសូម្បីមានជើងខ្ពស់ហួសប្រមាណក៏គួរ បើតាំងដែលវែង លុះតែធ្វើឱ្យមានជើងកំពស់ត្រឹម ៨ ធ្នាប់ទើបគួរ ។

អនុជានាមិ ភិក្ខវេ ឧច្ចកម្បិ សត្តង្គំ ម្នាលភិក្ខុទាំង ឡាយ តថាគតអនុញ្ញាតគ្រែមានអង្គ ៧ សូម្បីមានជើងខ្ពស់ ក៏បាន ។

គ្រែដែលមានបង្អែក ១ ភ្នាក់ដៃ ២ និងជើង ៤ ទុកជា កន្លងហួសប្រមាណក៏គួរ ។

សត្តង្គោ ណាម តីសុ ទិសាសុ អបស្សយំ កត្វា កតមញ្ចោ អយម្បិ បមាណាតិក្កន្តោបិ វដ្ដតិ គ្រែដែលគេ

ធ្វើក្របាំងបង្អែក ៣ ឈ្មោះថា សត្តង្គៈៗ នេះ សូម្បីលើសប្រមាណក៏គួរ ។

**បមាណាតិក្កន្តោបិ វដ្ដតីតិ សមចតុរស្សមេវ សន្ធាយ វុត្តំ ។ អាយតចតុរស្សា បន សត្តង្គបញ្ចង្គាបិ ឧច្ចាសនា ន វដ្ដតិ ។** ពាក្យថា សូម្បីលើសប្រមាណក៏គួរ លោកពោលសំដៅយកគ្រែរាងការេស្មើ, បើសូម្បីគ្រែអង្គ ៧ , ៥ រាងចតុកោណកែង ជើងខ្ពស់រមែងមិនគួរ ។

អដ្ឋកថាព្រហ្មជាលសូត្រ និងឧបោសថសូត្រថា "ទីដេកដែលខ្ពស់ហួសប្រមាណ ឈ្មោះថា **ឧច្ចាសយនៈ** ។ ទីដេកដែលក្រាលដោយគ្រឿងកម្រាលដែលមិនសមគួរ ឈ្មោះថា **មហាសយនៈ**" ។

ដីកាព្រហ្មជាលសូត្រ និងឧបោសថសូត្រនោះថា "ទីដេកដែលខ្ពស់ និងទីដេកដែលធំ ព្រះមានព្រះភាគទ្រង់ព្រះបំណងយកទីដេកដែលប្រាសចាកសមណៈសារូប ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលថា '**បមាណាតិក្កន្តំ អកប្បិយត្ថតំ**' ដូច្នេះ" ។

ដីកាព្រហ្មជាលសូត្រជាដើមថា "សព្ទថា **ឧច្ចា** ជាសព្ទ ពិសេសមួយ ដែលមានសេចក្តីស្មើនឹង **ឧច្ច** សព្ទ ។ បុគ្គល តែងដេកក្នុងទីនុ៎ះ ហេតុនោះ ទីនុ៎ះ ឈ្មោះថា ទីជាទីដេក គឺអាសន្ទិជាដើម ។ ក៏អាសនៈ លោកសង្គ្រោះហើយ ដោយ **សយន** សព្ទក្នុងបទថា **ឧច្ចាសយនមហាសយនំ** នុ៎ះ ដូច្នេះ" ។

ឧច្ចាសយនមហាសយនសិក្ខាបទនេះ មានអង្គ ៣ គឺ :

១- **ឧច្ចាសយនមហាសយនំ** ទីដេកទីអង្គុយដ៏ខ្ពស់ហួស ប្រមាណ និងទីដេក ទីអង្គុយដ៏ប្រសើរ

២- **បរិភោគចិត្តំ** ចិត្តគិតនឹងដេកឬអង្គុយ

៣- **បរិភោគករណំ** បានដេកឬអង្គុយ ។

**អានាបត្តិ:** ហេតុដែលមិនត្រូវទោសមាន ៨ យ៉ាងគឺ :

១- ដេកឬអង្គុយលើគ្រែ ឬតាំងដែលមានជើងកំពស់ ត្រឹម ៨ ធ្នាប់ព្រះសុគត ឬថយចុះ

២- បានគ្រែឬតាំងដែលអ្នកដទៃធ្វើឱ្យហួសប្រមាណ ហើយ យកមកកាត់ចេញឱ្យត្រូវនឹងប្រមាណក្តី ជីកកប់ទៅក្នុង ផែនដីឱ្យសល់នៅត្រឹមល្មមប្រមាណក្តី ធ្វើឱ្យជាធ្នើរក្តី

ធ្វើជាភនក្តី ហើយទើបប្រើប្រាស់( អង្គុយ-ដេក )

៣- ដេកឬអង្គុយលើគ្រែមានអង្គ ៧ សូម្បីមានជើងខ្ពស់ហួសប្រមាណ

៤- ដេកអង្គុយលើតាំង ៤ ជ្រុងស្មើ សូម្បីមានជើងខ្ពស់ហួសប្រមាណ

៥- បានគ្រែ តាំង ពូកដែលញាត់ដោយសំឡីគ ហើយយកមកកាយចេញ ទើបប្រើប្រាស់ អង្គុយ ដេក

៦- ដេកឬអង្គុយលើពូក ៥ យ៉ាង

៧- មិនដេក គ្រាន់តែអង្គុយលើអាសនៈ ១៧ យ៉ាងដែលជាគិហិវិកដ (គ្រហស្ថធ្វើដោយវត្ថុរបស់គេ )

៨- ឆ្អួត ។

"ចប់ ឧច្ចាសយនមហាសយនសិក្ខាបទទី ៩ "

រួមសិក្ខាបទទី ៧-៨ ចូលគ្នាជាសិក្ខាបទមួយ ហើយទាញបន្ថយឧច្ចាសយនមហាសយនសិក្ខាបទមកនៅត្រឹមទី ៨ វិញ ទៅជាសីលសង្កាត់ទី ២ មានសិក្ខាបទ ៨ ។

( គហដ្ឋសីល សង្កាត់ទី ២ មានសិក្ខាបទ ៨ ចប់ប៉ុណ្ណឹង )

## ១០. ជាតរូបរជតប្បដិគ្គហណសិក្ខាបទ

ជាតរូប... កិរិយាទទួលកាន់យកនូវមាសនិងប្រាក់ដោយខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យទទួលទុកដាក់ដើម្បីខ្លួនក្តី ត្រេកអរចំពោះមាស និងប្រាក់ជាអកប្បិយៈ ដែលគេទុកដាក់ឱ្យខ្លួនក្តី ឈ្មោះថា ដាច់នូវជាតរូបរជតសិក្ខាបទ ។

លោហៈវិសេសមានពណ៌លឿង ដូចជាពណ៌នៃព្រះសាស្តាហៅថា **មាស** ។

កហាបណៈដែលធ្វើដោយមាស ឬប្រាក់និងកហាបណៈប្រក្រតីក្តី មាសកៈដែលធ្វើដោយជាតិលោហៈទាំងឡាយ មានទង់ដែង ឬស្ពាន់ជាដើមក្តី មាសកៈដែលគេឆ្លាក់រូបធ្វើដោយឈើខ្លឹម ឬចម្រៀកឫស្សី ដោយហោចទៅសូម្បីតែធ្វើដោយស្លឹកត្នោតក្តី មាសកៈដែលគេសូនរូប ដោយកាកល័ក្តឬជ័រឈើក្តី រមែងដល់នូវវោហារ ( ល្មមចាយវាយបាន ) មាននៅក្នុងជនបទនោះៗ ហៅថា **ប្រាក់** ក្នុងទីនេះ ។

ឯការទទួលក្នុងសិក្ខាបទនេះ ៣ យ៉ាងគឺ :

១- **កាយេន បដិគ្គហណំ** ទទួលដោយកាយ គឺទទួលអំពី

ដៃអ្នកដទៃ ឬកាន់យកដោយខ្លួនឯង នូវមាស និងប្រាក់ដែលគេឱ្យដល់ខ្លួន ឬរើសយកដោយខ្លួនឯង នូវមាស និងប្រាក់ដែលគ្មានម្ចាស់ក្នុងទីណាមួយ ។

២- **វាចាយ បដិគ្គហាណំ** ទទួលដោយវាចាគឺប្រើអ្នកដទៃឱ្យទទួល ឱ្យរើសនូវមាស និងប្រាក់នោះមកដើម្បីប្រយោជន៍ដល់ខ្លួន

៣- **មនសា បដិគ្គហាណំ** ទទួលដោយចិត្ត គឺត្រេកអរចំពោះមាស និងប្រាក់ដែលគេទុកដាក់ឱ្យខ្លួន ។

ការទទួលទាំង ៣ យ៉ាងនេះ មិនគួរដល់អ្នកសមាទាននូវសិក្ខាបទនេះឡើយ បើសមាទាននូវសិក្ខាបទនេះហើយទទួល ក៏ដាច់ជាតរូបរជតសិក្ខាបទ ។

ឯពាក្យថា ត្រេកអរក្នុងសិក្ខាបទនេះ លោកសំដៅយកត្រង់ការមិនឃាត់ដោយទ្វារទាំង ៣ ទ្វារណាមួយ ដូចជាគេនាំយកមាសនិងប្រាក់មកតម្កល់ទុក ក្នុងទីចំពោះមុខអ្នកសមាទាននូវសិក្ខាបទនេះ ហើយពោលថា មាសនិងប្រាក់នេះចូរជារបស់លោកចុះដូច្នេះក្តី គេតម្កល់ទុកនូវមាសនិងប្រាក់ក្នុងទីកំបាំងមុខ

ហើយមកកាន់សំណាក់អ្នកសមាទាននូវសិក្ខាបទនេះ រួចហើយ ពោលយ៉ាងនេះថា មាសនិងប្រាក់របស់ខ្ញុំមាននៅក្នុងទីឯណោះ ខ្ញុំឱ្យនូវមាសនិងប្រាក់នោះដល់អ្នកដូច្នេះក្តី កាលបើគេពោលប្រាប់យ៉ាងនេះហើយ ខ្លួនជាអ្នកសមាទាននូវសិក្ខាបទនេះ មិនហាមឃាត់គេដោយកាយនិងវាចា ហើយទទួលដោយចិត្តឈ្មោះថា "ត្រេកអរ" ។ ប្រសិនបើត្រេកអរដោយចិត្ត ជាអ្នកមានប្រាថ្នានឹងទទួល តែបានហាមឃាត់ដោយកាយឬវាចាថា មាសនិងប្រាក់នេះមិនគួរទេ ដូច្នេះ មិនដាច់ជាតរូបរជតសិក្ខាបទនេះទេ ព្រោះបានហាមឃាត់រួចស្រេចហើយ ។

មួយទៀត ទុកជាអ្នកសមាទាននូវសិក្ខាបទនេះ មិនបានហាមឃាត់ដោយកាយនិងវាចាទេ តែថាជាអ្នកមានចិត្តស្អាតបរិសុទ្ធ មិនត្រេកអរដោយគិតក្នុងចិត្តថា មាសនិងប្រាក់នេះមិនគួរដល់យើងទេ ដូច្នេះក៏មិនដាច់សិក្ខាបទហ្នឹងដែរ ព្រោះការហាមឃាត់ដោយទ្វារទាំង ៣ ទ្វារណាមួយ ឈ្មោះថា បានហាមឃាត់ពិត ។ បើអ្នកសមាទាននូវសិក្ខាបទនេះ មិនបានហាមឃាត់ដោយកាយនិងវាចា ហើយទទួលដោយចិត្ត ដាច់សិក្ខាបទ

ដោយកាយទ្វារផង វចីទ្វារផង ដែលជាអកិរិយាសមុដ្ឋាន ត្រូវទោសព្រោះមិនធ្វើការហាមឃាត់ ដែលខ្លួនគប្បីធ្វើដោយកាយនិងវាចា ឯឈ្មោះថា ត្រូវទោសតាមមនោទ្វារនោះមិនមានទេ ។

ម្យ៉ាងទៀត ប្រសិនបើមានអ្នកណាម្នាក់ គេតម្កល់ទុកនូវប្រាក់ចំនួន ១០០ រៀល ឬ ១០០០ រៀល ជិតជើងខ្លួន ហើយគេពោលប្រាប់ថា ប្រាក់នេះចូរជារបស់អ្នកចុះ អ្នកសមាទាននូវសិក្ខាបទនេះ បានហាមឃាត់ថា ប្រាក់នេះមិនគួរទេ គេពោលទៀតថា ប្រាក់នេះខ្ញុំលះបង់ឱ្យដល់អ្នកហើយដូច្នេះ រួចចៀសចេញទៅ ។ ទើបឧបាសកម្នាក់ទៀត ចូលមកក្នុងទីនោះ ឃើញហើយសួរថា អ្វីនេះអ្នក ? អ្នកសមាទាននូវសិក្ខាបទនេះ គប្បីប្រាប់នូវពាក្យរបស់អ្នកនិយាយមុននោះ និងពាក្យដែលខ្លួនបាននិយាយនោះ ឱ្យគេស្តាប់ បើឧបាសកដែលចូលមកខាងក្រោយនោះនិយាយថា អ្នក(ឬលោកម្ចាស់) ខ្ញុំនឹងគ្រប់គ្រងនូវប្រាក់នោះ សូមអ្នក(ឬលោកម្ចាស់) ចង្អុលបង្ហាញកន្លែងសម្រាប់គ្រប់គ្រងចុះ ។

បើខ្លួនមានអ្នកទទួលធ្វើកប្បិយការកៈ ឬវេយ្យាវច្ចករគេ

បានកំណត់ទីកន្លែងសម្រាប់ទុកដាក់ សម្រាប់គ្រប់គ្រងហើយ ក៏គប្បីដើរទៅ កាន់ទីនោះហើយ ប្រាប់គេថា នេះកន្លែងសម្រាប់គេទុកដាក់ តែកុំនិយាយថា អ្នកចូរដាក់កន្លែងនេះចុះដូច្នេះឡើយ បើគេដាក់ហើយ គប្បីបិទទ្វារនៅរក្សាចុះ ។ ឯការប្រាប់កន្លែងសម្រាប់ទុកដាក់នោះ សូម្បីនៅជាន់លើៗ ដល់ទៅ ៧ ជាន់ ក៏ដើរឡើងទៅប្រាប់គេបានដែរ ។

ប្រសិនបើមានអ្នកលក់ អ្នកជំនួញណាមួយ នាំយកភណ្ឌៈពពាយនាយថា អ្នកត្រូវការរបស់នោះដែរឬ ? បើត្រូវការគប្បីនិយាយតបថា អើអ្នក ! ខ្ញុំត្រូវការរបស់នេះដែរ ឯវត្ថុមានសភាពបែបនេះ ក៏មានព្រម តែគ្មានកប្បិយការកៈ បើអ្នកជំនួញនោះនិយាយថា ខ្ញុំនឹងធ្វើជាកប្បិយការកៈឱ្យ សូមអ្នកបើកទ្វារឱ្យចុះ ។ គប្បីបើកទ្វារហើយប្រាប់ថា រូបិយៈ តាំងនៅត្រង់ឱកាសនេះ តែកុំនិយាយថា អ្នកចូរកាន់យករូបិយៈនោះ ហើយគេឱ្យកប្បិយភណ្ឌដល់ខ្លួនយ៉ាងនេះគួរ ។ បើអ្នកជំនួញគេយកប្រាក់លើស តម្លៃភណ្ឌៈ ខ្លួនគប្បីនិយាយប្រាប់ថា យើងមិនយកភណ្ឌៈរបស់អ្នកឯងទេ អ្នកចូរទុកវិញចុះ ។

ន័យមួយទៀត បើជនទាំងឡាយគេត្រូវការដោយបុណ្យ គេដាក់នូវមាសនិងប្រាក់ក្នុងវត្ថុទាំងឡាយ មានបាយនិងបង្អែមជាដើម ហើយគេជូនខ្លួនជាអ្នកសមាទាននូវសិក្ខាបទនេះក្ដី គេឱ្យសំពត់ជាមួយនិងកហាបណៈជាដើម ដែលគេវេចនឹងជាយសំពត់ដល់ខ្លួនជាអ្នកសមាទាននូវសិក្ខាបទនេះក្ដី ឬកាលដើរទៅសុំសំពត់ គេដាក់ប្រាក់វេចនឹងសំពត់ឱ្យមកក្ដី ខ្លួនក៏បានសម្គាល់ថាជាសំពត់ក្ដី ក៏គង់ដាច់សិក្ខាបទជាតរូបរជតៈដែរ ព្រោះសិក្ខាបទនេះជាអចិត្តកៈ ទោះមានចិត្តក្លែងក្ដី មិនក្លែងក្ដី ដឹងឬមិនដឹងក្ដី មិនយកជាប្រមាណក្នុងសិក្ខាបទនេះទេ ឱ្យតែទទួលនូវមាសនិងប្រាក់ហើយ ក៏ចេះតែដាច់សិក្ខាបទជាតរូបរជតៈហ្នឹងទាំងអស់ ។

ជាតរូបរជត...សិក្ខាបទនេះ មានអង្គ ៣ គឺ :

១- ជាតរូបរជតំ មាសនិងប្រាក់ដែលជាអកប្បិយភណ្ឌ

២- អត្តុទ្ទិសតា ចំពោះជារបស់ខ្លួន

៣- បដិគ្គណ្ហាតិ បានទទួលកាន់យកដោយខ្លួនឯង ឬប្រើគេឱ្យទទួលកាន់យកទុកដាក់ឱ្យ ឬត្រេកអរចំពោះមាស និង

ប្រាក់ដែលគេទុកដាក់នោះ ។

**អនាបត្តិ:** ហេតុដែលមិនត្រូវទោសមាន ២ យ៉ាងគឺ :

១- បានរើសយកខ្លួនឯង ឬប្រើគេឱ្យរើសយកនូវរូបិយៈ ដែលធ្លាក់ចុះក្នុងទីលំនៅរបស់ខ្លួនដោយគិតថា រូបិយៈរបស់អ្នកណា អ្នកនោះនឹងនាំយកទៅចុះ (គឺរើសទុកឱ្យគេ)

២- ឆ្កួត ។

(ចប់ គហដ្ឋសីល សង្កាត់ទី ៣ មាន ១០ សិក្ខាបទតែប៉ុណ្ណោះ)

## វិធីបវារណាបច្ច័យ ៤

ទាយកជាម្ចាស់ទាន កាលប្រាថ្នាទុកដាក់ប្រាក់ ឬលុយសម្រាប់បវារណាចំពោះភិក្ខុរូបណាមួយ គប្បីចូលទៅរកភិក្ខុនោះ ហើយសួរថា អ្នកណាជាកប្បិយការករបស់លោកម្ចាស់ កាលភិក្ខុប្រាប់កប្បិយការកៈ ហើយគប្បីពោលបវារណាដោយពាក្យថា

ឥទំ ហិរញ្ញំ កប្បិយការកានំ ហត្ថេ ភវិស្សតិ

ភោវលំ តុម្ហេ បច្ចយេ បរិភុញ្ជថ ។

(បពិត្រលោកម្ចាស់ដ៏ចម្រើន) ប្រាក់(ចំនួន.......) នេះ នឹងនៅក្នុងដៃរបស់ពួកកប្បិយការកៈ សូមលោកម្ចាស់ប្រើប្រាស់នូវបច្ច័យទាំងឡាយតែម្យ៉ាងប៉ុណ្ណោះ ។

(បើបានទុកដាក់ប្រាក់ដល់ដៃពួកកប្បិយការកៈ រួចហើយទើបបវារណា គប្បីប្តូរត្រង់ពាក្យថា "នឹងនៅក្នុងដៃរបស់ពួកកប្បិយការកៈ"មកថា "**មាននៅក្នុងដៃរបស់ពួកកប្បិយការកៈ**" ដូច្នេះវិញ) ។

ម្យ៉ាងទៀត ប្រាក់តម្រូវបវារណានោះ បើខ្លួនឯងអ្នកទុកដាក់ ទោះទាយកជាម្ចាស់ទានក្តី ឬជាកប្បិយការកៈក្តី គប្បីបវារណាថា ៖

**ឥទំ ហិរញ្ញំ មយ្ហំ ហត្ថេ ភវិស្សតិ**
**កោវលំ តុម្ហេ បច្ចយេ បរិភុញ្ជថ ។**

(បពិត្រលោកម្ចាស់ដ៏ចម្រើន) ប្រាក់(ចំនួន........) នេះ មាននៅក្នុងដៃរបស់ខ្ញុំព្រះករុណា សូមលោកម្ចាស់ប្រើប្រាស់នូវបច្ច័យទាំងឡាយតែម្យ៉ាងប៉ុណ្ណោះ ។

" ចប់ ជាតរូបរជតប្បដិគ្គហណសិក្ខាបទទី ១០ "

## សីលវគ្គគាថា

១- សីលមេវិធ សិក្ខេថ អស្មិំ លោកេ សុសិក្ខិតំ
សីលំ ហិ សព្វសម្បត្តិំ ឧបនាមេតិ សេវិតំ ។

*បុគ្គលគប្បីសិក្សានូវសីល ឱ្យជាសីលដែលខ្លួនសិក្សាល្អ ហើយ ក្នុងលោកនេះ ព្រោះថា សីលដែលបុគ្គលសេព ហើយ រមែងបង្អោនមកនូវសម្បត្តិទាំងពួង ។*

២- សីលំ រក្ខេយ្យ មេធាវី បត្ថយានោ តយោ សុខេ
បសំសំ វិត្តិលាភញ្ច បេច្ច សគ្គេ បមោទនំ ។

*ជនអ្នកមានប្រាជ្ញា កាលចង់បាននូវសេចក្តីសុខ ៣ យ៉ាង គឺសេចក្តីសរសើរ ១ ការបាននូវសេចក្តីត្រេកអរ ១ ការ លះលោកនេះទៅហើយ រីករាយក្នុងឋានសួគ៌ ១ គប្បី រក្សានូវសីល ។*

៣- សីលវា ហិ ពហូ មិត្តេ សញ្ញមេនាធិគច្ឆតិ
ទុស្សីលោ បន មិត្តេហិ ធំសតេ បាបមាចរំ ។

*ពិតណាស់ បុគ្គលអ្នកមានសីល រមែងបាននូវមិត្តទាំង ឡាយ ច្រើនដោយការសង្រួម ចំណែកបុគ្គលទ្រុស្តសីល*

កាលប្រព្រឹត្តអាក្រក់រមែងឃ្លាតចាកមិត្តទាំងឡាយ ។

៤- អវណ្ណញ្ច អកិត្តិញ្ច ទុស្សីលោ លភតេ នរោ
វណ្ណំ កិត្តឹ បសំសញ្ច សទា លភតិ សីលវា ។

ជនទ្រុស្តសីលរមែងបាននូវទោសផង បាននូវជំណោះជំនៀលផង ឯជនអ្នកមានសីល រមែងបាននូវគុណផង បាននូវកិត្តិស័ព្ទផង បាននូវសេចក្តីសរសើរផង សព្វៗកាល ។

៥- អាទិ សីលំ បតិដ្ឋា ច កល្យាណានញ្ច មាតុកំ
បមុខំ សព្វធម្មានំ តស្មា សីលំ វិសោធយេ ។

សីលជាខាងដើម សីលជាទីតាំង សីលជាមេនៃកល្យាណធម៌ សីលជាប្រធាននៃធម៌ទាំងពួង ព្រោះហេតុនោះបុគ្គលគប្បីជម្រះសីលឱ្យស្អាត ។

៦- វេលា ច សំវរំ សីលំ ចិត្តស្ស អភិហាសនំ
តិត្ថញ្ច សព្វពុទ្ធានំ តស្មា សីលំ វិសោធយេ ។

សីលជាប្រាំង ជាទំនប់ ជាគ្រឿងញ៉ាំងចិត្តឱ្យរីករាយ ទាំងជាកំពង់របស់ព្រះពុទ្ធគ្រប់ព្រះអង្គ ព្រោះហេតុនោះ បុគ្គល

គប្បីជម្រះនូវសីល ។

៧- សីលំ ពលំ អប្បដិមំ សីលំ អាវុធមុត្តមំ
សីលំ អាភរណំ សេដ្ឋំ សីលំ កវចមព្ភុតំ ។

សីលជាកម្លាំងរកអ្វីប្រៀបផ្ទឹមមិនបាន សីលជាអាវុធដ៏ឧត្តម សីលជាគ្រឿងអាភរណៈដ៏ប្រសើរ សីលជាគ្រឿងក្រោះដ៏អស្ចារ្យ ។

៨- សីលំ សេតុ មហេសក្ខោ សីលំ គន្ធោ អនុត្តរោ
សីលំ វិលេបនំ សេដ្ឋំ យេន វាតិ ទិសោ ទិសំ ។

សីលជាស្ពានមានសក្តិធំ សីលជាគ្រឿងក្រអូបដ៏ប្រសើរ សីលជាគ្រឿងលាបដ៏ប្រសើរ តែងបក់ក្លិនទៅសព្វៗទិស ។

៩- សីលំ សម្ពលមេវគ្គំ សីលំ បាថេយ្យមុត្តមំ
សីលំ សេដ្ឋោ អតិវាហោ យេន វាតិ ទិសោ ទិសំ ។

សីលជាកញ្ចប់បាយដ៏ប្រសើរ សីលជាស្បៀងដ៏ឧត្តម សីលជាវាហនៈដ៏ប្រសើរ សម្រាប់ទៅកាន់ទិសទាំងពួង ។

១០- ឥធេវ និន្ទំ លភតិ បេច្ចាបាយេ ច ទុម្មនោ

សព្វត្ថ ទុម្មនោ ពាលោ សីលេសុ អសមាហិតោ ។

*បុគ្គលពាល មានចិត្តអាក្រក់ក្នុងទីទាំងពួង មិនតាំងមាំក្នុងសីលទាំងឡាយ រមែងបាននូវសេចក្ដីនិន្ទាក្នុងលោកនេះផង លុះលះលោកនេះទៅហើយ រមែងមានចិត្តជាទុក្ខក្នុងអបាយផង ។*

១១. ឥធេវ កិត្តឹ លភតិ បេច្ច សគ្គេ ច សុមនោ

សព្វត្ថ សុមនោ ធីរោ សីលេសុ សុសមាហិតោ ។

*អ្នកប្រាជ្ញមានចិត្តល្អក្នុងទីទាំងពួង តាំងនៅមាំក្នុងសីលទាំងឡាយ រមែងបាននូវកិត្តិស័ព្ទក្នុងលោកនេះផង លុះលះលោកនេះទៅ រមែងមានចិត្តរីករាយក្នុងឋានសួគ៌ផង ។*

១២. សីលមេវ ឥធ អគ្គំ បញ្ញវា បន ឧត្តមោ

មនុស្សេសុ ច ទេវេសុ សីលបញ្ញាណតោ ជយំ ។

*សីលជាកំពូលក្នុងលោកនេះ ចំណែកបុគ្គលមានប្រាជ្ញាក៏ឧត្តមដែរ មានជ័យជម្នះក្នុងមនុស្សលោក និងទេវលោកព្រោះតែសីលនិងបញ្ញាហ្នឹងឯង ។*

*( បិដក. ៥៧ ទំ. ២៨ )( ក្នុងថេរគាថា ទ្វាទសកនិបាត )*

# ពណ៌នាអំពីការប្រព្រឹត្តធម៌

(បិដកលេខ ២២ ទំព័រ ២៤១)

ព្រះមានព្រះភាគត្រាស់ភាសិតនេះថា ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តមិនស្មើ ពោលគឺមិនប្រព្រឹត្តតាមធម៌ ដោយកាយមាន ៣ ប្រការ កិរិយាប្រព្រឹត្តមិនស្មើ ពោលគឺមិនប្រព្រឹត្តតាមធម៌ ដោយវាចាមាន ៤ ប្រការ កិរិយាប្រព្រឹត្តមិនស្មើ ពោលគឺមិនប្រព្រឹត្តតាមធម៌ ដោយចិត្តមាន ៣ ប្រការ ។

ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តមិនស្មើ ពោលគឺមិនប្រព្រឹត្តតាមធម៌ ដោយកាយមាន ៣ ប្រការ តើដូចម្ដេចខ្លះ ។ ម្នាលគហបតីទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះជាអ្នកសម្លាប់សត្វ ជាមនុស្សអាក្រក់ មានបាតដៃប្រឡាក់ដោយឈាម មានចិត្តបោះជាប់ក្នុងការសម្លាប់សត្វ ជាអ្នកមិនមានសេចក្ដីអៀនខ្មាស មានចិត្តមិនអាសូរចំពោះពួកសត្វទាំងអស់ ។

មួយទៀត ជាអ្នកកាន់យកនូវវត្ថុដែលគេមិនបានឱ្យ ដូចជាគ្រឿងឧបករណ៍ គឺសម្បត្តិនៃបុគ្គលដទៃណា ដែលគេទុកក្នុងស្រុកក្ដី ទុកក្នុងព្រៃក្ដី ជាអ្នកកាន់យកគ្រឿងឧបករណ៍ដែលគេមិនបានឱ្យនោះ ដោយចំណែកនៃចិត្តលួច ។

មួយទៀត ជាអ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ដូចជាស្ត្រីទាំងឡាយណា គឺស្ត្រីដែលមាតារក្សា ដែលបិតារក្សា ដែលមាតាបិតារក្សា ដែលបងប្អូនប្រុសរក្សា ដែលបងប្អូនស្រីរក្សា ដែលញាតិរក្សា ដែលមានស្វាមី ដែលប្រកបដោយអាជ្ញា ដោយហោចទៅ សូម្បីតែស្ត្រីដែលបុរសបំពាក់កម្រងផ្កា ឱ្យជាអ្នកដល់នូវការប្រព្រឹត្តកន្លងក្នុងស្ត្រីទាំងឡាយ មានសភាពដូច្នោះ ។ ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តមិនស្មើ ពោលគឺមិនប្រព្រឹត្តតាមធម៌ ដោយកាយមាន ៣ ប្រការយ៉ាងនេះឯង ។

ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តមិនស្មើ ពោលគឺមិនប្រព្រឹត្តតាមធម៌ដោយវាចាមាន ៤ ប្រការ តើដូចម្តេចខ្លះ ។

ម្នាលគហបតីទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាអ្នកពោលពាក្យកុហក ទោះបីឋិតនៅក្នុងរោងក្តី ឋិតនៅក្នុងបរិស័ទក្តី ឋិតនៅក្នុងកណ្តាលញាតិក្តី ឋិតនៅក្នុងកណ្តាលសេនីយ៍ក្តី ឋិតនៅកណ្តាលរាជត្រកូលក្តី គេនាំទៅធ្វើជាសាក្សី ហើយសួរថា នែបុរសដ៏ចម្រើន ចូរអ្នកមកនេះ បើអ្នកដឹងហេតុណា ចូរនិយាយហេតុនោះ ។ បុរសនោះ កាលមិនដឹង និយាយថា ខ្ញុំដឹង ឬកាលដឹង និយាយថា ខ្ញុំមិនដឹង កាលមិនឃើញ និយាយថា

ខ្ញុំឃើញ ឬកាលឃើញ និយាយថា ខ្ញុំមិនឃើញ ។ ជាអ្នកពោលពាក្យកុហកទាំងដឹងខ្លួន ព្រោះហេតុតែខ្លួនក្តី ព្រោះហេតុអ្នកដទៃក្តី ព្រោះហេតុសំណូក គឺអាមិសបន្តិចបន្តួចក្តី ។

មួយទៀត ជាអ្នកពោលនូវពាក្យញុះញង់ គឺឮពាក្យអំពីសំណាក់ជននេះហើយនាំទៅប្រាប់ជនឯណោះ ដើម្បីនឹងបំបែកជនទាំងនេះ ឮពាក្យអំពីជនឯណោះ ហើយនាំយកមកប្រាប់ជននេះ ដើម្បីបំបែកជនឯណោះ ជាអ្នកបំបែកនូវពួកជនដែលព្រមព្រៀងគ្នាផង ជាអ្នកជម្រុលពួកជន ដែលបែកគ្នាហើយផង ជាអ្នកត្រេកអរតែក្នុងពួក មានតម្រេកក្នុងពួក ជាអ្នករីករាយតែក្នុងពួក ជាអ្នកពោលនូវវាចាដែលធ្វើឱ្យប្រកាន់ពួកដូច្នេះឯង ។

មួយទៀត ជាអ្នកពោលពាក្យអាក្រក់ គឺវាចាណាទ្រគោះខ្នោះខ្នួរ ពេលពាល ស្ទាក់ដំណើរជនដទៃ ជាវាចាជិតនឹងសេចក្តីក្រោធ មិនប្រព្រឹត្តទៅដើម្បីសមាធិបាន ហើយជាអ្នកពោលនូវវាចាមានសភាពដូច្នោះ ។

មួយវិញទៀត ជាអ្នកពោលនូវពាក្យមិនមានប្រយោជន៍ពោលពាក្យខុសកាល ពោលនូវពាក្យមិនពិត ពោលពាក្យមិនមែនជាអត្ថ ពោលពាក្យមិនមែនជាធម៌ ពោលពាក្យមិនមែនជាវិន័យ

ពោលពាក្យដែលមិនគួរ តាំងទុកក្នុងហឫទ័យខុសកាល ប្រាសចាកគ្រឿងអាង ជាពាក្យមិនមានទីបំផុត មិនប្រកបដោយប្រយោជន៍ ។ ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តមិនស្មើ ពោលគឺមិនប្រព្រឹត្តតាមធម៌ ដោយវាចាមាន ៤ ប្រការដូច្នោះឯង ។

ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តមិនស្មើ ពោលគឺមិនប្រព្រឹត្តតាមធម៌ ដោយចិត្តមាន ៣ ប្រការ តើដូចម្តេចខ្លះ ។

ម្នាលគហបតីទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះច្រើនដោយអភិជ្ឈា គយគន់នូវគ្រឿងឧបករណ៍ដែលជាសម្បត្តិនៃបុគ្គលដទៃដោយគិតថា ឱហ្ន៎ គ្រឿងឧបករណ៍ដែលជាសម្បត្តិនៃបុគ្គលដទៃណា គ្រឿងឧបករណ៍នោះ គប្បីបានមកអាត្មាអញ ។

មួយទៀត ជាអ្នកមានចិត្តព្យាបាទ មានតម្រិះក្នុងចិត្តដែលទោសប្រទូស្តហើយថា សត្វទាំងឡាយចូរលំបាកខ្លះចូរស្លាប់ខ្លះ ចូរវិនាសសាបសូន្យទៅខ្លះ ដែលថាមិនវិនាសកុំឱ្យមានឡើយ ។

មួយវិញទៀត ជាអ្នកមានគំនិតយល់ខុស ឃើញនូវសេចក្តីវិបរិតថា ទានដែលបុគ្គលឱ្យហើយមិនមានផល ការបូជាធំមិនមានផល ការបូជាតូចក៏មិនមានផល ផលវិបាកនៃ

កុសលាកុសលកម្ម ដែលសត្វធ្វើល្អ និងអាក្រក់មិនមាន លោកនេះមិនមាន លោកខាងមុខមិនមាន មាតាមិនមានគុណ បិតាមិនមានគុណ សត្វទាំងឡាយជាឱបបាតិកៈមិនមាន ពួកសមណព្រាហ្មណ៍ក្នុងលោកជាអ្នកព្រមព្រៀងគ្នា ប្រតិបត្តិដោយត្រឹមត្រូវ ធ្វើឱ្យជាក់ច្បាស់ដោយខ្លួនឯង នូវលោកនេះនិងលោកខាងមុខហើយសម្តែង ក៏មិនមាន ។ ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តមិនស្មើ ពោលគឺ មិនប្រព្រឹត្តតាមធម៌ដោយចិត្តមាន ៣ ប្រការ យ៉ាងនេះឯង ។

ម្នាលគហបតីទាំងឡាយ សត្វទាំងឡាយពួកខ្លះក្នុងលោកនេះ លុះបែកធ្លាយរាងកាយ ខាងមុខបន្ទាប់អំពីមរណៈ ចូលទៅកាន់អបាយទុគ្គតិវិនិបាត នរកយ៉ាងនេះ ព្រោះហេតុតែកិរិយាប្រព្រឹត្តមិនស្មើ ពោលគឺមិនប្រព្រឹត្តតាមធម៌ យ៉ាងនេះឯង ។

ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ដោយកាយមាន ៣ ប្រការ ។ កិរិយាប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ ដោយវាចាមាន ៤ ប្រការ ។ កិរិយាប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ ដោយចិត្តមាន ៣ប្រការ ។

ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តស្មើ ពោលគឺ

ប្រព្រឹត្តតាមធម៌ដោយកាយមាន ៣ ប្រការ តើដូចម្តេច ?

ម្នាលគហបតីទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ លះបង់បាណាតិបាត វៀរស្រឡះចាកបាណាតិបាត ជាអ្នកដាក់ចុះនូវអាជ្ញា ដាក់ចុះនូវសស្ត្រាវុធ ប្រកបដោយសេចក្តីខ្មាស ដល់នូវមេត្តាចិត្ត ជាអ្នកអនុគ្រោះដោយប្រយោជន៍ ចំពោះសត្វទាំងអស់ ។

ជាអ្នកលះបង់នូវអទិន្នាទាន វៀរស្រឡះចាកអទិន្នាទាន ដូចជាគ្រឿងឧបករណ៍គឺសម្បត្តិនៃបុគ្គលណា ដែលគេទុកក្នុងស្រុកក្តី ទុកក្នុងព្រៃក្តី ក៏ជាអ្នកមិនកាន់យកនូវវត្ថុដែលគេមិនបានឱ្យនោះ ដោយចំណែកនៃចិត្តលួចឡើយ ។

ជាអ្នកលះបង់នូវកាមេសុមិច្ឆាចារ វៀរស្រឡះចាកកាមេសុមិច្ឆាចារៈ ទោះបីស្ត្រីណា ដែលមាតារក្សា បិតារក្សា មាតាបិតារក្សា បងប្អូនប្រុសរក្សា បងប្អូនស្រីរក្សា ញាតិរក្សា មានស្វាមីប្រកបដោយអាជ្ញា ដោយហោចទៅសូម្បីស្ត្រី ដែលបុរសបំពាក់កម្រងផ្កាឱ្យ ក៏ជាអ្នកមិនដល់នូវការប្រព្រឹត្តកន្លងក្នុងស្ត្រីទាំងឡាយមានសភាពដូច្នោះឡើយ ។ ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ដោយកាយមាន ៣ ប្រការ

ដូច្នោះឯង ។

ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ដោយវាចាមាន ៤ ប្រការ តើដូចម្តេចខ្លះ ។

ម្នាលគហបតីទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ លះបង់នូវមុសាវាទ វៀរស្រឡះចាកមុសាវាទ ទោះបីឋិតនៅក្នុងរោងក្តី ឋិតនៅក្នុងកណ្តាលបរិស័ទក្តី ឋិតនៅកណ្តាលញាតិក្តី ឋិតនៅកណ្តាលសេនីយ៍ក្តី ឋិតនៅកណ្តាលរាជត្រកូលក្តី គេនាំទៅធ្វើជាសាក្សីហើយសួរថា នែបុរសដ៏ចម្រើន ចូរអ្នកមកនេះ បើអ្នកដឹងហេតុណា ចូរនិយាយប្រាប់ហេតុនោះ ដូច្នេះក្តី ។ បុរសនោះ កាលមិនដឹង និយាយថា ខ្ញុំមិនដឹង ឬកាលដឹងក៏និយាយថា ខ្ញុំដឹង កាលមិនឃើញនិយាយថា ខ្ញុំមិនឃើញ ឬកាលឃើញក៏និយាយថា ខ្ញុំឃើញ ។ ជាអ្នកមិនពោលនូវពាក្យកុហកទាំងដឹងខ្លួនដូច្នេះ ព្រោះហេតុខ្លួនក្តី ព្រោះហេតុអ្នកដទៃក្តី ព្រោះហេតុតែសំណូក គឺអាមិសៈបន្តិចបន្តួចក្តី ។

មួយវិញទៀត ជាអ្នកលះបង់នូវបិសុណវាចា វៀរស្រឡះចាកបិសុណវាចា គឺឮពាក្យអំពីជននេះ ហើយមិននាំទៅប្រាប់ជនឯណោះ ដើម្បីនឹងបំបែកជនទាំងនេះផង ឮពាក្យអំពីជនឯណោះ

ហើយ មិននាំមកប្រាប់ជនទាំងនេះ ដើម្បីនឹងបំបែកជនឯណោះផង ជាអ្នកផ្សះផ្សានូវពួកជនដែលបែកគ្នាផង ជាអ្នកទំនុកបម្រុងនូវពួកជន ដែលព្រមព្រៀងគ្នាស្រាប់ហើយផង ជាអ្នកត្រេកអរតែក្នុងសេចក្ដីព្រមព្រៀងគ្នា ជាអ្នកមានតម្រេក តែក្នុងសេចក្ដីព្រមព្រៀងគ្នា ជាអ្នករីករាយ តែនៅក្នុងសេចក្ដីព្រមព្រៀងគ្នា ពោលនូវវាចាដែលធ្វើឱ្យកើតសេចក្ដីព្រមព្រៀង ដោយប្រការដូច្នេះ ។

ជាអ្នកលះបង់នូវផរុសវាចា វៀរស្រឡះចាកផរុសវាចា គឺវាចាណាមិនមានទោស ជាសុខដល់ត្រចៀក គួរឱ្យកើតសេចក្ដីស្រឡាញ់ ចូលទៅកាន់ហឫទ័យជាវាចាអ្នកបូរី ជាទីស្រឡាញ់ដល់ជនច្រើន ជាទីពេញចិត្តដល់ជនច្រើន ជាអ្នកពោលនូវវាចាមានសភាពដូច្នោះ ។

ជាអ្នកលះបង់នូវសម្ផប្បលាបៈ វៀរស្រឡះចាកសម្ផប្បលាបៈ ពោលពាក្យត្រូវតាមកាល ពោលពាក្យពិត ពោលពាក្យដែលជាអត្ថ ពោលពាក្យដែលជាធម៌ ពោលពាក្យជាវិន័យ ពោលពាក្យដែលគួរឱ្យតាំងទុកក្នុងហឫទ័យ ត្រូវតាមកាល ប្រកបដោយគ្រឿងអាង ជាវាចាមានទីបំផុត ប្រកបដោយប្រយោជន៍ ។

ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ ដោយវាចាមាន ៤ ប្រការយ៉ាងនេះឯង ។

ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ដោយចិត្តមាន ៣ ប្រការ តើដូចម្តេចខ្លះ ?

ម្នាលគហបតីទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ មិនច្រើនដោយអភិជ្ឈា គ្រឿងឧបករណ៍ដែលជាសម្បត្តិនៃបុគ្គលដទៃណា ក៏មិនគយគន់នូវគ្រឿងឧបករណ៍នោះថា ឱហ្ន៎ គ្រឿងឧបករណ៍ដែលជាសម្បត្តិនៃបុគ្គលដទៃណា គ្រឿងឧបករណ៍នោះ គប្បីបានមកអាត្មាអញ ដូច្នេះឡើយ ។

មួយទៀត ជាអ្នកមានចិត្តមិនព្យាបាទ មានតម្រិះក្នុងចិត្តដែលទោសមិនប្រទូស្តហើយថា សត្វទាំងឡាយនេះចូរកុំមានពៀរ កុំមានព្យាបាទ កុំមានទុក្ខ រក្សាខ្លួនឱ្យបានសេចក្តីសុខចុះ ។

មួយវិញទៀត ជាអ្នកមានគំនិតយល់ត្រូវ ឃើញនូវសេចក្តីមិនវិបរិតថា ទានដែលបុគ្គលឱ្យហើយមានផល ការបូជាធំមានផល ការបូជាតូចមានផល ផលវិបាកនៃកុសលាកុសលកម្មដែលសត្វធ្វើល្អនិងធ្វើអាក្រក់មាន លោកនេះមាន លោកខាងមុខមាន មាតាមានគុណ បិតាមានគុណ សត្វដែលជា

ឧបបាតិកៈកំណើតមាន ពួកសមណព្រាហ្មណ៍ក្នុងលោក ជាអ្នកព្រមព្រៀងប្រតិបត្តិដោយត្រឹមត្រូវ ធ្វើឱ្យជាក់ច្បាស់ដោយប្រាជ្ញាចំពោះខ្លួនឯង នូវលោកនេះនិងលោកខាងមុខ ហើយប្រកាសក៏មាន ។ ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ដោយចិត្តមាន ៣ ប្រការយ៉ាងនេះឯង ។

ម្នាលគហបតីទាំងឡាយ សត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ បែកធ្លាយរាងកាយ ខាងមុខបន្ទាប់អំពីមរណៈ ចូលទៅកាន់សុគតិសួគ៌ទេវលោកយ៉ាងនេះ ព្រោះហេតុតែកិរិយាប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ យ៉ាងនេះឯង ។

ម្នាលគហបតីទាំងឡាយ បុគ្គលប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ បើប្រាថ្នាថា ឱ ខ្លួនអាត្មាអញ លុះទម្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ សូមឱ្យបានកើតជាមួយពួកខត្តិយមហាសាល ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះ ក៏នឹងបានសម្រេច ព្រោះថាបុគ្គលនោះ លុះទម្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ ក៏បានទៅកើតជាមួយពួកខត្តិយមហាសាលមែន សេចក្តីនោះព្រោះហេតុដូចម្តេច ព្រោះហេតុថា បុគ្គលនោះជាអ្នកប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ ។

ម្នាលគហបតីទាំងឡាយ បុគ្គលប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ បើប្រាថ្នាថា ឱ ខ្លួនអាត្មាអញ លុះទម្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ សូមឱ្យបានទៅកើតជាមួយពួកព្រាហ្មណមហាសាល ។ល ។ កើតជាមួយនឹងគហបតីមហាសាល ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះ ក៏នឹងបានសម្រេច ព្រោះថាបុគ្គលនោះ លុះទម្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ ក៏បានទៅកើតជាមួយនឹងពួកគហបតីមហាសាលមែន សេចក្តីនោះព្រោះហេតុដូចម្តេច ព្រោះហេតុថា បុគ្គលនោះ ជាអ្នកប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ ។

ម្នាលគហបតីទាំងឡាយ បុគ្គលប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ បើប្រាថ្នាថា ឱ ខ្លួនអាត្មាអញ លុះទម្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ សូមឱ្យបានទៅកើតជាមួយពួកទេវតា ក្នុងជាន់ចាតុម្មហារាជិកា ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះ ក៏នឹងបានសម្រេច ព្រោះថាបុគ្គលនោះ លុះបែកធ្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ ក៏បានទៅកើតជាមួយនឹងពួកទេវតាក្នុងជាន់ចាតុម្មហារាជិកាពិតមែន សេចក្តីនោះ ព្រោះហេតុដូចម្តេច ព្រោះហេតុថា បុគ្គលនោះ ជាអ្នកប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្ត

តាមធម៌ ។

ម្នាលគហបតីទាំងឡាយ បុគ្គលប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ បើប្រាថ្នាថា ឱ ខ្លួនអាត្មាអញ លុះទម្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ សូមឱ្យបានទៅកើតជាមួយនឹងពួកទេវតា ក្នុងជាន់តាវត្តិង្ស ។ល ។ ពួកទេវតាជាន់យាម... ពួកទេវតាជាន់តុសិត... ពួកទេវតាជាន់និម្មានរតី... ពួកទេវតាជាន់បរនិម្មិតវសវត្តី... ពួកទេវតាជាន់ព្រហ្មកាយិកា ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះ ក៏នឹងបានសម្រេច ព្រោះថា បុគ្គលនោះលុះបែកធ្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ ក៏បានទៅកើតជាមួយនឹងពួកទេវតាជាន់ព្រហ្មកាយិកាមែន សេចក្តីនោះព្រោះហេតុដូចម្តេច ព្រោះហេតុថា បុគ្គលនោះ ជាអ្នកប្រព្រឹត្តស្មើពោលគឺប្រព្រឹត្តតាមធម៌ ។

ម្នាលគហបតីទាំងឡាយ បុគ្គលប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ ។ បើប្រាថ្នាថា ឱ ខ្លួនអាត្មាអញ លុះបែកធ្លាយរាងកាយខាងមុខ បន្ទាប់អំពីមរណៈ សូមឱ្យបានទៅកើតជាមួយពួកទេវតាជាន់អាភា ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះ

ក៏នឹងបានសម្រេច ព្រោះថា បុគ្គលនោះ លុះបែកធ្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ ក៏បានទៅកើតជាមួយពួកទេវតាជាន់អាភា មែន សេចក្តីនោះ ព្រោះហេតុដូចម្តេច ព្រោះហេតុថា បុគ្គលនោះជាអ្នកប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ ។

ម្នាលគហបតីទាំងឡាយ បុគ្គលប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ បើប្រាថ្នាថា ឱ ខ្លួនអាត្មាអញ លុះបែកធ្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ សូមឱ្យបានទៅកើតជាមួយពួកទេវតាជាន់បរិត្តាភា ។ល ។ នឹងពួកទេវតាជាន់អប្បមាណាភា... ពួកទេវតាជាន់អាភស្សរា... ពួកទេវតាជាន់បរិត្តសុភា... ពួកទេវតាជាន់អប្បមាណសុភា... ពួកទេវតាជាន់សុភកិណ្ហកា... ពួកទេវតាជាន់វេហប្ផលា... ពួកទេវតាជាន់អវិហា... ពួកទេវតាជាន់អតប្បា... ពួកទេវតាជាន់សុទស្សា... ពួកទេវតាជាន់សុទស្សី... ពួកទេវតាជាន់អកនិដ្ឋា... ពួកទេវតាដែលកើតក្នុងអាកាសានញ្ចាយតនៈ... ពួកទេវតាដែលកើតក្នុងវិញ្ញានញ្ចាយតនៈ... ពួកទេវតាដែលកើតក្នុងអាកិញ្ចញ្ញាយតនៈ... និងពួកទេវតាដែលកើតក្នុងជាន់នេវសញ្ញានាសញ្ញាយតនៈ ការណ៍ដែលបុគ្គលប្រាថ្នា

បែបនេះក៏នឹងបានសម្រេច ព្រោះថា បុគ្គលនោះ លុះបែកធ្លាយរាងកាយបន្ទាប់អំពីមរណៈក៏បានទៅកើតជាមួយពួកទេវតា ដែលកើតក្នុងជាន់នេវសញ្ញានាសញ្ញាយតនៈមែន សេចក្តីនោះ ព្រោះហេតុដូចម្តេច ព្រោះហេតុថា បុគ្គលនោះ ជាអ្នកប្រព្រឹត្តស្មើពោលគឺប្រព្រឹត្តតាមធម៌ ។

ម្នាលគហបតីទាំងឡាយ បុគ្គលប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ បើប្រាថ្នាថា ឱ ខ្លួនអាត្មាអញ សូមឱ្យអស់អាសវៈទាំងឡាយ ហើយធ្វើឱ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈដោយប្រាជ្ញាចំពោះខ្លួនឯង ក្នុងបច្ចុប្បន្ននេះ ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះ ក៏នឹងបានសម្រេច ព្រោះថាបុគ្គលនោះ នឹងអស់អាសវៈទាំងឡាយហើយធ្វើឱ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិដែលមិនមានអាសវៈ ដោយប្រាជ្ញាចំពោះខ្លួនឯង ក្នុងបច្ចុប្បន្នមែន សេចក្តីនោះ ព្រោះហេតុដូចម្តេច ព្រោះហេតុថា បុគ្គលនោះជាអ្នកប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ ។

(បិដកលេខ ៨២ ទំព័រ ៣៣០) ក្នុងធម្មហទយវិភង្គ

ព្រះមានព្រះភាគ ទ្រង់ត្រាស់សម្ដែងថា បុគ្គលឱ្យទាន សមាទានសីល ធ្វើឧបោសថកម្ម ពួកខ្លះ ទៅកើតជាមួយពួកខត្តិយមហាសាល ពួកខ្លះទៅកើតជាមួយពួកព្រាហ្មណមហាសាល ពួកខ្លះ ទៅកើតជាមួយនឹងពួកគហបតីមហាសាល ។ ប្រមាណនៃអាយុរបស់មនុស្ស កំណត់មួយរយឆ្នាំ ឬតិចជាង ឬក៏ច្រើនជាងមួយរយឆ្នាំ ។

ពួកខ្លះ កើតជាមួយនឹងពួកនៃទេវតាមានប្រមាណនៃអាយុនោះៗ គឺ : ៥០ ឆ្នាំណាជារបស់នៃមនុស្ស ៥០ ឆ្នាំនោះជាមួយយប់មួយថ្ងៃនៃទេវតាជាន់ចាតុម្មហារាជិកៈ ៣០ រាត្រីដោយរាត្រីនោះជាមួយខែ ១២ ខែដោយខែនោះជាមួយឆ្នាំ ៥០០ ឆ្នាំទិព្វដោយឆ្នាំនោះ ជាប្រមាណនៃអាយុ របស់ទេវតាជាន់ចាតុម្មហារាជិកៈ ។ ត្រូវជា ៩ លានឆ្នាំនៃមនុស្ស ។

-១០០ ឆ្នាំណាជារបស់នៃមនុស្ស មួយរយឆ្នាំនោះជាមួយយប់មួយថ្ងៃរបស់ទេវតាជាន់តាវត្តិង្ស ៣០ រាត្រីដោយរាត្រីនោះជាមួយខែ ១២ ខែដោយខែនោះជាមួយឆ្នាំ មួយពាន់ឆ្នាំទិព្វដោយឆ្នាំនោះ ជាប្រមាណនៃអាយុរបស់ទេវតាជាន់តាវត្តិង្ស ។

ត្រូវជា ៣ កោដិ ៦ លានឆ្នាំមនុស្ស ។

ពីររយឆ្នាំណា ជារបស់នៃមនុស្ស ពីររយឆ្នាំនោះជាមួយយប់មួយថ្ងៃរបស់ទេវតាជាន់យាមៈ ៣០ រាត្រីដោយរាត្រីនោះជាមួយខែ ១២ ខែដោយខែនោះជាមួយឆ្នាំ ពីរពាន់ឆ្នាំទិព្វដោយឆ្នាំនោះ ជាប្រមាណនៃអាយុរបស់ទេវតាជាន់យាមៈ ។ ត្រូវជា ១៤ កោដិ ៤ លានឆ្នាំមនុស្ស ។

បួនរយឆ្នាំណាជារបស់នៃមនុស្ស បួនរយឆ្នាំនុ៎ះ ជាមួយយប់មួយថ្ងៃរបស់ទេវតា ជាន់តុសិត ៣០ រាត្រីដោយរាត្រីនោះជាមួយខែ ១២ ខែដោយខែនោះជាមួយឆ្នាំ បួនពាន់ឆ្នាំទិព្វដោយឆ្នាំនោះ ជាប្រមាណនៃអាយុរបស់ទេវតាជាន់តុសិត ។ ត្រូវជា ៥៧ កោដិ ៦ លានឆ្នាំមនុស្ស ។

៨ រយឆ្នាំណា ជារបស់នៃមនុស្ស ៨ រយឆ្នាំនុ៎ះជាមួយយប់មួយថ្ងៃនៃទេវតាជាន់និម្មានរតី ៣០ រាត្រីដោយរាត្រីនោះជាមួយខែ ១២ ខែដោយខែនោះជាមួយឆ្នាំ ៨ ពាន់ឆ្នាំទិព្វដោយឆ្នាំនោះ ជាប្រមាណនៃអាយុរបស់ទេវតាជាន់និម្មានរតី ។ ត្រូវជា ២៣០ កោដិ ៤ លានឆ្នាំមនុស្ស ។

- ១៦ រយឆ្នាំ ( ១៦០០ឆ្នាំ ) ណាជារបស់មនុស្ស ១៦ រយឆ្នាំនោះ ជាមួយយប់មួយថ្ងៃរបស់ទេវតាជាន់បរនិម្មិតវសវត្តី ៣០ រាត្រីដោយរាត្រីនោះ ជាមួយខែ ១២ ខែដោយខែនោះជាមួយឆ្នាំ ១៦ ពាន់ឆ្នាំទិព្វ ( ១ ម៉ឺន ៦ ពាន់ឆ្នាំ ) ដោយឆ្នាំនោះ ជាប្រមាណនៃអាយុ របស់ទេវតាជាន់បរនិម្មិតវសវត្តី ។ ត្រូវជា ៩២១ កោដិ ៦ លានឆ្នាំមនុស្ស ។

( អាយុរបស់ព្រហ្មកាយិកទេវតា មានប្រមាណ ១ កប្ប បិដកភាគ ៤២ ទំ. ៣២៣ ) ។

បុគ្គលចម្រើនបឋមជ្ឈាន យ៉ាងឱនថយ កើតជាមួយនឹងពួកទេវតាជាន់ព្រហ្មបរិសជ្ជៈ ។ កប្បមួយចែកជា ៣ ភាគ ឬ ៤ ភាគ ( យកមួយភាគ ជាអាយុរបស់ទេវតាជាន់នោះ ) ។

បុគ្គលចម្រើនបឋមជ្ឈាន យ៉ាងកណ្តាល កើតជាមួយនឹងពួកទេវតាជាន់ព្រហ្មបរោហិតៈ ។ ពាក់កណ្តាលកប្ប ( ជាអាយុរបស់ទេវតាជាន់នោះ ) ។

បុគ្គលចម្រើនបឋមជ្ឈានជាន់ខ្ពស់ កើតជាមួយនឹងពួកទេវតាជាន់មហាព្រហ្ម ។ មួយកប្ប ( ជាអាយុរបស់ទេវតាជាន់នោះ ) ។

បុគ្គលចម្រើនទុតិយជ្ឈានយ៉ាងឱនថយ កើតជាមួយនឹង

ទេវតាជាន់បរិត្តាភៈ ។ ពីរកប្ប (ជាអាយុរបស់ទេវតាជាន់នោះ) ។ បុគ្គលចម្រើនទុតិយជ្ឈានយ៉ាងកណ្ដាល កើតជាមួយនឹងទេវតាជាន់អប្បមាណាភៈ ។ ៤ កប្ប (ជាអាយុរបស់ទេវតាជាន់នោះ) ។

បុគ្គលចម្រើនទុតិយជ្ឈានជាន់ខ្ពស់ កើតជាមួយនឹងទេវតាជាន់អាភស្សរៈ ។ ៨ កប្ប (ជាអាយុរបស់ទេវតាជាន់នោះ) ។

បុគ្គលចម្រើនតតិយជ្ឈានយ៉ាងឱនថយ កើតជាមួយនឹងទេវតាជាន់បរិត្តសុភៈ ។ ១៦ កប្ប (ជាអាយុរបស់ទេវតាជាន់នោះ) ។

បុគ្គលចម្រើនតតិយជ្ឈានយ៉ាងកណ្ដាល កើតជាមួយនឹងទេវតាជាន់អប្បមាណសុភៈ ។ ៣២ កប្ប (ជាអាយុរបស់ទេវតាជាន់នោះ) ។

បុគ្គលចម្រើនតតិយជ្ឈានជាន់ខ្ពស់ កើតជាមួយនឹងទេវតាជាន់សុភកិណ្ហៈ ។ ៦៤ កប្ប (ជាអាយុរបស់ទេវតាជាន់នោះ) ។

បុគ្គលចម្រើនចតុត្ថជ្ឈាន ព្រោះមានអារម្មណ៍ផ្សេងគ្នា ព្រោះមានមនសិការផ្សេងគ្នា ព្រោះមានឆន្ទៈផ្សេងគ្នា ព្រោះមាន

បណិធិ ( ការតម្កល់ ) ផ្សេងគ្នា ព្រោះមានអធិមោក្ខ ( ការចុះចិត្ត ) ផ្សេងគ្នា ព្រោះមានអភិនីហារ ( ការកសាង ) ផ្សេងគ្នា ព្រោះមានបញ្ញាផ្សេងគ្នា ពួកខ្លះ កើតជាមួយនឹងទេវតាជាន់អសញ្ញសត្វ ពួកខ្លះ កើតជាមួយនឹងទេវតាជាន់វេហប្ផលៈ ។ ៥០០ កប្ប ( ជាអាយុរបស់ទេវតាពីរជាន់នោះដូចគ្នា ) ។

ពួកខ្លះ កើតជាមួយនឹងពួកទេវតាជាន់អវិហៈ ។ មួយពាន់កប្ប ( ជាអាយុរបស់ទេវតាជាន់នោះ ) ។

ពួកខ្លះ កើតជាមួយនឹងពួកទេវតាជាន់អតប្បៈ ។ ពីរពាន់កប្ប ( ជាអាយុរបស់ទេវតាជាន់នោះ ) ។

ពួកខ្លះ កើតជាមួយនឹងទេវតាជាន់សុទស្សៈ ។ ៤ ពាន់កប្ប ( ជាអាយុរបស់ទេវតាជាន់នោះ ) ។

ពួកខ្លះ កើតជាមួយនឹងពួកទេវតាជាន់សុទស្សី ។ ៨ ពាន់កប្ប ( ជាអាយុរបស់ទេវតាជាន់នោះ ) ។

ពួកខ្លះ កើតជាមួយនឹងទេវតាជាន់អកនិដ្ឋៈ ។ ១៦ ពាន់កប្ប ( ជាអាយុរបស់ទេវតាជាន់នោះ ) ។

ពួកខ្លះ កើតជាមួយនឹងពួកទេវតាជាន់អាកាសានញ្ចាយតនៈ ។

២០ ពាន់កប្ប (ជាអាយុរបស់ទេវតាជាន់នោះ) ។

ពួកខ្លះកើតជាមួយនឹងពួកទេវតាជាន់វិញ្ញាណញ្ចាយតនៈ ។ ៤០ ពាន់កប្ប(ជាអាយុរបស់ទេវតាជាន់នោះ) ។

ពួកខ្លះ កើតជាមួយនឹងពួកទេវតាជាន់អាកិញ្ចញ្ញាយតនៈ ។ ៦០ ពាន់កប្ប (ជាអាយុរបស់ទេវតាជាន់នោះ) ។

ពួកខ្លះ កើតជាមួយនឹងពួកទេវតាជាន់នេវសញ្ញានាសញ្ញាយតនៈ ។ ៨៤ ពាន់កប្ប(ជាអាយុរបស់ទេវតាជាន់នោះ) ។

ពួកសត្វដែលតេជៈ គឺបុណ្យស្ទួយហើយ រមែងទៅកាន់កាមគតិនិងរូបគតិ ឬឱ្យដល់ភវគ្គព្រហ្ម ក៏គង់ត្រឡប់មកកាន់ទុគ្គតិវិញ ពួកសត្វដែលមានអាយុវែងដល់ម៉្លោះ ក៏គង់ច្យុតដោយអស់អាយុ ព្រះមហេសីត្រាស់ថា គ្មានភពណាមួយទៀងទេ ព្រោះហេតុនោះ អ្នកប្រាជ្ញមានប្រាជ្ញារក្សាខ្លួន មានប្រាជ្ញាល្អិត អ្នកគិតនូវអត្ថរមែងចម្រើននូវមគ្គដ៏ប្រសើរ ដើម្បីដោះខ្លួនចាកជរានិងមរណៈ លុះចម្រើននូវមគ្គដ៏ស្អាត សម្រាប់ធ្វើដំណើរទៅកាន់អមតនិព្វានហើយ រមែងជាអ្នកមិនមានអាសវៈ កំណាត់នូវអាសវៈទាំងពួងហើយបរិនិព្វាន ។

# អរិយមគ្គប្រកបដោយអង្គ ៨

(ក្នុងសុត្តន្តបិដក សំយុត្តនិកាយ មហាវារវគ្គ បិដកលេខ ៣៧ ទំព័រ ១៨)

មានភិក្ខុមួយអង្គក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា

បពិត្រព្រះអង្គដ៏ចម្រើន គេតែងនិយាយថា **អមតៈ អមតៈ** (មិនស្លាប់ មិនស្លាប់)ដូច្នេះ ។ បពិត្រព្រះអង្គដ៏ចម្រើនអមតៈ តើដូចម្ដេច ? ផ្លូវជាដំណើរទៅកាន់អមតៈតើដូចម្ដេច ? ម្នាលភិក្ខុ ការអស់ទៅនៃរាគៈ ការអស់ទៅនៃទោសៈ ការអស់ទៅនៃមោហៈឯណា នេះហៅថា **អមតៈ** ។ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯង ជាផ្លូវដំណើរទៅកាន់អមតៈ ។ មគ្គទាំង ៨ តើដូចម្ដេច ? គឺ **សម្មាទិដ្ឋិ** ១ ។ល។ **សម្មាសមាធិ** ១ ។

សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងនឹងចែកនូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរប្រុងស្ដាប់នូវមគ្គនោះ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្ដែង ។ ភិក្ខុទាំងនោះទទួលស្ដាប់ព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ តើដូចម្ដេច ? មគ្គទាំង ៨ គឺ

អ្វីខ្លះ ។ គឺ**សម្មាទិដ្ឋិ** ១ ។បេ ។ **សម្មាសមាធិ** ១ ។

ម្នាលភិក្ខុទាំងឡាយ **សម្មាទិដ្ឋិ** តើដូចម្តេច ? ម្នាលភិក្ខុទាំងឡាយ សេចក្តីដឹងក្នុងទុក្ខ សេចក្តីដឹងក្នុងហេតុជាទីកើតឡើងនៃទុក្ខ សេចក្តីដឹងក្នុងការរលត់នៃទុក្ខ សេចក្តីដឹងក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់នៃទុក្ខឯណា ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **សម្មាទិដ្ឋិ** ។

(ព្រះពុទ្ធដីកាខាងមុខនេះ ព្រះមានព្រះភាគ ទ្រង់សម្តែងក្នុងមហាសតិប្បដ្ឋានសូត្រ បិដកភាគ ១៧ ទំព័រ ២៨១ ខ្ញុំស្រង់យកមកចែកសេចក្តីបំភ្លឺក្នុងសម្មាទិដ្ឋិ ដោយព្រះតម្រាស់ )ថា :

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងប្រាកដតាមពិតថា នេះជាទុក្ខ ដឹងប្រាកដតាមពិតថា នេះជាហេតុនាំឱ្យកើតទុក្ខ ដឹងប្រាកដតាមពិតថា នេះជាសភាវៈរលត់ទុក្ខ ដឹងប្រាកដតាមពិតថា នេះជាបដិបទាឱ្យបានដល់នូវសភាវៈរលត់ទុក្ខ ។

ម្នាលភិក្ខុទាំងឡាយ ចុះ**ទុក្ខអរិយសច្ច** តើដូចម្តេច ? **ជាតិ** គឺកំណើតដែលកើតជាដំបូង ក៏ជាទុក្ខ **ជរា** គឺសេចក្តីចាស់គ្រាំគ្រា ក៏ជាទុក្ខ **មរណៈ** គឺសេចក្តីស្លាប់ ក៏ជាទុក្ខ **សោកៈ** គឺសេចក្តីស្តាយស្រណោះ **បរិទេវៈ** គឺសេចក្តីខ្សឹកខ្សួល **ទុក្ខៈ** គឺសេចក្តី

លំបាកកាយ **ទោមនស្ស** គឺសេចក្តីអាក់អន់តូចចិត្ត **ឧបាយាសៈ** គឺសេចក្តីចង្អៀតចង្អល់ចិត្ត ក៏សុទ្ធតែជាទុក្ខ **អប្បិយេហិសម្បយោគៈ** គឺដំណើរជួបប្រសព្វដោយសត្វនិងសង្ខារទាំងឡាយ ដែលមិនជាទីស្រឡាញ់ ក៏ជាទុក្ខ **បិយេហិវិប្បយោគៈ** គឺសេចក្តីព្រាត់ប្រាសចាកសត្វនិងសង្ខារទាំងឡាយដែលជាទីស្រឡាញ់ ក៏ជាទុក្ខ **យម្បិច្ឆំ ន លភតិតម្បិ** គឺបុគ្គលកាលចង់បាននូវរបស់ណា តែមិនបាន ឯការមិនបានរបស់នោះ ក៏ជាទុក្ខ បើដោយសេចក្តីបំប្រួញ ឧបាទានក្ខន្ធទាំង ៥ មានរូបក្ខន្ធជាដើម ក៏ជាទុក្ខ[១] ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា **ជាតិ** ។ កិរិយាកើតជាដំបូង កិរិយាកើតព្រម ការចុះចាប់ផ្ទៃ ការវិលត្រឡប់មកកើត ការកើតប្រាកដនៃខន្ធ ការបាននូវអាយតនៈណា របស់សត្វនោះៗ ក្នុងសត្តនិកាយនោះៗ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **ជាតិ** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា **ជរា** ។ ជរាគឺសេចក្តីចាស់ គ្រាំគ្រា ឬការប្រែប្រួល ធ្មេញបាក់ សក់ស្កូវ ស្បែកជ្រួញជ្រីវ យុរយារ ការរួញថយនៃអាយុ ការទ្រុឌទ្រោម

១ ប្រែតាមធម្មចក្ក ក៏បាន ។

ឥន្ទ្រិយទាំងឡាយណា របស់សត្វទាំងឡាយនោះៗ ក្នុងសត្តនិកាយនោះៗ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **ជរា** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា **មរណៈ** ។ ភាវៈនៃចិត្តដែលឃ្លាតចេញ អាការៈនៃចិត្តដែលឃ្លាតទៅ ការបែកធ្លាយទៅ ការបាត់បង់ទៅ សេចក្តីវិនាសជីវិត សេចក្តីស្លាប់ កាលកិរិយា ការបែកធ្លាយនៃខន្ធទាំងឡាយ ការដាក់ចុះនូវសាកសព ការផ្តាច់ផ្តិលនូវជីវិតិន្ទ្រិយណា របស់សត្វទាំងឡាយនោះៗ ចាកសត្តនិកាយនោះៗ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **មរណៈ** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា **សោកៈ** ។ ម្នាលភិក្ខុទាំងឡាយ សោកៈគឺសេចក្តីស្តាយស្រណោះ សេចក្តីស្រងេះស្រងោច សេចក្តីសោកសៅ សេចក្តីរីងស្ងួតក្នុងចិត្ត សេចក្តីក្រៀមក្រំក្នុងចិត្តណារបស់សត្វ ដែលប្រកបហើយដោយសេចក្តីវិនាសណាមួយ (ឬ)ដែលសេចក្តីទុក្ខណាមួយពាល់ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **សោកៈ** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា **បរិទេវៈ** ។ ម្នាលភិក្ខុទាំងឡាយ សភាវៈទួញរក (បិយជនមានកូនជាដើម) សភាវៈទួញ រៀបរាប់(សរសើរគុណ) កិរិយាយំអណ្តឺតអណ្តក

កិរិយាយំបម្រះនទៀល ភាវៈនៃការយំអណ្ដឺតអណ្ដក ភាវៈនៃការយំបម្រះនទៀលណារបស់សត្វ ដែលប្រកបហើយដោយសេចក្ដីវិនាសណាមួយ (ឬ)ដែលសេចក្ដីទុក្ខណាមួយពាល់ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **បរិទេវៈ** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចហៅថា **ទុក្ខៈ** ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីលំបាកកាយ សេចក្ដីមិនសប្បាយកាយ សេចក្ដីលំបាកដែលកើត អំពីកាយសម្ផ័ស្ស ការទទួលរងសេចក្ដីមិនស្រួលណា ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **ទុក្ខៈ** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចហៅថា **ទោមនស្ស** ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីលំបាកក្នុងចិត្ត សេចក្ដីមិនសប្បាយក្នុងចិត្ត សេចក្ដីលំបាក ដែលកើតអំពីមនោសម្ផ័ស្ស ការទទួលអារម្មណ៍មិនស្រួលណា ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **ទោមនស្ស** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចហៅថា **ឧបាយាសៈ** ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីតានតឹងក្នុងចិត្ត សេចក្ដីចង្អៀតចង្អល់ចិត្ត ភាវៈនៃសេចក្ដីតានតឹងក្នុងចិត្ត ភាវៈនៃសេចក្ដីចង្អៀតចង្អល់ចិត្តណារបស់សត្វ ដែលប្រកបហើយដោយសេចក្ដីវិនាសណា

មួយ (ឬ)ដែលសេចក្តីទុក្ខណាមួយពាល់ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **ឧបាយាសៈ** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា **អប្បិយេហិ សម្បយោគទុក្ខ** ។ ម្នាលភិក្ខុទាំងឡាយ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ទាំងឡាយណា ដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត មានដល់បុគ្គលណាក្នុងលោកនេះ ពុំនោះសោត ជនទាំងឡាយណា ប្រាថ្នានូវសេចក្តីមិនចម្រើន ប្រាថ្នានូវអំពើឥតប្រយោជន៍ ប្រាថ្នានូវសេចក្តីមិនសប្បាយ ប្រាថ្នានូវអំពើដែលមិនក្សេមចាកយោគៈចំពោះបុគ្គលនោះ កិរិយាបានជួបគ្នា កិរិយាជួបជុំគ្នា កិរិយាប្រជុំគ្នា ការនៅប្រឡូកប្រឡំគ្នា នឹងអារម្មណ៍ទាំងឡាយនោះៗ នឹងជនទាំងឡាយនោះៗ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **អប្បិយេហិ សម្បយោគទុក្ខ** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា **បិយេហិ វិប្បយោគទុក្ខ** ។ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ទាំងឡាយ ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានដល់បុគ្គលណា ក្នុងលោកនេះ

ពុំនោះសោត ជនទាំងឡាយណា ទោះមាតាក្តី បិតាក្តី បងប្អូនប្រុសក្តី បងប្អូនស្រីក្តី មិត្រក្តី អមាត្យក្តី ញាតិសាលោហិតក្តី ដែលជាអ្នកប្រាថ្នានូវសេចក្តីចម្រើន ប្រាថ្នានូវប្រយោជន៍ ប្រាថ្នានូវសេចក្តីសប្បាយ ប្រាថ្នានូវសេចក្តីក្សេមចាកយោគៈ ចំពោះបុគ្គលនោះ ការមិនបានជួបគ្នា ការមិនបានជួបជុំគ្នា កិរិយាមិនបានប្រជុំគ្នា ការមិនទៅប្រឡូកប្រឡំ នឹងអារម្មណ៍ទាំងឡាយនោះៗ នឹងជនទាំងឡាយនោះៗ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **បិយេហិ វិប្បយោគទុក្ខ** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា **យម្បិច្ឆំ ន លភតិតម្បិទុក្ខ** ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានជាតិជាធម្មតា តែងមានសេចក្តីប្រាថ្នាកើតឡើងយ៉ាងនេះថា ធ្វើម្តេចហ្ន៎ ឱ្យយើងទាំងឡាយ កុំគប្បីមានជាតិជាធម្មតា ពុំនោះសោត ជាតិកុំគប្បីមកដល់យើងទាំងឡាយ សេចក្តីនេះ ពួកសត្វក៏មិនបានសម្រេចតាមប្រាថ្នាសោះឡើយ នេះឯងឈ្មោះថា **យម្បិច្ឆំ ន លភតិតម្បិទុក្ខ** ។

ម្នាលភិក្ខុទាំងឡាយ ពួកសត្វ ដែលមានសេចក្តីគ្រាំគ្រាឬប្រែប្រួលជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមាន

សេចក្តីឈឺថ្កាត់ជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានសេចក្តីស្លាប់ជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានសេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីអាក់អន់តូចចិត្ត សេចក្តីខ្លោចផ្សាចិត្តជាធម្មតា តែងមានសេចក្តីប្រាថ្នាកើតឡើងយ៉ាងនេះថា ធ្វើម្តេចហ្ន៎ ឱ្យយើងទាំងឡាយកុំគប្បីមានសេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីអាក់អន់តូចចិត្ត សេចក្តីខ្លោចផ្សាចិត្តជាធម្មតា ពុំនោះសោត សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីអាក់អន់តូចចិត្ត សេចក្តីខ្លោចផ្សាចិត្ត កុំគប្បីមកដល់យើងទាំងឡាយឡើយ សេចក្តីនេះ ពួកសត្វក៏មិនបានសម្រេចតាមប្រាថ្នាឡើយ នេះឯងក៏ឈ្មោះថា **យម្បិច្ឆំ ន លភតិតម្បិទុក្ខំ** ដែរ ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា ឧបាទានក្ខន្ធទាំង ៥ ដោយសេចក្តីបំប្រួញ ដែលថាជាទុក្ខ ។ ឧបាទានក្ខន្ធទាំង ៥ នោះគឺអ្វីខ្លះ គឺរូប ជាឧបាទានក្ខន្ធ ១ វេទនា ជាឧបាទានក្ខន្ធ ១ សញ្ញា ជាឧបាទានក្ខន្ធ ១ សង្ខារ ជាឧបាទានក្ខន្ធ ១ វិញ្ញាណ ជាឧបាទានក្ខន្ធ ១ ម្នាលភិក្ខុទាំងឡាយ ទាំងនេះតថាគតហៅថា ឧបាទានក្ខន្ធទាំង ៥ ដោយសេចក្តីបំប្រួញថាជាទុក្ខ ។

ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **ទុក្ខអរិយសច្ច** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា **ទុក្ខសមុទយអរិយសច្ច** ។ តណ្ហាណា ជាធម្មជាតិនាំសត្វឱ្យកើតទៀត ប្រកបដោយតម្រេករីករាយ ជាធម្មជាតិនាំសត្វឱ្យត្រេកត្រអាលនៅក្នុងភពនោះៗ ឬក្នុងអារម្មណ៍នោះៗ តណ្ហានោះ គឺអ្វីខ្លះ ? គឺកាមតណ្ហា (សេចក្តីប្រាថ្នាក្នុងកាមភព)១ ភវតណ្ហា(១)(សេចក្តីប្រាថ្នាក្នុងរូបភពនិងអរូបភព)១ វិភវតណ្ហា(សេចក្តីប្រាថ្នាប្រាសចាកភព(២))១ ។

ម្នាលភិក្ខុទាំងឡាយ ចុះតណ្ហានុ៎ះ កាលដែលកើតឡើង តើកើតឡើងក្នុងទីណា កាលដែលជាប់នៅ តើជាប់នៅក្នុងទីណា ។ អារម្មណ៍ណា ក្នុងលោកដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងអារម្មណ៍នុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងអារម្មណ៍នុ៎ះ ។

អារម្មណ៍អ្វីមួយក្នុងលោក ដែលមានសភាពគួរស្រឡាញ់

---

១. អដ្ឋកថា ថា ភវតណ្ហានេះជាឈ្មោះនៃតម្រេកក្នុងរូបភព និងអរូបភព ដែលប្រកបដោយសស្សតទិដ្ឋិគឺយល់ឃើញថា សត្វទៀង លោកទៀង កើតឡើងព្រោះសេចក្តីប្រាថ្នាចំពោះភព ។ ២. តាមន័យក្នុងអដ្ឋកថានិងដីកាថា តម្រេកប្រកបដោយឧច្ឆេទទិដ្ឋិ គឺយល់ថា សត្វស្លាប់ទៅសូន្យ ហៅថា វិភវតណ្ហា ។

មានសភាពគួរត្រេកអរ ។ ចក្ខុក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងចក្ខុនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងចក្ខុនុ៎ះ ។ សោតៈ ក្នុងលោក ។ ឃានៈ ក្នុងលោក ។ ជិវ្ហា ក្នុងលោក ។ កាយ ក្នុងលោក ។ មនោ ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងមនោនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងមនោនុ៎ះ ។

រូបារម្មណ៍ទាំងឡាយក្នុងលោក ។ សទ្ទារម្មណ៍ទាំងឡាយក្នុងលោក ។ គន្ធារម្មណ៍ទាំងឡាយ ក្នុងលោក ។ រសារម្មណ៍ទាំងឡាយ ក្នុងលោក ។ ផោដ្ឋព្វារម្មណ៍ទាំងឡាយ ក្នុងលោក ។ ធម្មារម្មណ៍ទាំងឡាយក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងធម្មារម្មណ៍នុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងធម្មារម្មណ៍នុ៎ះ ។

ចក្ខុវិញ្ញាណ ក្នុងលោក ។ សោតវិញ្ញាណ ក្នុងលោក ។ ឃានវិញ្ញាណ ក្នុងលោក ។ ជិវ្ហាវិញ្ញាណ ក្នុងលោក ។ កាយវិញ្ញាណ ក្នុងលោក ។ មនោវិញ្ញាណ ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ

កាលដែលកើតឡើង ក៏កើតឡើងក្នុងមនោវិញ្ញាណនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងមនោវិញ្ញាណនុ៎ះ ។

ចក្ខុសម្ផ័ស្ស ក្នុងលោក ។ សោតសម្ផស្ស ក្នុងលោក ។ ឃានសម្ផ័ស្ស ក្នុងលោក ។ ជិវ្ហាសម្ផ័ស្ស ក្នុងលោក ។ កាយសម្ផ័ស្ស ក្នុងលោក ។ មនោសម្ផ័ស្ស ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងមនោសម្ផ័ស្សនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងមនោសម្ផ័ស្សនុ៎ះ ។

វេទនាកើតអំពីចក្ខុសម្ផ័ស្ស ក្នុងលោក ។ វេទនាកើតអំពីសោតសម្ផ័ស្ស ក្នុងលោក ។ វេទនាកើតអំពីឃានសម្ផ័ស្ស ក្នុងលោក ។ វេទនាកើតអំពីជិវ្ហាសម្ផ័ស្ស ក្នុងលោក ។ វេទនាកើតអំពីកាយសម្ផ័ស្ស ក្នុងលោក ។ វេទនាកើតអំពីមនោសម្ផ័ស្ស ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងវេទនាដែលកើតអំពីមនោសម្ផ័ស្សនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងវេទនាដែលកើតអំពីមនោសម្ផ័ស្សនុ៎ះ ។

សេចក្តីសម្គាល់នូវរូបារម្មណ៍ ក្នុងលោក ។ សេចក្តី

សម្គាល់នូវសទ្ទារម្មណ៍ ក្នុងលោក ។ សេចក្ដីសម្គាល់នូវគន្ធារម្មណ៍ ក្នុងលោក ។ សេចក្ដីសម្គាល់នូវរសារម្មណ៍ ក្នុងលោក ។ សេចក្ដីសម្គាល់នូវផោដ្ឋព្វារម្មណ៍ ក្នុងលោក ។ សេចក្ដីសម្គាល់នូវធម្មារម្មណ៍ ក្នុងលោកដែលមានសភាពគួរសទ្បាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើង ក្នុងសេចក្ដីសម្គាល់នូវធម្មារម្មណ៍នុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងសេចក្ដីសម្គាល់នូវធម្មារម្មណ៍នុ៎ះ ។

ការគិតសន្សំនូវរូបារម្មណ៍ក្នុងលោក ។ ការគិតសន្សំនូវសទ្ទារម្មណ៍ ក្នុងលោក ។ ការគិតសន្សំនូវគន្ធារម្មណ៍ ក្នុងលោក ។ ការគិតសន្សំនូវរសារម្មណ៍ ក្នុងលោក ។ ការគិតសន្សំនូវផោដ្ឋព្វារម្មណ៍ក្នុងលោក ។ ការគិតសន្សំនូវធម្មារម្មណ៍ ក្នុងលោកដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងការគិតសន្សំនូវធម្មារម្មណ៍នុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងការគិតសន្សំនូវធម្មារម្មណ៍នុ៎ះ ។

សេចក្ដីប្រាថ្នានូវរូបារម្មណ៍ ក្នុងលោក ។ សេចក្ដីប្រាថ្នានូវសទ្ទារម្មណ៍ ក្នុងលោក ។ សេចក្ដីប្រាថ្នានូវគន្ធារម្មណ៍ ក្នុងលោក ។ សេចក្ដីប្រាថ្នានូវរសារម្មណ៍ ក្នុងលោក ។ សេចក្ដី

ប្រាថ្នានូវផោដ្ឋព្វារម្មណ៍ ក្នុងលោក ។ សេចក្តីប្រាថ្នានូវធម្មារម្មណ៍ ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងសេចក្តីប្រាថ្នានូវធម្មារម្មណ៍នុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងសេចក្តីប្រាថ្នានូវធម្មារម្មណ៍នុ៎ះ ។

សេចក្តីត្រិះរិះនូវរូបារម្មណ៍ ក្នុងលោក ។ សេចក្តីត្រិះរិះនូវសទ្ទារម្មណ៍ ក្នុងលោក ។ សេចក្តីត្រិះរិះនូវគន្ធារម្មណ៍ ក្នុងលោក ។ សេចក្តីត្រិះរិះនូវរសារម្មណ៍ ក្នុងលោក ។ សេចក្តីត្រិះរិះនូវផោដ្ឋព្វារម្មណ៍ ក្នុងលោក ។ សេចក្តីត្រិះរិះនូវធម្មារម្មណ៍ ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើង ក្នុងសេចក្តីត្រិះរិះនូវធម្មារម្មណ៍នុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងសេចក្តីត្រិះរិះនូវធម្មារម្មណ៍នុ៎ះ ។

ការពិចារណានូវរូបារម្មណ៍ ក្នុងលោក ។ ការពិចារណានូវសទ្ទារម្មណ៍ ក្នុងលោក ។ ការពិចារណានូវគន្ធារម្មណ៍ ក្នុងលោក ។ ការពិចារណានូវរសារម្មណ៍ ក្នុងលោក ។ ការពិចារណានូវផោដ្ឋព្វារម្មណ៍ ក្នុងលោក ។ ការពិចារណានូវ

ធម្មារម្មណ៍ ក្នុងលោកដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះកាលដែលកើតឡើង ក៏កើតឡើងក្នុងការពិចារណានូវធម្មារម្មណ៍នុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងការពិចារណានូវធម្មារម្មណ៍នុ៎ះ ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **ទុក្ខសមុទយអរិយសច្ច** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា **ទុក្ខនិរោធអរិយសច្ច** ។ ការអស់ទៅនិងការរលត់ទៅ ដោយមិនមានសេសសល់ ការលះបង់ ការរលាស់ចោល ការជម្រះចោល ការមិនមានអាល័យ ចំពោះតណ្ហានោះឯង ( ហៅថា **ទុក្ខនិរោធអរិយសច្ច** ) ។

ម្នាលភិក្ខុទាំងឡាយ ចុះតណ្ហានោះឯង កាលដែលបុគ្គលលះបង់ តើលះបង់ក្នុងទីណា កាលដែលរលត់ទៅ តើរលត់ទៅក្នុងទីណា ។ អារម្មណ៍ណាក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ តែងលះបង់ក្នុងអារម្មណ៍នុ៎ះ កាលដែលរលត់ទៅ តែងរលត់ទៅក្នុងអារម្មណ៍នុ៎ះ ។

ចុះអារម្មណ៍អ្វី ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ។ ចក្ខុក្នុងលោក ដែលមានសភាពគួរ

ស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងចក្ខុនោះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងចក្ខុនុ៎ះ ។ សោតៈ ក្នុងលោក ។ ឃានៈ ក្នុងលោក ។ ជិវ្ហា ក្នុងលោក ។ កាយ ក្នុងលោក ។ មនោ ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងមនោនោះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងមនោនោះ ។

រូបារម្មណ៍ទាំងឡាយ ក្នុងលោក ។ សទ្ទារម្មណ៍ទាំងឡាយ ក្នុងលោក ។ គន្ធារម្មណ៍ទាំងឡាយ ក្នុងលោក ។ រសារម្មណ៍ទាំងឡាយ ក្នុងលោក ។ ផោដ្ឋព្វារម្មណ៍ទាំងឡាយ ក្នុងលោក ។ ធម្មារម្មណ៍ទាំងឡាយ ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងធម្មារម្មណ៍នុ៎ះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងធម្មារម្មណ៍នុ៎ះ ។

ចក្ខុវិញ្ញាណ ក្នុងលោក ។ សោតវិញ្ញាណ ក្នុងលោក ។ ឃានវិញ្ញាណ ក្នុងលោក ។ ជិវ្ហាវិញ្ញាណ ក្នុងលោក ។ កាយវិញ្ញាណ ក្នុងលោក ។ មនោវិញ្ញាណ ក្នុងលោក ដែលមាន

សភាពគួរ ស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងមនោវិញ្ញាណនុ៎ះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងមនោវិញ្ញាណនុ៎ះ ។

ចក្ខុសម្ផ័ស្ស ក្នុងលោក ។ សោតសម្ផ័ស្ស ក្នុងលោក ។ ឃានសម្ផ័ស្ស ក្នុងលោក ។ ជិវ្ហាសម្ផ័ស្ស ក្នុងលោក ។ កាយសម្ផ័ស្ស ក្នុងលោក ។ មនោសម្ផ័ស្ស ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងមនោសម្ផ័ស្សនុ៎ះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងមនោសម្ផ័ស្សនុ៎ះ ។

វេទនាដែលកើតអំពីចក្ខុសម្ផ័ស្ស ក្នុងលោក ។ វេទនាដែលកើតអំពីសោតសម្ផ័ស្ស ក្នុងលោក ។ វេទនាដែលកើតអំពីឃានសម្ផ័ស្ស ក្នុងលោក ។ វេទនាដែលកើតអំពីជិវ្ហាសម្ផ័ស្ស ក្នុងលោក ។ វេទនាដែលកើតអំពីកាយសម្ផ័ស្ស ក្នុងលោក ។ វេទនាដែលកើតអំពីមនោសម្ផ័ស្ស ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងមនោសម្ផ័ស្សនុ៎ះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងមនោសម្ផ័ស្សនុ៎ះ ។

សេចក្តីសម្គាល់នូវរូបារម្មណ៍ ក្នុងលោក ។ សេចក្តីសម្គាល់នូវសទ្ទារម្មណ៍ ក្នុងលោក ។ សេចក្តីសម្គាល់នូវគន្ធារម្មណ៍ ក្នុងលោក ។ សេចក្តីសម្គាល់នូវរសារម្មណ៍ ក្នុងលោក ។ សេចក្តីសម្គាល់នូវផោដ្ឋព្វារម្មណ៍ ក្នុងលោក ។ សេចក្តីសម្គាល់នូវធម្មារម្មណ៍ ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងសេចក្តីសម្គាល់នូវធម្មារម្មណ៍នុ៎ះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងសេចក្តីសម្គាល់នូវធម្មារម្មណ៍នុ៎ះ ។

ការគិតសន្សំនូវរូបារម្មណ៍ ក្នុងលោក ។ ការគិតសន្សំនូវសទ្ទារម្មណ៍ ក្នុងលោក ។ ការគិតសន្សំនូវគន្ធារម្មណ៍ ក្នុងលោក ។ ការគិតសន្សំនូវរសារម្មណ៍ ក្នុងលោក ។ ការគិតសន្សំនូវផោដ្ឋព្វារម្មណ៍ ក្នុងលោក ។ ការគិតសន្សំនូវធម្មារម្មណ៍ ក្នុងលោកដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងការគិតសន្សំនូវធម្មារម្មណ៍នុ៎ះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងការគិតសន្សំនូវធម្មារម្មណ៍នុ៎ះ ។

សេចក្តីប្រាថ្នានូវរូបារម្មណ៍ ក្នុងលោក ។ សេចក្តីប្រាថ្នានូវសទ្ទារម្មណ៍ ក្នុងលោក ។ សេចក្តីប្រាថ្នានូវគន្ធារម្មណ៍ ក្នុង

លោក ។ សេចក្ដីប្រាថ្នានូវរសារម្មណ៍ ក្នុងលោក ។ សេចក្ដីប្រាថ្នានូវ ផោដ្ឋព្វារម្មណ៍ ក្នុងលោក ។ សេចក្ដីប្រាថ្នានូវធម្មារម្មណ៍ ក្នុងលោកដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ទៅក្នុងសេចក្ដីប្រាថ្នានូវធម្មារម្មណ៍នុ៎ះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងសេចក្ដីប្រាថ្នានូវធម្មារម្មណ៍នុ៎ះ ។

សេចក្ដីត្រិះរិះនូវរូបារម្មណ៍ ក្នុងលោក ។ សេចក្ដីត្រិះរិះនូវសទ្ទារម្មណ៍ ក្នុងលោក ។ សេចក្ដីត្រិះរិះនូវគន្ធារម្មណ៍ ក្នុងលោក ។ សេចក្ដីត្រិះរិះនូវរសារម្មណ៍ ក្នុងលោក ។ សេចក្ដីត្រិះរិះនូវផោដ្ឋព្វារម្មណ៍ ក្នុងលោក ។ សេចក្ដីត្រិះរិះនូវធម្មារម្មណ៍ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងសេចក្ដីត្រិះរិះនូវធម្មារម្មណ៍នុ៎ះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងសេចក្ដីត្រិះរិះនូវធម្មារម្មណ៍នុ៎ះ ។

ការពិចារណានូវរូបារម្មណ៍ ក្នុងលោក ។ ការពិចារណានូវសទ្ទារម្មណ៍ ក្នុងលោក ។ ការពិចារណានូវគន្ធារម្មណ៍ ក្នុងលោក ។ ការពិចារណានូវរសារម្មណ៍ ក្នុងលោក ។ ការ

ពិចារណានូវផោដ្ឋព្វារម្មណ៍ ក្នុងលោក ។ ការពិចារណានូវធម្មារម្មណ៍ ក្នុងលោកដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងការពិចារណានូវធម្មារម្មណ៍នុ៎ះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងការពិចារណានូវធម្មារម្មណ៍នុ៎ះ ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **ទុក្ខនិរោធអរិយសច្ច** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេច ហៅថា **ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ច** ។ អរិយមគ្គដែលប្រកបដោយអង្គ ៨ ប្រការនេះឯង (ហៅថា **ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច**) អរិយមគ្គដែលប្រកបដោយអង្គ ៨ ប្រការ តើដូចម្ដេច គឺ **សម្មាទិដ្ឋិ** (ប្រាជ្ញាយល់ឃើញត្រូវ) ១ **សម្មាសង្កប្បៈ** (ត្រិះរិះត្រូវ) ១ **សម្មាវាចា** (សម្ដីត្រូវ) ១ **សម្មាកម្មន្តៈ** (ការងារត្រូវ) ១ **សម្មាអាជីវៈ** (កិរិយាចិញ្ចឹមជីវិតត្រូវ) ១ **សម្មាវាយាមៈ** (ព្យាយាមត្រូវ) ១ **សម្មាសតិ** (សេចក្ដីរលឹកត្រូវ)១ **សម្មាសមាធិ** (កិរិយាតម្កល់ចិត្តឱ្យនឹងត្រូវ) ១ ។ អដ្ឋង្គិកមគ្គដ៏ប្រសើរនេះឯង ឈ្មោះថា **ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ច** ។

ចប់បទចែកសេចក្ដីបំភ្លឺក្នុងសម្មាទិដ្ឋិ ។

ម្នាលភិក្ខុទាំងឡាយ **សម្មាសង្កប្បៈ** តើដូចម្ដេច ? ម្នាលភិក្ខុទាំងឡាយ សេចក្តីត្រិះរិះក្នុងការចេញចាកកាម សេចក្តីត្រិះរិះក្នុងការមិនព្យាបាទ សេចក្តីត្រិះរិះក្នុងការមិនបៀតបៀនឯណា ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **សម្មាសង្កប្បៈ** ។

ម្នាលភិក្ខុទាំងឡាយ **សម្មាវាចា** តើដូចម្តេច ? ម្នាលភិក្ខុទាំងឡាយ ចេតនាវៀរចាកការនិយាយកុហក ចេតនាវៀរចាកការនិយាយញុះញង់ ចេតនាវៀរចាកការនិយាយទ្រគោះ ចេតនាវៀរចាកការ និយាយរោយរាយឯណា ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **សម្មាវាចា** ។

ម្នាលភិក្ខុទាំងឡាយ **សម្មាកម្មន្តៈ** តើដូចម្តេច ? ម្នាលភិក្ខុទាំងឡាយ ចេតនាវៀរចាកការសម្លាប់សត្វ ចេតនាវៀរចាកការលួចទ្រព្យគេ ចេតនាវៀរចាកការប្រព្រឹត្តធម៌មិនប្រសើរឯណា ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **សម្មាកម្មន្តៈ** ។

ម្នាលភិក្ខុទាំងឡាយ **សម្មាអាជីវៈ** តើដូចម្តេច ? ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ លះបង់នូវការចិញ្ចឹមជីវិតខុស សម្រេចការចិញ្ចឹមជីវិតដោយការចិញ្ចឹមជីវិតត្រូវ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **សម្មាអាជីវៈ** ។

ម្នាលភិក្ខុទាំងឡាយ **សម្មាវាយាមៈ** តើដូចម្ដេច ? ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឱ្យកើត ប្រឹងប្រែងប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុំាងពួកអកុសលធម៌ដ៏លាមកដែលមិនទាន់កើត មិនឱ្យកើតឡើងបាន ញុំាងឆន្ទៈឱ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីលះបង់នូវពួកអកុសលធម៌ដ៏លាមកដែលកើតឡើងហើយ ញុំាងឆន្ទៈឱ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុំាងកុសលធម៌ដែលមិនទាន់កើតឱ្យកើតឡើង ញុំាងឆន្ទៈឱ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុំាងពួកកុសលធម៌ដែលកើតឡើងហើយ ឱ្យតាំងនៅមិនឱ្យភ្លេចភ្លាំងទៅវិញ ឱ្យចម្រើនធំទូលាយ ពេញបរិបូណ៌ក្រៃលែងឡើង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **សម្មាវាយាមៈ** ។

ម្នាលភិក្ខុទាំងឡាយ **សម្មាសតិ** តើដូចម្ដេច ? ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញរឿយៗនូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានសេចក្ដីដឹងខ្លួន មានស្មារតីកំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ពិចារណាឃើញរឿយៗនូវវេទនាក្នុងវេទនាទាំងឡាយ

មានព្យាយាមជាគ្រឿងដុត កំដៅកិលេស មានសេចក្ដីដឹងខ្លួន មានស្មារតី កំចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញ ពិចារណាឃើញរឿយៗ នូវចិត្តក្នុងចិត្ត មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានសេចក្ដីដឹងខ្លួន មានស្មារតីកំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ពិចារណាឃើញរឿយៗនូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានសេចក្ដីដឹងខ្លួន មានស្មារតី កំចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **សម្មាសតិ** ។

(ព្រះពុទ្ធដីកាខាងមុខនេះ ព្រះមានព្រះភាគ ទ្រង់សម្ដែងក្នុងមហាសតិប្បដ្ឋានសូត្រ បិដកភាគ ១៧ ទំព័រ ២៤៦ ខ្ញុំស្រង់យកមកចែកសេចក្ដីបំភ្លឺក្នុងសម្មាសតិ ដោយព្រះតម្រាស់ )ថា

ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ តើដោយវិធីដូចម្ដេច ? ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទៅកាន់ព្រៃក្ដី ទៅកាន់ម្លប់ឈើក្ដី ទៅកាន់ផ្ទះស្ងាត់ក្ដី អង្គុយពែនភ្នែន តាំងកាយឱ្យត្រង់ តាំងសតិឱ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន) ។ ភិក្ខុនោះមានសតិដកដង្ហើមចេញ មានសតិដកដង្ហើមចូល កាលដកដង្ហើមចេញវែងក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង ឬកាលដកដង្ហើម

ចូលវែង ក៏ដឹងច្បាស់ថាអាត្មាអញដកដង្ហើមចូលវែង កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញខ្លី ឬក៏កាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលខ្លី (ភិក្ខុ)សិក្សាថា អាត្មាអញ នឹងកំណត់ដឹងច្បាស់នូវកាយ គឺខ្យល់ចេញទាំងពួង ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់នូវកាយ គឺខ្យល់ចូលទាំងពួង ហើយដកដង្ហើមចូល សិក្សាថាអាត្មាអញនឹងរម្ងាប់នូវកាយសង្ខារ (អស្សាសបស្សាសៈ) ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញនឹងរម្ងាប់នូវកាយសង្ខារ ហើយដកដង្ហើមចូល ។ ម្នាលភិក្ខុទាំងឡាយ ជាងក្រឡឹងក្ដី កូនសិស្សនៃជាងក្រឡឹងក្ដី ដែលប៉ិនប្រសប់ កាលទាញខ្សែក្រឡឹងវែង ក៏ដឹងច្បាស់ថា អាត្មាអញទាញខ្សែក្រឡឹងវែង ឬកាលទាញខ្សែក្រឡឹងខ្លី ក៏ដឹងច្បាស់ថា អាត្មាអញទាញខ្សែក្រឡឹងខ្លី មានឧបមាដូចម្ដេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង ឬកាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញខ្លី ឬកាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលខ្លី (ភិក្ខុ)សិក្សាថា អាត្មាអញនឹងកំណត់

ដឹងច្បាស់នូវកាយ គឺខ្យល់ចេញទាំងពួង ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញ នឹងកំណត់ដឹងច្បាស់នូវកាយ គឺខ្យល់ចូលទាំងពួង ហើយដកដង្ហើមចូល សិក្សាថា អាត្មាអញនឹងរម្ងាប់នូវកាយសង្ខារ ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញនឹងរម្ងាប់នូវកាយសង្ខារ ហើយដកដង្ហើមចូល មានឧបមេយ្យដូច្នេះឯង ។

ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយខាងក្នុង (កាយរបស់ខ្លួន)ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវកាយក្នុងកាយខាងក្រៅ (កាយរបស់បុគ្គលដទៃ)ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវកាយក្នុងកាយខាងក្នុងនិងកាយខាងក្រៅ (កាយរបស់ខ្លួន និងកាយរបស់បុគ្គលដទៃ) ជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើងក្នុងកាយ[១] ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅក្នុងកាយ[២]ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញ

---

១-២-អដ្ឋកថា ប្រាប់ថា ខ្យល់អស្សាស-បស្សាសៈ អាស្រ័យនៅក្នុងករជកាយផង ក្តោងច្រមុះផង ចិត្តផង ទើបសញ្ចរទៅមកបាន ព្រោះហេតុនោះ ធម៌ទាំងនេះឈ្មោះថា ធម៌ប្រជុំកើតឡើងក្នុងកាយ លុះដល់ធម៌ទាំងនោះ រលត់ទៅវិញ ឈ្មោះថា ធម៌សូន្យទៅក្នុងកាយ ។

នូវធម៌ដែលប្រជុំ កើតឡើងក្នុងកាយ ទាំងធម៌ដែលសូន្យទៅក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ។ មួយទៀត ស្មារតីរបស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា កាយមានមែន (តែមិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុសជាដើម) គ្រាន់តែជាទីកំណត់ ដើម្បីឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យ (ដោយតណ្ហា និងទិដ្ឋិ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោក ផង ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

ចប់ អានាបានបព្វៈ ។

ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុកាលដើរក្តី ក៏ដឹងច្បាស់ថា អាត្មាអញដើរ កាលឈរក្តី ក៏ដឹងច្បាស់ថា អាត្មាអញឈរ កាលអង្គុយក្តី ក៏ដឹងច្បាស់ថា អាត្មាអញអង្គុយ កាលដេកក្តី ក៏ដឹងច្បាស់ថា អាត្មាអញដេក ។ មួយទៀត ភិក្ខុនោះបានតាំងនូវកាយ ដោយអាការយ៉ាងណាៗ ក៏ដឹងច្បាស់នូវកាយនោះដោយអាការយ៉ាងនោះៗ ។

ភិក្ខុពិចារណា យើញនូវកាយក្នុងកាយខាងក្នុងយ៉ាងនេះ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវកាយក្នុងកាយខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវកាយក្នុងកាយខាងក្នុង និងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើងក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ ដែលសូន្យទៅក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើងនិងធម៌ដែលសូន្យទៅក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ។ មួយទៀត ស្មារតីរបស់ភិក្ខុនោះក៏ផ្ចង់ឡើងចំពោះថា កាយមានមែន គ្រាន់តែជាទីកំណត់ដើម្បីឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យ (ដោយតណ្ហា និងទិដ្ឋិ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

ចប់ ឥរិយាបថបព្វៈ ។

ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុធ្វើនូវសម្បជញ្ញៈ(១) គឺសេចក្តីដឹងខ្លួន ក្នុងកាលដើរទៅមុខ ឬថយក្រោយ ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងកាលក្រឡេកមើលទៅមុខ ឬក្រឡេកមើលទៅទិសផ្សេងៗ ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងការបត់ដៃជើង ឬលាដៃជើង ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងការទ្រទ្រង់នូវសង្ឃាដី បាត្រនិងចីវរ ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងកាលបរិភោគភោជន ផឹកទឹក ទំពាស៊ីខាទនីយៈ ជញ្ជាប់ (នូវភេសជ្ជៈ មានសប្បិជាដើម) ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងកាលបន្ទោបង់នូវឧច្ចារៈបស្សាវៈ ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងកាលដែលដើរ ឈរ អង្គុយ ដេកលក់ ភ្ញាក់ឡើង និយាយ ស្ងៀម ។

ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយខាងក្នុង ជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវកាយក្នុងកាយខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញ

---

១. សម្បជញ្ញៈមាន ៤ គឺ សាត្ថកសម្បជញ្ញៈ កិរិយាដឹងច្បាស់នូវកម្មដែលមានប្រយោជន៍ និងកម្មឥតប្រយោជន៍ ១ សប្បាយសម្បជញ្ញៈ កិរិយាដឹងច្បាស់នូវអារម្មណ៍ដែលជាទីសប្បាយ ១ គោចរសម្បជញ្ញៈ កិរិយាដឹងច្បាស់នូវកម្មដ្ឋានដែលត្រូវចិត្ត ១ អសម្មោហសម្បជញ្ញៈ កិរិយាដឹងច្បាស់នូវហេតុដែលមិនវង្វេងភ្លេច ១ ។ (អដ្ឋកថា) ទីឃនិកាយសីលក្ខន្ធវគ្គ ។

នូវកាយក្នុងកាយ ខាងក្នុងនិងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញ នូវធម៌ដែលប្រជុំកើតឡើងក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅ ក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើង ទាំងធម៌ដែលសូន្យទៅក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ។ មួយទៀតស្មារតីរបស់ភិក្ខុនោះក៏ផ្ចង់ឡើងចំពោះថា កាយមានមែន គ្រាន់តែជាទីកំណត់ដើម្បីឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យ (ដោយតណ្ហានិងទិដ្ឋិ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

ចប់ សម្បជញ្ញៈបព្វៈ ។

ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុពិចារណាឃើញច្បាស់នូវកាយនេះឯង ខាងលើតាំងអំពីបាទដើងឡើងទៅ ខាងក្រោមតាំង អំពីចុងសក់ចុះមក ដែលមានស្បែកបិទបាំងជុំវិញ ពេញដោយវត្ថុមិនស្អាត មានប្រការផ្សេងៗ ដូច្នេះថា

ក្នុងកាយនេះមាន សក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងបស្សាវៈ បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសំបោរ ទឹករំអិល ទឹកមូត្រ ។ ម្នាលភិក្ខុទាំងឡាយ ថៃដែលមានមាត់ទាំងពីរខាង ពេញដោយធញ្ញជាត មានប្រការផ្សេងៗ ធញ្ញជាតទាំងនោះ គឺស្រូវខ្សាយស ស្រូវខ្សាយក្រហម សណ្តែកបាយ សណ្តែករាជមាស ល្ង អង្ករ បុរសដែលមានចក្ខុគប្បីស្រាយនូវថៃនោះ ហើយពិនិត្យមើលដូច្នេះថា នេះស្រូវខ្សាយស នេះស្រូវខ្សាយក្រហម នេះសណ្តែកបាយ នេះសណ្តែករាជមាស នេះល្ង នេះអង្ករ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញច្បាស់នូវកាយនេះឯង ខាងលើតាំងអំពីបាទជើងឡើងទៅ ខាងក្រោមតាំងអំពីចុងសក់ចុះមក ដែលមានស្បែកបិទបាំងជុំវិញ ពេញដោយវត្ថុមិនស្អាតមានប្រការផ្សេងៗ ដូច្នេះថា ក្នុងកាយនេះមានសក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងបស្សាវៈ បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់

ទឹកសំបោរ ទឹករំអិល ទឹកមូត្រ មានឧបមេយ្យដូច្នោះឯង ។

(ភិក្ខុ)ពិចារណាឃើញនូវកាយក្នុងកាយខាងក្នុង ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវកាយក្នុងកាយខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវកាយក្នុងកាយ ខាងក្នុងនិងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញ នូវធម៌ដែលប្រជុំកើតឡើងក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅ ក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើង ទាំងធម៌ដែលសូន្យទៅ ក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ។ មួយទៀត ស្មារតីរបស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា កាយមានមែន គ្រាន់តែជាទីកំណត់ ដើម្បីឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យ (ដោយតណ្ហានិងទិដ្ឋិ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វី តិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

ចប់ បដិកូលមនសិការបព្វៈ ។

ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុពិចារណា ឃើញច្បាស់នូវកាយនេះឯង ដែលឋិតនៅយ៉ាងណា ដែលតាំងនៅយ៉ាងណា ដោយកំណត់ថា គ្រាន់តែជាធាតុដូច្នេះថា ក្នុងកាយនេះមានធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់ ។ ម្នាលភិក្ខុទាំងឡាយ បុរសអ្នកពិឃាតគោក្តី កូនសិស្សនៃបុរសអ្នកពិឃាតគោក្តី ដែលប៉ិនប្រសប់គប្បីពិឃាតគោ ហើយរំលែកជាចំណែកៗ អង្គុយនៅទៀបផ្លូវធំបែកជាបួន មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញច្បាស់នូវកាយនេះឯង ដែលឋិតនៅយ៉ាងណា ដែលតាំងនៅយ៉ាងណា ដោយកំណត់ថាគ្រាន់តែជាធាតុ ដូច្នេះថា ក្នុងកាយនេះ មានធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់ មានឧបមេយ្យដូច្នេះឯង ។ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយខាងក្នុង (ដោយការកំណត់ ថាជាធាតុ ៤) ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។បេ ។

ចប់ ធាតុមនសិការបព្វៈ ។

ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុឃើញនូវសរីរៈស្លាប់ ដែលគេចោលនៅក្នុងព្រៃស្មសាន ទោះស្លាប់អស់ ១ ថ្ងៃក្តី ស្លាប់អស់ ២ ថ្ងៃក្តី ស្លាប់អស់ ៣ ថ្ងៃក្តី ដែលកំពុង

ហើម មានសម្បុរខៀវដោយច្រើន មានខ្ទុះហូរចេញតាមទ្វារផ្សេងៗ ដូចម្តេចមិញ ។ ភិក្ខុនោះ (ក៏បង្អោនសរីរៈស្លាប់នោះ) មកប្រៀបផ្ទឹមនឹងកាយនេះឯងថា សូម្បីកាយនេះសោត ក៏គង់នឹងមានសភាពដូច្នោះ គង់នឹងក្លាយទៅជាដូច្នោះ នឹងកន្លងនូវភាវៈដូច្នោះពុំបានឡើយ ។ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយជាខាងក្នុងជាប្រក្រតី (ដោយការកំណត់នូវអសុភ មានអសុភកំពុងហើមជាដើម) គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។ បេ ។

ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខ នៅមានទៀត ភិក្ខុគប្បីឃើញនូវសរីរៈស្លាប់ ដែលគេចោលនៅក្នុងព្រៃស្មសាន ដែលក្អែកទាំងឡាយកំពុងចឹកស៊ីក្តី ត្រដក់គម្រង់ទាំងឡាយ កំពុងចឹកស៊ីក្តី ត្មាតទាំងឡាយ កំពុងចឹកស៊ីក្តី សត្វស្វានទាំងឡាយ កំពុងកកេរស៊ីក្តី ចចកទាំងឡាយ កំពុងកកេរស៊ីក្តី បាណកជាតិ (សត្វល្អិតៗ មានរុយជាដើម)ទាំងឡាយផ្សេងៗ កំពុងរូងជញ្ជក់ស៊ីក្តី ដូចម្តេចមិញ ។ ភិក្ខុនោះ (ក៏បង្អោនសរីរៈស្លាប់នោះ) មកប្រៀបនឹងកាយនេះឯងថា សូម្បីកាយនេះសោត ក៏គង់នឹងមានសភាពដូច្នោះ គង់នឹងក្លាយទៅជាដូច្នោះ នឹងកន្លងនូវភាវៈដូច្នោះពុំបានឡើយ ។

ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយខាងក្នុង ជាប្រក្រតី (ដោយការកំណត់នូវអសុភ មានអសុភដែលពួកសត្វកំពុងចឹកស៊ី

ជាដើម ) គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវកាយក្នុងកាយខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវកាយក្នុងកាយខាងក្នុង និងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើងក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថ ទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើង និងធម៌ដែលសូន្យទៅក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ។ មួយទៀត ស្មារតីរបស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា កាយមានមែន គ្រាន់តែជាទីកំណត់ ដើម្បីឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យ ( ដោយតណ្ហានិងទិដ្ឋិ ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុគប្បីឃើញនូវសរីរៈស្លាប់ ដែលគេចោលនៅក្នុងព្រៃស្មសាន នៅសល់តែរាងឆ្អឹង ប្រកបដោយសាច់និងឈាម មានសរសៃជាគ្រឿងចងដូចម្ដេចមិញ ។ បេ ។

សរីរៈនៅសល់តែរាងឆ្អឹង ឥតមានសាច់ប្រឡាក់ដោយឈាម មានសរសៃជាគ្រឿងចង ។ បេ ។

សរីរៈនៅសល់តែរាងឆ្អឹង មិនមានសាច់និងឈាម មានតែសរសៃជាគ្រឿងចង ។ បេ ។

សរីរៈនៅសល់តែរាងឆ្អឹងទទេ មិនមានសរសៃចងរួបរឹតខ្ចាត់ខ្ចាយ រាត់រាយទៅក្នុងទិសតូចនិងទិសធំ គឺឆ្អឹងដៃទៅដោយឡែក ឆ្អឹងជើងទៅដោយឡែក ឆ្អឹងស្មងទៅដោយឡែក ឆ្អឹងភ្លៅទៅដោយឡែក ឆ្អឹងចង្កេះទៅដោយឡែក ឆ្អឹងខ្នងទៅដោយឡែក ឆ្អឹងទ្រនុងខ្នងទៅដោយឡែក ឆ្អឹងជំនីរទៅដោយឡែក ឆ្អឹងទ្រូងទៅដោយឡែក ឆ្អឹងស្មាទៅដោយឡែក ឆ្អឹងកំភួនដៃទៅដោយឡែក ឆ្អឹងកទៅដោយឡែក ឆ្អឹងចង្កាទៅដោយឡែក ធ្មេញទៅដោយឡែក លលាដ៍ក្បាលទៅដោយឡែក (ដូចម្តេចមិញ) ។ ភិក្ខុនោះ (ក៏បង្អោនសរីរៈស្លាប់នោះ) មកប្រៀបផ្ទឹមនឹងកាយនេះឯងថា សូម្បីកាយនេះសោត ក៏គង់នឹងមានសភាពដូច្នោះ គង់នឹងក្លាយទៅជាដូច្នោះ នឹងកន្លងនូវភាវៈដូច្នោះពុំបានឡើយ ។

ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយខាងក្នុង ជាប្រក្រតី (ដោយការកំណត់នូវសរីរៈស្លាប់ ដែលនៅសល់តែរាងឆ្អឹងជាដើម)

គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវកាយក្នុងកាយខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវកាយក្នុងកាយ ខាងក្នុងនិងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើងក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើង និងធម៌ដែលសូន្យទៅក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ។ មួយទៀត ស្មារតីរបស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា កាយមានមែន គ្រាន់តែជាទីកំណត់ដើម្បីឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះ ភិក្ខុមានចិត្តមិនអាស្រ័យ (ដោយតណ្ហានិងទិដ្ឋិ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុគប្បីឃើញនូវសរីរៈស្លាប់ដែលគេបោលក្នុងព្រៃស្មសាន នៅសល់តែរាងឆ្អឹងទទេ មានសម្បុរស ដូចជាសម្បុរនៃស័ង្ខ ។ បេ ។

សរីរៈនៅសល់តែរាងឆ្អឹងទទេ រោយរាយជាពំនូកៗ កន្លងហួសទៅ មួយឆ្នាំហើយ ។ បេ ។

សរីរៈនៅសល់តែរាងឆ្អឹងទទេ ពុកផុយខ្ទេចខ្ទី ជាកម្ទេចតូច កម្ទេចធំផ្សេងៗ (ដូចម្ទេចមិញ) ។ ភិក្ខុនោះ (ក៏បង្អោនសរីរៈស្លាប់នោះ) មកប្រៀបទឹងកាយនេះឯងថា សូម្បីកាយនេះសោត ក៏គង់នឹងមានសភាពដូច្នោះ គង់នឹងក្លាយទៅជាដូច្នោះ នឹងកន្លងនូវភាវៈដូច្នោះពុំបានឡើយ ។

ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយខាងក្នុង ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវកាយក្នុងកាយខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវកាយក្នុងកាយ ខាងក្នុងនិងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើងក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ ដែលប្រជុំកើតឡើងនិងធម៌ដែលសូន្យទៅក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ។ មួយទៀត ស្មារតីរបស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា កាយមាន

មែន គ្រាន់តែជាទីកំណត់ ដើម្បីឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យ (ដោយតណ្ហានិងទិដ្ឋិ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

ចប់ នវសីវថិកាបព្វៈ ។

ចប់ កាយានុបស្សនា ។

ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ តើដោយវិធីដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលទទួលសុខវេទនាក្ដី ក៏ដឹងច្បាស់ថា អាត្មាអញទទួលសុខវេទនា កាលទទួលទុក្ខវេទនាក្ដី ក៏ដឹងច្បាស់ថា អាត្មាអញទទួលទុក្ខវេទនា កាលទទួលអទុក្ខមសុខវេទនាក្ដី ក៏ដឹងច្បាស់ថា អាត្មាអញទទួលអទុក្ខមសុខវេទនា, កាលទទួលសុខវេទនាប្រកបដោយអាមិសៈក្ដី[១] ក៏ដឹងច្បាស់ថា អាត្មាអញទទួលសុខវេទនាប្រកបដោយអាមិសៈ

---

១ អដ្ឋកថាថា សោមនស្សវេទនា ដែលអាស្រ័យនូវកាមគុណ ៥ ប្រព្រឹត្តទៅក្នុងទ្វារ ៦, ហៅថា សាមិសសុខ ។

កាលទទួលសុខវេទនាដែលឥតអាមិសៈក្តី[១] ក៏ដឹងច្បាស់ថា អាត្មាអញទទួលសុខវេទនា ដែលឥតអាមិសៈ កាលទទួលទុក្ខវេទនាប្រកបដោយអាមិសៈក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលទុក្ខវេទនាប្រកបដោយអាមិសៈ កាលទទួលទុក្ខវេទនាដែលឥតអាមិសៈក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលទុក្ខវេទនាដែលឥតអាមិសៈ កាលទទួលអទុក្ខមសុខវេទនា ដែលប្រកបដោយអាមិសៈក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលអទុក្ខមសុខវេទនាប្រកបដោយអាមិសៈ កាលទទួលអទុក្ខមសុខវេទនាដែលឥតអាមិសៈក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលអទុក្ខមសុខវេទនាឥតអាមិសៈ ។

(ភិក្ខុ)ពិចារណាឃើញនូវវេទនា ក្នុងវេទនាទាំងឡាយខាងក្នុង (ដោយការកំណត់នូវវេទនាមានសុខវេទនាជាដើម) ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយខាងក្នុងនិងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ ដែលប្រជុំកើតឡើងក្នុងវេទនាទាំងឡាយជាប្រក្រតី គ្រប់

---

១. បានខាងសោមនស្សវេទនា ដែលអាស្រ័យនេក្ខម្មៈ ប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ ។

ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅក្នុងវេទនាទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើង ទាំងធម៌ដែលសូន្យទៅក្នុងវេទនាទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ។ មួយទៀត ស្មារតី(ជាគ្រឿងកំណត់នូវវេទនា) របស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា វេទនាទាំងឡាយមានមែន គ្រាន់តែជាទីកំណត់ ដើម្បីឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះ ។ (ភិក្ខុ) មានចិត្តមិនអាស្រ័យ (ដោយតណ្ហានិងទិដ្ឋិ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

ចប់ វេទនានុបស្សនា ។

ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុពិចារណាឃើញនូវចិត្តក្នុងចិត្តជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ តើដោយវិធីដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទោះចិត្តប្រកបដោយរាគៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ទោះចិត្តប្រាសចាករាគៈ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាករាគៈ ទោះចិត្តប្រកបដោយទោសៈ

ក៏ដឹងច្បាស់ថាចិត្តប្រកបដោយទោសៈ ទោះចិត្តប្រាសចាកទោសៈ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកទោសៈ ទោះចិត្តប្រកបដោយមោហៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយមោហៈ ទោះចិត្តប្រាសចាកមោហៈ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកមោហៈ ទោះចិត្តរួញរា ក៏ដឹងច្បាស់ថា ចិត្តរួញរា ទោះចិត្តរាយមាយ ក៏ដឹងច្បាស់ថា ចិត្តរាយមាយ ទោះចិត្តដល់នូវភាវៈជាធំ (ជារូបាវចរនិងអរូបាវចរ)ក៏ដឹងច្បាស់ថា ចិត្តដល់នូវភាវៈជាធំ ទោះចិត្តមិនដល់នូវភាវៈជាធំ (ជាកាមាវចរ) ក៏ដឹងច្បាស់ថា ចិត្តមិនដល់នូវភាវៈជាធំ ទោះចិត្តនៅមានចិត្តដទៃប្រសើរជាង (ជាកាមាវចរ) ក៏ដឹងច្បាស់ថាចិត្តនៅមានចិត្តដទៃប្រសើរជាង ទោះចិត្តមិនមានចិត្តដទៃប្រសើរជាង (ជារូបាវចរនិងអរូបាវចរ) ក៏ដឹងច្បាស់ថា ចិត្តមិនមានចិត្តដទៃប្រសើរជាង ទោះចិត្តតាំងនៅមាំ (ជាអប្បនាសមាធិនិងឧបចារសមាធិ) ក៏ដឹងច្បាស់ថា ចិត្តតាំងនៅមាំ ទោះចិត្តមិនតាំងនៅមាំ (ប្រាសចាកសមាធិទាំង ២) ក៏ដឹងច្បាស់ថា ចិត្តមិនតាំងនៅមាំ ទោះចិត្តរួចស្រឡះ(១)

---

១-ពាក្យថា ចិត្តរួចស្រឡះក្នុងទីនេះ សំដៅយកចិត្តដែលប្រកបដោយវិមុត្តិ ២ ប្រការ គឺ តទង្គវិមុត្តិ ១ វិក្ខម្ភនវិមុត្តិ ១ ។ អនុបស្សនា ៧ មានអនិច្ចានុបស្សនាជាដើម ហៅថា តទង្គវិមុត្តិ ព្រោះជាធម្មជាតិរួចស្រឡះចាកនិច្ចសញ្ញាគឺ សេចក្តីសម្គាល់ថាទៀង តាមទំនង ដែលយោគីបានកំណត់នូវអង្គនៃធម៌ (នៅមានត)

*ក៏ដឹងច្បាស់ថា ចិត្តរួចស្រឡះ ទោះចិត្តមិនទាន់រួចស្រឡះ ក៏ដឹងច្បាស់ថា ចិត្តមិនទាន់រួចស្រឡះ ។*

*(ភិក្ខុ)ពិចារណាឃើញនូវចិត្តក្នុងចិត្តខាងក្នុង ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវចិត្តក្នុងចិត្តខាងក្រៅ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវចិត្តក្នុងចិត្តខាងក្នុងនិងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ ដែលប្រជុំកើតឡើងក្នុងចិត្តជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅក្នុងចិត្តជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើង ទាំងធម៌ដែលសូន្យទៅក្នុងចិត្តជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ។ មួយទៀត ស្មារតី(ជាគ្រឿងកំណត់នូវចិត្ត) របស់ភិក្ខុនោះក៏ផ្ចង់ឡើងចំពោះថា ចិត្តមានមែន គ្រាន់តែជាទីកំណត់ដើម្បីឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះ ។ (ភិក្ខុមានចិត្តមិនអាស្រ័យដោយតណ្ហានិងទិដ្ឋិ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោក*

---

(ត) ជាសត្រូវដល់ធម៌នោះ ។ សមាបត្តិ ៨ ហៅថា វិក្ខម្ភនវិមុត្តិ ព្រោះជាធម្មជាតិរួចស្រឡះចាកពួកអកុសលធម៌ មាននីវរណៈជាដើម តាមទំនងដែលយោគីបានសង្កត់សង្កិន ដោយខ្លួនឯង ។ អដ្ឋកថា មហាបទានសូត្រ ទំព័រ ២៦ ។

ផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវចិត្តក្នុងចិត្ត ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

ចប់ ចិត្តានុបស្សនា ។

ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ តើដោយវិធីដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី គឺនីវរណៈទាំង ៥ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុពិចារណា ឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី គឺនីវរណៈទាំង ៥ យ៉ាង តើដូចម្តេច ?

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទោះកាមច្ឆន្ទៈមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា កាមច្ឆន្ទៈមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ, ទោះកាមច្ឆន្ទៈមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា កាមច្ឆន្ទៈមិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ, ទោះកាមច្ឆន្ទៈដែលមិនទាន់កើតឡើង ហើយកើតឡើងបានដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង[១] កិរិយាលះបង់

---

១. អដ្ឋកថាថា ការធ្វើទុកក្នុងចិត្តដោយឥតឧបាយប្រាជ្ញា ចំពោះអសុភនិមិត្តឬចំពោះសភាវៈ មិនទៀង ថាទៀង ទុក្ខថាសុខ មិនមែនខ្លួនថាខ្លួន ដូច្នេះ ជាហេតុនាំឱ្យកើតកាមច្ឆន្ទៈ ។

នូវកាមច្ឆន្ទៈដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង(១) កាមច្ឆន្ទៈដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង(២) ។

ទោះព្យាបាទ មាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ព្យាបាទ មាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះព្យាបាទមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ព្យាបាទមិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះព្យាបាទមិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង(៣) កិរិយាលះបង់នូវព្យាបាទដែលកើតឡើងហើយ ដោយហេតុណា

---

១. អដ្ឋកថាថា ការធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះសភាវៈមិនទៀងថាមិនទៀងមែន ទុក្ខថាទុក្ខមែន មិនមែនខ្លួន ថាមិនមែនខ្លួន ពិត ដូច្នេះជាហេតុលះបង់នូវកាមច្ឆន្ទៈ ។ មួយទៀតថា លះបង់ដោយធម៌ ៦ ប្រការគឺ កំណត់ឬរៀននូវអសុភនិមិត្ត គឺអារម្មណ៍ ថាមិនល្អ ១ កិរិយាប្រកបរឿយៗ នូវការចម្រើនអសុភ ១ ភាវៈជាអ្នកមានទ្វារគ្រប់គ្រងល្អក្នុងឥន្ទ្រិយទាំងប្រាំមួយ ១ ភាវៈជាអ្នកដឹងប្រមាណក្នុងការបរិភោគភោជន ១ ភាវៈជាអ្នករាប់រកកល្យាណមិត្ត ១ ភាវៈជាអ្នករៀនឬនិយាយតែពាក្យដែលជាទីសប្បាយ ១ ។ ២. កាមច្ឆន្ទៈមិនកើតតទៅទៀតដោយសារអរហត្តមគ្គ ។ ៣. ការធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញាចំពោះបដិឃនិមិត្តគឺ អារម្មណ៍ដែលខ្ទាំងខ្ទប់ចិត្ត ជាហេតុនាំឱ្យកើតព្យាបាទ ។

ក៏ដឹងច្បាស់នូវហេតុនោះផង[១] ព្យាបាទដែលលះបង់បាន ហើយមិនកើតតទៅទៀតដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង[២] ។

ទោះថីនមិទ្ធៈ មាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ថីនមិទ្ធៈ មាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះថីនមិទ្ធៈមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ថីនមិទ្ធៈមិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះថីនមិទ្ធៈដែលមិនទាន់កើតឡើង ហើយកើតឡើងបានដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង[៣] កិរិយាលះបង់នូវថីនមិទ្ធៈដែលកើតឡើងហើយ ដោយហេតុណា ក៏

---

១. ការធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះមេត្តាជាចេតោវិមុត្តិ គឺមេត្តាចិត្តដែលបានអប្បនាឈាន ជាហេតុឱ្យលះបង់នូវព្យាបាទបាន ។ មួយទៀតថា លះបង់ដោយធម៌ ៦ ប្រការគឺ រៀនមេត្តានិមិត្ត ១ កិរិយាប្រកបរឿយៗនូវការចម្រើនមេត្តា ១ ពិចារណាឃើញនូវភាវៈនៃសត្វដែលមានកម្មជារបស់ខ្លួន ១ ភាវៈជាអ្នកច្រើនដោយការពិចារណា ១ ភាវៈជាអ្នករាប់រកកល្យាណមិត្ត ១ ភាវៈជាអ្នកនិយាយ នូវពាក្យជាទីសប្បាយ ១ ។ **២.** អដ្ឋកថាថា ព្យាបាទមិនកើតតទៅទៀតដោយសារអនាគាមិមគ្គ ។ **៣.** ហេតុដែលនាំឱ្យកើតថីនមិទ្ធៈមាន ៥ ប្រការគឺ មិនត្រេកអរ ១ ច្រអូស ឬ ទម្រន់កាយ ១ មិតពត់កាយ ១ ពុលបាយ ១ រួញចិត្ត ១ ។

*ដឹងច្បាស់នូវហេតុនោះផង[១] ថីនមិទ្ធៈដែលលះបង់បានហើយ មិនកើតតទៅទៀតដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង[២] ។*

*ទោះឧទ្ធច្ចកុក្កុច្ចៈមាននៅក្នុងសន្ដានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ឧទ្ធច្ចកុក្កុច្ចៈ មាននៅក្នុងសន្ដានចិត្តរបស់អាត្មាអញ ទោះឧទ្ធច្ចកុក្កុច្ចៈមិនមាននៅក្នុងសន្ដានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ឧទ្ធច្ចកុក្កុច្ចៈមិនមាននៅក្នុងសន្ដាន ចិត្តរបស់អាត្មាអញ ទោះឧទ្ធច្ចកុក្កុច្ចៈដែលមិនទាន់កើតឡើងហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង[៣] កិរិយាលះបង់នូវឧទ្ធច្ចកុក្កុច្ចៈដែលកើតឡើង*

---

**១.** ហេតុដែលលះបង់ថីនមិទ្ធៈដោយព្យាយាម ៣ យ៉ាងគឺ ព្យាយាមដែលប្រារព្ធផ្ដើមឡើងជាដំបូង ១ ព្យាយាមយ៉ាងកណ្ដាលជាគ្រឿងចេញចាកកោសជ្ជៈ (សេចក្ដីខ្ជិល) ព្យាយាមយ៉ាងក្រៃលែង ដែលកន្លងរួចចាកកោសជ្ជៈ ១ ។ ម្យ៉ាងទៀតថា លះបង់ដោយធម៌ ៦ ប្រការគឺ កាន់យកនិមិត្តក្នុងការបរិភោគហួសប្រមាណ ១ ភាពនៃកិរិយាផ្លាស់ប្ដូរឥរិយាបថ ១ ការធ្វើទុកក្នុងចិត្តចំពោះអាលោកសញ្ញា ១ នៅក្នុងឱកាសដែលស្រឡះ ១ ភាពជាអ្នករាប់រកកល្យាណមិត្ត ១ ភាពជាអ្នកនិយាយនូវពាក្យជាទីសប្បាយ ១ ។ **២.** ថីនមិទ្ធៈ មិនកើតតទៅទៀត ដោយសារអរហត្តមគ្គ ។ អដ្ឋកថា ។ **៣.** ការធ្វើទុកក្នុងចិត្តដោយឥតឧបាយប្រាជ្ញា ចំពោះធម៌ដែលមិនមែនជាគ្រឿងរម្ងាប់ចិត្ត ជាហេតុនាំឱ្យកើតឧទ្ធច្ចកុក្កុច្ចៈ ។

ហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ[១] ផង ឧទ្ធច្ចកុក្កុច្ចៈដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ[២]ផង ។

ទោះវិចិកិច្ឆា មាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា វិចិកិច្ឆា មាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះវិចិកិច្ឆាមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា វិចិកិច្ឆាមិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះវិចិកិច្ឆាមិនទាន់កើតឡើងហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ[៣] ផង កិរិយាលះបង់នូវវិចិកិច្ឆាដែលកើតឡើងហើយ ដោយហេតុណា

---

១. ការធ្វើទុកក្នុងចិត្តដោយឧបាយ ប្រាជ្ញា ចំពោះធម៌ដែលជាគ្រឿងរម្ងាប់ចិត្ត ជាហេតុលះបង់នូវឧទ្ធច្ចកុក្កុច្ចៈបាន ។ មួយទៀតថា លះបង់ដោយធម៌ ៦ ប្រការគឺ ភាវៈជាអ្នកចេះដឹង ឬស្តាប់ច្រើន ១ ភាវៈជាអ្នកឧស្សាហ៍សាកសួរ ១ ភាវៈជាអ្នកចេះដឹងស្ទាត់ក្នុងវិន័យ ១ ភាវៈជាអ្នកសេពនូវបុគ្គលដែលចម្រើន ១ ភាវៈជាអ្នករាប់រកកល្យាណមិត្ត ១ ភាវៈជាអ្នកនិយាយនូវពាក្យដែលជាទីសប្បាយ ១ ។

២. ឧទ្ធច្ចៈ មិនកើតតទៅទៀតដោយសារអរហត្តមគ្គ ឯកុក្កុច្ចៈ មិនកើតតទៅទៀតដោយសារអនាគាមិមគ្គ ។ អដ្ឋកថា។ ៣. អដ្ឋកថាថា ការធ្វើទុកក្នុងចិត្តដោយឥតឧបាយប្រាជ្ញា ចំពោះធម៌ដែលជាទីតាំងនៃសេចក្តីសង្ស័យ ជាហេតុនាំឱ្យកើតវិចិកិច្ឆា ។

ក៏ដឹងច្បាស់នូវហេតុនោះ[១]ផង វិចិកិច្ឆាដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ[២]ផង ។

ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយខាងក្នុង (ដោយការកំណត់នូវនីវរណធម៌ ៥ យ៉ាង)ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្នុងនិងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើតឡើងក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ ដែលសូន្យទៅក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ ដែលជាទីប្រជុំ

---

១. ការធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះកុសលធមិជាដើម ជាហេតុឱ្យលះបង់វិចិកិច្ឆាបាន ។ មួយទៀតថា លះបង់ដោយធមិ ៦ ប្រការគឺ ភាវៈ ជាអ្នកចេះដឹងឬស្តាប់ច្រើន ១ ភាវៈជាអ្នកឧស្សាហ៍សាកសួរ ១ ភាវៈជាអ្នកចេះដឹងស្ទាត់ក្នុងវិន័យ ១ ភាវៈជាអ្នកច្រើនទៅដោយចិត្តដែលជឿស៊ប់ ១ ភាវៈជាអ្នករាប់រកកល្យាណមិត្ត ១ ជាអ្នកនិយាយនូវពាក្យជាទីសប្បាយ ១ ។ **២**. វិចិកិច្ឆា មិនកើតតទៅទៀត ដោយសារសោតាបត្តិមគ្គ ។

កើតឡើង ទាំងធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ។ មួយទៀត ស្មារតី(ជាគ្រឿងកំណត់) របស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា ធម៌ទាំងឡាយមានមែន គ្រាន់តែជាទីកំណត់ ដើម្បីឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យ (ដោយតណ្ហានិងទិដ្ឋិ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺនីវរណៈទាំង ៥ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

ចប់ នីវរណបព្វៈ ។

ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុពិចារណាឃើញនូវធម៌ ក្នុងធម៌ទាំងឡាយ គឺឧបាទានក្ខន្ធទាំង ៥ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺឧបាទានក្ខន្ធទាំង ៥ ជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ តើដោយវិធីដូចម្តេច ? ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ (ពិចារណាឃើញដូច្នេះ

ថា ) រូបមានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនកើតឡើងនៃរូប មានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនវិនាសទៅនៃរូប មានប្រមាណប៉ុណ្ណេះ, វេទនាមានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនកើតឡើងនៃវេទនា មានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនវិនាសទៅនៃវេទនា មានប្រមាណប៉ុណ្ណេះ, សញ្ញាមានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនកើតឡើងនៃសញ្ញា មានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនវិនាសទៅនៃសញ្ញា មានប្រមាណប៉ុណ្ណេះ សង្ខារទាំងឡាយ មានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនកើតឡើងនៃសង្ខារទាំងឡាយ មានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនវិនាសទៅនៃសង្ខារទាំងឡាយ មានប្រមាណប៉ុណ្ណេះ វិញ្ញាណមានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនកើតឡើងនៃវិញ្ញាណ មានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនវិនាសទៅនៃវិញ្ញាណ មានប្រមាណប៉ុណ្ណេះ ។

ភិក្ខុពិចារណាឃើញ នូវធម៌ក្នុងធម៌ទាំងឡាយខាងក្នុងជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវធម៌ ក្នុងធម៌ទាំងឡាយខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ទាំងខាងក្នុងទាំងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណា

ឃើញនូវធម៌ដែលជាទីប្រជុំកើតឡើងក្នុង ធម៌ទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញ នូវធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើតឡើង និងធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ។ មួយទៀត ស្មារតី(ជាគ្រឿងកំណត់)របស់ភិក្ខុនោះ ក៏ផ្ចង់ឡើង ចំពោះថា ធម៌ទាំងឡាយមានមែន គ្រាន់តែជាទីកំណត់ដើម្បីឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យ (ដោយតណ្ហានិងទិដ្ឋិ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺឧបាទានក្ខន្ធទាំង ៥ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

ចប់ ខន្ធបព្វៈ ។

ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុពិចារណាឃើញ នូវធម៌ក្នុងធម៌ទាំងឡាយ គឺអាយតនៈ ៦ ទាំងខាងក្នុងទាំងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ។

ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺអាយតនៈ ៦ ទាំងខាងក្នុងទាំងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ តើដោយវិធីដូចម្តេច ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់នូវភ្នែកផង ដឹងច្បាស់នូវរូបទាំងឡាយផង មួយវិញទៀត សញ្ញោជនៈណា អាស្រ័យនូវភ្នែកនិងរូបទាំងពីរនោះហើយកើតឡើង ក៏ដឹងច្បាស់នូវសញ្ញោជនៈនោះ[១]ផង សញ្ញោជនៈដែលមិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាលះបង់បាននូវសញ្ញោជនៈដែលកើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង សញ្ញោជនៈដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។

ភិក្ខុដឹងច្បាស់នូវត្រចៀកផង ដឹងច្បាស់នូវសំឡេងទាំងឡាយផង, មួយវិញទៀត សញ្ញោជនៈណា អាស្រ័យនូវត្រចៀកនិងសំឡេង ទាំងពីរនោះហើយកើតឡើង ក៏ដឹងច្បាស់នូវសញ្ញោជនៈ

---

១. អដ្ឋកថា ថា កិលេសជាតជាគ្រឿងចងសត្វទុក ហៅថា សញ្ញោជនៈ មាន ១០ យ៉ាងគឺ កាមរាគៈ ១ បដិឃៈ ១ មានៈ ១ ទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាសៈ ១ ភវរាគៈ ១ ឥស្សា ១ មច្ឆរិយៈ ១ អវិជ្ជា ១ ។

នោះផង សញ្ញោជនៈដែលមិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាលះបង់បាននូវសញ្ញោជនៈដែលកើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង សញ្ញោជនៈដែលលះបង់បាន ហើយមិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។

ដឹងច្បាស់នូវច្រមុះផង ដឹងច្បាស់នូវក្លិនទាំងឡាយផង, មួយវិញទៀត សញ្ញោជនៈណា អាស្រ័យនូវច្រមុះនិងក្លិនទាំងពីរនោះ ហើយកើតឡើង ក៏ដឹងច្បាស់នូវសញ្ញោជនៈនោះផង សញ្ញោជនៈដែលមិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាលះបង់បាននូវសញ្ញោជនៈដែលកើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង សញ្ញោជនៈដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។

ដឹងច្បាស់នូវអណ្តាតផង ដឹងច្បាស់នូវរសទាំងឡាយផង, មួយវិញទៀត សញ្ញោជនៈណា អាស្រ័យនូវអណ្តាតនិងរសទាំងពីរនោះ ហើយកើតឡើង ក៏ដឹងច្បាស់នូវសញ្ញោជនៈនោះផង សញ្ញោជនៈដែលមិន ទាន់កើតឡើងហើយកើតឡើងបាន ដោយ

ហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាលះបង់បាននូវសញ្ញោជនៈដែលកើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង សញ្ញោជនៈដែលលះបង់បាន ហើយមិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។

ដឹងច្បាស់នូវកាយផង ដឹងច្បាស់នូវផោដ្ឋព្វៈទាំងឡាយផង, មួយវិញទៀត សញ្ញោជនៈណា អាស្រ័យនូវកាយនិងផោដ្ឋព្វៈទាំងពីរនោះ ហើយកើតឡើង ក៏ដឹងច្បាស់នូវសញ្ញោជនៈនោះផង សញ្ញោជនៈដែលមិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាលះបង់បាននូវសញ្ញោជនៈដែលកើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង សញ្ញោជនៈដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។

ដឹងច្បាស់នូវចិត្តផង ដឹងច្បាស់នូវធម្មារម្មណ៍ទាំងឡាយផង, មួយវិញទៀត សញ្ញោជនៈណា អាស្រ័យនូវចិត្តនិងធម្មារម្មណ៍ទាំងពីរនោះហើយកើតឡើង ក៏ដឹងច្បាស់នូវសញ្ញោជនៈនោះផង សញ្ញោជនៈដែលមិនទាន់កើតឡើង ហើយកើតឡើងបាន

ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ[១]ផង កិរិយាលះបង់បាន នូវសញ្ញោជនៈដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះ[២]ផង សញ្ញោជនៈដែលលះបង់បានហើយ មិនកើត

---

១. សំយោជនៈទាំង ១០ កើតឡើង ព្រោះអាស្រ័យហេតុផ្សេងគ្នាគឺ **កាមរាគ-សំយោជនៈ** គឺតម្រេកដោយអំណាចកាមចំពោះអារម្មណ៍គួរប្រាថ្នា ដែលមកកាន់គន្លងចក្ខុទ្វារ ។ **បដិឃសំយោជនៈ** គឺសេចក្តីក្រោធចំពោះអារម្មណ៍ ដែលមិនគួរប្រាថ្នា ។ **មានសំយោជនៈ** គឺសេចក្តីសម្គាល់ថា បើក្រៅតែពីអញ មិនមានអ្នកណាមួយអាចចម្រើននូវអារម្មណ៍នុ៎ះបានឡើយ ។ **ទិដ្ឋិសំយោជនៈ** គឺសេចក្តីប្រកាន់នូវរូបារម្មណ៍នុ៎ះថាទៀង ថាឋិតថេរ ។ **វិចិកិច្ឆាសំយោជនៈ** គឺសេចក្តីសង្ស័យចំពោះរូបារម្មណ៍នុ៎ះ ថាជាសត្វ ឬថាជារបស់សត្វ ។ **ភវរាគសំយោជនៈ** គឺសេចក្តីប្រាថ្នានូវភពថា ភពនេះយើងតែងបានដោយងាយក្នុងសម្បត្តិភព ។ **សីលព្វតបរាមាសសំយោជនៈ** គឺសេចក្តីប្រកាន់នូវសីលព្វតថា សីលព្វតយ៉ាងនេះយើងអាចសមាទានកាន់យកបាន ។ **ឥស្សាសំយោជនៈ** គឺសេចក្តីច្រណែនថា សូមកុំឱ្យជនដទៃបានរូបារម្មណ៍នេះឡើយ ។ **មច្ឆរិយសំយោជនៈ** គឺសេចក្តីកំណាញ់លាក់លៀមរូបារម្មណ៍ដែលខ្លួនបានហើយនឹងបុគ្គលដទៃ ។ **អវិជ្ជាសំយោជនៈ** គឺសេចក្តីមិនដឹងនូវសហជាតធម៌ទាំងអស់ ។

២. លះបង់ដោយបហានៈ ២ យ៉ាងគឺ តទង្គប្បហានៈ ១ វិក្ខម្ភនប្បហានៈ ១ ។

តទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ(១)ផង ។

ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្នុងជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ ក្នុងធម៌ទាំងឡាយ ទាំងខាងក្នុងទាំងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ ដែលជាទីប្រជុំកើតឡើងក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅ ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើតឡើង និងធម៌ដែលសូន្យទៅក្នុងធម៌

១. សំយោជនៈទាំង ៥ ប្រការគឺ ទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាសៈ ១ ឥស្សា ១ មច្ឆរិយៈ ១ ដែលមិនកើតតទៅទៀត ដោយសារសោតាបត្តិមគ្គ ។ កាមរាគៈ បដិឃៈទាំងពីរ ដែលគ្រោតគ្រាត មិនកើតតទៅទៀត ដោយសារសកទាគាមិមគ្គ ។ ដែលយ៉ាងល្អិត មិនកើតតទៅទៀត ដោយសារអនាគាមិមគ្គ ។ មានះ ១ ភវរាគៈ ១ អវិជ្ជា ១ ដែលមិនកើតតទៅទៀត ដោយសារអរហត្តមគ្គ ។ ឯសំយោជនៈដែលកើតអាស្រ័យនូវត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ក៏ត្រូវតាមន័យនេះដែរ ។ អដ្ឋកថា ។

ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ។ មួយទៀត ស្មារតី ( ជាគ្រឿងកំណត់ ) របស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា ធម៌ទាំងឡាយមានមែន គ្រាន់តែជាទីកំណត់ដើម្បីឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យ ( ដោយតណ្ហានិងទិដ្ឋិ ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយគឺអាយតនៈ ៦ ទាំងខាងក្នុងទាំងខាងក្រៅ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

ចប់ អាយតនៈបព្វៈ ។

ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺពោជ្ឈង្គ ៧ ប្រការ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺពោជ្ឈង្គ ៧ ប្រការជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ តើដោយវិធីដូចម្ដេច ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទោះសតិសម្ពោជ្ឈង្គ មាននៅក្នុងសន្ដានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គ មាននៅក្នុងសន្ដានចិត្តរបស់អាត្មាអញ ទោះ

សតិសម្ពោជ្ឈង្គ មិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គ មិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះ សតិសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ(១)ផង កិរិយាចម្រើន ពេញបរិបូរណ៍ នៃសតិសម្ពោជ្ឈង្គដែលកើតឡើងហើយ ដោយ ហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ(២)ផង ។

ទោះធម្មវិចយសម្ពោជ្ឈង្គ មាននៅក្នុងសន្តានចិត្តនៃខ្លួន(៣)

---

១-២. អដ្ឋកថាថា ការធ្វើយោនិសោមនសិការ ឱ្យច្រើនក្នុងសម្ពោជ្ឈង្គនោះ ជាហេតុនាំឱ្យសតិសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង ឱ្យកើតឡើងបាន ឬដែលកើតឡើងហើយ រឹងរឹតតែប្រព្រឹត្តទៅធំទូលាយ ចម្រើនឡើងពេញបរិបូរណ៍ជាភិយ្យោភាព ។ មួយទៀត ធម៌ដែលជាហេតុនាំឱ្យកើតសតិសម្ពោជ្ឈង្គនោះ មាន ៤ យ៉ាងគឺ ត្រូវឱ្យមានសតិ និងសម្បជញ្ញៈក្នុងទីទាំង ៧ មានដើរទៅមុខជាដើម ១ វៀរចាកបុគ្គលភ្លេចស្មារតី ១ រាប់រកបុគ្គលដែលមានស្មារតីខ្ជាប់ខ្ជួន ១ បង្អោនចិត្តទៅដើម្បីតម្កល់សតិគ្រប់ឥរិយាបថ ១ ។ ៣. ធម៌ដែលជាហេតុនាំឱ្យកើតធម្មវិចយសម្ពោជ្ឈង្គមាន ៧ គឺ សភាវៈសាកសួរ ១ ធ្វើវត្ថុខាងក្នុងគឺសក់ រោមជាដើម និងវត្ថុខាងក្រៅគឺ ចីវរ សេនាសនៈជាដើមឱ្យស្អាត ១ ប្រមូលឥន្ទ្រិយ ទាំង ៥ មានសតិន្ទ្រិយជាដើមឱ្យស្មើគ្នា ១ វៀរចាកបុគ្គលដែលអាប់ឥតប្រាជ្ញា ១ រាប់រកបុគ្គលដែលមានប្រាជ្ញា ១ ពិចារណាចំពោះបញ្ហាក្តន្ធដ៏ជ្រៅ ដោយញាណចរិយា ១ បង្អោនចិត្តទៅដើម្បីកំណត់ធម្មវិចយសម្ពោជ្ឈង្គគ្រប់ឥរិយាបថ ១ ។

ក៏ដឹងច្បាស់ថា ធម្មវិចយសម្ពោជ្ឈង្គ មាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះធម្មវិចយសម្ពោជ្ឈង្គ មិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ធម្មវិចយសម្ពោជ្ឈង្គ មិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះធម្មវិចយសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើងហើយ កើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាចម្រើនពេញបរិបូរណ៍នៃធម្មវិចយសម្ពោជ្ឈង្គ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។

ទោះវិរិយសម្ពោជ្ឈង្គ មាននៅក្នុងសន្តានចិត្តនៃខ្លួន(១) ក៏ដឹងច្បាស់ថា វិរិយសម្ពោជ្ឈង្គ មាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះវិរិយសម្ពោជ្ឈង្គ មិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា វិរិយសម្ពោជ្ឈង្គ មិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះវិរិយសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយា

---

១. ធម៌ដែលជាហេតុនាំឱ្យកើតវីរិយសម្ពោជ្ឈង្គ មាន ១១ គឺ ពិចារណាឃើញនូវភ័យតិចតួច ១ ឃើញនូវអានិសង្ស(នៃការព្យាយាម) ១ ពិចារណាឃើញនូវផ្លូវដែលគួរទៅ ១ កោតក្រែងចំពោះបិណ្ឌបាត ១ ពិចារណាឃើញនូវអរិយទ្រព្យទាំង ៧ ថាជាទ្រព្យមរតកធំ ១ នូវព្រះសាស្តាជាធំ ១ នូវជាតិជាធំ ១ នូវសព្រហ្មចរិយបុគ្គលជាធំ ១ វៀរចាកបុគ្គលខ្ជិលច្រអូស ១, រាប់រកបុគ្គលមានព្យាយាម ១ បង្អោនចិត្តទៅដើម្បីកំណត់នូវវីរិយសម្ពោជ្ឈង្គគ្រប់ឥរិយាបថ ១

*ចម្រើនពេញបរិបូរណ៍នៃវីរិយសម្ពោជ្ឈង្គ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។*

*ទោះបីតិសម្ពោជ្ឈង្គ មាននៅក្នុងសន្ដានចិត្តនៃខ្លួន[១] ក៏ដឹងច្បាស់ថា បីតិសម្ពោជ្ឈង្គ មាននៅក្នុងសន្ដានចិត្តរបស់អាត្មាអញ ទោះបីតិសម្ពោជ្ឈង្គ មិនមាននៅក្នុងសន្ដានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា បីតិសម្ពោជ្ឈង្គ មិនមាននៅក្នុងសន្ដានចិត្តរបស់អាត្មាអញ ទោះបីតិសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាចម្រើនពេញបរិបូរណ៍នៃបីតិសម្ពោជ្ឈង្គ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។*

*ទោះបស្សទ្ធិសម្ពោជ្ឈង្គ មាននៅក្នុងសន្ដានចិត្តនៃខ្លួន[២]*

---

១. ធម៌ដែលជាហេតុនាំឱ្យកើតបីតិសម្ពោជ្ឈង្គមាន ១១ គឺ រលឹកចំពោះព្រះពុទ្ធ ១ ព្រះធម៌ ១ ព្រះសង្ឃ ១ សីល ១ បរិច្ចាគ ១ ធម៌នាំឱ្យកើតជាទេវតា ១ ព្រះនិព្វាន ១ វៀរចាកបុគ្គលមិនស្អាត ១ រាប់រកបុគ្គលស្អាត ១ ពិចារណាតាម បាសាទនីយសូត្រ ១ បង្អោនចិត្តទៅដើម្បីតម្កល់បីតិសម្ពោជ្ឈង្គគ្រប់ឥរិយាបថ ១ ។ អដ្ឋកថា ។

**២.** ធម៌ដែលជាហេតុនាំឱ្យកើតបស្សទ្ធិសម្ពោជ្ឈង្គមាន ៧ គឺ ត្រូវការភោជនថ្លៃថ្លា ១ ត្រូវការរដូវសប្បាយ ១ ត្រូវការឥរិយាបថសប្បាយ ១ ប្រកបខ្លួនឱ្យតាំងនៅជាកណ្ដាល ១ វៀរចាកបុគ្គលអ្នកស្ហួនគ្រងកាយ ១ រាប់រកបុគ្គលដែលមានកាយស្ងប់ស្ងាត់ ១ បង្អោនចិត្ត ទៅដើម្បីតម្កល់បស្សទ្ធិសម្ពោជ្ឈង្គគ្រប់ឥរិយាបថ ១ ។

ក៏ដឹងច្បាស់ថា បស្សទ្ធិសម្ពោជ្ឈង្គ មាននៅក្នុងសន្ដានចិត្តរបស់អាត្មាអញ ទោះបស្សទ្ធិសម្ពោជ្ឈង្គ មិនមាននៅក្នុងសន្ដានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា បស្សទ្ធិសម្ពោជ្ឈង្គ មិនមាននៅក្នុងសន្ដានចិត្តរបស់អាត្មាអញ ទោះបស្សទ្ធិសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើងហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាចម្រើនពេញបរិបូរណ៍នៃបស្សទ្ធិសម្ពោជ្ឈង្គ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។

ទោះសមាធិសម្ពោជ្ឈង្គ មាននៅក្នុងសន្ដានចិត្តនៃខ្លួន(១) ក៏ដឹងច្បាស់ថា សមាធិសម្ពោជ្ឈង្គ មាននៅក្នុងសន្ដានចិត្តរបស់អាត្មាអញ ទោះសមាធិសម្ពោជ្ឈង្គ មិនមាននៅក្នុងសន្ដានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា សមាធិសម្ពោជ្ឈង្គ មិនមាននៅក្នុងសន្ដានចិត្ត

---

១. ធម៌ជាហេតុនាំឱ្យកើតសមាធិសម្ពោជ្ឈង្គមាន ១១ គឺ ធ្វើវត្ថុខាងក្នុងនិងខាងក្រៅឱ្យស្អាត ១ ប្រមូលឥន្ទ្រិយទាំង ៥ ឱ្យស្មើគ្នា ១ ឈ្លាសក្នុងកសិណនិមិត្ត ១ ផ្គងចិត្តឡើងតាមសម័យ ១ សង្កត់សង្កិនចិត្តតាមសម័យ ១ ធ្វើចិត្តឱ្យរីករាយ (ចំពោះសំវេគវត្ថុ ៨ ប្រការ) តាមសម័យ ១ ធ្វើចិត្តឱ្យសម្លឹង (នូវអារម្មណ៍) ១ វៀរចាកបុគ្គលដែលមានចិត្តមិនខ្ជាប់ខ្ជួន ១ រាប់រកបុគ្គល ដែលមានចិត្តខ្ជាប់ខ្ជួន ១ ពិចារណានូវឈានវិមោក្ខ ១ បង្អោនចិត្តទៅដើម្បីឱ្យកើតសមាធិសម្ពោជ្ឈង្គគ្រប់ឥរិយាបថ ១ ។

របស់អាត្មាអញ ទោះសមាធិសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាចម្រើនពេញបរិបូរណ៍នៃសមាធិសម្ពោជ្ឈង្គ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។

ទោះឧបេក្ខាសម្ពោជ្ឈង្គ មាននៅក្នុងសន្ដានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គ មាននៅក្នុងសន្ដានចិត្តរបស់អាត្មាអញ ទោះឧបេក្ខាសម្ពោជ្ឈង្គ មិនមានក្នុងសន្ដានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គ មិនមានក្នុងសន្ដានចិត្តរបស់អាត្មាអញ ទោះឧបេក្ខាសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាចម្រើនពេញបរិបូរណ៍នៃឧបេក្ខាសម្ពោជ្ឈង្គ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ[១]ផង ។

ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្នុងជា

---

១. ធម៌ដែលជាហេតុនាំឱ្យកើតឧបេក្ខាសម្ពោជ្ឈង្គមាន ៥ គឺ ធ្វើចិត្តឱ្យតាំងនៅជាកណ្ដាលចំពោះសត្វ ១ ធ្វើចិត្តឱ្យតាំងនៅកណ្ដាលចំពោះសង្ខារ ១ វៀរចាកបុគ្គលដែលមាន ការទំនុកបម្រុងចំពោះសត្វនិងសង្ខារ ១ រាប់រកបុគ្គលដែលមានចិត្តជាកណ្ដាលចំពោះសត្វនិងសង្ខារ ១ បង្អោនចិត្តទៅដើម្បីឱ្យកើតឧបេក្ខាសម្ពោជ្ឈង្គគ្រប់ឥរិយាបថ ១ ។

ប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្នុងនិងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើងក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើង ទាំងធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ។ មួយទៀត ស្មារតី (ជាគ្រឿងកំណត់) របស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា ធម៌ទាំងឡាយមានមែន គ្រាន់តែជាទីកំណត់ ដើម្បីឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យ (ដោយតណ្ហានិងទិដ្ឋិ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួច ក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយគឺ ពោជ្ឈង្គ ៧ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

ចប់ ពោជ្ឈង្គបព្វៈ ។

ចប់ បទចែកសេចក្តីបំភ្លឺក្នុងសម្មាសតិ ។

ម្នាលភិក្ខុទាំងឡាយ **សម្មាសមាធិ** តើដូចម្តេច ? ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ បានដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ មានតែបីតិនិងសុខកើតអំពីវិវេក ហើយសម្រេចសម្រាន្តនៅ បានដល់នូវទុតិយជ្ឈានជាធម្មជាតកើតមានក្នុងសន្តានចិត្ត ប្រកបដោយសេចក្តីជ្រះថ្លាគឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខកើតអំពីសមាធិ គឺទុតិយជ្ឈាន ព្រោះរម្ងាប់នូវវិតក្កៈនិងវិចារៈ ហើយសម្រេចសម្រាន្តនៅ ភិក្ខុមានចិត្តនឿយណាយចាកបីតិ ប្រកបដោយឧបេក្ខា មានស្មារតីដឹងខ្លួន សោយនូវសុខដោយនាមកាយ ព្រះអរិយៈទាំងឡាយតែងសរសើរនូវបុគ្គលដែលបាននូវតតិយជ្ឈាននោះថា បុគ្គលដែលបាននូវតតិយជ្ឈានមានចិត្តប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានឯណា ក៏បានដល់នូវតតិយជ្ឈាននោះ ហើយសម្រេចសម្រាន្តនៅ ភិក្ខុលះបង់នូវសុខផង លះបង់នូវទុក្ខផង មានសោមនស្សនិងទោមនស្សអស់ហើយក្នុងកាល

មុន ក៏បានដល់នូវចតុត្ថជ្ឈានដែលមិនមានទុក្ខ មិនមានសុខមាន តែសតិដ៏បរិសុទ្ធដែលកើតអំពីឧបេក្ខា ហើយសម្រេចសម្រាន្ត នៅ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **សម្មាសមាធិ** ។

អ្នកទាំងឡាយ ចូរឃើញនូវបមាទ ថាជាភ័យផង ឃើញនូវអប្បមាទ ថាជាគុណដ៏ក្សេមផង ហើយចូរចម្រើនមគ្គមានអង្គ ៨ នេះ ជាអនុសាសន៍របស់ព្រះពុទ្ធ ។ ព្រះពុទ្ធទាំងឡាយ ជាអចិន្តិយបុគ្គល (បុគ្គលដែលគេមិនគប្បីគិតកើត) ធម៌របស់ព្រះពុទ្ធជាអចិន្តិយធម៌ យ៉ាងនេះ កាលបុគ្គលជ្រះថ្លាចំពោះគុណជាអចិន្តិយ រមែងបានផលជាអចិន្តិយ ។ ភិក្ខុណាមិនប្រមាទ ហើយនៅក្នុងធម្មវិន័យនេះ (ភិក្ខុនោះ)នឹងលះបង់ជាតិសង្សារ ហើយធ្វើនូវបរិនិព្វាន ជាទីបំផុតនៃកងទុក្ខបានមិនខានឡើយ ។

ចប់ អរិយមគ្គប្រកបដោយអង្គ ៨

## គុណរបស់ព្រះនិព្វានមាន ២៩ យ៉ាង

១- មទនិម្មទ្ទនោ ព្រះនិព្វានជាធម៌ញ៉ាំញីនូវសេចក្តីស្រវឹងផ្សេងៗ

២- បិបាសវិនយោ ព្រះនិព្វានជាធម៌ដែលបន្ទោបង់ចេញនូវការស្រេកក្នុងអារម្មណ៍ជាកាមគុណ

៣- អាលយសមុគ្ឃាតោ ព្រះនិព្វានជាធម៌ដែលដកចេញនូវសេចក្តីអាល័យក្នុងអារម្មណ៍ជាកាមគុណ

៤- វដ្តូបច្ឆេទោ ព្រះនិព្វានជាធម៌កាត់ចេញនូវការវិលទៅក្នុងវដ្តទាំង ៣ ឱ្យដាច់

៥- តណ្ហាក្ខយោ ព្រះនិព្វានជាធម៌ដែលអស់តណ្ហា

៦- វិរាគោ ព្រះនិព្វានជាធម៌ដែលប្រាសចាករាគៈ

៧- និរោធោ ព្រះនិព្វានជាធម៌ដែលរំលត់នូវតណ្ហា

៨- ធុវំ ព្រះនិព្វានជាធម៌ដែលតាំងនៅមាំជានិច្ច

៩- អជរំ ព្រះនិព្វានជាធម៌ដែលមិនមានជរា

១០- និប្បបញ្ចំ ព្រះនិព្វានជាធម៌ដែលប្រាសចាកបបញ្ចធម៌ គឺ តណ្ហា ទិដ្ឋិ មានះ ដែលធ្វើវដ្តសង្សារឱ្យវែងឆ្ងាយ

១១- សច្ចំ ព្រះនិព្វានជាធម៌ដែលមានសភាពពិតប្រាកដ

១២- បារំ ព្រះនិព្វានជាធម៌ដែលឆ្លងផុតចាកច្រាំងនៃវដ្តទុក្ខ

១៣- សុទុទ្ទសំ ព្រះនិព្វានជាធម៌ដែលអ្នកមានបញ្ញាតិច ឃើញបានដោយកម្រក្រៃលែង

១៤- សិវំ ព្រះនិព្វានជាធម៌ដែលសប្បាយប្រាសចាកកិលេស

១៥- អមតំ ព្រះនិព្វានជាធម៌ដែលមិនមានសេចក្តីស្លាប់

១៦- ខេមំ ព្រះនិព្វានជាធម៌ដែលប្រាសចាកភ័យ

១៧- អព្ភុតំ ព្រះនិព្វានជាធម៌ដ៏មហស្ចារ្យយ៉ាងក្រៃលែង

១៨- អណីតិកំ ព្រះនិព្វានជាធម៌ដែលមិនមានភ័យដ៏ខ្លាំងក្លា ដែល( ភ័យនោះ ) នាំនូវសេចក្តីវិនាសមកឱ្យ

១៩- តាណំ ព្រះនិព្វានជាធម៌ដែលជួយរក្សាសត្វ មិនឱ្យធ្លាក់ក្នុងវដ្តសង្សារ

២០- លេណំ ព្រះនិព្វានជាធម៌ដែលពួនពីភ័យផ្សេងៗ

២១- ទីបំ ព្រះនិព្វានជាកោះ ដែលផុតចាកការលិចលង់របស់ឱឃៈទាំង ៤

២២- វិសុទ្ធិ ព្រះនិព្វានជាធម៌ដែលបរិសុទ្ធប្រាសចាកកិលេស

២៣- វរំ ព្រះនិព្វានជាធម៌ដែលសប្បុរសទាំងឡាយគប្បីប្រាថ្នា

២៤- និបុណំ ព្រះនិព្វានជាធម៌ដែលសុខុមល្អិត

២៥- អសង្ខតំ ព្រះនិព្វានជាធម៌ដែលមិនត្រូវតាក់តែងដោយបច្ច័យ

២៦- មោក្ខោ ព្រះនិព្វានជាធម៌ដែលផុតចាកកិលេស

២៧- សេដ្ឋោ ព្រះនិព្វានជាធម៌ដែលប្រសើរដោយវិសេស

២៨- អនុត្តរោ ព្រះនិព្វានជាធម៌ដែលប្រសើរក្រៃលែង រកអ្វីមកប្រៀបមិនបាន

២៩- លោកស្សន្តោ ព្រះនិព្វានជាធម៌ដែលផុតស្រឡះចាកអំពីលោកទាំង ៣ ។

សុខំ និដ្ឋិមរិយេភិ សក្កាយស្ស និរោធំ
បច្ចនីកមិទំ ហោតិ សព្វលោកេន បស្សតំ ។

ក៏ឯសេចក្តីរលត់នូវសក្កាយទិដ្ឋិ ព្រះអរិយៈទាំងឡាយ បានឃើញច្បាស់ថា ជាសុខ សេចក្តីសុខនេះ តែងមានដល់បណ្ឌិតទាំងឡាយ ដែលឃើញច្បាស់ ( ដោយប្រាជ្ញា ) ប៉ុន្តែជាសត្រូវនឹងលោកទាំងមូល ។

គុណរបស់ព្រះនិព្វានមាន ២៩ យ៉ាង ចប់ ។

**គហដ្ឋសីល ចប់**

បោះពុម្ពលើកទី ២ ដោយព្រះសង្ឃ
និងពុទ្ធបរិស័ទទូទៅ ទាំងក្នុងនិងក្រៅប្រទេស ។

យោ គវំ ន វិជានាតិ

ន សោ រក្ខតិ គោគណំ

ឯវំ សីលំ អជានន្តោ

កឹ សោ រក្ខេយ្យ សំវរំ ។

បុគ្គលណា មិនស្គាល់គោ បុគ្គលនោះ នឹងរក្សាហ្វូងគោ ដូចម្ដេចបាន យ៉ាងណាមិញ ភិក្ខុណា មិនស្គាល់សីល ភិក្ខុនោះ នឹងរក្សាសេចក្ដីសង្រួមក្នុងសីល ដូចម្ដេចបាន យ៉ាងនោះដែរ ។

រក្សាសិទ្ធិ